ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



លេខ ៥០ ខែកុម្ភៈ ឆ្នាំ២០០៤

ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៦២ ខែកុម្ភៈ ឆ្នាំ២០០៥

## មាតិកា

◆ សំបុត្រៈ ការព្យាបាលរបួសចាស់ និងការផ្សះផ្សាជាតិ .................១

**ផ្នែកឯកសារ**

◆ តូច ខាំខឿន...................................................................២
◆ បញ្ជីឈ្មោះជនរងគ្រោះដែលកម្ទេចនៅមន្ទីរ ស-២១....................៦
◆ ការគាំទ្ររបស់ប្រទេសចិនចំពោះកម្ពុជាប្រជាធិបតេយ្យ.................៨

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ហេតុអ្វីខ្មែរក្រហមសម្លាប់ប្រជាជនច្រើនម្ល៉េះ...........................១១
◆ របៀបចងក្រងប្រវត្តិសាស្ត្រ..............................................២២

**ផ្នែកច្បាប់**

◆ ការបង្កើតការទទួលខុសត្រូវសម្រាប់មេដឹកនាំខ្មែរក្រហម.........២៥

**វេទិកាពិភាក្សាសាធារណៈ**

◆ និយមន័យផ្លូវច្បាប់នៃអំពើប្រល័យពូជសាសន៍.................... ៣៥
◆ បុព្វហេតុនៃព្រឹត្តិការណ៍ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១...........៣៧
◆ ការប្រល័យពូជសាសន៍ខ្លួនឯង........................................៤៥

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ជីវិតក្នុងភាពនឹងថ្កល់.....................................................៤៧
◆ ឪពុកខ្ញុំគ្មានកំហុសទេ......................................................៥៤
◆ អ្នកស្លាប់ ស្លាប់ទាំងបិទភ្នែកមិនជិត................................ ៥៦



ចាន់ លាង និងប្តីឈ្មោះ ព្រំ ញ៉ែម (កណ្តាល) ថតឆ្នាំ១៩៧៥ ។ ដកស្រង់ចេញពីសៀវភៅ "ជីវិតក្នុងភាពនឹងថ្កល់" របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។



ការប្រគុំភ្លេងក្នុងពេលពិធីបុណ្យចូលឆ្នាំថ្មីក្នុងខេត្តក្រចេះ នៅឆ្នាំ១៩៧៥

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នាដៃលេខនេះ** យិន នាន, ម៉ូង សាន់ឃ្វីស, សឹម សុរិយា, ដាវីដ ប៉ីយ, វ៉ែន វ៉ូប៊ីន, អៀ ម៉េងទ្រី, ទិត្យ ណាវ៉ាញ់ គិរី, ហ៊ូ ផ្លូន **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, សូ ហ្វារីណា **អ្នកបកប្រែៈ** ដាត រចនា, ដី ទេរិទ្ធិ **និពន្ធនាយករងៈ** សាន់ កល្យាណ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** មាស ប៊ុនថាន

Email: dccam@online.com.kh, Homepage: www.dccam.org

# ហេតុអ្វីខ្មែរក្រហមសម្លាប់ប្រជាជនច្រើនម្ល៉េះ?

**(តពីលេខមុន)**

### ៥) វិធីសាស្ត្រចងក្រង និងប្រភពឯកសារ

នៅពេលសិក្សាអំពីករណីដែលកើតឡើងនៅប្រទេសកម្ពុជា ជាទូទៅអ្នកសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្របានពឹងផ្អែកទាំងស្រុងទៅលើប្រភពបន្ទាប់បន្សំ (ឯកសារទី២ ឬឯកសារដែលចងក្រងជាសៀវភៅស្រាប់ៗ) ដែលបានបង្ហាញពីការពន្យល់ផ្សេងៗគ្នា ។ ហេតុនេះហើយ នៅពេលដែលអ្នកស្រាវជ្រាវណាម្នាក់ជ្រើសរើសយកការពន្យល់បែបណាមួយនោះ ការសន្និដ្ឋានរបស់អ្នកស្រាវជ្រាវរូបនោះក៏ស្រដៀងនឹងប្រភពនោះដែរ ។ នៅពេលជ្រើសរើសប្រភពណាមួយ អ្នកស្រាវជ្រាវម្នាក់មិនបានពិភាក្សាអំពីភាពអាចទុកចិត្តបាននិងភាពជុយគ្នារបស់ប្រភពនោះនិងប្រភពដទៃទៀតទេ ។ នៅក្នុងការសិក្សារបស់ វ៉ាំមល យើងសឹងតែអាចនិយាយថា លោកប្រើប្រាស់ប្រភពមិនត្រឹមត្រូវ ។

គួរឲ្យភ្ញាក់ផ្អើល មានមនុស្សតិចតួចប៉ុណ្ណោះបានសិក្សាទៅលើឯកសាររបស់បក្សកុម្មុយនិស្តកម្ពុជា បើទោះបីជាដឹងថានឹងអាចរកឃើញគោលនយោបាយដែលនាំឲ្យមានការសម្លាប់រង្គាលនៅក្នុងឯកសារទាំងនោះក្តី ។ ដូចជាបក្សកុម្មុយនិស្តដទៃទៀតដែរ បក្សកុម្មុយនិស្តកម្ពុជាបានរៀបចំផែនការយ៉ាងល្អិតល្អន់ ហើយដែលចេញពីផែនការនេះ មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាបានរៀបចំគម្រោងបដិវត្តន៍សង្គមនិយមរបស់ខ្លួន ។ អត្ថបទនេះនឹងផ្តោតជាសំខាន់ទៅលើផែនការនេះ ។

ការសិក្សាអំពីទិដ្ឋភាពដទៃទៀតនៃគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជាក៏មានផលប្រយោជន៍ដែរ ប៉ុន្តែមិនស្ថិតនៅក្នុងវិសាលភាពនៃការសិក្សាបច្ចុប្បន្ននេះទេ ។ ទិដ្ឋភាពមួយគឺការវាតទីយកដីដែលបានបាត់បង់ ហើយដែលទង្វើនេះបាននាំឲ្យមានសង្គ្រាមជាមួយវៀតណាម ។ ទិដ្ឋភាពមួយទៀតគឺការណ៍សម្ងាត់របស់បក្សកុម្មុយនិស្តកម្ពុជា ។ អស់រយៈពេលពីរឆ្នាំកន្លះ បក្សកុម្មុយនិស្តកម្ពុជាបានគ្រប់គ្រងប្រទេសកម្ពុជានៅក្រោមឈ្មោះដ៏អាថ៌កំបាំងមួយគឺ អង្គការ ។

ប្រភពសំខាន់បំផុតគឺផែនការបួនឆ្នាំរបស់បក្សក្នុងការកសាងរបបសង្គមនិយមលើគ្រប់វិស័យ និងសេចក្តីពន្យល់របស់ ប៉ុល ពត ចំពោះផែនការនោះ ដែលមានសរសេរនៅក្នុងសៀវភៅ "ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត" និងឯកសារបន្ទាប់បន្សំផ្សេងៗទៀត អំពីកិច្ចប្រជុំរបស់ថ្នាក់ដឹកនាំ សុន្ទរកថា កំណត់ត្រាអង្គប្រជុំនិងអត្ថបទនៅក្នុងទស្សនាវដ្តីប្រចាំខែរបស់បក្សឈ្មោះ "ទង់បដិវត្ត" ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូលឯកសារដែលពាក់ព័ន្ធនឹងរបបខ្មែរក្រហមរាប់ពាន់ឯកសារ ហើយដែលមានចុះផ្សាយនៅក្នុងទស្សនាវដ្តីស្វែងរកការពិត ។

ប្រភពផ្សេងទៀតគឺចម្លើយសារភាពចំនួន៤ពាន់ដែលរកឃើញនៅក្នុងគុកទួលស្លែង ហើយមានខ្លះសរសេរជាភាសាអង់គ្លេស ។ ដេវីដ ឆេនដល័រ ដែលបានសិក្សាទៅលើចម្លើយសារភាពជាងមួយពាន់ បានសង្កត់ធ្ងន់ថា បើទោះបីជាមានចម្លើយសារភាពមួយចំនួនអាចទទួលបានថាជាការពិតក៏ដោយ ក៏យើងអាចសន្និដ្ឋានបានថា ចម្លើយសារភាពភាគច្រើនត្រូវបានប្រឌិតដើម្បីឲ្យសមទៅតាមការចង់បានរបស់មជ្ឈិមបក្ស ។ ផ្នែកខ្លះរៀបរាប់អំពីការរួមគំនិតក្បត់ ផ្នែកខ្លះទៀតមានការប្រឌិតបទសន្ទនាបែបវីរសម្បា ។ នៅក្នុងចម្លើយសារភាពជាច្រើន អ្នកទោសបាននិយាយអំពីការប្រទូសរ៉ាយនយោបាយដែលកើតមានពិតប្រាកដ ។ ដោយសារតែភាគច្រើននៃអ្នកទោសនៅមន្ទីរ ស-២១ មានតំណែងខ្ពស់ៗនៅក្នុងជួរបក្សនិងជួរកងទ័ព ឯកសារទាំងអស់នេះបាននាំយើងឲ្យចូលកៀកទៅនឹងជម្លោះនៅក្នុងជួរថ្នាក់ដឹកនាំ ។

ស៊ីវ ហេដ័រ និង ប្រាយអិន ទីគេម័រ បានត្រួតពិនិត្យឯកសារដើមរបស់បក្សកុម្មុយនិស្តកម្ពុជានិងបទសម្ភាសន៍ជាមួយសាក្សីជាច្រើន ។

### ៦) ការប្រើប្រាស់វាក្យស័ព្ទ

ដោយសារតែនេះជាការសិក្សាអំពីនយោបាយមិនមែនអំពីច្បាប់ ពាក្យ អំពើប្រល័យពូជសាសន៍នៅកម្ពុជា នឹងត្រូវបាន

*(អត្ថបទសង្ខេបចេញពីឯកសារចម្លើយសារភាព)*

# គួច ខាំឌឿន

**(តចប់)**

នៅដើមឆ្នាំ១៩៦៣ ខាំឌឿន ណែនាំឲ្យនិស្សិតខ្មែរអានកាសែតទស្សនាវដ្ដីរបស់សូវៀតនិងបារាំង មើលខ្សែភាពយន្ដរបស់សូវៀតនិងបារាំង ហើយលើកសរសើរអំពីភាពខ្លាំងពូកែនិងជឿនលឿនរបស់សូវៀត ។ ឆ្នាំនេះ ខាំឌឿន បានទទួលប្រាក់ចំនួន៣ពាន់ត្រណោគពី សង់ពីយែរ ហ៊ីលីព ដែលជាអ្នកចាត់ចែងជំនួយហិរញ្ញវត្ថុរបស់កា.ហ្សេ.បេ ។ ដើមឆ្នាំ១៩៦៤ ខាំឌឿន បានចុះផ្សាយអត្ថបទជាច្រើននៅក្នុងព្រឹត្តិបត្រសហភាពនិស្សិតខ្មែរដែលនិយាយសរសើរមាគ៌ាប្រជាធិបតេយ្យ ។ ពាក់កណ្ដាលឆ្នាំ១៩៦៤ ខាំឌឿន បានទទួលប្រាក់ចំនួន១ម៉ឺន៥ពាន់ហ្វ្រង់បន្ថែមពីសង់ពីយែរ ហ៊ីលីព ដើម្បីជួយឧបត្ថម្ភដល់និស្សិតខ្មែរដែលដាច់អាហារូបករណ៍ ។

នៅឆ្នាំ១៩៦៥ ខាំឌឿន និង ជួន ម៉ុម បានទៅជួបជនជាតិបារាំងម្នាក់ឈ្មោះ ប៉ូលឡូវ៉ង់ ដើម្បីសួរមតិណែនាំរបស់កា.ហ្សេ.បេ ចំពោះមាគ៌ាដែលត្រូវដើរទៅមុខ ។ ប៉ូលឡូវ៉ង់ បានតបវិញថា ឥណ្ឌូនេស៊ីទទួលបរាជ័យដោយសាររដ្ឋការនិយមប៉េកាំង ចំណែកនៅកម្ពុជា «ផ្លូវប្រជាធិបតេយ្យជាតិ» ជាផ្លូវតែមួយគត់ដែលត្រូវដើរ ។

នៅចុងឆ្នាំ១៩៦៥ ប៉ែន ថៅងអាន និស្សិតខ្មែរនៅមូស្គូ បានជួបជាមួយជាមួយ ខាំឌឿន, ជួន ម៉ុម និង សួង ស៊ីគឿន ហើយប្រាប់អំពីការបង្កើតបក្សកុម្មុយនិស្តមួយទៀតផ្សេងពីបក្សកុម្មុយនិស្តកម្ពុជាដើម្បីដឹកនាំការតស៊ូរបស់ប្រជាជនកម្ពុជាមានទិសដៅឈានទៅរកការកសាងកុម្មុយនិស្តនិយម ដោយជ្រើសរើសអ្នកដឹកនាំបក្សក្នុងចំណោមសមាជិកសហភាពនិស្សិតខ្មែរវ័យក្មេងដែលរៀននៅមូស្គូ ។ ក្រោយពីពន្យល់ប្រាប់រួចរាល់ហើយ ថៅងអាន ក៏បបួលអ្នកទាំងបីឲ្យចូលជាសមាជិកគណៈមជ្ឈិមបក្សថ្មីនេះ ប៉ុន្តែទាំងបីនាក់សុំពេលពិចារណាសិន ។

ឆ្នាំ១៩៦៦ ក្រោយពីបានចូលរួមសមាជសហភាពនិស្សិតអន្តរជាតិនៅអ៊ូឡង់បាទ័រប្រទេសម៉ុងហ្គោលី ប៉ែន ថៅងអាន បានឧទ្ទេសនាម ម៉ុក សូវង្ស និងបានយ៉ាន ចូលជាភ្នាក់ងារកា.ហ្សេ.បេ ។ ជាងនេះទៀត ប៉ែន ថៅងអាន បានប្រាប់ ខាំ ឌឿន ថាបក្សកុម្មុយនិស្តដែលបង្កើតឡើងតាំងពីឆ្នាំ១៩៦៤មានលក្ខន្តិកៈរួចជាស្រេច និងមាន ហាក់ សៀងឡាយនី ជាអគ្គលេខាធិការ ។ ខាំឌឿន, ជួន ម៉ុម និង សួង ស៊ីគឿន ក៏យល់ព្រមចូលជាសមាជិក ។

ដើមឆ្នាំ១៩៦៧ ខាំឌឿន បានប្រឆាំងនឹងសមាជិកសហភាពនិស្សិតខ្មែរមួយចំនួនដែលសរសេរអត្ថបទសរសើរការតស៊ូអាវុធដើម្បីដណ្ដើមអំណាច ដោយចោទប្រកាន់អ្នកទាំងនោះថាជាអ្នកផ្សងព្រេងនិយម ។ ដើមឆ្នាំ១៩៦៨ ខាំឌឿន ពន្យល់និស្សិតខ្មែរឲ្យប្រឆាំងនឹងការផ្ទុះសង្គ្រាមផ្ទៃក្នុងនៅកម្ពុជាដោយលើកហេតុផលថាការផ្ទុះអាវុធគឺជាការផ្សងព្រេង ហើយអាចបណ្ដាលឲ្យប្រជាជនស្លាប់អសារឥតការ ។

នៅឆ្នាំ១៩៦៩ នៅពេលសង្គ្រាមផ្ទៃក្នុងកាន់តែឆេះសន្ធោសន្ធៅ ខាំឌឿន បានប្រជុំគណៈកម្មាធិការ «វង់ម៉ាក្សលេនីន» ដើម្បីដាក់វិធានការកុំឲ្យសហភាពនិស្សិតខ្មែរឯកោពីមតិប្រជាជន និងដើម្បីឃោសនាប្រឆាំងនឹងការតស៊ូដោយអាវុធ ។ អង្គប្រជុំបានសម្រេចថានឹងចុះផ្សាយព្រឹត្តិបត្រស្ដីអំពីព្រឹត្តិការណ៍នៃសង្គ្រាមផ្ទៃក្នុង ប៉ុន្តែបញ្ចូលទស្សនៈថា រវាងខ្មែរនិងខ្មែរអាចសម្រុះសម្រួលគ្នានិងរួបរួមគ្នាដើម្បីប្រឆាំងនឹងចក្រពត្តិនិយម ។

សមាជិកមជ្ឈិមបក្សនៅមូស្គូបានសម្រេចឲ្យនិស្សិតខ្មែរមួយចំនួនដែលជាភ្នាក់ងារកា.ហ្សេ.បេវិលត្រឡប់ទៅប្រទេសកម្ពុជាដើម្បីពង្រីកជួរបក្សនៅក្នុងចំណោមនិស្សិត សាស្ត្រាចារ្យ និងអនុធន ។ ដំបូងបំផុតពង្រីកជួរកា.ហ្សេ.បេក្នុងចំណោមនិស្សិតដែល

រៀននៅសាលាបច្ចេកទេសរុស្ស៊ី ។ នៅពេលពព្រឹកដូរបានល្ហមហើយ និស្សិតខ្មែរទាំងនោះត្រូវធ្វើកូដកម្មនៅក្នុងរោងចក្រនិងសាលារៀន ប្រឆាំងនឹងការបិទសេរីភាពក្នុងជីវភាពប្រចាំថ្ងៃ ក្នុងគោលបំណងឲ្យសហភាពនិស្សិតខ្មែរនៅមូស្គូមានឱកាសសុំច្បាប់បង្កើតបក្សកុម្មុយនិស្តថ្មីមួយទៀតស្របច្បាប់ ។

ខាំ ឌឿន បានដឹងដំណឹងពី ហាក់ សៀងឡាយនី ថា ប៉ែន ថៅងអាន និងសមាជិកនិស្សិតខ្មែរដែលបានត្រឡប់មកពីមូស្គូបានចុះចូលជាមួយរដ្ឋាភិបាលដោយសារខ្លាចប៉ូលិសចាប់ ។ ក្រោយពីឃើញផែនការត្រូវបរាជ័យ ខាំ ឌឿន, ជួន ម៉ុម និង សួង ស៊ីគឿន បានស្នើទៅ ហាក់ សៀងឡាយនី ឲ្យឃាត់និស្សិតខ្មែរកុំអាលត្រឡប់មកប្រទេសកម្ពុជា រង់ចាំការអប់រំនិងហ្វឹកហ្វឺនឲ្យបានរឹងមាំជាមុនសិន ។

ពាក់កណ្តាលឆ្នាំ១៩៦៩ ខាំ ឌឿន, ជួន ម៉ុម និង សួង ស៊ីគឿន ត្រូវនិស្សិតមួយក្រុមនៅក្នុងសហភាពនិស្សិតខ្មែរចោទថាជាខ្ញុំកញ្ជះសូវៀត ។ អ្នកទាំងបីបានដេញនិស្សិតទាំងនោះចេញពីសហភាពនិស្សិតខ្មែរ ដោយចោទថាក្រុមនោះជាខ្ញុំកញ្ជះចិនប៉េកាំង ។ ក្រោយមក ខាំ ឌឿន សុំលាលែងតំណែងជាប្រធានសហភាពនិស្សិតខ្មែរ ហើយតែងតាំង សួង ស៊ីគឿន ឲ្យធ្វើប្រធានជំនួសវិញ ។

ចុងឆ្នាំ១៩៦៩ ខាំ ឌឿន និង សួង ស៊ីគឿន បានទៅជួបសង់ពីយែរ ហ៊ុំលីព ហើយ សុំប្រាក់ចំនួន៥ពាន់ត្រណោត ដើម្បីយកមករៀបចំបោះដំរិវិស្សមកាលក្នុងគោលបំណងទាក់ទាញទឹកចិត្តនិស្សិតឲ្យនៅក្នុងសហភាពនិស្សិតខ្មែរបន្តទៀត ។ ដើមឆ្នាំ១៩៧០ នៅពេលមានរដ្ឋប្រហារដែលរៀបចំដោយ លន់ ណុល, ខាំ ឌឿន បានចូលរួមជាមួយរណសិរ្សប្រជុំបង្រួបបង្រួមជាតិកម្ពុជាក្នុងទិសដៅឆ្លៀតឱកាសស្វែងរកបុណ្យស័ក្តិក្នុងជួររណសិរ្ស ។

នៅខែ៨ ឆ្នាំ១៩៧០ ជួន ម៉ុម, សួង ស៊ីគឿន និង ខាំ ឌឿន បានធ្វើដំណើរទៅទីក្រុងប៉េកាំង ហើយបានជួបជាមួយ ហាក់ សៀងឡាយនី និងពិភាក្សាគម្រោងមួយចំនួនសម្រាប់ពេលអនាគត ។ ជួន ម៉ុម បានស្នើទៅប្រធានរណសិរ្សរួបរួមជាតិកម្ពុជាសុំធ្វើជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ, ហាក់ សៀងឡាយនី សុំធ្វើជារដ្ឋលេខាធិការក្រសួងការបរទេស, ខាំ ឌឿន សុំធ្វើជាមន្ត្រីទូតប្រចាំនៅប្រទេសគុយបា ហើយ សួង ស៊ីគឿន សុំចូលធ្វើការនៅក្រសួងឃោសនាការនៅប៉េកាំង ។

នៅខែ៨ ឆ្នាំ១៩៧១ ខាំ ឌឿន បានមកចូលរួមវគ្គរៀនសូត្របដិវត្តន៍និងជួបជាមួយ អៀង សារី នៅទីក្រុងប៉េកាំង ។ នៅខែ៩ ខាំ ឌឿន បានចូលជាសមាជិកបក្សកុម្មុយនិស្តកម្ពុជា ។

ចុងឆ្នាំ១៩៧២ ខាំ ឌឿន បានមកចូលរួមវគ្គសិក្សានៅទីក្រុងប៉េកាំងដែលរៀបចំឡើងដោយ អៀង សារី ។ ពេលនោះ ខាំ ឌឿន បានជួបជាមួយ ហាក់ សៀងឡាយនី, ជួន ម៉ុម និង សួង ស៊ីគឿន ហើយបានលើកផែនការសម្រាប់ឆ្នាំ១៩៧៣ គឺបំផុសរណសិរ្សផ្នែកខាងក្រៅឲ្យចរចាសម្រុះសម្រួលជាមួយ លន់ ណុល នៅពេលដែលការចរចារវាងអាមេរិកនិងវៀតណាមជិតបានសម្រេច ។

ដើមឆ្នាំ១៩៧៣ ខាំ ឌឿន បានត្រឡប់មកដល់ប្រទេសគុយបា ហើយទៅធ្វើទស្សនកិច្ចនៅប្រទេសស៊ីលី ។ ក្រោយពីត្រឡប់មកពីប្រទេសស៊ីលីវិញ ខាំ ឌឿន ធ្វើដំណើរទៅប្រទេសចិន ។ ខាំ ឌឿន បានមកដល់ទីក្រុងប៉េកាំងនៅខែ២ ឆ្នាំ១៩៧៣ ចំពេលដែលប្រទេសវៀតណាមចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុង


អៀង សារី
នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ប៉ារីស ។ ដើម្បីចៀសវាងការសង្ស័យពីសំណាក់រដ្ឋាភិបាលចិន ខាំឌឿន បានបញ្ឈប់ទំនាក់ទំនងជាមួយស្ថានទូតសូវៀតនៅទីក្រុងប៉េកាំង ប៉ុន្តែនៅតែជួបមួងម្កាលជាសម្ងាត់ ។

ចុងឆ្នាំ១៩៧៤ ហាក់ សៀងឡាយនី និង សួង ស៊ីគឿន បានស្នើសុំអង្គការដើម្បីចូលតំបន់រំដោះ ។ សួង ស៊ីគឿន មានបំណងចូលមកក្តាប់ទីភ្នាក់ងារពត៌មានអាការ៉ុ និងវិទ្យុផ្សាយសំឡេងរបស់រណសិរ្សរួបរួមជាតិកម្ពុជា ។ បន្ទាប់ពីអង្គការកាន់កាប់ប្រទេសកម្ពុជាទាំងស្រុង នៅខែ៩ ឆ្នាំ១៩៧៥ ដួន ម៉ុម វិលត្រឡប់ចូលមកក្នុងប្រទេសកម្ពុជា ហើយសមាជិកកា.ហ្វេ.បេមួយចំនួនទៀតក៏បានចូលជាបន្តបន្ទាប់ ។

ខែ១២ ឆ្នាំ១៩៧៥ អង្គការបានអនុញ្ញាតឲ្យ ខាំឌឿន ត្រឡប់មកប្រទេសវិញជាមួយទូតរណសិរ្សក្រៅប្រទេសឯទៀត ។ ខែ២ ឆ្នាំ១៩៧៦ ខាំឌឿន ចូលរៀនសូត្រវគ្គសិក្សានយោបាយមួយរយៈ ។ ចប់វគ្គសិក្សានេះ អង្គការបញ្ជូន ខាំឌឿន មកធ្វើការនៅមន្ទីរ ប-១ ក្រសួងការបរទេស ។ ខាំឌឿន បានជួបជាមួយឡាយនី ដែលធ្វើការនៅទីនេះដែរ ។ ឡាយនី បានទាក់ទងជាមួយនងសួន ហៅ ជ័យ, ទីវអុល, សៀង ប៉ូសែ, ងួន អេង, ឌីដុន និងសរ គិមល្មុត ឡើងវិញ ។ ខាំឌឿន បានជួបជា តូចភឿន និង ភិន នៅមន្ទីរ ស-៨ ។ ឆ្លៀតពេលនោះ ភិន បាន បបួល ខាំឌឿន ឲ្យចូលជាសមាជិកក្រុមស-៨០៨ដែលជាក្រុមមួយបង្កើតឡើងដើម្បីប្រឆាំងនឹងអង្គការបដិវត្តន៍ ។ អង្គការបានចាត់តាំងឲ្យ ខាំឌឿន ទៅរស់នៅសង្កាត់ស្ពឺ ស្រុកចម្ការលើ ដែលនៅទីនោះគាត់បានជួបជាមួយ ព្រុំ ភឿន ។ រស់នៅសង្កាត់ស្ពឺបាន១៣ថ្ងៃ អង្គការហៅ ខាំឌឿន ត្រឡប់មកធ្វើការនៅភ្នំពេញវិញ ។ ខែ៤ ខាំឌឿន បានជួបជាមួយ សៀង ប៉ោសែ នៅពហុកីឡដ្ឋានជាតិអូឡាំពិកក្នុងឱកាសបុណ្យរំឭកខួប១ឆ្នាំនៃជ័យជម្នះ ។ ប៉ោសែស្នើឲ្យ ខាំឌឿន រាយការណ៍អំពីដំណើរចេញចូលក្នុងនិងក្រៅប្រទេសរបស់ អៀង សារី ។

នៅឱកាសនេះដែរ ថោង សេរីវុធ បានលើកឡើងថានៅកម្ពុជាដើម្បីធ្វើឃាតអ្នកដឹកនាំបានសម្រេច ឃាតករត្រូវតែឈ្លាសវៃខ្លាំងណាស់ ពីព្រោះបើមើលតាមស្ថានការណ៍ពេលនេះគឺមានការឃាមកាមតឹងរ៉ឹងនិងដែកឆេរម៉ត់ចត់ណាស់ ។

នៅខែដដែល ភិន បានប្រាប់ ខាំឌឿន អំពីផែនការរបស់ក្រុមស៨០៨គឺពង្រីកកម្លាំងដើម្បីត្រៀមកម្ទេចក្បាលម៉ាស៊ីនដឹកនាំ ។

**កម្មវិធីរដ្ឋប្រហារ**

តាមគម្រោង ការធ្វើរដ្ឋប្រហារនឹងចាប់ផ្តើមនៅវេលាម៉ោង ១រសៀលថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦ ដោយមានការដាក់គ្រាប់បែកផ្លាស្ទិកដើម្បីសម្លាប់ថ្នាក់ដឹកនាំធំៗគឺ បងទី១ ទី២ និងទី៣ និងចាប់ខ្លួនមេដឹកនាំមួយចំនួនទៀតដូចជា បងវន បងខៀវ, អៀង ធីរិទ្ធ, យ៉ុន យ៉ាតជាដើម ប៉ុន្តែផែនការនេះមិនត្រូវបានអនុវត្តទេ ។

ឆ្នាំ១៩៧៧ បក្សចាប់ផ្តើមបោសសម្អាតខ្សែក្បត់ធំៗមួយចំនួន ធ្វើឲ្យ ខាំឌឿន និងបក្ខពួកបារម្ភចំពោះសុវត្ថិភាពរបស់ខ្លួនជាខ្លាំង ។ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ ខាំឌឿន ត្រូវអង្គការចាប់ខ្លួន ហើយបញ្ជូនមកមន្ទីរឃុំឃាំងស-២១ ។ យោងតាមបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរស-២១ តូច ខាំឌឿន បានស្លាប់ដោយជំងឺនៅក្នុងមន្ទីរឃុំឃាំងនៅថ្ងៃទី៦ ខែ៥ ឆ្នាំ១៩៧៧ ។

**សូ ហ្វារីណា**

## ពន្យល់ពាក្យខ្មែរក្រហម

◆ **នាយទុនៈ** អ្នកមានសម្បត្តិស៊ីចាយហូរហៀរមិនចេះខ្វះ ។

(កំណត់ហេតុរបស់សមមិត្ត អ៊ីវ ពេជ្រ)

◆ **នាយទុនកុំប្រាដរៈ** គឺពួកនាយទុនធំៗដែលប្រមូលស្រូវ អង្ករ ពោត សណ្តែក ថ្នាំ និងផលិតផលឯទៀតៗនៅក្នុងស្រុក បញ្ជូនទៅលក់ក្រៅប្រទេសដែលវាមានខ្សែទាក់ទងជាមួយ ។

◆ **នាយទុនជាតិៈ** គឺជានាយទុនរកស៊ីក្នុងស្រុកខាងឧស្សាហកម្មក្តី ខាងពាណិជ្ជកម្មក្តី ខាងកសិកម្មក្តី ។ ប្រើប្រាស់វត្ថុធាតុដើម មធ្យោបាយពលកម្ម (កម្មករ) របស់ជាតិខ្លួន ហើយផលិតផលក្នុងប្រទេស ឬលក់ផលិតផលបន្តិចបន្តួចទៅក្រៅប្រទេស ។

◆ **អនុធនបញ្ញាជនៈ** សិស្ស និស្សិត អ្នករដ្ឋការ ដែលរស់នៅដោយប្រើប្រាជ្ញាជាសំខាន់ ។ ចំណុចសំខាន់របស់គេគ្រង់ស្រលាញ់ជាតិ ស្រឡាញ់បដិវត្តន៍ ។

(យុវជន-យុវនារីបដិវត្ត លេខពិសេសខែសីហា-កញ្ញា ១៩៧៤)

# មជ្ឈមណ្ឌលឯកសារកម្ពុជាស្វែងរករូបថតជនរងគ្រោះ ដែលបានថតនៅរវាងឆ្នាំ១៩៦០ដល់ឆ្នាំ១៩៧៥

ថ្មីៗនេះមជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយសៀវភៅមួយក្បាលដែលមានចំណងជើងថា "ជីវិតក្នុងភាពនឹងថ្កល់" ដែលបង្ហាញអំពីរូបថតជាច្រើនដែលបន្សល់ទុកពីសម័យខ្មែរក្រហម ។ សៀវភៅនេះរៀបរាប់អំពីដំណើរជីវិតរបស់បុរស៣៥នាក់និងស្ត្រី១៦នាក់មកពីខេត្តកំពង់ចាម កណ្តាល កំពង់ធំ និងតាកែវ ដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ មនុស្សចំនួន៣៩នាក់ ក្នុងចំណោម៥១នាក់ដែលបានចុះនៅក្នុងសៀវភៅនេះបានស្លាប់នៅមន្ទីរសន្តិសុខ ស-២១ ហើយមានតែ៩នាក់ប៉ុណ្ណោះដែលមានជីវិតរហូតមកដល់សព្វថ្ងៃនេះ ។

នៅក្នុងពេលឆាប់ៗខាងមុខនេះ យើងនឹងអានអត្ថបទស្តីពីរឿងរ៉ាវរបស់មនុស្សមួយចំនួននៅក្នុងសៀវភៅនេះផ្សាយតាមរលកធាតុអាកាសវិទ្យុ *FM102MHz* ទីក្រុងភ្នំពេញ វិទ្យុ *FM93.25MHz* ខេត្តកំពត វិទ្យុ *FM99MHz* ខេត្តព្រះវិហារ និងវិទ្យុ*FM* ១០៣.២៥*MHz* ខេត្តបាត់ដំបង ។

ក្នុងការសរសេរសៀវភៅនេះ យើងបានធ្វើសម្ភាសន៍អតីតកម្មាភិបាលខ្មែរក្រហម ប្រជាជនមូលដ្ឋាន និងសមាជិកក្រុមគ្រួសាររបស់អ្នកទាំងនោះ ។ សាក្សីរបស់យើងបានឲ្យរូបថតជាច្រើនមកយើង ដែលភាគច្រើននៃរូបថតទាំងនោះបានថតមុនពេលខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជា ប៉ុន្តែក៏មានរូបថតកម្មាភិបាលមួយចំនួនបានថតក្នុងអំឡុងពេលចូលបម្រើបដិវត្តន៍ខ្មែរក្រហមដែរ ។

សៀវភៅដែលរួមមានទាំងរូបថតនិងរឿងរ៉ាវអមជាមួយនេះបានទទួលជំនួយពី "ទាយជ្ជទានជាតិដើម្បីប្រជាធិបតេយ្យ" ។ សៀវភៅនេះបង្ហាញថា អ្នកដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហមមានក្តីសង្ឃឹមនិងការចង់បានដូចជាប្រជាជនកម្ពុជាដទៃទៀត ហើយអ្នកទាំងនោះក៏បានជួបប្រទះនូវការលំបាកជាច្រើនដែរ រួមទាំងការបាត់បង់មនុស្សជាទីស្រលាញ់របស់ខ្លួនផង ។ យើងសង្ឃឹមថាសៀវភៅនេះនឹងជួយឲ្យប្រជាជនកម្ពុជាយល់ថា ទាំងជនរងគ្រោះនិងជនដៃដល់គឺជាមនុស្សដូចគ្នា ។

ឥឡូវនេះ យើងមានគម្រោងសរសេរសៀវភៅថ្មីមួយក្បាលទៀតដែលរៀបរាប់អំពីដំណើររឿងរបស់ប្រជាជនថ្មីនៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ ។ ប្រសិនបើលោកអ្នកឬសាច់ញាតិណាម្នាក់របស់លោកអ្នកជាប្រជាជនថ្មី ហើយចង់រួមចំណែកចែករំលែករឿងរ៉ាវនៅក្នុងសៀវភៅនេះ យើងនឹងទៅសម្ភាសលោកអ្នកដោយផ្ទាល់ ។ យើងសូមស្វាគមន៍ចំពោះការចូលរួមចំណែករបស់ប្រជាពលរដ្ឋខ្មែរទាំងក្នុងនិងក្រៅប្រទេស ហើយដោយសារតែរូបថតទាំងនេះជាផ្នែកមួយដែលមានសារសំខាន់សម្រាប់សៀវភៅ យើងគ្រាន់តែស្នើសុំការជួយជ្រោមជ្រែងពីសំណាក់ប្រជាពលរដ្ឋដែលស្ម័គ្រចិត្តចែករំលែករូបថតរបស់ខ្លួន ។ រូបថតទាំងនោះចាំបាច់ត្រូវតែជារូបថតដែលបានថតមុនឬក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងនឹងថតចម្លងរូបថតរបស់អស់លោកអ្នកបន្ទាប់មកនឹងប្រគល់រូបថតដើមជូនទៅលោកអ្នកវិញ ។



សូមលោកអ្នកទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬផ្ញើលិខិតមកប្រអប់សំបុត្រ លេខ១១១០ ភ្នំពេញ ឬទាក់ទងតាមអ៊ីមែល *truthwynne@dccam.org* ឬ *truthpivoine@dccam.org* ។

សូមអរគុណ ។

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

## រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | មុខងារ | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ១៨៤០ | ទិត ដៃ | សាស្ត្រាចារ្យ | សាំងហ្គាពួ | ១២-១២-៧៦ | ១៨-៣-៧៧ |
| ១៨៤១ | ដឹង ឈុនលាង ហៅ វ៉ាត | វិស្វករ | រុស្ស៊ី | ២៨-១១-៧៦ | ១៨-៣-៧៧ |
| ១៨៤២ | ហ្វូត បូផាណា ហៅ មុំ (ស្រី) | អង្គការមនុស្សធម៌ | បារាយណ៍ | ១២-១០-៧៦ | ១៨-៣-៧៧ |
| ១៨៤៣ | ហ៊ុយ តាន់ | និស្សិត | ស្រុកបារាំង | ២៩-១០-៧៦ | ១៨-៣-៧៧ |
| ១៨៤៤ | នង គិរី | ចៅក្រម | មន្ទីរក-១៥ | ២៨-១០-៧៦ | ១៨-៣-៧៧ |
| ១៨៤៥ | ខាត់ ឆុន | ពេទ្យព-២៧ | ពាណិជ្ជកម្មរដ្ឋ | ១៨-៩-៧៦ | ១៨-៣-៧៧ |
| ១៨៤៦ | គុន ទ្រី | យុទ្ធជន | ដែកំពង់សោម | ?-១០-៧៦ | ១៨-៣-៧៧ |
| ១៨៤៧ | កង សំអុន ហៅ ចិត្ត | អនុវរសេនាតូច | ដែកំពង់សោម | ២១-១០-៧៦ | ១៨-៣-៧៧ |
| ១៨៤៨ | ព្រឹម អេម | កម្មករ | ពាណិជ្ជកម្មរដ្ឋ | ?-១០-៧៦ | ១៨-៣-៧៧ |
| ១៨៤៩ | ហ្វូត លីស៊ីថា ហៅ ដែត | យុទ្ធជន | ពាណិជ្ជកម្ម | ១៩-៩-៧៦ | ១៨-៣-៧៧ |
| ១៨៥០ | ជា យិន ហៅ ណេត | សមាជិក | ពាណិជ្ជកម្ម | ១៩-១០-៧៦ | ១៨-៣-៧៧ |
| ១៨៥១ | ទុំ ឈឿន ហៅ ឆន | វរសេនាតូច | ពាណិជ្ជកម្ម | ៧-៩-៧៦ | ១៨-៣-៧៧ |
| ១៨៥២ | សូ ដេងហៃ ហៅ លីហៃ | កម្មករ | ស្រែអំបិល | ១៨-១១-៧៦ | ១៨-៣-៧៧ |
| ១៨៥៣ | ង៉ែត បេង | កម្មករថ្មី | ស្រែអំបិល | ?-១១-៧៦ | ១៨-៣-៧៧ |
| ១៨៥៤ | ម៉ី ប៊ុយ | យុទ្ធជន | ស្រែអំបិល | ២២-១១-៧៦ | ១៨-៣-៧៧ |
| ១៨៥៥ | ចាន់ ហឿន ហៅ ភី | ប្រធានកងហា | ពាណិជ្ជកម្មរដ្ឋ | ២១-៩-៧៦ | ១៨-៣-៧៧ |
| ១៨៥៦ | ប៊ិល ថុល ហៅ យុទ្ធ | យុទ្ធជន | ពាណិជ្ជកម្មរដ្ឋ | ១៣-៤-៧៦ | ១៨-៣-៧៧ |
| ១៨៥៧ | ជា វ៉េងហុង ហៅ ផល | អនុក្រុម | ពាណិជ្ជកម្មរដ្ឋ | ៦-១០-៧៦ | ១៨-៣-៧៧ |
| ១៨៥៨ | គង់ សារិន | អនុប្រធានមន្ទីរ | ពាណិជ្ជកម្មរដ្ឋ | ២១-១២-៧៦ | ១៨-៣-៧៧ |
| ១៨៥៩ | សួង សឿង ហៅ លឹម | កងធំ | ដែកំពង់សោម | ១០-១០-៧៦ | ១៨-៣-៧៧ |
| ១៨៦០ | មូល មឿ ហៅ សុង | យុទ្ធជន | ដែកំពង់សោម | ១៨-៩-៧៦ | ១៨-៣-៧៧ |
| ១៨៦១ | ឡេង វល្លា ហៅ នះ | នីរសារ | ដែកំពង់សោម | ៦-១០-៧៦ | ១៨-៣-៧៧ |
| ១៨៦២ | ណុច ផន ហៅ ចាន់ | ពេទ្យ | ពាណិជ្ជកម្ម | ២៧-១១-៧៦ | ១៨-៣-៧៧ |
| ១៨៦៣ | ស៊ីវ រ៉េន ហៅ រី | កម្មករ | ស្រែអំបិល | ១៨-១០-៧៦ | ១៨-៣-៧៧ |
| ១៨៦៤ | យិន នួន ហៅ វ៉ាន់ (ស្រី) | ពេទ្យ | ស្រែអំបិល | ២៥-១១-៧៦ | ១៨-៣-៧៧ |
| ១៨៦៥ | អៃ កាន់ ហៅ កាន | អនុកងហា | ពាណិជ្ជកម្ម | ២-១២-៧៦ | ១៨-៣-៧៧ |
| ១៨៦៦ | ឃុន ចាន់ស៊ីថា ហៅ ថាត | កងហា | ពាណិជ្ជកម្ម | ១៧-១០-៧៦ | ១៨-៣-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ១៨៦៧ | ប្រាក់ សយ | យុទ្ធជន | ដែកំពង់សោម | ១៧-១០-៧៦ | ១៨-៣-៧៧ |
| ១៨៦៨ | អ៊ុន សាយ ហៅ សំ | យុទ្ធជន | ដែកំពង់សោម | ១៧-១០-៧៦ | ១៨-៣-៧៧ |
| ១៨៦៩ | យិន សយ ហៅ សិទ្ធ | ពាណិជ្ជកម្មស្រុក | ព្រះវិហារ | ២៩-៩-៧៦ | ១៨-៣-៧៧ |
| ១៨៧០ | ឡាំ សាម៉េត | ប្រធានផ្លូវថ្មី | រទេះភ្លើង | ២៦-១០-៧៦ | ១៨-៣-៧៧ |
| ១៨៧១ | ជុំ សេតថា | កម្មករថ្មី | រទេះភ្លើង | ២៨-៩-៧៦ | ១៨-៣-៧៧ |
| ១៨៧២ | ស ខន ហៅ នៃ | កម្មករថ្មី | រទេះភ្លើង | ១០-៩-៧៦ | ១៨-៣-៧៧ |
| ១៨៧៣ | សឹម សាត | អនុប្រធានមន្ទីរ | ថាមពល | ១៦-១០-៧៦ | ១៨-៣-៧៧ |
| ១៨៧៤ | អ៊ិត ស៊ិន ហៅ សាន | កងហ | ថាមពល | ៩-១០-៧៦ | ១៨-៣-៧៧ |
| ១៨៧៥ | យ៉ុន ឡឿន ហៅ ឈាន | សមាជិក | ដឹកជញ្ជូនជើងគោក | ៦-១០-៧៦ | ១៨-៣-៧៧ |
| ១៨៧៦ | រស់ សារ៉ូ ហៅ ចន | ប្រធានមន្ទីរ | ដឹកជញ្ជូនជើងគោក | ៨-១១-៧៦ | ១៨-៣-៧៧ |
| ១៨៧៧ | វ៉ាន ខុំ ហៅ ថា (ស្រី) | សេដ្ឋកិច្ច | ដឹកជញ្ជូនជើងគោក | ៨-១១-៧៦ | ១៨-៣-៧៧ |
| ១៨៧៨ | វ៉ែត គុន | សមាជិកផ្នែក | ដឹកជញ្ជូនជើងគោក | ៩-១១-៧៦ | ១៨-៣-៧៧ |
| ១៨៧៩ | ចៅ សេន ហៅ សុផល | មេក្រុម | កសិដ្ឋានអង្គរជ័យ | ៩-១០-៧៦ | ១៨-៣-៧៧ |
| ១៨៨០ | លឹម ញឹម | ប្រធានកសិដ្ឋាន | កសិដ្ឋានអង្គរជ័យ | ?-១០-៧៦ | ១៨-៣-៧៧ |
| ១៨៨១ | អៀម ហ៊ាង ហៅ អៀម | កម្មករ | រោងពុម្ពក-២៧ | ២១-៩-៧៦ | ១៨-៣-៧៧ |
| ១៨៨២ | គ្រី លៀន ហៅ សំ | គណៈសាលា | សាលាប្ញស្សីកែវ | ១២-១២-៧៦ | ១៨-៣-៧៧ |
| ១៨៨៣ | អ៊ុក សុក ហៅ ទោម | គណៈសាលា | សាលាប្ញស្សីកែវ | ១២-១២-៧៦ | ១៨-៣-៧៧ |
| ១៨៨៤ | ទី លីសេង ហៅ ទោម | ប្រធានមន្ទីរ | ក្រសួងការបរទេស | ៦-១១-៧៦ | ១៨-៣-៧៧ |
| ១៨៨៥ | ស្មៀក អែប ហៅ វ៉ុន (ស្រី) | កងហ | ក្រសួងការបរទេស | ២០-១០-៧៦ | ១៨-៣-៧៧ |
| ១៨៨៦ | កុយ សិន (ស្រី) | មេក្រុម | ក្រសួងការបរទេស | ២០-១០-៧៦ | ១៨-៣-៧៧ |
| ១៨៨៧ | ង៉ាន ថុន ហៅ រ៉ម | សមាជិកកងធំ | ឃ្លាំងរដ្ឋ | ៧-៩-៧៦ | ១៨-៣-៧៧ |
| ១៨៨៨ | សុក ហឿន ហៅ ហំ | កងធំ | ឃ្លាំងរដ្ឋ | ៤-៩-៧៦ | ១៨-៣-៧៧ |
| ១៨៨៩ | យឹម គ្រឿង | សមាជិកវរសេនាតូច | ឃ្លាំងរដ្ឋ | ៧-៩-៧៦ | ១៨-៣-៧៧ |
| ១៨៩០ | អៀន រី (ស្រី) | យុទ្ធនារី | កងពល៣១០ | ២៥-១-៧៧ | ២៣-៣-៧៧ |
| ១៨៩១ | ព្រុំ សុផុន ហៅ វ៉ាត (ស្រី) | មេក្រុមព-៣១ | កងពល៣១០ | ៣-៣-៧៧ | ២៣-៣-៧៧ |
| ១៨៩២ | គ្រួច ជន ហៅ ជុន | យុទ្ធជន | កងពល៣១០ | ១៧-៣-៧៧ | ២៣-៣-៧៧ |
| ១៨៩៣ | អ៊ុំ វណ្ណា ហៅ ឆុន | យុទ្ធជន | កងពល៣១០ | ១៧-៣-៧៧ | ២៣-៣-៧៧ |
| ១៨៩៤ | ជា សំផុន ហៅ ទោម | យុទ្ធជន | កងពល៣១០ | ២២-១-៧៧ | ២៣-៣-៧៧ |
| ១៨៩៥ | យ៉េង ឆេង ហៅ ហេង | យុទ្ធជនពិការ | កងពល៣១០ | ២៤-២-៧៧ | ២៣-៣-៧៧ |
| ១៨៩៦ | នុត ភឿន ហៅ ហ៊ឹម | យុទ្ធជន | កងពល៣១០ | ២៤-២-៧៧ | ២៣-៣-៧៧ |
| ១៨៩៧ | យឹម សំ | យុទ្ធជន | កងពល៣១០ | ១១-១-៧៧ | ២៣-៣-៧៧ |

(នៅមានត)



# ការគាំទ្ររបស់ប្រទេសចិនចំពោះកម្ពុជា

បន្ទាប់ពីទទួលជ័យជម្នះលើរបប លន់ ណុល ភ្លាម កម្ពុជាប្រជាធិបតេយ្យបានកាត់ផ្តាច់ទំនាក់ទំនងទាំងអស់របស់ខ្លួនពីប្រទេសដែលមិនកាន់លទ្ធិកុម្មុយនិស្ត ប៉ុន្តែនៅរក្សាទំនាក់ទំនងជាមួយប្រទេសមួយចំនួនដែលជាប្រទេសកុម្មុយនិស្ត ។

ក្នុងចំណោមប្រទេសកុម្មុយនិស្តទាំងនោះ ទំនាក់ទំនងជាមួយប្រទេសចិនមានភាពស្អិតល្មួតខ្លាំងបំផុត ដោយសារតែរដ្ឋាភិបាលមួយនេះបានគាំទ្រការតស៊ូនៅក្នុងព្រៃរបស់អ្នកតស៊ូកុម្មុយនិស្តកម្ពុជា តាមរយៈការឧបត្ថម្ភជាសព្វាវុធនិងជំនួយផ្នែកយោធាផ្សេងទៀត ។ បើតាមសេចក្តីរាយការណ៍របស់កាសែតញូវយ៉កថែម នៅឆ្នាំ១៩៧៥ បានឲ្យដឹងថា រដ្ឋាភិបាលថ្មីរបស់កម្ពុជាបានសង្កត់ធ្ងន់អំពីចំណងទាក់ទងដ៏រឹងមាំរបស់ខ្លួនជាមួយប្រទេសចិន និងបានថ្លែងអំណរគុណចំពោះវៀតណាមខាងជើងនិងកូរ៉េខាងជើង ដែលបានជួយគាំទ្រក្នុងការយកជ័យជម្នះលើចក្រពត្តិនិយមអាមេរិក ។ វិទ្យុទីក្រុងភ្នំពេញបានរាយការណ៍ថា "ជ័យជម្នះរបស់ប្រជាជនកម្ពុជាក៏ដូចជាជ័យជម្នះរបស់ប្រជាជនចិនដែរ ។ សាមគ្គីភាពរវាងកម្ពុជានិងចិននឹងឋិតនៅជាអមតៈ ។ យើងគោរពគ្នាទៅវិញទៅមក ទាំងទំនាក់ទំនងផ្ទៃក្នុងនិងនៅលើឆាកអន្តរជាតិ" ។

ទំនាក់ទំនងដ៏ស្អិតល្មួតរវាងកម្ពុជាប្រជាធិបតេយ្យជាមួយប្រទេសចិនត្រូវបានមើលឃើញយ៉ាងច្បាស់តាមរយៈទស្សនកិច្ចជាផ្លូវការរបស់ប្រមុខរដ្ឋាភិបាលក្រុងភ្នំពេញមិនដល់ពីរសប្តាហ៍បន្ទាប់ពីថ្ងៃដែលខ្លួនទទួលបានជ័យជម្នះលើរដ្ឋាភិបាល លន់ ណុល ។ កាសែតវ៉ាស៊ីងតោនប៉ុស្តិ៍បានរាយការណ៍កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៥ថា "គណៈប្រតិភូជាន់ខ្ពស់របស់កម្ពុជាដែលធ្វើដំណើរចេញក្រៅប្រទេសជាលើកទីមួយបន្ទាប់ពីរដ្ឋាភិបាល



# ប្រជាធិបតេយ្យ

កុម្មុយនិស្តទទួលបានជ័យជម្នះត្រូវបានទទួលស្វាគមន៍យ៉ាងអធឹកអធឹកនៅប្រទេសចិន។ គណៈប្រតិភូនេះដឹកនាំដោយឧបនាយករដ្ឋមន្ត្រីខៀវ សំផន និង អៀង សារី តាមការអញ្ជើញរបស់រដ្ឋាភិបាលចិន"។ នៅថ្ងៃសុក្រ ទី២៣ ខែមករា ឆ្នាំ១៩៧៦ ជើងហោះហើរផ្ទាល់រវាងក្រុងភ្នំពេញនិងក្រុងប៉េកាំងត្រូវបានសម្ពោធជាផ្លូវការ។ នៅក្នុងឱកាសនោះ ក្រុងប៉េកាំងបានបរិយាយថា ព្រឹត្តិការណ៍វិវត្តនេះជាលទ្ធផលនៃកិច្ចប្រឹងប្រែងមិនធម្មតាមួយនិងជាលទ្ធផលនៃសហប្រតិបត្តិការមិត្តភាពរវាងរដ្ឋាភិបាលចិននិងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ ភ្នាក់ងារសារព័ត៌មានចិនបានរាយការណ៍ថា "បើទោះបីជាយន្តហោះរបស់ចិនបានចាប់ផ្តើមចុះចតនៅទីក្រុងភ្នំពេញភ្លាមៗបន្ទាប់ពីបដិវត្តកុម្មុយនិស្តទទួលបានជ័យជម្នះនៅខែមេសា ឆ្នាំ១៩៧៥ក៏ពិតមែន ប៉ុន្តែនេះជាសេវាកម្មហោះហើរទៀងទាត់លើកទីមួយដែលកម្ពុជាមានជាមួយនឹងប្រទេសខាងក្រៅចាប់តាំងពីមានការផ្លាស់ប្តូររដ្ឋាភិបាលមក"។ ភ្នាក់ងារសារព័ត៌មាននេះបានបន្ថែមទៀតថា ទំនាក់ទំនងសេវាកម្មផ្លូវអាកាសនេះជាចំណងមិត្តភាពមួយដែលនឹងជួយពង្រឹងសាមគ្គីភាពរវាងប្រជាជនកម្ពុជានិងប្រជាជនចិន ហើយក៏នឹងជួយបង្កើនការផ្លាស់ប្តូរគ្នាលើវិស័យនយោបាយ សេដ្ឋកិច្ចនិងវប្បធម៌ រវាងប្រទេសទាំងពីរនេះដែរ។

ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៧ ប៉ុល ពត បានធ្វើដំណើរទៅប្រទេសចិនក្នុងដំណើរទស្សនកិច្ចក្រៅប្រទេសជាផ្លូវការលើកទីមួយ បន្ទាប់ពីការឡើងកាន់អំណាចរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ ដំណើរទស្សនកិច្ចនេះត្រូវបានទទួលស្វាគមន៍នៅឯព្រលានយន្តហោះដោយលោក ហួរ គួហ្វុង ប្រធានបក្សកុម្មុយនិស្តចិន និងលោក តេង សៀវភីង ឧបនាយករដ្ឋមន្ត្រីជាន់ខ្ពស់របស់ប្រទេសចិន។ ក្រុងប៉េកាំងតែងតែអះអាងជាញឹកញាប់ថា ទំនាក់ទំនងចិន-កម្ពុជាជាទំនាក់ទំនងដែលមិនអាចកាត់ផ្តាច់បាន។

នៅឆ្នាំ១៩៧៨ ពេលដែលជម្លោះរវាងកម្ពុជាប្រជាធិប-តេយ្យនិងប្រទេសវៀតណាមផ្ទុះឡើង ទីក្រុងប៉េកាំងបានបង្ហាញកាយវិការគាំទ្រកម្ពុជា។ នៅថ្ងៃទី១៨ ខែមករាឆ្នាំ១៩៧៨ ប្រទេសចិនបានបញ្ជូនប្រពន្ធរបស់អតីតនាយករដ្ឋមន្ត្រី ជូ អេនឡាយ គឺលោកស្រី តេង អ៊ីងឆាវ មកធ្វើទស្សនកិច្ចនៅទីក្រុងភ្នំពេញ។



ប៉ុល ពត និង តេង សៀវភីង

កាសែតញូវយ៉កថែម បានសរសេរថា មានពាក្យចចាមអារ៉ាមថា ដំណើរទស្សនកិច្ចរបស់លោកស្រី គេង អ៊ីងសារី អាចជាផ្នែកមួយនៃកិច្ចប្រឹងប្រែងរបស់ចិនក្នុងការសម្រុះសម្រួលជម្លោះរវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាម ។ ប៉ុន្តែកាសែតនោះបានរាយការណ៍ទៀតថា មិនទាន់ច្បាស់លាស់នៅឡើយទេថាតើដំណើរទស្សនកិច្ចរបស់លោកស្រី គេង ជាការបញ្ជាក់អំពីការគាំទ្ររបស់ក្រុងប៉េកាំងចំពោះកម្ពុជាបុយ៉ាងណា ។ ទីភ្នាក់ងារសារព័ត៌មានស៊ីនហួរបស់ចិនបានបរិយាយដំណើរនេះថាជា «ទស្សនកិច្ចមិត្តភាពតាមរយៈការអញ្ជើញរបស់គណៈកម្មាធិការមជ្ឈិមរបស់បក្សកុម្មុយនិស្តកម្ពុជា» ។ តាមរយៈការមកដល់របស់ស្ត្រីមានឥទ្ធិពលរូបនេះអ្នកវិភាគបាននិយាយថាវៀតណាមបានបញ្ឈប់ការរុលទៅមុខរបស់ខ្លួននៅត្រឹមអ្នកលឿង ចម្ងាយប្រមាណ៦០គីឡូម៉ែត្រពីទីក្រុងភ្នំពេញ ។ ហើយដោយសារតែការគាំទ្ររបស់ចិនចំពោះកម្ពុជា វៀតណាមបានចោទប្រកាន់ចិនថាជា «មេខ្លាងធំបំផុត» នៅក្នុងជម្លោះតាមព្រំដែនរវាងប្រទេសវៀតណាមនិងកម្ពុជា ។ សារព័ត៌មានរបស់បក្សកុម្មុយនិស្តវៀតណាម ញ៉ាន ហ្សាន បានចោទប្រកាន់មេដឹកនាំកម្ពុជាថាបានបង្ហូរឈាមប្រជាជនវៀតណាមនិងប្រជាជនកម្ពុជាខ្លួនឯង ហើយថាមេដឹកនាំនៅពីក្រោយរឿងនេះគឺប្រទេសចិន ព្រោះមេដឹកនាំរបស់ប្រទេសនេះកំពុងតែអនុវត្តនយោបាយវាតទីនិយម ហើយបានទិញមេដឹកនាំក្រុងភ្នំពេញឲ្យប្រព្រឹត្តដូច្នេះ ។

នៅខែធ្នូ ឆ្នាំ១៩៧៨ នៅពេលដែលទីក្រុងហាណូយ បើកយុទ្ធនាការមួយបង្កើនកងទ័ពនៅក្នុងការរៀបចំដើម្បីវាយលុកប្រទេសកម្ពុជានោះ ទីក្រុងភ្នំពេញនិងទីក្រុងប៉េកាំងបានបញ្ចេញសញ្ញាឲ្យដឹងថា សង្គ្រាមរវាងកងទ័ពវៀតណាមដែលបំពាក់ដោយអាវុធយ៉ាងច្រើននៅក្នុងទឹកដីកម្ពុជាមិនមែនជាសង្គ្រាមធម្មតាទេ ប៉ុន្តែជាសង្គ្រាមឈ្លបដ៏យូរអង្វែង ។ ទស្សនាវដ្តី «សេដ្ឋកិច្ចចុងបូព៌ា» បានរាយការណ៍ឲ្យដឹងថា បើទោះបីជាប្រទេសចិនបានផ្តល់យោបល់ឲ្យ ប៉ុល ពត នៅអំឡុងពេលដំណើរទស្សនកិច្ចរបស់លោក វ៉ាង ទុងស៊ិញ មកកាន់ទីក្រុងភ្នំពេញអំពីការធ្វើសង្គ្រាមឈ្លបក្តី សេចក្តីប្រកាសរបស់រណសិរ្សបង្រួបបង្រួមជាតិដើម្បីរំដោះជាតិបានថ្លែងថា ទីក្រុងប៉េកាំងបាននិយាយយោងទៅដល់ដំហរថ្មីហើយនេះសញ្ញាជាលើកដំបូងនិងយ៉ាងច្បាស់លាស់ដែលថាប្រទេសចិននឹងមិនចូលរួមដោយផ្ទាល់ទៅក្នុងជម្លោះយោធានៅក្នុងប្រទេសកម្ពុជាទេ ។ ទស្សនាវដ្តីមួយនេះបានសរសេរទៀតថា នៅក្នុងរបាយការណ៍មួយផ្ញើជូនសភាប្រជាជនចិន លោកឧបនាយករដ្ឋមន្ត្រី យូ ឆួយលី ដែលបានមកធ្វើទស្សនកិច្ចនៅកម្ពុជាជាមួយលោក វ៉ាង ទុងស៊ិញដែរ បាននិយាយថា បក្សកុម្មុយនិស្តកម្ពុជាបាន «រៀបចំខ្លួនរួចរាល់នៅគ្រប់ផ្នែកទាំងអស់ដើម្បីធ្វើការតស៊ូដ៏យូរអង្វែងមួយជាមួយប្រទេសវៀតណាម» ហើយបើទោះបីជាការប្រយុទ្ធនេះ «សាហាវ យូរអង្វែង និងលំបាក» យ៉ាងណាក៏ដោយ ជ័យជម្នះគឺជារបស់បក្សកុម្មុយនិស្តកម្ពុជា ។

ចាប់តាំងពីជម្លោះរវាងកម្ពុជានិងវៀតណាមបានបើកចំហនៅថ្ងៃទី៣១ ខែធ្នូ ១៩៧៨មក ប្រទេសចិនបានដាក់ចេញនូវគោលនយោបាយប្រយ័ត្នប្រយែងជាទីបំផុត ។ ក្រសួងការបរទេសរបស់ចិនបាននិយាយថា គួរឲ្យសោកស្តាយណាស់ដែលមានជម្លោះដូច្នេះ ហើយសង្ឃឹមថាជម្លោះនេះនឹងអាចដោះស្រាយបានតាមរយៈការចរចាដោយសន្តិវិធី ។ ការប្រយ័ត្នប្រយែងនយោបាយរបស់ចិនយ៉ាងនេះគឺដោយសារតែប្រទេសចិនមើលឃើញថាវៀតណាមកំពុងតែខិតទៅជិតទីក្រុងម៉ូស្គូ ហើយប្រទេសចិនបានមើលឃើញពីលទ្ធផលដ៏អាក្រក់ប្រសិនបើខ្លួនមានជម្លោះជាមួយប្រទេសរុស្ស៊ី ។ សារព័ត៌មានញូវយ៉កថែមបានសរសេរថា ទីក្រុងប៉េកាំងកាន់តែមិនសប្បាយចិត្តជាមួយវៀតណាមចាប់តាំងពីពេលបញ្ចប់សង្គ្រាមវៀតណាមម្ល៉េះ ដោយសារតែប្រទេសចិនបានមើលឃើញមហិច្ឆតារបស់ទីក្រុងហាណូយក្នុងការគ្រប់គ្រងតំបន់ឥណ្ឌូចិនទាំងមូល ហើយចិនក៏មានគោលបំណងដូច្នេះដែរ ។ ជាងនេះទៅទៀតក្រុងប៉េកាំងបានមើលឃើញថា ទីក្រុងហាណូយកំពុងតែខិតទៅជិតទីក្រុងម៉ូស្គូ ហើយតាមរយៈនេះវៀតណាមអាចក្លាយជាមូលដ្ឋានសម្រាប់ឲ្យរុស្ស៊ីពង្រីកឥទ្ធិពលនៅក្នុងតំបន់ឥណ្ឌូចិន ។ ប៉ុន្តែបើចិនប្រកាន់អាកប្បកិរិយាតឹងរ៉ឹងពេកចំពោះទីក្រុងហាណូយនោះ ទីក្រុងហាណូយនឹងខិតទៅរកទីក្រុងម៉ូស្គូកាន់តែជិតថែមទៀត ។

**ឌី ឆេរិទ្ធិ**

# ហេតុអ្វីខ្មែរក្រហមសម្លាប់ប្រជាជនច្រើនម្ល៉េះ?

**(តពីលេខមុន)**

### ៥) វិធីសាស្ត្រចងក្រង និងប្រភពឯកសារ

នៅពេលសិក្សាអំពីករណីដែលកើតឡើងនៅប្រទេសកម្ពុជា ជាទូទៅអ្នកសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្របានពឹងផ្អែកទាំងស្រុងទៅលើប្រភពបន្ទាប់បន្សំ (ឯកសារទី២ ឬឯកសារដែលចងក្រងជាសៀវភៅស្រាប់ៗ) ដែលបានបង្ហាញពីការពន្យល់ផ្សេងៗគ្នា ។ ហេតុនេះហើយ នៅពេលដែលអ្នកស្រាវជ្រាវណាម្នាក់ជ្រើសរើសយកការពន្យល់បែបណាមួយនោះ ការសន្និដ្ឋានរបស់អ្នកស្រាវជ្រាវរូបនោះក៏ស្រដៀងនឹងប្រភពនោះដែរ ។ នៅពេលជ្រើសរើសប្រភពណាមួយ អ្នកស្រាវជ្រាវម្នាក់មិនបានពិភាក្សាអំពីភាពអាចទុកចិត្តបាននិងភាពផ្ទុយគ្នារបស់ប្រភពនោះនិងប្រភពដទៃទៀតទេ ។ នៅក្នុងការសិក្សារបស់ វ៉ាំមល យើងសឹងតែអាចនិយាយថា លោកប្រើប្រាស់ប្រភពមិនត្រឹមត្រូវ ។

គួរឲ្យភ្ញាក់ផ្អើល មានមនុស្សតិចតួចប៉ុណ្ណោះបានសិក្សាទៅលើឯកសាររបស់បក្សកុម្មុយនិស្តកម្ពុជា បើទោះបីជាដឹងថានឹងអាចរកឃើញគោលនយោបាយដែលនាំឲ្យមានការសម្លាប់រង្គាលនៅក្នុងឯកសារទាំងនោះក្តី ។ ដូចជាបក្សកុម្មុយនិស្តដទៃទៀតដែរ បក្សកុម្មុយនិស្តកម្ពុជាបានរៀបចំផែនការយ៉ាងល្អិតល្អន់ ហើយដែលចេញពីផែនការនេះ មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាបានរៀបចំគម្រោងបដិវត្តន៍សង្គមនិយមរបស់ខ្លួន ។ អត្ថបទនេះនឹងផ្តោតជាសំខាន់ទៅលើផែនការនេះ ។

ការសិក្សាអំពីទិដ្ឋភាពដទៃទៀតនៃគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជាក៏មានផលប្រយោជន៍ដែរ ប៉ុន្តែមិនស្ថិតនៅក្នុងវិសាលភាពនៃការសិក្សាបច្ចុប្បន្ននេះទេ ។ ទិដ្ឋភាពមួយគឺការវាតទីយកដីដែលបានបាត់បង់ ហើយដែលទង្វើនេះបាននាំឲ្យមានសង្គ្រាមជាមួយវៀតណាម ។ ទិដ្ឋភាពមួយទៀតគឺការណ៍សម្ងាត់របស់បក្សកុម្មុយនិស្តកម្ពុជា ។ អស់រយៈពេលពីរឆ្នាំកន្លះ បក្សកុម្មុយនិស្តកម្ពុជាបានគ្រប់គ្រងប្រទេសកម្ពុជានៅក្រោមឈ្មោះដ៏អាថ៌កំបាំងមួយគឺ អង្គការ ។

ប្រភពសំខាន់បំផុតគឺផែនការបួនឆ្នាំរបស់បក្សក្នុងការកសាងរបបសង្គមនិយមលើគ្រប់វិស័យ និងសេចក្តីពន្យល់របស់ ប៉ុល ពត ចំពោះផែនការនោះ ដែលមានសរសេរនៅក្នុងសៀវភៅ “ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត” និងឯកសារបន្ទាប់បន្សំផ្សេងៗទៀត អំពីកិច្ចប្រជុំរបស់ថ្នាក់ដឹកនាំ សុន្ទរកថា កំណត់ត្រាអង្គប្រជុំនិងអត្ថបទនៅក្នុងទស្សនាវដ្តីប្រចាំខែរបស់បក្សឈ្មោះ “ទង់បដិវត្ត” ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូលឯកសារដែលពាក់ព័ន្ធនឹងរបបខ្មែរក្រហមរាប់ពាន់ឯកសារ ហើយដែលមានចុះផ្សាយនៅក្នុងទស្សនាវដ្តីស្វែងរកការពិត ។

ប្រភពផ្សេងទៀតគឺចម្លើយសារភាពចំនួន៤ពាន់ដែលរកឃើញនៅក្នុងគុកទួលស្លែង ហើយមានខ្លះសរសេរជាភាសាអង់គ្លេស ។ ដេវីដ ឆេនដល័រ ដែលបានសិក្សាទៅលើចម្លើយសារភាពជាងមួយពាន់ បានសង្កត់ធ្ងន់ថា បើទោះបីជាមានចម្លើយសារភាពមួយចំនួនអាចទទួលបានថាជាការពិតក៏ដោយ ក៏យើងអាចសន្និដ្ឋានបានថា ចម្លើយសារភាពភាគច្រើនត្រូវបានប្រឌិតដើម្បីឲ្យសមទៅតាមការចង់បានរបស់មជ្ឈិមបក្ស ។ ផ្នែកខ្លះរៀបរាប់អំពីការរួមគំនិតក្បត់ ផ្នែកខ្លះទៀតមានការប្រឌិតបទសន្ទនាបែបទីងសម្បា ។ នៅក្នុងចម្លើយសារភាពជាច្រើន អ្នកទោសបាននិយាយអំពីការប្រទូសរ៉ាយនយោបាយដែលកើតមានពិតប្រាកដ ។ ដោយសារតែភាគច្រើននៃអ្នកទោសនៅមន្ទីរ ស-២១ មានតំណែងខ្ពស់ៗនៅក្នុងជួរបក្សនិងជួរកងទ័ព ឯកសារទាំងអស់នេះបាននាំយើងឲ្យចូលកៀកទៅនឹងជម្លោះនៅក្នុងជួរថ្នាក់ដឹកនាំ ។

ស៊ីវ ហេដ័រ និង ប្រាយអិន ទីគេម័រ បានត្រួតពិនិត្យឯកសារដើមរបស់បក្សកុម្មុយនិស្តកម្ពុជានិងបទសម្ភាសន៍ជាមួយសាក្សីជាច្រើន ។

### ៦) ការប្រើប្រាស់វាក្យស័ព្ទ

ដោយសារតែនេះជាការសិក្សាអំពីនយោបាយមិនមែនអំពីច្បាប់ ពាក្យ អំពើប្រល័យពូជសាសន៍នៅកម្ពុជា នឹងត្រូវបាន

ប្រើប្រាស់នៅក្នុងនិយមន័យដែលទូលំទូលាយជាងនិយមន័យដែលចែងនៅក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ដើម្បីបង្កុលបង្ហាញនូវការស្លាប់ដ៏សន្ធឹកសន្ធាប់ដែលបង្កឡើងដោយនយោបាយរបស់គណបក្សកាន់អំណាច ។

ជារឿងធម្មតាក្នុងការកំណត់ថា "ខ្មែរក្រហម" ជាអ្នកប្រព្រឹត្តអំពើប្រល័យពូជសាសន៍នៅកម្ពុជា ប៉ុន្តែ "ខ្មែរក្រហម" ជាពាក្យដែលបង្កើតឡើងដោយសម្តេចសីហនុ សម្រាប់ហៅជនជ្រុលនិយមមួយក្រុមដែលបានទទួលការអប់រំពីទីក្រុងប៉ារីស ។ ជនកុម្មុយនិស្តខ្លួនឯងមិនដែលប្រើពាក្យនេះទេ ។ អង្គការដែលគ្រប់គ្រងអំណាចនៅកម្ពុជាពីឆ្នាំ១៩៧៥ដល់១៩៧៩ គឺ"បក្សកុម្មុយនិស្តកម្ពុជា" ហើយពាក្យនេះនឹងត្រូវបានប្រើប្រាស់នៅក្នុងសៀវភៅនេះ ។

ជាធម្មតា ភាសាដែលប្រើប្រាស់នៅក្នុងឯកសាររបស់បក្សកុម្មុយនិស្តកម្ពុជាគឺមិនច្បាស់លាស់ ។ ហេដ៍រ បានកត់សម្គាល់ថាពាក្យ "កម្ទេច" ជាពាក្យសម្រាលរបស់ពាក្យ "សម្លាប់" ។ ពាក្យ "បន្សុទ្ធកម្ម" បើទោះបីជាមិនសូវច្បាស់លាស់ក៏ដោយ គឺសំដៅទៅរកការសម្លាប់ ។

### ៣) ផ្លូវឆ្ពោះទៅអំណាចរបស់បក្សកុម្មុយនិស្តកម្ពុជា

លទ្ធិកុម្មុយនិស្តបានហូរចូលប្រទេសកម្ពុជាតាមទិសដៅផ្សេងៗគ្នា ហើយពលរដ្ឋកម្ពុជាមានហេតុផលផ្សេងៗគ្នាក្នុងការចូលរួមនៅក្នុងបក្សនេះ ។ ជនកុម្មុយនិស្តដំបូងគឺជាសមាជិកជនជាតិវៀតណាមរបស់បក្សកុម្មុយនិស្តឥណ្ឌូចិនដែលបង្កើតឡើងនៅឆ្នាំ១៩៣០ ។ សាឡុត ស (ប៉ុល ពត) និងអ្នកផ្សេងៗទៀតដែលក្រោយមកបានក្លាយទៅជាមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា មានប្រភពមកពីសមាគមនិស្សិតស៊ីសុវត្ថិ ។ សមាគមនេះគឺជាក្រុមអ្នកជាតិនិយមដែលមានការរីកចម្រើនយ៉ាងឆាប់រហ័សនៅក្នុងចំណោមអ្នកចេះដឹងនៅទីក្រុងភ្នំពេញនៅទសវត្សរ៍ឆ្នាំ១៩៣០ ។ មានសកម្មជនបួនប្រាំនាក់គឺជាព្រះសង្ឃដែលចេញពីសាលាបាលីជាន់ខ្ពស់ ។ នៅក្នុងចំណោមអ្នកទាំងនោះមានម្នាក់ជាអាចារ្យគឺ តាម៉ុក ។ សាឡុត ស និង អៀង សារី គឺជាសកម្មជននៅក្នុងគណបក្សប្រជាធិបតេយ្យ ។ សោ ភឹម និងអ្នកដទៃទៀតចេញមកពីក្រុមប្រឆាំងបារាំង និងចេញមកពីបក្សប្រជាជនបដិវត្តខ្មែរដែលបង្កើតឡើងនៅឆ្នាំ១៩៥១ ។ មិនយូរប៉ុន្មាន បក្សនេះបានប្រមូលសមាជិកជាជនជាតិខ្មែរចំនួន១ពាន់នាក់និងសមាជិកជាជនជាតិវៀតណាមបានចំនួន៣ពាន់នាក់ ។ ម្នាក់ក្នុងចំណោមនោះគឺ តាម៉ុក ។ នៅខេត្តបាត់ដំបងឯណោះវិញ នួន ជា និងអ្នកផ្សេងៗទៀត បានចូលរួមជាមួយបក្សកុម្មុយនិស្តថៃ ។

ក្នុងចំណោមនិស្សិតដែលទៅសិក្សានៅប្រទេសបារាំងនៅចុងទសវត្សរ៍ឆ្នាំ១៩៤០ ហើយដែលបានចូលរួមនៅក្នុងបក្សកុម្មុយនិស្តបារាំងមានៈ សាឡុត ស, អៀង សារី, សុន សេន, ហ៊ូ នឹម និង ហ៊ូ យន់ ។ អ្នកទាំងប្រាំបានសិក្សាអំពី"សំណួរជាតិ" របស់ស្តាលីន, "ចក្រពត្តិនិយម" របស់លេនីន, "ទីក្រុង" របស់ម៉ាក្ស ហើយប្រហែលជាសិក្សាអំពី "ប្រវត្តិសាស្ត្ររបស់បក្សកុម្មុយនិស្តសូវៀត" របស់ស្តាលីនដែរ ។ ហ៊ូ យន់ បានសរសេរនិក្ខេបបទថ្នាក់បណ្ឌិតរបស់គាត់អំពី "ឋានៈអ្នកស្រែចម្ការកម្ពុជាៈ អាណានិគមនិយមនិងទំនើបភាវូបនីយកម្ម" ។ បន្ទាប់ពីប្រទេសកម្ពុជាទទួលបានឯករាជ្យពីបារាំង មាននិស្សិតមួយចំនួនបានធ្វើដំណើរទៅសិក្សានៅទីក្រុងប៉ារីស ។ ខៀវ សំផន ជាមនុស្សម្នាក់



នៅក្នុងចំណោមនេះ ហើយដែលបានសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់ខ្លួនអំពីសេដ្ឋកិច្ចនិងការអភិវឌ្ឍន៍ខស្សរាហកម្មរបស់កម្ពុជា ដែលឆ្លុះបញ្ចាំងពីប្រព័ន្ធទ្រឹស្តីនៅលើពិភពលោក និងបានស្នើសុំឲ្យមានកំណែទម្រង់មួយដែលសមរម្យជាងនេះ ។ សមាជិកភាគច្រើនរបស់បក្សកុម្មុយនិស្តកម្ពុជាបានចូលបម្រើបក្សនៅក្នុងសង្គ្រាមពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ។

### ក) ជនកុម្មុយនិស្តនៅក្នុងរជ្ជកាលរបស់សម្តេច សីហនុ

ពីដើមដំបូង ជនកុម្មុយនិស្តកម្ពុជាជួបការលំបាកនៅក្នុងការ



ផ្សះផ្សារវាងប្រជាជនវៀតណាមនិងប្រជាជនកម្ពុជាដែលមានអារម្មណ៍ស្អប់វៀតណាម ។ ជួនកាលអ្នកទាំងនេះបានបង្អើបអំពីទស្សនៈជាតិនិយមរបស់ប្រជាជនកម្ពុជា ។ ឧទាហរណ៍ នៅឆ្នាំ១៩៥១ អ្នកនាំពាក្យបក្សកុម្មុយនិស្តកម្ពុជាបានអះអាងថា "ពូជសាសន៍កម្ពុជាមានដើមកំណើតជាអ្នកថ្លៃថ្នូរ ។ យើងហ៊ានលះបង់ជីវិតដើម្បីការពារសាសនានិងមាតុភូមិរបស់យើង" ។

បក្សប្រជាជនបដិវត្តន៍ខ្មែរគឺជាបក្សប្រឆាំងនឹងសម្តេច សីហនុ ។ ដោយសារតែព្រះអង្គត្រូវបានបារាំងលើកឲ្យឡើងសោយរាជ្យ បក្សនេះបានហៅព្រះអង្គថា "ហ្វាស៊ីស" ។ នៅឆ្នាំ១៩៥២ អៀង សារី, សាឡុត ស, ហ៊ូ យន់, ខៀវ ធីរិទ្ធិ និងនិស្សិតដទៃទៀត បានសរសេរសំបុត្រមួយថ្វាយសម្តេច សីហនុ ដោយចោទប្រកាន់ព្រះអង្គថា ព្រះអង្គកំពុងតែគាបសង្កត់លទ្ធិប្រជាធិបតេយ្យ និងបោះបង់ចោលទឹកដីដែលកំពុងតែស្ថិតនៅក្រោមការត្រួតត្រារបស់វៀតណាម ។ លិខិតនោះបានសរសេរថា "មានតែក្រុមយើងទេដែលជាអ្នកតំណាងដ៏ពិតប្រាកដរបស់ប្រជាជនកម្ពុជា" ។ នៅក្នុងឆ្នាំដដែលនោះ សាឡុត ស បានសរសេរបទអត្ថាធិប្បាយមួយសរសើរបដិវត្តន៍បារាំង បដិវត្តន៍រុស្ស៊ី និងបដិវត្តន៍ចិន ថាមានលក្ខណៈប្រជាធិបតេយ្យ ព្រោះបានបំបាត់ចោលនូវរបបរាជាធិបតេយ្យ ។ គាត់បានចុះហត្ថលេខាដោយដាក់ឈ្មោះថា "ខ្មែរដើម" ។

តាមរយៈកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវនៅឆ្នាំ១៩៥៤ ក្រុមអ្នកប្រឆាំងត្រូវតែទម្លាក់អាវុធចុះ ។ ដោយភ័យខ្លាចត្រូវរដ្ឋាភិបាលចាប់ខ្លួន អ្នកប្រឆាំងប្រមាណ១ពាន់នាក់បានចាកចេញពីប្រទេសជាមួយនឹងកងទ័ពវៀតមិញ ។ ក្នុងចំណោមនោះមានប្រមាណ៥រយនាក់ជាសមាជិករបស់បក្សប្រជាជនបដិវត្តន៍ខ្មែរ ។ បក្សនេះមានសមាជិកទាំងអស់១៨៦២នាក់ ។ អ្នកប្រយុទ្ធប្រឆាំងជាច្រើននាក់បានវិលត្រឡប់ទៅស្រែចម្ការរបស់ខ្លួនវិញដោយសារតែគិតថាការតស៊ូរបស់ខ្លួនបានចប់ទៅហើយ ។ ភាគច្រើននៃអ្នកដែលចូលបម្រើចលនាកុម្មុយនិស្តមិនមែនជាអ្នកក្រីក្រឬក៏អតីតអ្នកសកម្មប្រយុទ្ធនៅតាមជនបទទេ ប៉ុន្តែគឺជានិស្សិតគ្រូបង្រៀន កម្មករនៅតាមទីក្រុង និងយុវជនក្មេងៗដែលមានគំនិតជ្រុលនិយមតាមរយៈការសិក្សារបស់ខ្លួននៅក្រៅប្រទេស ។ ចំនួននៃអ្នកគាំទ្រចលនាកុម្មុយនិស្តមិនមានច្រើនប៉ុន្មានទេ ។ សម្តេច សីហនុ បានហៅក្រុមនេះថា "ខ្មែរក្រហម" ។

ជនកុម្មុយនិស្តមួយចំនួនដែលនៅសេសសល់បានបង្កើតជាគណបក្សនយោបាយមួយស្របច្បាប់ដោយដាក់ឈ្មោះថា "គណបក្សប្រជាជន" ។ គណបក្សនេះបានគាំទ្រគោលនយោបាយការបរទេសរបស់សម្តេច សីហនុ ប្រឆាំងនឹងសហរដ្ឋអាមេរិក ។ ក៏ប៉ុន្តែអ្នកផ្សេងទៀតគិតថា ត្រូវតែមានការផ្លាស់ប្តូរសង្គម ។ កិច្ចការនយោបាយកាន់តែស្មុគស្មាញឡើងៗនៅពេលដែលសម្តេច សីហនុ

ផរាកទៅរកនយោបាយអព្យាក្រឹត និងនៅពេលដែលព្រះអង្គពង្រឹងចំណងមិត្តភាពជាមួយនឹងក្រុមសង្គមនិយម ។ បដិវត្តន៍ដែលអន់ថយរបស់ទីក្រុងហាណូយ បានគាំទ្រការខិតចូលជិតគ្នានូវនយោបាយរបស់ខ្លួននិងនយោបាយរបស់សម្តេច សីហនុ ។

ទំនាក់ទំនងរបស់សម្តេច សីហនុ ជាមួយអ្នកឆ្វេងនិយមបានប្រែប្រួល ។ អ្នកចេះដឹងមួយចំនួនដូចជា ហ៊ូ យន់ និង ខៀវ សំផន លែងកោតសរសើរព្រះអង្គតទៅទៀត ។ នៅឆ្នាំ១៩៥៩ ហ៊ូ យន់ បានក្លាយជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងឧស្សាហកម្ម ហើយ ហ៊ូ នឹម បានក្លាយជាឧបការីរងរដ្ឋមន្ត្រីក្រសួងការបរទេស ។ អ្នកឆ្វេងនិយមមួយចំនួនទៀតដែលទទួលបានការសិក្សានៅប្រទេសបារាំងក៏បានទទួលតំណែងសំខាន់ៗដែរ ។ ក៏ប៉ុន្តែនៅពេលដែលសារពត៌មានរបស់អ្នកឆ្វេងនិយមវាយប្រហារទៅលើសម្តេច សីហនុ នៅឆ្នាំ១៩៦០ ព្រះអង្គបានបិទសារពត៌មាននោះចោល ។ អ្នកសរសេរសារពត៌មានត្រូវបានចាប់ដាក់គុក ក្នុងនោះមាន ខៀវ សំផន ដែរ ។ នាយទាហានដើងចាស់របស់បក្សប្រជាជនបដិវត្តន៍ខ្មែរត្រូវបានបង្ក្រាបមូលហេតុម្យ៉ាងគឺដោយសារតែទំនាក់ទំនងរបស់ក្រុមនេះជាមួយនឹងទីក្រុងហាណូយ ។

សមាជមួយនៅឆ្នាំ១៩៦០បានប្តូរឈ្មោះបក្សទៅជា "បក្សពលករកម្ពុជា" ។ មិនច្បាស់ថាតើសមាជនាពេលនោះជាសមាជលើកទីពីររបស់បក្សប្រជាជនបដិវត្តន៍ខ្មែរ ឬក៏ជាសមាជលើកទីមួយរបស់បក្សថ្មីនេះ ។ លើកនេះ សាឡុត ស ត្រូវបានជ្រើសតាំងឲ្យកាន់តំណែងសំខាន់ទីបីរបស់បក្ស ។ សមាជនៅក្នុងខែកុម្ភៈ ឆ្នាំ១៩៦៣ បានដំឡើងតំណែង សាឡុត ស ទៅជាលេខាបក្ស ។ តាម៉ុក និង សុន សេន បានចូលរួមនៅក្នុងគណៈកម្មាធិការមជ្ឈិម ។ នៅពេលនេះ អ្នកចេះដឹងនៅក្នុងទីក្រុងបានបង្កើនឥទ្ធិពលរបស់ខ្លួន ហើយក៏ជាពេលដែលនាយទាហានដើងចាស់ភាគច្រើនបាត់បង់តំណែង ។ សាឡុត ស, នួន ជា, អៀង សារី និង វន វេត បានចូលកាន់តំណែងនៅក្នុងមជ្ឈិមបក្ស ។

ខណៈដែលកុបកម្មនិស្សិតផ្ទុះឡើង សម្តេច សីហនុ បានទម្លាក់កំហុសទៅលើក្រុមឆ្វេងនិយមដែលមកពីប្រទេសបារាំង ហើយព្រះអង្គបានផ្សព្វផ្សាយបញ្ជីមួយដែលមានឈ្មោះមេដឹកនាំចលនាប្រឆាំងចំនួន៣៤រូប ។ ព្រឹត្តិការណ៍នេះបានធ្វើឲ្យ សាឡុត ស, អៀង សារី, សុន សេន និង នួន ជា គេចខ្លួនទៅព្រំដែនវៀតណាមនៅខែឧសភា ឆ្នាំ១៩៦៣ ។

ជនកុម្មុយនិស្តបានបញ្ចេញទស្សនៈប្លែកៗគ្នាចំពោះសម្តេច សីហនុ ។ នៅពេលដែលព្រះអង្គធ្វើជាតូបនីយកម្មវិស័យពាណិជ្ជកម្មអាហារ័ណនីហរ័ណនិងធនាគារ និងឈប់ទទួលជំនួយរបស់អាមេរិកនៅក្នុងឆ្នាំ១៩៦៣ ស្របគ្នានឹងកំណែទម្រង់ដែល ខៀវ សំផន លើកឡើងនៅក្នុងនិក្ខេបបទគាត់នៅក្នុងឆ្នាំ១៩៥៩ ។ ប៉ុន្តែឥឡូវនេះព្រះអង្គបានរិះគន់កំណែទម្រង់ទាំងនោះ ហើយមានព្រះបន្ទូលថារដ្ឋមិនអាចធ្វើកំណែទម្រង់បានឡើយ ។ ហ៊ូ យន់ បានគាំទ្រកំណែទម្រង់នោះយ៉ាងសស្រាក់សស្រាំ ។ គាត់នៅតែមើលឃើញថាសម្តេច សីហនុ មានទស្សនៈជាតិនិយមដដែល ហើយបានបដិសេធយុទ្ធសាស្ត្របដិវត្តរបស់ក្រុម សាឡុត ស ។ ហ៊ូ យន់ បានសរសេរថា គួរតែដោះស្រាយទំនាស់វណ្ណៈតាមរយៈមធ្យោបាយដែលមិនប៉ះពាល់ដល់ឯកភាពជាតិក្នុងការប្រឆាំងទៅនឹងចក្រពត្តិនិយមអាមេរិក ។ គោលជំហរនេះគឺស្របទៅនឹងនយោបាយការបរទេសរបស់វៀតណាមខាងជើងដែលយល់ថា ទំនាក់ទំនងល្អជាមួយសម្តេច សីហនុ គឺជាអត្ថិភាពចម្បងបំផុត ។ បញ្ហាយុទ្ធសាស្ត្រទាំងនេះអាចជាមូលហេតុនៃជម្លោះនៅពេលដែល សាឡុត ស រៀបចំកិច្ចពិភាក្សាជាមួយមេដឹកនាំវៀតណាមនៅទីក្រុងហាណូយក្នុងឆ្នាំ១៩៦៥ ។ នេះជាចំណុចសំខាន់បំផុតនៅក្នុងទំនាក់ទំនងកុម្មុយនិស្តកម្ពុជា-វៀតណាម ។

នៅពាក់កណ្តាលឆ្នាំ១៩៦៦ រដ្ឋាភិបាលបានចាប់ផ្តើមយុទ្ធនាការបង្ក្រាបអ្នកឆ្វេងនិយម ដោយសារតែសម្តេច សីហនុ ទ្រង់ជ្រាបថាក្រុម សាឡុត ស មានគោលជំហរប្រឆាំងនឹងព្រះអង្គ ។

នៅខែវិច្ឆិកា កិច្ចប្រជុំរបស់គណៈកម្មាធិការមជ្ឈិមបក្សពលករកម្ពុជាបានប្តូរឈ្មោះបក្សទៅជា "បក្សកុម្មុយនិស្តកម្ពុជា" ។ ក្រោយមកទស្សនាវដ្តីទង់បដិវត្តបានសរសេរថា "យើងបានសម្រេចថា បក្សត្រូវតែឯករាជ្យ និងមិនធ្វើជាទាសកររបម្រើជនវាតទីនិយមណាមួយទេ" ។

នៅពេលដែលការបះបោររបស់កសិករផ្ទុះឡើងនៅសំឡូតក្នុងឆ្នាំ១៩៦៧ សម្តេច សីហនុ បានទម្លាក់កំហុសទៅលើក្រុមឆ្វេងនិយមនៅទីក្រុងមានដូចជា ហ៊ូ យន់, ខៀវ សំផន, ហ៊ូ នឹម

និងអ្នកដទៃទៀត ។ ប៉ុន្មាននាក់នេះត្រូវតុលាការកាត់ទោសប្រហារជីវិត ប៉ុន្តែបានភៀសខ្លួនទៅមូលដ្ឋានរបស់បក្សកុម្មុយនិស្តកម្ពុជាដែលមានទីតាំងនៅក្នុងព្រៃ ។

ចុងឆ្នាំ១៩៦៧ សាឡុត ស បានបើកវគ្គអប់រំមួយ ហើយបានដាក់ចេញនូវគោលនយោបាយមួយដែលច្របាច់បញ្ចូលគ្នានូវការតស៊ូនយោបាយនិងការតស៊ូប្រដាប់អាវុធ ។ វៀតណាមបានបដិសេធមិនជួយក្រុមខ្មែរកុម្មុយនិស្តមួយនេះទេដោយលើកហេតុផលថា “ចាំរំដោះវៀតណាមបានសិនទើបជួយកម្ពុជាជាក្រោយ” ។ ទ័ពព្រៃកុម្មុយនិស្តបានកើនច្រើនឡើងៗ ។ នៅឆ្នាំ១៩៦៩ រដ្ឋមន្ត្រីក្រសួងការពារជាតិ លន់ ណុល បានវាយតម្លៃថាមានខ្មាំងប្រដាប់អាវុធប្រមាណ២ពាន់៤រយនាក់ ។

នៅខែមីនា ឆ្នាំ១៩៦៩ សហរដ្ឋអាមេរិកចាប់ផ្តើមទម្លាក់គ្រាប់បែកជាសម្ងាត់មកលើតំបន់នានាតាមព្រំដែនកម្ពុជាដោយគិតថា តំបន់ទាំងនោះជាទីតាំងទីបញ្ជាការរបស់វៀតណាមខាងជើង និងរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង ។ ការទម្លាក់គ្រាប់បែកបានធ្វើឲ្យយុវជនយុវនារីជាច្រើនចូលរួមធ្វើបដិវត្តន៍ ។ នៅឆ្នាំ១៩៧០ ចំនួនទ័ពព្រៃប្រដាប់អាវុធបានកើនឡើងជាងពីរដងលើសឆ្នាំ១៩៦៩ ។

នៅមុនឆ្នាំ១៩៧០ សារជាតិអនាធិបតេយ្យរបស់សង្គមកសិករខ្មែរនិងការរីកចម្រើននៃសេដ្ឋកិច្ចគឺជាឧបសគ្គចម្បងដែលរារាំងដល់ការប្រមូលអ្នកគាំទ្របក្សកុម្មុយនិស្តកម្ពុជា ។ បក្សនេះអូសទាញអ្នកគាំទ្រនៅតាមជនបទបានតិចតួចណាស់ ។

នៅចុងឆ្នាំ១៩៦៩ សាឡុត ស បានធ្វើដំណើរទៅទីក្រុងហាណូយ ជាពេលដែលថ្នាក់ដឹកនាំវៀតណាមចាប់ផ្តើមភ័យខ្លាចថាសហរដ្ឋអាមេរិកនឹងរំកិលចូលទៅក្នុងប្រទេសកម្ពុជា ហើយនឹងគំរាមកំហែងដល់ការបះបោរនៅភាគខាងត្បូង ។ ស្ថានភាពនេះបានក្លាយទៅជាចំណុចយុទ្ធសាស្ត្រថ្មីមួយរបស់វៀតណាម ហើយវៀតណាមបានចាប់ផ្តើមគិតដល់សហប្រតិបត្តិការយោធាជាមួយបក្សកុម្មុយនិស្តកម្ពុជា ។ សាឡុត ស បានធ្វើដំណើរទៅទីក្រុងប៉េកាំង ។ នៅពេលដែលសម្តេច សីហនុ យាងទៅដល់ទីក្រុងប៉េកាំងនៅខែមីនា ឆ្នាំ១៩៧០ សាឡុត ស នៅទីនោះនៅឡើយ ។ សម្តេច សីហនុ ត្រូវការឲ្យបក្សកុម្មុយនិស្តកម្ពុជាប្រយុទ្ធជាមួយ លន់ ណុល ដែលបានទម្លាក់ព្រះអង្គពីតំណែងនៅថ្ងៃទី១៨ ខែមីនា នៅក្នុងរដ្ឋប្រហារមួយដែលបង្កឲ្យមានយុទ្ធនាការសម្លាប់ជនជាតិវៀតណាម ។ ជនជាតិវៀតណាមជាច្រើនត្រូវបានសម្លាប់ ជិត២សែននាក់ទៀតបានភៀសខ្លួនទៅវៀតណាមខាងត្បូង ។

នៅឯទីក្រុងប៉េកាំងឯណោះវិញ សម្តេច សីហនុ បានយល់ព្រមដឹកនាំរណសិរ្សរួបរួមជាតិដែលទាហានភាគច្រើនរបស់រណសិរ្សនេះជាជនកុម្មុយនិស្តដែលកងទ័ពរបស់ព្រះអង្គទើបតែព្យាយាមកម្ចាត់តែមួយខែមុននេះប៉ុណ្ណោះ ។ ព្រះអង្គបានអំពាវនាវឲ្យប្រជាជនកម្ពុជាកាន់អាវុធប្រឆាំងនឹង លន់ ណុល ស្របពេលជាមួយគ្នានោះ ព្រះអង្គបានប្រកាសបង្កើតរណសិរ្សរួបរួមជាតិនៃកម្ពុជានិងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដោយតែងតាំងខ្លួនព្រះអង្គផ្ទាល់ជាប្រធានចលនាទាំងពីរនេះ ។ កងទ័ពរំដោះជាតិមួយត្រូវបានបង្កើតឡើងក្រោម បញ្ជាការរបស់ ខៀវ សំផន, សាឡុត ស, នួន ជា, សោ ភឹម, តាម៉ុក និង សុន សេន ។

## ៧) បក្សកុម្មុយនិស្តកម្ពុជានៅក្នុងសង្គ្រាម

នៅដើមឆ្នាំ១៩៧០ កងកម្លាំងរបស់បក្សកុម្មុយនិស្តកម្ពុជាមានចំនួនសរុបប្រមាណតែ៤ពាន់នាក់ប៉ុណ្ណោះ ហើយមិនដល់ពាក់កណ្តាលនៃចំនួននេះទេដែលមានអាវុធកាន់ ។ ទីក្រុងហាណូយបានបញ្ជូនមកវិញស្ទើរតែទាំងអស់នូវអ្នកប្រឆាំងបារាំង ។ បក្សកុម្មុយនិស្តកម្ពុជាមិនបានផ្តល់ឲ្យអ្នកទាំងនោះនូវតំណែងនយោបាយណាមួយឡើយ ហើយក៏មិនអាចធ្វើឲ្យអ្នកទាំងនោះអព្យាក្រឹតទាំងស្រុងដែរ ដោយសារ៨២២នាក់នៃក្រុមនោះជាសមាជិករបស់បក្ស ។ ជាការចាប់ផ្តើម ទាហានរបស់វៀតណាមខាងជើងទទួលខុសត្រូវក្នុងការប្រយុទ្ធស្ទើរតែទាំងអស់ ហើយក្នុងរវាងតែប៉ុន្មានខែប៉ុណ្ណោះក៏កាន់កាប់បានជាងពាក់កណ្តាលនៃប្រទេសកម្ពុជា ។ ទាហានវៀតណាមបានប្រាប់អ្នកភូមិថាខ្លួនជាបេសកជនផ្ទាល់របស់សម្តេច សីហនុ ហើយបានជ្រើសរើសមេភូមិនិងមេឃុំថ្មី ។ រដ្ឋបាលបដិវត្តន៍មូលដ្ឋានមានតួនាទីសំខាន់ក្នុងការធ្វើឲ្យជនជាតិវៀតណាមនិងខ្មែរយល់ព្រមធ្វើការជាមួយក្រុមទាហានទាំងនោះ ។ វៀតណាមធ្វើយ៉ាងនេះដោយមិនបានពិភាក្សាជាមួយនឹងបក្សកុម្មុយនិស្តកម្ពុជាទេ ។ តវិយាបថរបស់វៀតណាម

គឺជួយខបត្តម្ភ ឧទាហរណ៍ដូចជានិយាយថាៈ «បើទោះបីជាបដិវត្តន៍កម្ពុជាប្រើងប្រែងយ៉ាងណាក៏ដោយក៏មិនអាចធ្វើបានដែរ... យើងបានជួយកម្ពុជាក្នុងការរៀបចំប្រព័ន្ធទ្រឹស្តី ជួយរៀបចំផែនការជួយបង្កើតអង្គការ» ។ មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាអាក់អន់ចិត្តជាខ្លាំងចំពោះទង្វើនេះ ។

បក្សកុម្មុយនិស្តកម្ពុជាបានរៀបចំមូលដ្ឋាននយោបាយជនបទរបស់ខ្លួនដោយការផ្តួលរំលំវណ្ណៈម្ចាស់ដី ។ ឯកសារមួយដែលសរសេរនៅឆ្នាំ១៩៧០មានចំណងជើងថា *យុទ្ធសាស្ត្រនិងគោលនយោបាយរបស់បក្សនៅតាមជនបទ*បានសរសេរថាៈ «ប្រសិនបើយើងអាចធ្វើឲ្យពាក្យស្លោកដែលថាដីជារបស់កសិករក្លាយជាការពិត នោះមានន័យថាយើងអាចដោះស្រាយបញ្ហាជាសារវន្តបាន ហើយបដិវត្តន៍របស់យើងនឹងទទួលបានជោគជ័យ» ។ បក្សកុម្មុយនិស្តកម្ពុជាជឿជាក់ថា នៅពេលដែលខ្លួនអាចធ្វើឲ្យវណ្ណៈកសិករភ្ញាក់រឭក នោះកសិករមុខជាងើបឡើងបះបោរទាំងអស់គ្នាជាមិនខាន ។ ប៉ុន្តែស្ថានភាពនេះមិនបានកើតឡើងទេ ។ គោលនយោបាយនេះមិនអាចទាក់ទាញកសិករបានទេ ព្រោះកសិករភាគច្រើនមានដីជាកម្មសិទ្ធិ លើកលែងតែតំបន់សំឡូតមួយប៉ុណ្ណោះ ។ បក្សកុម្មុយនិស្តកម្ពុជាបានរីកចម្រើនយ៉ាងឆាប់រហ័សដោយយកគំរូតាមចិននិងវៀតណាម ហើយបានបង្កើតស្ថាប័នគាបសង្កត់មួយដែលកសិករភាគច្រើនមើលមិនយល់ ។ បក្សបានរៀបចំអង្គប្រជុំជាច្រើនដើម្បីដាស់សតិអារម្មណ៍កសិករ ប៉ុន្តែការចូលរួមរបស់កសិករមិនមែនជាការបង្ហាញអំពីការគាំទ្ររបស់ខ្លួនចំពោះបដិវត្តន៍ទេ គឺដោយសារតែខ្លាចទណ្ឌកម្ម គោរពបញ្ជារបស់សម្តេច សីហនុ និងចង់ដឹងអំពីកម្មាភិបាលដែលមានសម្លៀកបំពាក់ពណ៌ខ្មៅទាំងនោះ ។ កសិករបានចងចាំនូវពាក្យស្លោកឃោសនារបស់អង្គប្រជុំ ប៉ុន្តែមិនយល់អត្ថន័យរបស់ពាក្យស្លោកទាំងនោះទេ ។ នៅក្នុងភាសាខ្មែរ ពាក្យ "ម្ចាស់ដី" ច្រើនសំដៅទៅរកម្ចាស់ផ្ទះជាជាងម្ចាស់ដី ។

មិនយូរប៉ុន្មាន បក្សកុម្មុយនិស្តកម្ពុជាចាប់ផ្តើមសម្លាប់ជនជាតិវៀតណាមនិងជនជាតិខ្មែរទាំងឡាយដែលសហការជាមួយវៀតណាម ។ នៅក្នុងទីរួមខេត្តកំពង់ធំ ជនជាតិវៀតណាមមួយចំនួនធំត្រូវបានប្រមូលផ្តុំឲ្យស្នាក់នៅបណ្តោះអាសន្ននៅតាមផ្ទះធំៗរបស់ប្រជាជនមូលដ្ឋាន ។ មុនពេលចាកចេញនៅឆ្នាំ១៩៧១ ខ្មែរកុម្មុយនិស្តបានគប់គ្រាប់បែកទៅក្នុងផ្ទះទាំងនេះ ។ គ្រួសារខ្លះស្លាប់សមាជិកទាំងអស់ ។ នេះប្រហែលជាការសម្លាប់រង្គាលលើកទីមួយរបស់បក្សកុម្មុយនិស្តកម្ពុជានូវអ្វីដែលហៅថា "ក្បាលយួនខ្លួនខ្មែរ" ។ នេះក៏ជាការចាប់ផ្តើមលុបបំបាត់ឥទ្ធិពលរបស់សម្តេច សីហនុ ដែរ ។

នៅភូមិភាគឦសានក្នុងឆ្នាំ១៩៧១ បក្សកុម្មុយនិស្តកម្ពុជាចាប់ផ្តើមប្រមូលជាតិពន្ធុឡាវនិងកុលសម្ព័ន្ធផ្សេងៗទៀតទៅដាក់នៅកន្លែងមួយដើម្បីបញ្ចប់ជីវភាពបែបពនេចររបស់ក្រុមនេះ ។ បក្សកុម្មុយនិស្តកម្ពុជាប្រមូលអ្នកទាំងនោះឲ្យលើកទំនប់និងធ្វើស្រែ ។ អ្នកដែលជឿសាសនាត្រូវសម្លាប់ចោល ។ នៅតំបន់និរតីបក្សកុម្មុយនិស្តកម្ពុជាចាប់ផ្តើមវាយប្រហារទៅលើវប្បធម៌របស់ជនជាតិចាមនៅពាក់កណ្តាលឆ្នាំ១៩៧២ ។

កិច្ចប្រជុំមួយរបស់បក្សកុម្មុយនិស្តកម្ពុជានៅខែកក្កដាឆ្នាំ១៩៧១ បានប្រកាសជាផ្លូវការអំពីបដិវត្តន៍ប្រជាធិបតេយ្យជាតិ ដែលមានន័យថាជាការប្រមូលដីដាក់ជាកម្មសិទ្ធិរួម លុបបំបាត់ទីផ្សារនិងការកេងប្រវ័ញ្ច ជម្លៀសប្រជាជនចេញពីទីក្រុងនិងបណ្តេញកងទ័ពវៀតណាមចេញ ។ អ្វីៗទាំងអស់ត្រូវបានប្រមូលយកមកដាក់ជារបស់សមូហភាព សូម្បីតែចាននិងឆ្នាំង ។ នៅឆ្នាំ១៩៧២ ការហូបរួមបានចាប់ផ្តើមអនុវត្ត ។ សក្តិភូមិនិយមត្រូវតែរំលាយចោល ។ បក្សកុម្មុយនិស្តកម្ពុជាបានដាក់បទបញ្ជាមួយថា អ្នកណាក៏ដោយឲ្យតែអាចសម្គាល់ថាជាភ្នាក់ងារស៊ើបការណ៍សម្ងាត់របស់សត្រូវ នឹងត្រូវចាប់ខ្លួនយកទៅសួរចម្លើយដើម្បីរកមុខសញ្ញាសត្រូវផ្សេងៗទៀតនៅក្នុងបក្ស រួចហើយអ្នកទាំងនោះនឹងត្រូវសម្លាប់ចោល ។

មានភាពមិនចុះសម្រុងគ្នាខ្លះជុំវិញបញ្ហានេះ ។ អ្នកដែលជំទាស់នឹងបទបញ្ជានេះមាន ហ៊ូ យន់, ហ៊ូ នឹម, ខៀវ សំផន, កុយ ធួន នៅភូមិភាគឧត្តរ និងមាននាយទាហានជើងចាស់ជាច្រើនទៀតដែលមានទំនាក់ទំនងជាមួយវៀតណាមដូចជាលេខាភូមិភាគបូព៌ា សោ ភឹម ជាដើម ។ ការណ៍នេះបានបង្កឲ្យមានការបាក់បែកតាមតំបន់ ។ ការប៉ះទង្គិចគ្នាក៏កើតមានឡើង ហើយអ្នករងគ្រោះគឺប្រជាជនសាមញ្ញ ។ បក្សកុម្មុយនិស្តកម្ពុជាបានបញ្ជូន

មេដឹកនាំសំខាន់ៗរបស់ខ្លួនឲ្យទៅភូមិភាគនិរតី ។

ឆ្នាំ១៩៧៣គឺជាឆ្នាំដែលសភាពការណ៍មានការប្រែប្រួលខ្លាំង ។ នៅខែមករា កិច្ចព្រមព្រៀងសន្តិភាពវៀតណាមត្រូវបានចុះហត្ថលេខានៅទីក្រុងប៉ារីស ហើយកងទ័ពវៀតណាមបានចាប់ផ្តើមដកចេញពីកម្ពុជា លើកលែងតែនៅភូមិភាគឦសាន ដែលជាកន្លែងសំខាន់បំផុតនៃគោលនយោបាយរបស់ហូជីមិញ ។ បក្សកុម្មុយនិស្តកម្ពុជាបានបដិសេធការចរចា ។ នៅថ្ងៃទី៩ ខែកុម្ភៈ សហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកយ៉ាងខ្លាំងក្លាដែលមិនធ្លាប់មានពីមុនមក ។ គិតរហូតដល់ពេលដែលអាមេរិកឈប់ទម្លាក់គ្រាប់បែកលើកម្ពុជានៅថ្ងៃទី១៥ ខែសីហា ចំនួនគ្រាប់បែកសរុបដែលបានទម្លាក់លើប្រទេសកម្ពុជាគឺ ៥៣៩.១២៩ តោន បើប្រៀបធៀបទៅនឹងគ្រាប់បែកដែលទម្លាក់លើប្រទេសជប៉ុននៅក្នុងសង្គ្រាមលោកលើកទីពីរ គឺមានតែ១ម៉ឺន៦ពាន់តោនប៉ុណ្ណោះ ។ ការទម្លាក់គ្រាប់បែកបានធ្វើឲ្យសមាជិកថ្មីៗរបស់បក្សឡើងកាន់តំណែងបដិវត្តតែម្តង ហើយជាធម្មតាអ្នកទាំងនេះត្រូវបានជំរុញឲ្យចូលបម្រើបដិវត្តន៍ដោយមានគំនុំសងសឹកក៏ដូចជាហេតុផលសង្គមនិងនយោបាយ ។

នៅថ្ងៃទី២០ ខែឧសភា បក្សកុម្មុយនិស្តកម្ពុជាចាប់បង្កើតសហករណ៍ ។ នយោបាយនេះបានចាប់ផ្តើមអនុវត្តនៅក្នុងតំបន់ជាច្រើន ។ ឥឡូវនេះដីត្រូវបានដកហូតយកដាក់ជាកម្មសិទ្ធិរួម ហើយផលដែលផលិតបានក៏ត្រូវដកហូត ។ កន្លែងខ្លះមានការបញ្ជាឲ្យបំផ្លាញសាសនានិងជីវភាពឯកជន និងអនុវត្តការហូបរួម ។ ប្រជាជនជាងមួយម៉ឺននាក់បានភៀសខ្លួនពីខេត្តស្វាយរៀងទៅវៀតណាមខាងត្បូង ដោយត្អូញត្អែរអំពីការបំផ្លាញព្រះពុទ្ធសាសនា និងអំពីការដកហូតសិទ្ធិក្នុងការនិយាយស្តីនិងសិទ្ធិក្នុងការសម្តែងការគាំទ្រចំពោះសម្តេច សីហនុ ។

ក្រោយមក ទស្សនាវដ្តីទង់បដិវត្តបានដោះសាចំពោះគោលនយោបាយនេះថា ឈ្មួញកណ្តាលមានឥទ្ធិពលខ្លាំងណាស់នៅតាមតំបន់រំដោះ រហូតដល់យក «រដ្ឋរបស់យើងជារណប» ។ នៅខេត្តក្រចេះ «រថយន្តហុងដាបើកបរចុះឡើងៗ ចំណែកឯអ្នកតស៊ូយើងមានសម្លៀកបំពាក់មិនសមរម្យហើយធ្វើដំណើរដោយថ្មើរជើង ។ នេះបញ្ជាក់ថាឈ្មួញទាំងនោះនៅតែជាចៅហ្វាយ... ហើយបើយើងនៅតែដើរនៅលើផ្លូវនេះ យើងនឹងចប់ហើយ» ។ កសិករបានលក់ស្រូវរបស់ខ្លួនទៅឲ្យភ្នាក់ងារវៀតណាមខាងត្បូង ឬក៏ទៅឲ្យរណសិរ្សជាតិរំដោះវៀតណាមខាងត្បូងដែលឲ្យថ្លៃខ្ពស់ជាង ។ ការរើសកងទ័ពក៏មានការលំបាកដែរដោយសារតែកសិករនិយាយថា គាត់ត្រូវការឲ្យកូនចៅរបស់គាត់នៅធ្វើការងារស្រែចម្ការ ។ បក្សកុម្មុយនិស្តកម្ពុជាបានដោះស្រាយបញ្ហាទាំងពីរនេះ ដោយការបង្កើតជាសហករណ៍ ហាមប្រាមការប្រើប្រាស់ក្រដាសប្រាក់ និងបង្កើតប្រព័ន្ធដោះដូរទំនិញ ។ ធ្វើដូច្នេះដើម្បីកុំឲ្យវៀតណាមអាចទិញស្រូវនិងទាក់ទងជាមួយអ្នកភូមិបាន ។

នៅពេលដែលការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកបានបញ្ចប់ បក្សកុម្មុយនិស្តកម្ពុជាចាប់ផ្តើមធ្វើបម្លាស់ទីប្រជាជននៅគ្រប់កន្លែងដែលខ្លួនកាន់កាប់ ។ នៅឧដុង្គ បក្សកុម្មុយនិស្តកម្ពុជាបាននាំប្រជាជនចូលទៅក្នុងព្រៃដែលនៅក្បែរនោះ ហើយបានសម្លាប់គ្រូបង្រៀននិងបុគ្គលិករាជការចោលទាំងអស់ ។ កសិករដែលត្រូវជម្លៀសបានត្អូញត្អែរអំពីរបបអាហារដែលហូបមិនឆ្អែត ធ្វើការហួសកម្លាំង សម្លៀកបំពាក់ពណ៌ខ្មៅ និងទណ្ឌកម្មប្រហារជីវិត ។ កសិករចំនួន៥ម៉ឺននាក់បានភៀសខ្លួនទៅខេត្តកំពង់ធំ ។ កសិករទាំងនោះបាននិយាយថា អង្គការបានដាក់ឲ្យអនុវត្តនូវវិន័យយ៉ាងយង់ឃ្នង ហើយសម្លាប់មនុស្សជាច្រើន ។ អង្គការបានបំផ្លាញព្រះពុទ្ធរូប និងហាមឃាត់ព្រះសង្ឃមិនឲ្យគោរពបូជា ។ បក្សកុម្មុយនិស្តកម្ពុជាមិនអនុញ្ញាតឲ្យមានផ្ទះជារបស់ផ្ទាល់ខ្លួនទេ គឺបង្កើតឲ្យមានជាជំរំសម្រាប់ស្ត្រី កុមារ និងយុវជន ។ អង្គការបានហាមឃាត់មិនឲ្យកុមារគោរពឪពុកម្តាយរបស់ខ្លួន ។ ប្រជាជនហូបបបរដែលគ្មានលាយសាច់រួមគ្នា ។ មនុស្សចាស់ជាច្រើនបានស្លាប់ដោយសារអត់អាហារនិងជំងឺ ។

អង្គការមិនអនុញ្ញាតឲ្យជាតិពន្ធចិននិងវៀតណាមចូលរួមក្នុងសហករណ៍ទេ ។ អង្គការគិតថា ជនជាតិចាមជាឧបសគ្គក្នុងការធ្វើសហករណ៍ ។ នៅក្នុងឯកសារមួយសរសេរនៅឆ្នាំ១៩៧៣ អំពីការតស៊ូវណ្ណៈ ជនជាតិចាមមិនត្រូវបានចាត់ទុកថាជាវណ្ណៈកម្មករដូចជនជាតិខ្មែរទេ ។ បក្សកុម្មុយនិស្តកម្ពុជាបានហៅជនជាតិចាមថាជា «សត្រូវផ្ទៃក្នុង» ទោះជាមានជនជាតិចាមជាច្រើននាក់បានចូលរួមក្នុងចលនាកុម្មុយនិស្តហើយបានបង្កើត

ជាចលនាឥស្លាមនៅឆ្នាំ១៩៧០ក៏ដោយ ។ ពីឆ្នាំ១៩៧៣ ដល់១៩៧៤ នៅភូមិភាគនិរតីនិងឧត្តរ ជនជាតិចាមត្រូវបានបង្ខំឲ្យចាកចេញពីតំបន់ដែលកំពុងតែរស់នៅ ។ ជនជាតិចាមបានចាប់ផ្ដើមធ្វើបាតុកម្មប្រឆាំងនឹងការគាបសង្កត់សាសនារបស់ខ្លួន ។ នៅពាក់កណ្ដាលឆ្នាំ១៩៧៤ យ៉ាងហោចណាស់មានជនជាតិចាមចំនួនពាររយនាក់ត្រូវចាប់ខ្លួន ដែលភាគច្រើនជាមេភូមិនិងអ្នកដឹកនាំសំខាន់ៗខាងសាសនា ។ ចលនាឥស្លាមត្រូវបានហាមឃាត់ ។

នៅក្នុងខេត្តកោះកុង ប្រជាជនភាគច្រើនជាអ្នកនេសាទនិងកសិករដែលអាចនិយាយភាសាថៃបាន ហើយភាគច្រើននៃសមាជិកគណៈកម្មាធិការបក្សកុម្មុយនិស្តកម្ពុជាគឺជាជនជាតិថៃ ។ នៅឆ្នាំ១៩៧៤ អង្គការបានសម្លាប់អ្នកដឹកនាំបក្សនៅមូលដ្ឋានជាមួយនឹងសមាជិកជនជាតិថៃប៉ុន្មាននាក់ទៀតនៃគណៈកម្មាធិការបក្សនៅមូលដ្ឋានដោយចោទប្រកាន់ថាជាចារបុរសរបស់ថៃ ។ ប្រធានសេនាធិការតំបន់បានវាយបកវិញ ហើយក៏មានការប្រយុទ្ធគ្នារវាងទ័ពមជ្ឈិមនិងអ្នកបះបោររហូតដល់ខែឧសភា ឆ្នាំ១៩៧៥ ។

### ក) ជ័យជម្នះរបស់បក្សកុម្មុយនិស្តកម្ពុជា

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អ្នកដែលទទួលជ័យជម្នះបានធ្វើដំណើរចូលទីក្រុងភ្នំពេញ ។ ក៏ប៉ុន្តែ អ្នកទាំងនោះមិនមែនជាកងកម្លាំងរំដោះជាតិរបស់ប្រជាជនកម្ពុជាទេ ។ កងទ័ពពិតប្រាកដដែលនៅសល់គឺសុទ្ធតែជាកងទ័ពបដិវត្តរបស់បក្សកុម្មុយនិស្តកម្ពុជា ។

ប៉ុល ពត បាននិយាយថា បក្សកុម្មុយនិស្តកម្ពុជាជាអ្នកដែលទទួលជ័យជម្នះលើសង្គ្រាម ជាជ័យជម្នះដែលមិនមានការលូកដៃចូលពីសំណាក់បរទេស ។ ប៉ុល ពត បានបន្តទៀតថាៈ "នៅក្នុងពិភពលោកទាំងមូល ចាប់តាំងពីមានសង្គ្រាមបដិវត្ត និងចាប់តាំងពីការចាប់កំណើតរបស់ចក្រពត្តិនិយមអាមេរិកមក គ្មានប្រទេសណាមួយ ប្រជាជនណាមួយ និងកងទ័ពណាមួយអាចបណ្ដេញចក្រពត្តិនិយមចេញពីប្រទេសនិងទទួលបាននូវជ័យជម្នះដ៏មហិមាដូចយើងទេ" ។ នេះគឺជាគំរូសម្រាប់ពិភពលោក និងជាការរីកចម្រើនមួយនៃប្រពៃណីបដិវត្តដែលបង្កើតឡើងដោយបុលសេវិកដែលត្រូវបានផ្ដួលរំលំបន្ទាប់ពីការស្លាប់របស់ស្តាលីន ប៉ុន្តែត្រូវបានយកមកអនុវត្តម្ដងទៀតដោយ ម៉ៅសេទុង បើទោះបីជាអនុវត្តក្នុងរបៀបមិនច្បាស់លាស់ដោយបក្សកុម្មុយនិស្តចិនក៏ដោយ ។

ខៀវ សំផន បាននិយាយថា "ប្រជាជាតិកម្ពុជាបានស្ដារបានវិញហើយនូវគុណភាពដែលមានតែមួយរបស់កម្ពុជា ។ អស់រយៈពេលបួនឆ្នាំហើយដែលអាណានិគមនិយម មូលធននិយម និងចក្រពត្តិនិយមប្រតិកិរិយា បានរុញសម្ពាក់យើងឲ្យចូលទៅក្នុងភក់ជ្រាំ... ឥឡូវនេះយើងបានស្ដារឡើងវិញនូវកិត្តិយសនិងមុខមាត់របស់យើង ។ ឥឡូវនេះយើងមានក្ដិនល្អវិញហើយ" ។

បក្សកុម្មុយនិស្តកម្ពុជាបានមើលឃើញជ័យជម្នះរបស់ខ្លួនក្នុងវិសាលភាពមួយយ៉ាងទូលាយ ពោលគឺមើលឃើញទៅដល់ការប្រកួតប្រជែងឥទ្ធិពលនៅតំបន់អាស៊ី-អាគ្នេយ៍ ។ នៅទីនេះ ប្រសិនបើបដិវត្តន៍ទទួលបានជោគជ័យ បក្សកុម្មុយនិស្តកម្ពុជាអាចប្រកួតប្រជែងអំពីការដឹកនាំ ហើយវៀតណាមនឹងត្រូវហ៊ុមព័ទ្ធ ។ ប្រសិនបើមិនដូច្នោះទេ ឥទ្ធិពលរបស់វៀតណាមនឹងគ្របដណ្ដប់តំបន់ទាំងមូល ។ ប៉ុល ពត បាននិយាយយ៉ាងសប្បាយចិត្តថា "កម្ពុជាបានធ្វើដំណើរទៅមុខយ៉ាងលឿនតាមគន្លងបដិវត្តលឿនជាងវៀតណាម ។ ប្រសិនបើប្រជាជនកម្ពុជាអាចកសាងអង្គរវត្តបាន យើងក៏អាចធ្វើអ្វីៗបានទាំងអស់" ។

ភ្លាមៗបន្ទាប់ពីទទួលបានជ័យជម្នះ បក្សកុម្មុយនិស្តកម្ពុជាបានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ទីរួមខេត្ត និងភូមិទាំងឡាយដែលស្ថិតក្រោមការកាន់កាប់របស់ខ្លួន ។ កសិករដែលពីមុនបានភៀសខ្លួនទៅទីក្រុងដើម្បីគេចពីសង្គ្រាម ហើយពេលនេះបានត្រឡប់មកភូមិវិញក៏ត្រូវបណ្ដេញចេញពីស្រុកកំណើតរបស់ខ្លួន ព្រោះអ្នកទាំងនេះជាខ្មាំងដែលសុខចិត្តគេចខ្លួនពីជនបទ មិនព្រមចូលបម្រើបក្សកុម្មុយនិស្តកម្ពុជា ។ កសិករទាំងនេះមានចំនួនសរុបប្រមាណ១លាននាក់ឯណោះ ។

សមាជិករបបមុនត្រូវចាប់ខ្លួននិងសម្លាប់ ។ មិនយូរប៉ុន្មាន នាយទាហាននិងបុគ្គលិកស៊ីវិលដែលមានតំណែងប្រហាក់ប្រហែលត្រូវអង្គការយកទៅសម្លាប់ ។ គ្រូបង្រៀន អ្នកដែលមានវិជ្ជាជីវៈនិស្សិត និងអ្នកចេះដឹង ត្រូវអង្គការកំណត់ជាមុខសញ្ញាដើម្បី

សម្លាប់ ដូនកាលត្រូវសម្លាប់ចោលភ្លាមៗតែម្តង ។ សត្រូវផ្សេងៗទៀតដែលត្រូវសម្លាប់ចោលទាំងអស់តែម្តងនោះ គឺអ្នកមូលធននិយមដែលរាប់បញ្ចូលទាំងអ្នកលក់នំបញ្ចុកតាមផ្លូវឬក៏អ្នកបើកតាក់ស៊ី ។ អ្នកចក្រពត្តិនិយម ឬក៏អ្នកទាំងឡាយដែលបញ្ចេញកាយវិការផ្សេងៗគាំទ្រសម្តេច សីហនុ ក៏ត្រូវប្រហារជីវិតដែរ ។ នៅតាមតំបន់ជាច្រើន សូម្បីតែប្រពន្ធនិងកូនរបស់នាយទាហានក៏ត្រូវសម្លាប់ដោយសារតែ "អ្នកទាំងនោះស្ថិតនៅក្នុងចំណោមមុខសញ្ញាដែលត្រូវតែដឹកទាំងឫស" ។ ព្រះសង្ឃត្រូវអង្គការសម្រាតស្បង់ចីវរ ហើយប្រសិនបើព្រះសង្ឃអង្គណាហ៊ានប្រឆាំងនឹងត្រូវសម្លាប់ចោល ក៏ប៉ុន្តែគ្មានផែនការសម្លាប់ព្រះសង្ឃទេ ។

អង្គការបានបែងចែកប្រជាជនជាពីរប្រភេទគឺ "ប្រជាជនថ្មី" និង "ប្រជាជនមូលដ្ឋាន" ឬ "ប្រជាជនចាស់" ។ ប្រជាជនចាស់គឺអ្នកដែលបានរស់នៅយ៉ាងតិចបួនឬប្រាំឆ្នាំនៅក្នុងតំបន់ដែលគ្រប់គ្រងដោយបក្សកុម្មុយនិស្តកម្ពុជា ។

## ៤) ការកសាងសង្គមនិយមដោយបក្សកុម្មុយនិស្តកម្ពុជា

ឥឡូវនេះ មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាមានអំណាចក្នុងការធ្វើឲ្យគំនិតរបស់ខ្លួនក្លាយជាការពិត ។ បក្សនេះមានសមាជិក ១ម៉ឺន៤ពាន់នាក់ និងមានកងទ័ពចំនួន៦ម៉ឺននាក់ ។ នៅក្នុងខែឧសភា មជ្ឈិមបក្សបានសម្រេចចិត្តកសាងសង្គមនិយមមួយឲ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន ។ នៅក្នុងកិច្ចប្រជុំមួយនៅទីក្រុងភ្នំពេញជាមួយកងទ័ពនិងកម្មាភិបាលស៊ីវិលរាប់ពាន់នាក់មកពីទូទាំងប្រទេស បក្សបានចេញសេចក្តីណែនាំឲ្យរំលាយទីផ្សារ បញ្ឈប់ការចាយវាយក្រដាសប្រាក់ ផ្សឹកព្រះសង្ឃ សម្លាប់មេដឹកនាំរបបលន់ណុលទាំងអស់ បង្កើតសហករណ៍កម្រិតខ្ពស់ បណ្តេញប្រជាជនវៀតណាមចេញពីប្រទេស និងបញ្ជូនកងទ័ពទៅតំបន់ព្រំដែន ជាពិសេសព្រំដែនវៀតណាម ។ ជនបង្កប់ផ្ទៃក្នុងត្រូវបានស្វែងរកនៅក្នុងចំណោមកម្មាភិបាលនិងប្រជាជន ។ ឯកសារមួយរបស់បក្សបានពន្យល់ថា ត្រូវតែបំបាត់ការចាយវាយលុយកាក់ ព្រោះលុយអាចនាំឲ្យមានកម្មសិទ្ធិឯកជននិងអំពើពុករលួយ "ហើយនៅក្នុងរយៈពេលមួយឆ្នាំ ដប់ឆ្នាំ ម្ភៃឆ្នាំ សង្គមកម្ពុជាដ៏បរិសុទ្ធមួយនេះនឹងក្លាយទៅជាវៀតណាម" ។

មេដឹកនាំទាំងអស់នៅក្នុងបក្សមានគំនិតមិនស្របគ្នាទេ ។ អ្នកខ្លះគាំទ្រឲ្យមានលុយ សាលារៀន និងសាសនា ។ អ្នកខ្លះមិនយល់ស្របនឹងនយោបាយប្រហារជីវិត ប៉ុន្តែចង់ឲ្យមានការកសាងខ្លួន ដើម្បីអាចក្លាយជាមនុស្សមានប្រយោជន៍វិញ ។ ហ៊ូ យន់ គឺជាអ្នកដែលប្រឆាំងយ៉ាងខ្លាំងក្លាបំផុតចំពោះការជម្លៀសប្រជាជន ។ មិនយូរប៉ុន្មាន គាត់ត្រូវបានបាញ់សម្លាប់ ហើយសាកសពរបស់គាត់ត្រូវបានបោះចោលទៅក្នុងទន្លេមេគង្គ ។

### ក) បដិវត្តន៍ខ្មែរដ៏បរិសុទ្ធ

ផ្នែកមួយនៃបេសកកម្មរបស់បក្សកុម្មុយនិស្តកម្ពុជាគឺ ធានាឲ្យបាននូវភាពគង់វង្សនៃជាតិសាសន៍ខ្មែរ ។ ដើម្បីសម្រេចឲ្យបាននូវគោលដៅនេះ មេដឹកនាំបក្សកុម្មុយនិស្តមានទស្សនៈមួយចាត់ទុកពូជសាសន៍ខ្មែរជាពូជសាសន៍ឧត្តុង្គឧត្តមនិងបរិសុទ្ធ ហើយជនជាតិភាគតិចគឺជាការគំរាមកំហែងដល់សុខភាពនិងឧត្តមភាពនៃជាតិខ្មែរ ។ មេដឹកនាំទាំងនេះបានចេញក្រឹត្យមួយដែលនិយាយថា "នៅកម្ពុជាមានជនជាតិតែមួយ ភាសាមានតែមួយគឺភាសាខ្មែរ ។ ចាប់ពីពេលនេះតទៅ លែងមានជនជាតិផ្សេងៗ...នៅលើទឹកដីកម្ពុជាទៀតហើយ" ។

ជនជាតិវៀតណាមស្ទើរតែទាំងអស់ត្រូវបាននិរទេសចេញពីប្រទេសនៅឆ្នាំ១៩៧៥ ។ ក្នុងអំឡុងពេលតែមួយសប្តាហ៍ដំបូងនៃការដណ្តើមយកបានទីក្រុងភ្នំពេញ បក្សកុម្មុយនិស្តកម្ពុជាបានវាយប្រហារទៅលើជនជាតិថៃដែលបះបោរនៅខេត្តកោះកុង ។ ប្រជាជនទាំងនោះប្រមាណ៥ពាន់នាក់បានភៀសខ្លួនទៅប្រទេសថៃ ។ ក្នុងភូមិពីរនៅខេត្តកំពង់ចាម ជនជាតិចាមបាននាំគ្នាបះបោរប្រឆាំងនៅពេលដែលអាជ្ញាធរបានហាមឃាត់ការគោរពបូជាសាសនានិងហាមឃាត់ការនិយាយភាសាចាម បង្ខំជនជាតិចាមឲ្យបរិភោគសាច់ជ្រូក និងបំបែកសហគមន៍ចាម ។ ការបះបោរនេះត្រូវបានបំបែក ។ ក្រុមគ្រួសារជាច្រើនត្រូវបានបញ្ជូនទៅកន្លែងផ្សេងៗតាមរយៈទូកនិងរថយន្ត ភាគច្រើនត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ ។ ខ្លះត្រូវបានបញ្ជូនទៅភូមិភាគឧត្តរ ដែលនៅទីនោះជនជាតិចាមរាប់រយនាក់ត្រូវបានប្រហារជីវិត ។ ជនជាតិចាមនិងខ្មែររាប់រយនាក់ត្រូវបាននាំយកទៅចម្ការកៅស៊ូ ដើម្បីសម្លាប់និងកប់នៅក្នុងរណ្តៅដែលជីករួចជាស្រេច ។ បន្ទាប់

ពីឆ្នាំ១៩៧០ ជនជាតិចិនស្ទើរតែទាំងអស់បានភៀសខ្លួនទៅទីក្រុងភ្នំពេញ ។ នៅពេលនោះទីក្រុងភ្នំពេញមានជនជាតិចិនដ៏ច្រើនសន្ធឹកសន្ធាប់ ។ នៅពេលដែលខ្មែរក្រហមចូលកាន់អំណាច ជនជាតិចិនទាំងនោះត្រូវបានជម្លៀសចេញទៅជនបទ ហើយឲ្យរស់នៅជាយភូមិ មិនឲ្យនៅលាយឡំជាមួយប្រជាជនទូទៅទេ ។ ការនិយាយភាសាចិនឬការបង្ហាញនូវការគោរពវប្បធម៌ចិន ត្រូវទទួលទណ្ឌកម្ម កន្លែងខ្លះរហូតដល់ស្លាប់ក៏មាន ។ ដូច្នេះដើម្បីរស់ ជនជាតិចិនត្រូវព្យាយាមបង្ហាញឲ្យឃើញថាខ្លួនចង់ក្លាយជាជនជាតិខ្មែរយ៉ាងពិតប្រាកដ ។ ជនជាតិសានចំនួន២ពាន់នាក់នៅតាមព្រំដែនថៃត្រូវបានបង្ខំឲ្យចាកចេញដោយមិនមានបន្សល់ទុកស្លាកស្នាម ។ ជនជាតិស្ទូចដែលជាសហគមន៍តូចមួយនៅភាគខាងលិចកម្ពុជាត្រូវបានជម្លៀសទៅតំបន់ព្រៃស្រោង ។ ជនជាតិអារ៉ាប់ ប៉ាគីស្ថាន និងឥណ្ឌា ចំនួន៩៧នាក់នៅភាគខាងត្បូងខេត្តកណ្តាល ត្រូវបានបញ្ជូនទៅឃុំឃាំងរហូតដល់ស្លាប់នៅទីក្រុងភ្នំពេញ ។ បក្សកុម្មុយនិស្តកម្ពុជាបានបង្ក្រាបជនមួយចំនួនធំដែលមាន “ក្បាលយួនខ្លួនខ្មែរ” ។ ខ្មែរក្រោមខ្លះដែលលួចឆ្លងព្រំដែននៅខែកុម្ភៈឆ្នាំ១៩៧៦ ដើម្បីស្នើសុំចូលរួមតស៊ូដើម្បីរំដោះកម្ពុជាក្រោមពីវៀតណាម ត្រូវបានចាប់ខ្លួននិងបាញ់សម្លាប់ចោល ។

## ខ) ការប្រយុទ្ធដើម្បីស្រូវ

សន្និសីទមួយនៅឆ្នាំ១៩៧៥អំពីសេដ្ឋកិច្ច បានពិភាក្សាអំពីគោលបំណងរបស់បក្សក្នុងការផលិតស្រូវឲ្យបានបីតោនក្នុងមួយហិកតា ។ មេដឹកនាំបក្សនិយាយថា ប្រសិនបើតស៊ូស្វាហាប់ កម្ពុជានឹងអាចសម្រេចគោលបំណងនេះនៅក្នុងឆ្នាំ១៩៧៦ ។ ការចល័តប្រជាជនថ្មីគឺជាផ្នែកមួយនៃផែនការសេដ្ឋកិច្ច ។ ឯកសារសម្ងាត់មួយរបស់មជ្ឈិមបក្សពីខែកញ្ញាឆ្នាំ១៩៧៥ បាននិយាយថា “យើងត្រូវតែបែងចែកប្រជាជនទៅតាមតម្រូវការផលិតកម្ម ...ភូមិភាគពាយ័ព្យត្រូវការកម្លាំងបន្ថែមចំនួន៥សែននាក់ ។ ខេត្តព្រះវិហារបានស្នើសុំចំនួន៥ម៉ឺននាក់... ជាដំបូងយើងផ្តល់ឲ្យ២ម៉ឺននាក់សិន” ។ ពីខែកញ្ញាដល់វិច្ឆិកា ប្រជាជនថ្មីត្រូវជម្លៀសម្តងទៀតពីភូមិភាគនិរតីជាកន្លែងដែលតាម៉ុកត្អូញត្អែរថាមានប្រជាជនច្រើនពេក ទៅតំបន់ផ្សេងទៀត ភាគច្រើនទៅភូមិភាគពាយ័ព្យ “ជាកន្លែងលេខមួយខាងផលិត” ។ ចំនួនប្រជាជននៃភូមិភាគនេះត្រូវបានបង្កើនពី៩សែន៨ពាន់នាក់នៅឆ្នាំ១៩៦៨ ទៅដល់១,៧៩លាននាក់នៅឆ្នាំ១៩៧៧ ។ មេដឹកនាំភូមិភាគបានជំទាស់នឹងផែនការនេះ ដោយសារតែភូមិភាគមិនអាចផ្គត់ផ្គង់ប្រជាជនបានទេ ព្រោះជារៀងរាល់ឆ្នាំភូមិភាគតែងតែខ្វះខាតស្រូវ ។

## គ) រដ្ឋរបស់បក្សកុម្មុយនិស្តកម្ពុជា

បក្សកុម្មុយនិស្តកម្ពុជាបានបែងចែកប្រទេសកម្ពុជាជា៧ភូមិភាគ ហើយនៅក្នុងភូមិភាគត្រូវបានបែងចែកបន្តទៅជាតំបន់និងស្រុក ។ នៅខែមករា ឆ្នាំ១៩៧៦ បក្សកុម្មុយនិស្តកម្ពុជាបានប្រកាសឲ្យប្រើប្រាស់រដ្ឋធម្មនុញ្ញ និងរៀបចំការបោះឆ្នោត ។ ព្រះបាទ នរោត្តម សីហនុ បានលាលែងពីតំណែងជាប្រមុខរដ្ឋ ។ រដ្ឋាភិបាលមួយត្រូវបានបង្កើតឡើងដោយមាន ប៉ុល ពត ជានាយករដ្ឋមន្ត្រី ។ នេះជាលើកទីមួយដែល សាឡុត ស ប្រើឈ្មោះជា ប៉ុល ពត ។

គណៈកម្មាធិការមជ្ឈិមបានប្រកាសថាៈ “នេះជារដ្ឋផ្ទាល់ខ្លួនរបស់យើង” “រដ្ឋដែលបក្សជាអ្នកកាន់អំណាចផ្តាច់មុខនៅគ្រប់ផ្នែកទាំងអស់” ។ គ្មានច្បាប់និងគ្មានភ្នាក់ងាររដ្ឋទេ គឺមានតែបក្សកុម្មុយនិស្តកម្ពុជាប៉ុណ្ណោះ ។

អារម្ភកថារបស់លក្ខន្តិកៈបក្សបានសរសេរថា “អំណាចបក្សត្រូវបានរៀបចំពីលើចុះក្រោម ដោយយោងទៅលើគោលការណ៍មជ្ឈការប្រជាធិបតេយ្យ ។ អំណាចភាគច្រើនគឺស្ថិតនៅលើគណៈកម្មាធិការបក្សប្រចាំភូមិភាគ ។ មាត្រា១៩បានអនុញ្ញាតឲ្យគណៈកម្មាធិការតំបន់ “តាមដានយ៉ាងជិតដល់នូវសកម្មភាពរបស់តំបន់ ស្រុក និងមន្ទីរឃុំឃាំង និងសកម្មភាពរបស់សមាជិកបក្សនៅក្នុងសហជីព សហករណ៍ និងកងកម្លាំងបដិវត្តនៅក្នុងភូមិភាគរបស់ខ្លួននិងត្រួតពិនិត្យការងាររបស់អ្នកទាំងនេះ” ។ គណៈកម្មាធិការទាំងអស់ក៏ត្រូវគ្រប់គ្រងគោលនយោបាយមនោគមវិជ្ជានិងរៀបចំនិងពិនិត្យពិច័យប្រវត្តិរូបរបស់ប្រជាជន ។ គណៈកម្មាធិការតំបន់ត្រូវរាយការណ៍ជូនគណៈកម្មាធិការមជ្ឈិម ។ មជ្ឈិមដាក់បញ្ជាទៅភូមិភាគ ហើយលេខាភូមិភាគជាអ្នកសរសេរលិខិតទៅកាន់ប៉ុលពតដើម្បីស្នើសុំការណែនាំដើម្បីដាក់ឲ្យថ្នាក់តំបន់និងថ្នាក់ស្រុកអនុវត្ត ។ កម្មាភិបាលគ្រប់គ្រង

តំបន់និងភូមិភាគ តែងតែឡើងមកទីក្រុងភ្នំពេញដើម្បីចូលរួមកិច្ចប្រជុំដែលធ្វើឡើងជាទៀងទាត់ និងដើម្បីពិគ្រោះយោបល់ជាមួយ ប៉ុល ពត និង នួន ជា ។ យូរៗម្តងលេខាតំបន់បានចូលរួមកិច្ចប្រជុំរៀនសូត្រដែលរៀបចំដោយមជ្ឈិម ហើយនៅពេលត្រឡប់ទៅវិញ លេខាតំបន់រៀបចំកិច្ចប្រជុំដើម្បីផ្ទេរការណែនាំរបស់មជ្ឈិមបក្សទៅឲ្យកម្មាភិបាលនៅមូលដ្ឋាន ។ លេខាតំបន់ចូលរួមកិច្ចប្រជុំនៅថ្នាក់ភូមិភាគដើម្បីទទួលយកផែនការ បន្ទាប់មកកោះហៅលេខាស្រុកមកប្រជុំដើម្បីផ្ទេរការណែនាំទាំងនេះ ។ ជាញឹកញាប់មេដឹកនាំភូមិភាគបើកអង្គប្រជុំជាមួយកម្មាភិបាលនៅថ្នាក់ស្រុក ។ មេដឹកនាំភូមិភាគតែងតែបញ្ជូនលិខិតទៅថ្នាក់ស្រុកនិងថ្នាក់មូលដ្ឋាន ហើយបានធ្វើទស្សនកិច្ចតាមស្រុកដើម្បីផ្តល់ការណែនាំទៅឲ្យគណៈកម្មាធិការបក្ស ។

ជូនកាលថ្នាក់ស្រុកទទួលឯកសារគោលនយោបាយពីថ្នាក់មជ្ឈិម ។ លេខាស្រុកធ្វើដំណើរមកក្រុងភ្នំពេញពីរដងក្នុងមួយឆ្នាំ ដើម្បីចូលរួមសន្និសីទបក្ស ។ ប៉ុល ពត, នួន ជា និងមេដឹកនាំដទៃទៀតជាអ្នកបង្រៀននៅក្នុងសន្និសីទទាំងនោះ ។ យ៉ាងហោចណាស់មួយដងក្នុងមួយឆ្នាំ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ បើកការពិភាក្សានិងស្តាប់សេចក្តីរាយការណ៍នៅក្នុងសន្និសីទថ្នាក់ភូមិភាគដែលចូលរួមដោយកម្មាភិបាលជាន់ខ្ពស់រហូតដល់ថ្នាក់ស្រុក ។

គណៈកម្មាធិការមជ្ឈិមបានកំណត់របៀបធ្វើរបាយការណ៍ប្រចាំសប្តាហ៍ទៅឲ្យមជ្ឈិមបក្សអំពីយុទ្ធនាការ«៣គោន» ។ កម្មាភិបាលនៅក្នុងសហករណ៍និងគណៈកម្មាធិការគ្រប់គ្រងខស្សាហកម្មចាំបាច់ត្រូវតែសរសេររបាយការណ៍អំពីរាល់បញ្ហាទាំងអស់តាំងពីឈ្មោះនិងអាយុរបស់សមាជិក ចំនួនកើតនិងស្លាប់ ចំនួនផលិត ចំនួនរបស់ដែលស្តុកទុករាប់តាំងពីខ្មៅដៃរហូតដល់ចបជីក ។ **(នៅមានត)** **ម៉ូង សាន់យ៉ឺស**

## វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរនឹងរៀបចំកម្មវិធី «វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» លើកទី២ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៤ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៥ ។ កម្មវិធីនេះសូមអំពាវនាវដល់សិស្ស និស្សិត និងប្រជាជនកម្ពុជាដែលរស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងរស់នៅទាំងក្នុងនិងក្រៅប្រទេសឲ្យសរសេរអត្ថបទស្តីអំពីរឿងរ៉ាវរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព័ត៌មានទាំងឡាយស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យដែលលោកអ្នកបានដឹងឮនិងទស្សនៈផ្ទាល់ខ្លួនចំពោះរបបកម្ពុជាប្រជាធិបតេយ្យដើម្បីរួមចំណែកចងក្រងប្រវត្តិសាស្ត្រនៃរបបនេះឲ្យកាន់តែពិស្តារ ។

វេទិកានេះមានគោលបំណងសំខាន់ៗដូចតទៅ÷

◆ រួមជាចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់ឲ្យកូនចៅជំនាន់ក្រោយបានដឹងនិងសិក្សារៀនសូត្រ ។

◆ ជាវិធីមួយដើម្បីរំសាយអារម្មណ៍ដោយយកហេតុការណ៍ សេចក្តីទុក្ខការឈឺចាប់មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។

◆ ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។

◆ ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមនិងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរនឹងមានកិត្តិយសចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តីស្វែងការរកការពិត ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរបន្ថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ លោកអ្នកអាចផ្ញើអត្ថបទមកសមាគមអ្នកនិពន្ធខ្មែរដែលមានទីស្នាក់ការនៅវត្តបទុមវតី ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬតាមរយៈអ៊ីមែលៈ dccam@online.com.kh ។

សូមទាក់ទងព័ត៌មានបន្ថែមតាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬ ០១២ ៨៨៣ ០៧២ ។ សូមអរគុណ ។

# របៀបចងក្រងប្រវត្តិសាស្ត្រ ដើម្បីការពិត ការទទួលខុសត្រូវ និងការផ្សះផ្សាជាតិ

ជោគជ័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺមិនត្រឹមតែអាស្រ័យលើប្រសិទ្ធភាពនៃការដឹកនាំនិងស្ថាប័នប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាស្រ័យលើភាពមិនលម្អៀងនៃគោលការណ៍ទូទៅនិងវិធីអនុវត្តការងារនីមួយៗទៀតផង ។

## ស្ថាប័នឯករាជ្យ

នៅឆ្នាំ១៩៩៥ ខណៈពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាចាប់ផ្តើមដំណើរការជាអង្គការក្រៅរដ្ឋាភិបាលចងក្រងឯកសារខ្មែរក្រហម យើងបានដឹងថាដំណាក់កាលនោះ ការងារទាក់ទងខ្មែរក្រហមជាបញ្ហារសើបឬងាយប្រេះស្រាំបំផុតដោយហេតុថារដ្ឋាភិបាលចម្រុះនៅក្មេងខ្ចី ហើយខ្មែរក្រហមនៅតែមានសកម្មភាពនៅជាយដែនជាប់ប្រទេសថៃ ។ ក្នុងប្រទេសយើងធ្វើការជាមួយសារមន្ទីរទួលស្លែង បណ្ណសារដ្ឋានជាតិ និងអង្គការក្នុងស្រុកមួយចំនួនដូចជា លីកាដូ មជ្ឈមណ្ឌលពត៌មានស្ត្រី សមាគមអ្នកនិពន្ធខ្មែរ វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យជាដើម ។ ក្រៅប្រទេសយើងធ្វើការជាមួយប្រទេសជាច្រើនដើម្បីធានាឲ្យបាននូវការដឹកនាំមួយដែលឯករាជ្យ ។ ការផ្តេកផ្តួលឬរំពឹងថវិកា ឬពត៌មានលើស្ថាប័ននយោបាយមួយ រដ្ឋាភិបាលមួយ ឬអង្គការក្រៅរដ្ឋាភិបាលតែមួយ នាំឲ្យយើងកំណត់ខ្លួនឯងមិនបាន និងធ្វើការបានតែលើបញ្ហាតែមួយជ្រុង ។ ឧទាហរណ៍ បើយើងធ្វើការតែជាមួយអ្នកគាំទ្រតុលាការខ្មែរក្រហម យើងមិនអាចទទួលបាននូវប្រវត្តិសាស្ត្រនិងទស្សនៈគ្រប់ជ្រុងជ្រោយឡើយ ។

## វិធីសាស្ត្រមិនសម្អៀង

ក្នុងការសាកសួរពត៌មាននៅតាមស្រុកភូមិឬក្នុងការចុះផ្សាយផ្សេងៗ យើងដើរលើផ្លូវមិនលម្អៀង ជាក់ស្តែង និងប្រកបដោយតម្លាភាព ។ យើងបើកចំហឯកសារដល់សាធារណជន (ដោយមិនរើសអើង) ហើយយើងនិយាយតែអំពីអ្វីដែលឯកសារមាន មិនលើសមិនខ្វះ ដើម្បីចៀសវាងការប្រកាន់បក្សឬនយោបាយ ។ យើងធ្វើការក្នុងនាមជាអ្នកចងក្រងឯកសារ មិនមែនជាជំនាញការអ្នកប្រវត្តិសាស្ត្រឬអ្នកច្បាប់ឡើយ ។ យើងធ្វើអ្វីដែលយើងអាចធ្វើបាន ដោយកំណត់គោលដៅច្បាស់លាស់និងជាក់ស្តែង ។ រាល់សកម្មភាពការងាររបស់យើងត្រូវបានផ្សព្វផ្សាយជាសាធារណៈ ។ ទង្វើត្រឹមត្រូវនិងបើកទូលាយមិនបង្អៀតបង្អល់ ធ្វើឲ្យយើងទទួលបានមកវិញនូវការគោរពនិងទទួលស្គាល់ ។ ឧទាហរណ៍ យើងផ្តល់ឯកសារទៅឲ្យសាច់ញាតិរបស់ជនរងគ្រោះ ហើយយើងក៏ធ្លាប់ផ្តល់ឯកសារដល់ព្រះរាជអាជ្ញាឬមេធាវីក្នុងរឿងក្តីខ្មែរក្រហមដែរ ។ យើងសហការជាមួយក្រសួងអប់រំយុវជននិងកីឡា (ការសិក្សាអំពីសៀវភៅកម្មវិធីថ្នាក់ទុតិយភូមិ) ក្រសួងទេសចរណ៍ (សិក្សាតំបន់អន្លង់វែង) ក្រសួងវប្បធម៌ (សារមន្ទីរទួលស្លែង) ។ ជាលទ្ធផល យើងទទួលបានការគាំទ្រពីគ្រប់មជ្ឈដ្ឋានតាំងពីព្រះមហាក្សត្ររហូតដល់កសិករ តាមរយៈលិខិតនានា ការចុះផ្សាយ តាមប្រព័ន្ធឃោសនា និងការជួយផ្តល់ពត៌មាននិងប្រគល់ឯកសារមកដល់យើងឲ្យរក្សាទុកនិងផ្សព្វផ្សាយ ។

## ចាត់ទុកថាមនុស្សដូចគ្នាៈ ទាំងជនរងគ្រោះ ទាំងជនដៃដល់

អ្នកដែលនៅរស់ពីរបបខ្មែរក្រហមមានទាំងអតីតប្រជាជនធម្មតានិងអតីតកម្មាភិបាលខ្មែរក្រហម ។ ដើម្បីចងក្រងឲ្យបានគ្រប់សព្វ យើងត្រូវតែស្រង់យកពត៌មានឬហេតុការណ៍ពីមនុស្សគ្រប់គ្នាដោយមិនរំលងចោលនិងមិនលម្អៀង ។ នៅរាល់ការស្រាវជ្រាវរបស់យើង យើងត្រូវតែរំឭកខ្លួនឯងថាមនុស្សមិនទាន់បានកាត់ទោសគឺមិនមានទោស ហើយយើងមិនធ្វើការដោយយកមកដាក់ពីមុខនូវគំនិតរើសអើងនិងកំហឹងឡើយ ព្រោះថាតួនាទីរបស់យើងមិនចុះទៅកាត់ទោសជនណានោះទេ ប៉ុន្តែដើម្បី

ចង់ក្រងឲ្យបាននូវរាល់ព្រឹត្តិការណ៍និងប្រវត្តិសាស្ត្រនៃសង្គមជាតិទាំងមូល ។ យើងចាត់ទុកថាមនុស្សដូចគ្នា ទាំងជនរងគ្រោះ ទាំងជនដៃដល់ ។

ផ្អែកលើគោលការណ៍ខាងលើនេះ យើងបាននិងកំពុងឈានទៅរកការពិតនៃប្រវត្តិសាស្ត្រ ជំរុញឲ្យមានការទទួលខុសត្រូវចំពោះមុខច្បាប់និងការផ្សះផ្សាជាតិតាមរយៈវិធីសាស្ត្របីធំៗ គឺការប្រមូលឯកសារដើមនិងចុះលេខ ការចុះយកពត៌មានពីស្រុកភូមិ និងការបោះពុម្ពផ្សាយ ។

## ការប្រមូលឯកសារដើមនិងចុះលេខ

មជ្ឈមណ្ឌលឯកសារកម្ពុជានៅតែបន្តប្រមូលឯកសារដើមពីប្រភពនានាដូចជាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ក្រសួងមហាផ្ទៃ អ្នកស្រាវជ្រាវប្រវត្តិសាស្ត្រខ្មែរក្រហមទាំងក្នុងនិងក្រៅប្រទេស និងប្រជាជននៅតាមជនបទស្រុកស្រែចម្ការជាដើម ។ រាល់ឯកសារដែលយើងប្រមូលបាន យើងបានចុះលេខ ធ្វើបញ្ជីឯកសារ និងរក្សាទុកយ៉ាងប្រយ័ត្នប្រយែង ។ ឯកសារទាំងនេះនឹងក្លាយជាប្រភពដ៏មានសារសំខាន់សម្រាប់និស្សិត អ្នកសិក្សាស្រាវជ្រាវ និងជាពិសេសតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនឹងមកដល់ក្នុងពេលឆាប់ៗខាងមុខនេះ ។

## ឯកសារដើមនាំផ្លូវយើងទៅជួបអតីតខ្មែរក្រហម

វិធីមួយយ៉ាងមានប្រសិទ្ធភាពក្នុងការជួបអតីតកម្មាភិបាលខ្មែរក្រហមគឺតាមរយៈឯកសារដើមរបស់កម្មាភិបាលទាំងនោះ ។ ក្នុងចំណោមឯកសារទាំងអស់ ប្រវត្តិរូបនិងចម្លើយសារភាពមានប្រយោជន៍ខ្លាំងបំផុត ដោយសារមានពត៌មានអំពីសាមីខ្លួននិងទីកន្លែងកំណើត ។ ទោះបីជាទូទៅ អតីតកម្មាភិបាលសហការនិងនិយាយរឿងរ៉ាវប្រាប់យើងក៏ដោយ ក៏យើងមិនប្រាកដថាធ្វើការបានលទ្ធផលក្នុងកម្រិតដូចសព្វថ្ងៃបានទេ ប្រសិនបើគ្មានប្រវត្តិរូប ។

យើងបានសម្ភាសន៍អតីតកម្មាភិបាលចំនួន ៥០០នាក់ និងជនរងគ្រោះចំនួន២០០នាក់ ។ ប្រធានបទដែលយើងបានសិក្សាមានកុមារ ប្រព័ន្ធសន្តិសុខ យោធា ជនជាតិភាគតិច រណ្តៅសាកសព ។ ក្នុងការសិក្សានេះ យើងតែងតែសំយោគយកពត៌មានពីការសម្ភាសន៍ជាមួយកម្មាភិបាល ប្រជាជន ឬជនរងគ្រោះ ។ មនុស្សទាំងអស់រួមទាំងជនដៃដល់មានសិទ្ធិក្នុងការបញ្ចេញមតិ ហើយការនិយាយចេញមកក្រៅជាឱកាសសំខាន់ដែលជនរងគ្រោះបានរសាយនិងបានដឹងថាមានអ្នករួមសុខទុក្ខ មានអ្នកស្តាប់និងអ្នកឈឺឆ្អាល ព្រមទាំងយកចិត្តទុកដាក់ចំពោះទុក្ខវេទនាកន្លងមករបស់គាត់ ។ ទន្ទឹមនឹងនេះដែរ គាត់អាចដឹងឮសុខទុក្ខរបស់ជនរងគ្រោះផ្សេងទៀតតាមរយៈការសំណេះសំណាលផ្ទាល់ឬការចុះផ្សាយទស្សនាវដ្តី វិទ្យុ សៀវភៅ និងកាសែត ។

## ការផ្សព្វផ្សាយតាមការជួបផ្ទាល់ ទស្សនាវដ្តី វិទ្យុ សៀវភៅ កាសែត និងអ៊ីនធឺណែត

តាមរយៈការផ្សព្វផ្សាយ អ្នកដែលនៅរស់ពីរបបខ្មែរក្រហមអាចដឹងបាននូវហេតុការណ៍ដូចគ្នានិងខុសគ្នាដែលកើតមានចំពោះខ្លួនឯង ចំពោះអ្នកដទៃ និងចំពោះអ្នកស្រុក ឬនៅតំបន់ផ្សេងៗ ។ ដូចនេះយើងអាចដឹងហេតុការណ៍ឬការពិតកាន់តែច្រើន ។ លោកសួន រិទ្ធិ មេឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល មិនដែលជឿលើពត៌មាននៅលើសារពត៌មានណាមួយទេពីមុនមក ។ ក្រោយពីបានអានទស្សនាវដ្តីស្វែងរកការពិតរបស់យើងដែលសរសេរអំពីអ្នកភូមិរបស់គាត់ គាត់ក៏ចាត់ទុករឿងនេះថាត្រឹមត្រូវប្រាកដមែន ។ គាត់បានប្រាប់អ្នកភូមិគាត់ថា ឥឡូវនេះមានទស្សនាវដ្តីដែលនិយាយអំពីការពិតហើយ ។ អ្នកភូមិទ្រាបោះបង់ចោលនូវគំនិតដែលថា រាល់ពត៌មានកាសែតសុទ្ធតែការបោកប្រាស់ឬភូតភរ ។ ជីវភាពរស់នៅមួយដែលបានចេះដឹងច្រើន ហើយមិនមានគំនិតលម្អៀង ជាមូលដ្ឋាននៃការផ្សះផ្សាជាតិឆ្ពោះទៅរកសង្គមមួយដែលសន្តិភាពនិងប្រជាធិបតេយ្យ ។

អ្នកស្រុកភូមិបានស្តាប់ការផ្សាយវិទ្យុរបស់យើង ហើយការណ៍នេះមានប្រយោជន៍នៅពេលដែលក្រុមការងាររបស់យើងចុះទៅធ្វើការនៅទីនោះ ។ សៀវភៅនិងទស្សនាវដ្តីរបស់យើងក៏មានប្រយោជន៍ក្នុងលំនាំនេះដែរ ។ ពេលដែលអ្នកស្រុកអ្នកភូមិឃើញថាយើងយកចិត្តទុកដាក់ចំពោះគាត់ យើងបានទទួលពត៌មានឬសាច់រឿងរបស់គាត់ ហើយយើងបានយកទៅឲ្យគាត់វិញជាសៀវភៅឬជាទស្សនាវដ្តី ដែលរួមមានទាំងសាច់រឿងរបស់អ្នក

ផ្សេងទៀតដែលគាត់មិនបានដឹងកន្លងមក ។ ជាថ្មីម្តងទៀត អ្នកភូមិអាចដឹងថា មាននណារខ្លះជួបប្រទះរឿងដូចគាត់ ឬខុសពីគាត់ ព្រមទាំងដឹងព្រឹត្តិការណ៍និងព័ត៌មានផ្សេងទៀត ។

នៅក្រៅប្រទេសក៏បានដឹងពុទ្ធិនិងទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈព័ត៌មានដែលយើងបានផ្សាយតាមប្រព័ន្ធអ៊ីនធឺណែត ។

**លទ្ធផល**

សរុបមក យើងបានផ្សព្វផ្សាយការងាររបស់យើងយ៉ាងទូលំទូលាយទាំងក្នុងនិងក្រៅប្រទេស ។ ការងារនិងបទពិសោធន៍ដែលបុគ្គលិកម្នាក់ៗបានជួបប្រទះផ្ទាល់ដូចបានរៀបរាប់ខាងលើនេះស្របទៅនឹងការស្ទង់មតិប្រជាជនចំនួនជាង៧០០នាក់ ។ ទាំងការងារផ្ទាល់ ទាំងការស្ទង់មតិ សុទ្ធតែបានបញ្ជាក់អំពីសារសំខាន់ជាចម្បងនៃបណ្តាសកម្មភាពការងារខាងលើរបស់យើង ។ ឧទាហរណ៍ដូចជាការផ្សះផ្សាជាតិត្រូវបានរកឃើញថាត្រូវដំណើរការយូរអង្វែងម្តងម្នាក់ៗឬមួយភូមិម្តងនៅមូលដ្ឋាន តាមរយៈអ្នកស្រុកភូមិផ្ទាល់ ។ អ្នកស្រុក ជនរងគ្រោះឬអ្នកដែលចាត់ទុកថាខ្លួនជាជនរងគ្រោះ បាននិយាយចេញនូវទស្សនៈនិងអ្វីដែលគាត់បានជួបប្រទះ ។ គាត់មានអ្នកស្តាប់រឿងទុក្ខលំបាករបស់គាត់ ។ គាត់បានដឹងពីទុក្ខអ្នកស្រុកឬជនរួមជាតិដទៃទៀត ។ គាត់បានដឹងកាន់តែច្រើនអំពីអ្នកបង្កឲ្យមានទុក្ខវេទនា និងអ្នកទទួលទុក្ខវេទនា ។ ក្រៅពីនេះមានលិខិតនិងសំណើសួររកព័ត៌មានសាច់ញាតិដែលបាត់ខ្លួនដែលយើងរកឃើញជាបន្តបន្ទាប់ មានលិខិតថ្លែងអំណរគុណ លិខិតគាំទ្រនិងសរសើរជាដើម ។

ការងាររបស់យើងបានបង្ហាញពីសារសំខាន់ក្នុងក្របខ័ណ្ឌជាតិនិងអន្តរជាតិ ។ ចាប់តាំងពីមជ្ឈមណ្ឌលឯកសារកម្ពុជាដំណើរការមក យើងឃើញមានការជឿនលឿនទៅមុខជាច្រើន ដូចជាលិខិតរបស់សហនាយករដ្ឋមន្ត្រីទាំងពីរក្នុងឆ្នាំ១៩៩៧ ស្នើអង្គការសហប្រជាជាតិឲ្យគាំទ្រដំណើរកាត់ទោសខ្មែរក្រហម ការពិនិត្យនិងវាយតម្លៃខ្ពស់ចំពោះឯកសារដែលតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ការចរចាររវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាការចូលរួមឲ្យយោបល់ដល់សភាជាតិក្នុងការរៀបចំច្បាប់កាត់ទោសខ្មែរក្រហម ព័ត៌មានចុះផ្សាយអំពីបញ្ហាខ្មែរក្រហមនិងការងាររបស់យើងស្ទើររាល់ថ្ងៃការសហការជាមួយរដ្ឋាភិបាលក្នុងគម្រោងអភិវឌ្ឍន៍ទេសចរណ៍តំបន់អន្លង់វែង ការសហការ និងផ្តល់ជាបទពិសោធន៍គំរូដល់បណ្តាប្រទេសនានានៅអាស៊ី អឺរ៉ុប និងមជ្ឈិមបូព៌ា ។

**សឹម សុរិយា**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ÷

◆ វិទ្យុ FM១០២MHz របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជា រៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧ៈ៣០-៧ៈ៤៥ល្ងាច ។

◆ វិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧-៧ៈ៣០ព្រឹក និងម៉ោង៧ៈ០០-៧ៈ៣០ល្ងាច ។

◆ វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង៧ៈ០០-៧ៈ៣០ព្រឹក និងម៉ោង៦ៈ៣០-៧ៈ០០ល្ងាច ។

◆ វិទ្យុ FM១០៣.២៥MHz ខេត្តបាត់ដំបង រៀងរាល់ថ្ងៃនៅម៉ោង៩ៈ០០-៩ៈ៣០ព្រឹក និងម៉ោង៣ៈ០០-៣ៈ៣០រសៀល ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើងនិងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **សុ ហ្វារីណា និង លី សុផល**

# ការបង្កើតការទទួលខុសត្រូវសម្រាប់មេដឹកនាំខ្មែរក្រហម ចំពោះបទឧក្រិដ្ឋកម្មអន្តរជាតិ

*(តពីលេខមុន)*

***ខ-១) ការស្វែងរកដំលំបាកនូវការព្រមព្រៀងគ្នាមួយដើម្បីបង្កើតសាលាក្តីចម្រុះកម្ពុជាដោយមានការចូលរួមពីអន្តរជាតិ***

ជម្រើសដ៏សាមញ្ញបំផុតសម្រាប់រដ្ឋាភិបាលកម្ពុជានិងកាតព្វកិច្ចរបស់កម្ពុជានៅក្រោមច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិនឹងផ្តល់យុត្តាធិការឲ្យសាលាក្តីដែលមានស្រាប់ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មអន្តរជាតិទាំងអស់ដែលប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជា ដោយមិនគិតអំពីពេលវេលាដែលឧក្រិដ្ឋកម្មនោះត្រូវបានប្រព្រឹត្តឡើង និងស្របទៅតាមខ្សែបន្ទាត់ច្បាប់ប៉ែលហ្វ៊ិកដែលបានអនុម័តនៅក្នុងឆ្នាំ១៩៩៩ ។ ទោះជាយ៉ាងណាក៏ដោយ បើពិនិត្យមើលភាពទន់ខ្សោយនៃប្រព័ន្ធច្បាប់កម្ពុជា ប្រទេសនេះមិនត្រឹមតែត្រូវការភាពស្របច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវការជំនួយពីខាងក្រៅលើផ្នែកតុលាការដែលភ្ជាប់មកជាមួយនូវការចូលរួមពីអន្តរជាតិ ។ ដោយប្រឈមមុខទៅនឹងភាពរឹងត្អឹងរបស់សម្តេច ហ៊ុន សែន អំពីជម្រើសអន្តរជាតិសុទ្ធសាធ អង្គការសហប្រជាជាតិបានស្ថិតនៅក្រោមសម្ពាធដ៏ធ្ងន់ឲ្យទទួលយកការសម្រុះសម្រួលគ្នាមួយដែលធានាឲ្យមានការជំនុំជម្រះគោរពទៅតាមដំណើរការដ៏សមស្រប ។ ដូច្នេះហើយ ភាគីទាំងពីរត្រូវបានតម្រូវឲ្យប្រមើលអំពីដំណោះស្រាយ “ចម្រុះ” ទាក់ទិនទៅនឹងការចូលរួមរបស់អន្តរជាតិនៅក្នុងតុលាការកម្ពុជា ។

ការចរចាទាក់ទងទៅនឹងបញ្ហានេះអូសបន្លាយរហូតដល់ចុងឆ្នាំ២០០០ ។ គោលបំណងគឺរកឲ្យឃើញគំរូមួយដែលជាតុល្យភាពរវាងការអនុវត្តយុត្តិធម៌ឯករាជ្យនិងប្រកបដោយប្រសិទ្ធភាពពិតប្រាកដ និងការគោរពអធិបតេយ្យភាពរបស់កម្ពុជា ។ នៅពីខាងក្រោយឆាក ការតស៊ូដើម្បីគ្រប់គ្រងដំណើរការរបស់តុលាការនេះបានចាប់ផ្តើមទៅហើយ ។ មនុស្សជាច្រើនបានមើលឃើញដោយភ័ន្តច្រឡំថានេះជាការប្រកួតប្រជែងរបស់រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិដើម្បីគ្រប់គ្រងទៅលើដំណើរការតុលាការ ។ ប្រសិនបើដូច្នេះមែន វាជាការចងភ្ជាប់ដែលមិនស្មើភាពគ្នា ព្រោះថាគោលជំហររបស់អង្គការសហប្រជាជាតិដែលចង់គ្រប់គ្រងសាលាក្តីអន្តរជាតិផ្ទុយគ្នាពីគោលជំហររបស់រាជរដ្ឋាភិបាលកម្ពុជា ។ ការចូលរួមរបស់អង្គការសហប្រជាជាតិគឺសំដៅបង្កើតយន្តការមួយដែលការពារការវិនិច្ឆ័យរបស់សាលាក្តីឲ្យផុតពីឥទ្ធិពលពីខាងក្រៅ ។

នៅក្នុងខែសីហា ឆ្នាំ១៩៩៩ ភាគីទាំងពីរបានផ្សព្វផ្សាយសំណើឲ្យធ្វើការរួមគ្នា ក៏ប៉ុន្តែមិនស្រុះស្រួលគ្នា ។ សម្តេច ហ៊ុន សែន បានគាំទ្រឲ្យមានសាលាក្តីជាតិមួយដែលទទួលហិរញ្ញវត្ថុពីខាងក្រៅ និងមានបុគ្គលិកអន្តរជាតិមួយចំនួនតូច ។ អង្គការសហប្រជាជាតិបានទទួលយកការបង្កើតតុលាការនៅក្រោមច្បាប់កម្ពុជា ក៏ប៉ុន្តែស្នើឲ្យយកគំរូតុលាការនូរឹមប៊ឺក គឺជំនុំជម្រះក្តីជនសង្ស័យទាំងអស់រួមគ្នា និងប្រើប្រាស់បុគ្គលិកអន្តរជាតិភាគច្រើន ។ ការចរចារយៈពេលមួយសប្តាហ៍រវាងក្រុមមកពីនាយកដ្ឋានកិច្ចការច្បាប់របស់អង្គការសហប្រជាជាតិនិងប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី សុខ អាន មិនមានលទ្ធផលទេ ។ ប្រធានក្រុមរបស់អង្គការសហប្រជាជាតិ រ៉ាល់ ហ្សាកឃ្លីន បានបញ្ជាក់ថាប្រសិនបើភាគីកម្ពុជាមិនទទួលយកលក្ខខណ្ឌជាមូលដ្ឋានមួយចំនួនអង្គការសហប្រជាជាតិនឹងមិនគាំទ្រដំណើរការនេះទេ ។ នៅខែកញ្ញា ឆ្នាំ១៩៩៩ សម្តេច ហ៊ុន សែន បានស្នើសុំជំនួយពីអង្គការសហប្រជាជាតិសាជាថ្មីទៀត ទោះជាតាមរយៈការចូលរួមដ៏ពេញលេញមួយ ឬក៏គ្រាន់តែតាមរយៈការផ្តល់ជំនួយក្នុងការ

ធ្វើសេចក្តីព្រាងច្បាប់ដែលចាំបាច់នេះក៏ដោយ ។ នៅទីបំផុត នៅខែតុលា ឆ្នាំ១៩៩៩ សមាជិកព្រឹទ្ធសភាអាមេរិក ចន ឃែរី បានបំបែកភាពទ័លច្រកដោយលើកសំណើមួយគាំទ្រដោយសហរដ្ឋអាមេរិក ។ ដើម្បីធានាបាននូវការគ្រប់គ្រងរបស់អន្តរជាតិទៅលើសារជាតិនៃយន្តការនេះ ឃែរី បានស្នើថា កិច្ចព្រមព្រៀងទ្វេភាគីត្រូវតែគោរពទៅតាមច្បាប់ជាតិដែលកំពុងប្រតិបត្តិ និងត្រូវតែអនុវត្តទៅតាមនីតិវិធីដែលអង្គការសហប្រជាជាតិចង់បាន ។ ដោយសាររាជរដ្ឋាភិបាលកម្ពុជាទទូចចង់ថែរក្សា"អធិបតេយ្យភាព"របស់ខ្លួន ឃែរី បានស្នើឡើងនូវរបនាសម្ព័ន្ធមួយដែលមានចៅក្រមកម្ពុជាភាគច្រើន ប៉ុន្តែត្រូវមាន"សំឡេងភាគច្រើនលើសលប់" សម្រាប់រាល់ការសម្រេចចិត្ត គឺត្រូវរាប់បញ្ចូលយ៉ាងហោចណាស់ចៅក្រមអន្តរជាតិម្នាក់ ។

ទោះជាមានការបំបែកភាពទ័លច្រកដ៏គួរឲ្យកត់សម្គាល់នេះក៏ដោយ ការបំពេញបន្ថែមជាលម្អិតជាពិសេសទាក់ទងទៅនឹងព្រះរាជអាជ្ញាបានធ្វើឡើងរហូតដល់ខែកក្កដា ឆ្នាំ២០០០ ។ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៩ សម្តេច ហ៊ុន សែន បានបញ្ជូនសេចក្តីព្រាងច្បាប់ទៅឲ្យអង្គការសហប្រជាជាតិ ហើយស្នើឲ្យឆ្លើយតបមុនពេលបុណ្យចូលឆ្នាំសកល ។ អគ្គលេខាធិការរងអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការច្បាប់ ហេន ខូរែល បានឆ្លើយតបនៅថ្ងៃទី២៣ ខែធ្នូ ថា បើពិនិត្យមើលទៅលើខ្លឹមសារនៃសេចក្តីព្រាងច្បាប់កម្ពុជា អង្គការសហប្រជាជាតិហាក់ដូចជាត្រូវបង្ខំឲ្យចូលរួមត្រឹមតែជំនួយបច្ចេកទេសប៉ុណ្ណោះ ដោយសារតែសំណើនេះគ្មានការធានាឲ្យបានគ្រប់គ្រាន់អំពីអព្យាក្រឹតភាព ។

នៅខែមករា ឆ្នាំ២០០០ បន្ទាប់ពីដំណើរទស្សនកិច្ចរបស់លោកនាយករដ្ឋមន្ត្រីជប៉ុននៅប្រទេសកម្ពុជា សម្តេច ហ៊ុន សែន បានយល់ព្រមបើកឲ្យមានការចូលរួមពីអន្តរជាតិឡើងវិញ ។ នៅថ្ងៃទី៥ ខែមករា លោក ហេន ខូរែល បានជួបជាមួយអ្នកតំណាងអចិន្ត្រៃយ៍របស់កម្ពុជានៅអង្គការសហប្រជាជាតិ អ៊ុច បូរិទ្ធ ដើម្បីផ្តល់យោបល់លម្អិតទៅលើកំណែលើកចុងក្រោយបង្អស់នៃច្បាប់ ។ ថ្ងៃបន្ទាប់ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ចប់ច្បាប់ "ស្តីអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាសម្រាប់ការកាត់សេចក្តីឧក្រិដ្ឋកម្មប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ" ។ ច្បាប់នេះត្រូវបានដាក់លើតុនៅចំពោះមុខសភាជាតិកម្ពុជានៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០០ ហើយអង្គការសហប្រជាជាតិបានទទួលអត្ថបទបកប្រែផ្លូវការមួយនៅក្នុងថ្ងៃដដែល ។ អត្ថបទជាមូលដ្ឋាននេះនឹងត្រូវពិនិត្យពិចារណានៅក្នុងឱកាសមួយចំនួនបន្ទាប់ពីមានការចរចាបន្ថែមទៀត ។

នៅខែកុម្ភៈ ឆ្នាំ២០០០ បន្ទាប់ពីសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ (ដែលត្រូវបានតែងតាំងជាព្រះប្រធានរដ្ឋសភាជាតិក្រោមការរៀបចំដៃគូចម្រុះថ្មី) បានបង្ហាញការមិនសប្បាយព្រះទ័យចំពោះភាពស្ទាក់ស្ទើររបស់អង្គការសហប្រជាជាតិអំពីបញ្ហានេះ ។ លោក ហេន ខូរែល បានផ្តល់ចម្លើយពិស្តារអំពីបញ្ហាចម្បងទាំងបួនទាក់ទងទៅនឹងច្បាប់នេះ÷

- ◆ កង្វះឯករាជ្យភាពរបស់ព្រះរាជអាជ្ញានិងចៅក្រមស៊ើបអង្កេតអន្តរជាតិ
- ◆ គ្មានការធានារបស់រដ្ឋាភិបាលក្នុងការចាប់ខ្លួនជនជាប់ចោទ
- ◆ ភាពស្រពេចស្រពិលទាក់ទងទៅនឹងការលើកលែងទោស
- ◆ គ្មានច្បាប់ទាក់ទងទៅនឹងចៅក្រមបរទេសភាគច្រើនដែលមានសមត្ថភាព

សម្តេច ហ៊ុន សែន បានស៊ីកសម្តីទៅវិញថា គួរតែដាក់ឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិចំនួនបីរូបចុងក្រោយ ទទួលខុសត្រូវចំពោះការរក្សាទុកខ្មែរក្រហមឲ្យអង្គុយនៅអាសនៈកម្ពុជានៅអង្គការសហប្រជាជាតិពេញមួយទសវត្សរ៍ឆ្នាំ១៩៨០ ។ បន្ទាប់ពីមានវិបត្តិនេះ ក្រុមអ្នកចរចាមិនបានជួបគ្នាម្តងទៀតទេរហូតដល់ថ្ងៃទី១៦ ខែមីនា ទើបមានការជួបប្រជុំថ្មីមួយទៀតរយៈពេលមួយសប្តាហ៍ ដើម្បីពិភាក្សាបញ្ហាដែលបានលើកឡើងដោយលោក កូហ្វី អាណាន់ ។ ការពិភាក្សានោះប្រកបដោយភាពតានតឹង និង"ប្រកបដោយការស្ថាបនា" ក៏ប៉ុន្តែមិនបានសម្រេចកិច្ចព្រមព្រៀងណាមួយទេ ។

នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០០ សមាជិកព្រឹទ្ធសភាអាមេរិក ចន ឃែរី បានស្នើសុំការសម្រុះសម្រួលលើកទីពីរម្តងនេះទាក់ទងទៅនឹងព្រះរាជអាជ្ញានិងចៅក្រមស៊ើបអង្កេត ។

នាយករដ្ឋមន្ត្រី ហ៊ុន សែន បានយល់ព្រមនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០០ ដោយស្នើសុំជាផ្លូវការទៅអង្គការសហប្រជាជាតិឲ្យចាប់ផ្តើមការពិភាក្សាសាជាថ្មី ស្របទៅតាមខ្សែបន្ទាត់ដាក់ចេញដោយ យែរី ។ នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០០០ លោក ហេន ខូរែល បានមកទីក្រុងភ្នំពេញម្តងទៀត ដើម្បីពិភាក្សាគ្នាបន្ថែមជាមួយឯកឧត្តម សុខ អាន ។ នៅថ្ងៃទី៧ ខែ កក្កដា ឆ្នាំ២០០០ ភាគីទាំងពីរហាក់ដូចជាបានឈានទៅដល់កិច្ចព្រមព្រៀងចុងបញ្ចប់ទាក់ទងទៅនឹងសេចក្តីពិស្តារចុងក្រោយៈ ការចោទប្រកាន់ ការផ្តល់មូលនិធិសម្រាប់ការជំនុំជម្រះ ភាសាដែលយកមកប្រើនៅក្នុងតុលាការ សន្តិសុខរបស់បុគ្គលិក និងទីតាំងសាលាជំនុំជម្រះ ។ បន្ទាប់មក លោក ខូរែល បានដាក់សេចក្តីព្រាងអនុស្សរណៈយោគយល់ទៅឲ្យរដ្ឋាភិបាលកម្ពុជា ក្នុងនោះរួមមានកិច្ចព្រមព្រៀងចុងក្រោយរវាងភាគីទាំងពីរទាក់ទងទៅនឹងការចូលរួមរបស់អន្តរជាតិនៅក្នុងដំណើរការជំនុំជម្រះ (ដែលចាប់ពីពេលនេះតទៅក្លាយជាសេចក្តីព្រាងអនុស្សរណៈយោគយល់គ្នា) ។

### ១-៧) ការគាំទ្រនៅក្នុងដំណើរការនីតិបញ្ញត្តិរបស់កម្ពុជា

សេចក្តីព្រាងអនុស្សរណៈយោគយល់នេះមិនត្រូវបានចុះហត្ថលេខាទេ លុះត្រាតែរដ្ឋសភាកម្ពុជាបង្កើតច្បាប់ដើម្បីផ្តល់សុពលភាពដល់សេចក្តីព្រាងនេះជាមុនសិន ។ ដើម្បីសម្រេចគោលបំណងនេះ រាជរដ្ឋាភិបាលកម្ពុជាបានស្នើសុំឲ្យគណៈកម្មការនីតិកម្មរដ្ឋសភា ធ្វើវិសោធនកម្មច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ដើម្បីឆ្លើយតបទៅនឹងសេចក្តីព្រាងអនុស្សរណៈយោគយល់នេះ ។ ក៏ប៉ុន្តែ រាជរដ្ឋាភិបាលកម្ពុជាហាក់ដូចជាចាត់ទុកសេចក្តីព្រាងនេះជាការសម្ងាត់ ហើយមិនបានថតចម្លងឲ្យទៅគណៈកម្មការនីតិកម្មទេ ។ អង្គការក្រៅរដ្ឋាភិបាលនៅកម្ពុជាបានរិះគន់យ៉ាងខ្លាំងចំពោះឥរិយាបថបែបនេះ ដោយនិយាយថា ធ្វើដូច្នេះជាការរាំងយ៉ាងច្បាស់ក្រឡែតចំពោះការពិភាក្សានៅក្នុងសភា និងការពិភាក្សាជាសាធារណៈអំពីសារជាតិរបស់សាលាក្តី ។ នៅទីបញ្ចប់ សេចក្តីព្រាងនេះត្រូវបានបោះពុម្ពផ្សាយមិនផ្លូវការដោយកាសែតក្នុងស្រុកមួយ ។

បន្ទាប់មក គ្មានអ្វីកើតឡើងទាល់តែសោះរហូតដល់ដំណាច់ឆ្នាំ ពេលដែលសមាជិកព្រឹទ្ធសភាអាមេរិកមកធ្វើទស្សនកិច្ចលើកទីបីនៅប្រទេសកម្ពុជា ។ សម័យប្រជុំពេញអង្គរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី១៨ ខែធ្នូ បានដាក់ច្បាប់នេះនៅលេខរៀងទីមួយនៃរបៀបវារៈ ។ ច្បាប់នេះត្រូវបានរដ្ឋសភាពិនិត្យពិភាក្សាពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ រហូតដល់ថ្ងៃទី២ ខែមករា ឆ្នាំ២០០១ និងត្រូវបានអនុម័តជាឯកច្ឆ័ន្ទដោយសមាជិកទាំងអស់ដែលមានវត្តមាន ។ ភាពតក់ក្រហល់ដែលនឹកស្មានមិនដល់នេះបានធ្វើឲ្យមានសេចក្តីសង្ឃឹមឡើងវិញថា នៅទីបំផុតកម្ពុជាអាចរកឃើញយុត្តិធម៌ ។ នៅពេលដែលច្បាប់នេះបានអនុម័តដោយរដ្ឋសភាជាតិរួចហើយ សហរដ្ឋអាមេរិកបានបន្តបេសកកម្មជាន់ខ្ពស់ខាងការទូតនិងខាងពាណិជ្ជកម្មជាមួយកម្ពុជាឡើងវិញ ។ ជំនួយអភិវឌ្ឍន៍របស់អាមេរិកមិនគ្រាន់តែសម្រាប់ការវិលត្រឡប់មកវិញនូវលទ្ធិប្រជាធិបតេយ្យប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងសម្រាប់សាលាក្តីទៀតផង ។

ទោះជាសភាបានអនុម័តច្បាប់សម្រាប់សាលាក្តីខ្មែរក្រហមជាឯកច្ឆ័ន្ទក៏ដោយ ក៏ក្នុងអំឡុងពេលពិភាក្សា មានការលើកបញ្ហាមួយចំនួនដើម្បីទាមទារឲ្យមានការស្រាយបំភ្លឺ ជាពិសេសអំពីយុត្តាធិការរបស់តុលាការ ដែនអាជ្ញាយុកាល សិទ្ធិជ្រើសរើសមេធាវី និងទោសប្រហារជីវិត ។ ជាងនេះទៅទៀត មានពត៌មានថាដោយសារតែមិនដែលបានទទួលដំណឹងជាផ្លូវការអំពីខ្លឹមសាររបស់សេចក្តីព្រាងអនុស្សរណៈយោគយល់ ភាគីខាងគណបក្សប្រឆាំងបានបង្ខំចិត្តទទួលយកការធានារបស់រដ្ឋាភិបាលថាស្របទៅតាមអត្ថបទពីរទៀត ។

នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០០១ អង្គការសហប្រជាជាតិបានសម្តែងការព្រួយបារម្ភថា ច្បាប់ដែលបានអនុម័តដោយរដ្ឋសភាជាតិកម្ពុជាមិនស្របគ្នាជាមួយនឹងអនុស្សរណៈយោគយល់ទេ ។ រដ្ឋាភិបាលមិនបានបញ្ជូនសេចក្តីអត្ថាធិប្បាយរបស់អង្គការសហប្រជាជាតិទៅឲ្យព្រឹទ្ធសភាកម្ពុជាឲ្យបានមុនពេលដែលព្រឹទ្ធសភាពិភាក្សានិងអនុម័តលើច្បាប់នេះនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០១ ទេ ។

នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០០ ក្រុមប្រឹក្សាធម្មនុញ្ញ

កម្ពុជាបានប្រកាសថា ច្បាប់នេះគោរពទៅតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ។ ទោះជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សានេះបានស្នើថា ត្រូវតែកែតម្រូវបញ្ហាបច្ចេកទេសទាក់ទងទៅនឹងទោសប្រហារជីវិត ។ នៅថ្ងៃទី២៣ ខែកុម្ភៈ សម្តេច ហ៊ុន សែន បានសម្រេចចិត្តប្រគល់ច្បាប់នេះទៅឲ្យក្រុមប្រឹក្សារដ្ឋមន្ត្រីធ្វើវិសោធនកម្មដើម្បីបញ្ជាក់ឲ្យបានច្បាស់ថា គ្មានទោសប្រហារជីវិតសម្រាប់បទឧក្រិដ្ឋកម្មក្នុងស្រុកទេ រួមទាំងយុត្តាធិការសាលាជំនុំជម្រះក្តីខ្មែរក្រហមផង ។ ចំណុចនេះត្រូវបានអ្នកខ្លះបកស្រាយថាជាកលល្បិចមួយថ្មីទៀតដើម្បីអូសបន្លាយពេលវេលា ។ ពិតណាស់ មិនគ្រាន់តែមិនចាំបាច់ផ្លាស់ប្តូរច្បាប់នេះប៉ុណ្ណោះទេ ប៉ុន្តែបញ្ហាសំខាន់មួយចំនួនទៀតដែលអាចកើតឡើងនៅក្នុងអង្គជំនុំជម្រះក៏មិនត្រូវបានលើកឡើងដោយក្រុមប្រឹក្សាធម្មនុញ្ញដែរ ។

ទោះជាសម័យប្រជុំរបស់រដ្ឋសភាថ្មីបានចាប់ផ្តើមនៅក្នុងខែមិថុនាឆ្នាំ២០០១ក៏ដោយ ក៏ក្រុមប្រឹក្សារដ្ឋមន្ត្រីគ្រាន់តែបានអនុម័តលើច្បាប់ថ្មីនេះនៅថ្ងៃទី២២ ខែមិថុនា ។ នៅថ្ងៃទី២៧ ខែមិថុនា លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានបញ្ជាក់អំពីការទទួលខុសត្រូវរបស់កម្ពុជាក្នុងការអនុម័តច្បាប់នេះឲ្យបានឆាប់រហ័សយោងទៅតាមសេចក្តីព្រាងអនុស្សរណៈយោគយល់ ។ សម្តេច ហ៊ុន សែន បានឆក់យកឱកាសនៅក្នុងដំណើរទស្សនកិច្ចរបស់តំណាងពិសេសអង្គការសហប្រជាជាតិទទួលបន្ទុកខាងសិទ្ធិមនុស្ស ភីតធើ ឡយប្រ៊ីច ដើម្បីបរិហារការជ្រៀតជ្រែករបស់អង្គការសហប្រជាជាតិទៅក្នុងដំណើរការនីតិកម្ម ។ នៅទីបញ្ចប់ រដ្ឋសភាជាតិបានពិនិត្យពិភាក្សាលើច្បាប់វិសោធនកម្មនៅក្នុងខែកក្កដា ឆ្នាំ២០០១ ។ បន្ទាប់ពីរិះគន់នាយករដ្ឋមន្ត្រី ហ៊ុន សែន ថាបាន "កុហក" កាលពីពេលអនុម័តច្បាប់នេះជាលើកដំបូង មេដឹកនាំគណបក្សប្រឆាំង សម រង្ស៊ី បានប្រកាសថា គណបក្សសមរង្ស៊ីលែងគាំទ្រច្បាប់នេះទៀតហើយ លុះត្រាតែធ្វើវិសោធនកម្មមួយចំនួនដើម្បីឲ្យស្របទៅនឹងបញ្ញត្តិរបស់សេចក្តីព្រាងអនុស្សរណៈយោគយល់ ។ បញ្ហានៅក្នុងការជំទាស់នេះរួមមាន ការជ្រើសរើសមេធាវី ការគាំពារសាក្សីនិងបុគ្គលិកសាលាជំនុំជម្រះក្តី និងភាពស្រពេចស្រពិលដែលមានជាប្រចាំ ទាក់ទងទៅនឹងការលើកលែងទោស ។

នៅទីបញ្ចប់ រដ្ឋសភាជាតិកម្ពុជាបានអនុម័តច្បាប់នេះនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០១ និងបន្ទាប់មកព្រឹទ្ធសភាអនុម័តនៅថ្ងៃទី២៣ ខែកក្កដា ។ នៅថ្ងៃទី៧ ខែសីហា ក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា ច្បាប់នេះស្របទៅតាមរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាហើយ ។ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាសម្រាប់ការកាត់សេចក្តីឧក្រិដ្ឋកម្មប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ក៏ត្រូវបានព្រះមហាក្សត្រនៃកម្ពុជា ព្រះបាទ នរោត្តម សីហនុ ប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ។

### ៤) រចនាសម្ព័ន្ធចម្រុះរបស់កម្ពុជា

នៅទីបញ្ចប់ទោះជាមិនពេញចិត្តក៏ដោយ ការបកប្រែជាផ្លូវការនូវច្បាប់តុលាការខ្មែរក្រហមត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅក្នុងឆ្នាំ២០០២ ។ រចនាសម្ព័ន្ធលម្អិតនៃអង្គជំនុំជម្រះវិសាមញ្ញដែលចែងក្នុងច្បាប់នេះអាចត្រូវបានវិភាគប្រកបដោយភាពប្រាកដប្រជាជាងមុន ។ ជាការពិត ច្បាប់តុលាការនេះត្រូវបានយោងទៅតាមកិច្ចព្រមព្រៀងឆ្នាំ២០០៣ ។ អង្គជំនុំជម្រះវិសាមញ្ញត្រូវបានបង្កើតឡើងជាផ្លូវការនៅក្រោមច្បាប់កម្ពុជា ប៉ុន្តែនឹងអនុវត្តប្រព័ន្ធច្បាប់ចម្រុះ ។ នៅក្នុងសាលាក្តីក្នុងស្រុកមានលក្ខណៈអន្តរជាតិបែបនេះ កម្លាំងប្រកួតប្រជែងគ្នាដែលបានគូសបញ្ជាក់ពីខាងលើបានដើរតួនាទីកាន់តែទូលំទូលាយឡើងនៅក្នុងការសូនឲ្យទៅជារូបរាងនៃអង្គជំនុំជម្រះជាជាងនៅក្នុងសាលាជំនុំជម្រះក្តីអន្តរជាតិសុទ្ធសាធ ។ កម្លាំងទាំងនេះបានពន្យល់អំពីសមាសភាពរួមផ្សំដែលរកឃើញថ្មីរបស់អង្គជំនុំជម្រះដែលជាច្បាប់តែមួយគត់ដែលរៀបចំឲ្យមានការចូលរួមពីអន្តរជាតិមានន័យថាជាការលាយគ្នារវាងនីតិវិធីឧក្រិដ្ឋកម្មក្នុងស្រុកនិងគោលការណ៍អន្តរជាតិ និងការកម្រិតយុត្តាធិការឲ្យនៅត្រឹមតែអំពើឧក្រិដ្ឋដែលប្រព្រឹត្តឡើងដោយខ្មែរក្រហមនៅក្នុងអំឡុងពេលនៃការកាន់អំណាច ។

#### ក) សមាសភាពរបស់អង្គជំនុំជម្រះវិសាមញ្ញរកឃើញមូលដ្ឋាន

## ផ្លូវច្បាប់ថ្មី

មាត្រាទី២ នៃច្បាប់តុលាការបានចែងឲ្យមានការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងទីក្រុងភ្នំពេញនៅក្នុងឋានានុក្រមរបស់ប្រព័ន្ធតុលាការកម្ពុជាទាំងបីថ្នាក់គឺ តុលាការទីក្រុងភ្នំពេញជាតុលាការដំបូង សាលាឧទ្ធរណ៍ និង តុលាការកំពូល ។ ច្បាប់នេះអនុញ្ញាតឲ្យជនជាប់ចោទធ្វើពាក្យបណ្តឹងទៅសាលាឧទ្ធរណ៍ ទោះជាគ្មានការលើកមកនិយាយអំពីសិទ្ធិណាមួយក្នុងការសើរើធម្មនុញ្ញភាពរបស់ច្បាប់នេះក៏ដោយ ។

ចំណុចពិសេសគឺថា សារជាតិនៃការចូលរួមពីអន្តរជាតិមានភាពខុសគ្នារវាងចៅក្រមនិងព្រះរាជអាជ្ញា ។ ការសម្រុះសម្រួលលើ"សម្លេងភាគច្រើនលើសលប់" ស្តីអំពីសមាសភាពនៃអង្គជំនុំជម្រះវិសាមញ្ញដែលបានចែងនៅក្នុងជំពូកទី៣និងទី៥នៃច្បាប់នេះ នៅតែមិនទាន់បានផ្លាស់ប្តូរជាមូលដ្ឋាននៅឡើយ ចាប់តាំងពីមានសំណើរបស់ព្រឹទ្ធសមាជិក ចន ឃែរី នៅក្នុងឆ្នាំ ១៩៩៩ ។ ដើម្បីជាការឆ្លើយតបទៅនឹងបញ្ហាអធិបតេយ្យភាពដែលលើកឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ចៅក្រមកម្ពុជានឹងមានចំនួនភាគច្រើននៅក្នុងអង្គជំនុំជម្រះនីមួយៗ ។ លើសពីនេះទៀត ចៅក្រមជំនុំជម្រះសម្រាប់អង្គជំនុំជម្រះនីមួយៗជាជនជាតិកម្ពុជា ប៉ុន្តែដើម្បីធានាប្រសិទ្ធភាពនៃការចូលរួមរបស់អន្តរជាតិ សម្លេងហាសិបបូកមួយនឹងមិនគ្រប់គ្រាន់សម្រាប់ការសម្រេចចិត្តទេ ។ មាត្រាទី១៤នៃច្បាប់តុលាការតម្រូវឲ្យចៅក្រម "ព្យាយាមសម្រេចឲ្យបាននូវឯកច្ឆន្ទនៅក្នុងសេចក្តីសម្រេចចិត្ត" ។ ប្រសិនបើមិនអាចធ្វើទៅបានទេ សម្លេងភាគច្រើនគ្រប់គ្រាន់នឹងក្លាយជាតម្រូវការចាំបាច់ដែលពាក់ព័ន្ធទៅនឹង"ការបោះឆ្នោតស្រប"ពីសំណាក់ចៅក្រមបរទេសយ៉ាងហោចណាស់ក៏ម្នាក់ដែរ ។

ការសម្រុះសម្រួលនេះផ្តល់ឧទាហរណ៍ល្អឥតខ្ចោះមួយដល់ដំណើរការចម្រុះនៃយុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិ ដែលបានមកពីការសម្រុះសម្រួលគ្នាខាងនយោបាយ ក៏ប៉ុន្តែក៏បានមកពីតម្រូវការដើម្បីសម្របទៅតាមវិធីសាស្ត្ររបស់ច្បាប់ធម្មតានិងច្បាប់ស៊ីវិលសម្រាប់នីតិវិធីជំនុំជម្រះក្តី ។ នៅក្នុងករណីនេះ ក្រុមអ្នកចរចារបស់អង្គការសហប្រជាជាតិបានទទួលយកគោលការណ៍ឯកច្ឆន្ទដែលបានបន្សល់ទុកពីប្រព័ន្ធតុលាការបារាំង ប៉ុន្តែបានទទូចសុំឲ្យមានការបញ្ចូលទាំងទស្សនៈភាគច្រើននិងទស្សនៈមិនយល់ស្របនៅក្នុងសេចក្តីសម្រេចចិត្តរបស់អង្គជំនុំជម្រះក្នុងករណីដែលមិនមានឯកច្ឆន្ទទេនោះ ។ ប្រសិនបើប្រៀបធៀបជាមួយនឹងសេចក្តីសម្រេចចិត្តខ្លីៗជាប្រពៃណីរបស់ច្បាប់ស៊ីវិល សេចក្តីសម្រេចចិត្តនេះជួយពង្រឹងដល់ប្រសិទ្ធភាពរបស់សម្រាប់ការជំនុំជម្រះក្តីតាមរយៈការរៀបរាប់ជាសាធារណៈនូវអំពើឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ ព្រមទាំងរួមចំណែកពង្រឹងការវិនិច្ឆ័យឧក្រិដ្ឋកម្មអន្តរជាតិតាមច្បាប់ ។

ទោះជាមានវិធានការដែលមិនអាចថ្លោះធ្លោយបានក៏ដោយ ក៏ប្រហោងចន្លោះជាយថាហេតុមួយចំនួនអាចនឹងកើតមាននៅក្នុងប្រព័ន្ធ "សម្លេងភាគច្រើនលើសលប់" ។ ជាងនេះទៅទៀត ដោយហេតុថាសម្លេងភាគច្រើនគ្រប់គ្រាន់ធានាឲ្យមានកិច្ចគាំពារជាអន្តរជាតិនូវសិទ្ធិរបស់ចុងចោទ ចៅក្រមអន្តរជាតិតែឯងនឹងមិនអាចសម្រេចការកាត់ទោសណាមួយបានទេបើគ្មានការយល់ព្រមពីចៅក្រមកម្ពុជាយ៉ាងហោចណាស់ពីររូប ។ ទោះជាប្រការនេះអាចជាចន្លោះប្រហោងដ៏មានសារសំខាន់ក៏ដោយ បើពិនិត្យមើលទៅលើភាពលម្អៀងរបស់រាជរដ្ឋាភិបាលកម្ពុជា ជនជាប់ចោទមួយចំនួនដែលមានសក្តានុពលទំនងជានឹងមិនបង្ហាញមុខនៅក្នុងតុលាការទេ ។ មានការពិភាក្សាមួយចំនួនស្តីអំពីថាតើវិធានភាគច្រើនលើសលប់យកមកប្រើតែជាមួយ"សេចក្តីសម្រេច"ចុងក្រោយ ឬក៏ប្រើជាមួយរាល់"សេចក្តីសម្រេច"ទាំងអស់របស់អង្គជំនុំជម្រះបូករួមទាំងការធ្វើបណ្តឹងនិងការចេញសាលក្រម ។ ប្រសិនបើច្បាប់តុលាការដាក់ការធ្វើបណ្តឹងឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អន្តរជាតិ ការជំនុំជម្រះប្រហែលជានឹងមិនដែលឈានទៅដល់ដំណាក់កាលនៃការកាត់សេចក្តីឡើយ ។ ដូចបានកំណត់ដោយសេចក្តីយោងទៅតាមអត្ថបទដើមជាភាសាខ្មែរដែលជាភាសាប្រើប្រាស់ផ្លូវការនៅក្រោមច្បាប់តុលាការ ពាក្យ "សេចក្តីសម្រេច" គ្របដណ្តប់លើសេចក្តីសម្រេចគ្រប់ថ្នាក់ទាំងអស់របស់តុលាការ ។

ច្បាប់តុលាការនេះបានចម្លងចេញពីប្រព័ន្ធច្បាប់របស់បារាំង

ដែលបែងចែកដាច់ពីគ្នារវាងតួនាទីរបស់ "ព្រះរាជអាជ្ញា" និងតួនាទីរបស់ "ចៅក្រមស៊ើបអង្កេត" ។ និយាយឲ្យខ្លីទៅ ព្រះរាជអាជ្ញាទទួលខុសត្រូវរៀបចំសំណុំរឿងចោទប្រកាន់និងរៀបចំការចោទប្រកាន់នៅក្នុងអំឡុងពេលជំនុំជម្រះក្តី ចំណែកចៅក្រមស៊ើបអង្កេតទទួលបន្ទុកស៊ើបអង្កេតអំពើឧក្រិដ្ឋដើម្បីស្វែងរកភស្តុតាងគាំទ្រនិងប្រឆាំងជនជាប់ចោទ ។ នៅទីបញ្ចប់ ប្រព័ន្ធតុលាការខ្មែរក្រហមបានជ្រើសរើសយកចំណុចនេះ ប៉ុន្តែខុសគ្នាត្រង់ចំនួនចៅក្រមនិងព្រះរាជអាជ្ញា ពោលគឺតុលាការខ្មែរក្រហមមាន "សហចៅក្រមស៊ើបអង្កេត" ពីររូប និង "សហព្រះរាជអាជ្ញា" ពីររូបសម្រាប់អង្គជំនុំជម្រះគ្រប់ថ្នាក់ ។ ដូច្នេះនឹងមានការតែងតាំងទាំងជនជាតិខ្មែរនិងជនជាតិបរទេសនៅក្នុងតំណែងទាំងពីរនេះ ហើយអ្នកទាំងពីរមានឋានៈនិងអំណាចស្មើគ្នា (ជំពូកទី៦ និងទី៧) ។

គួរឲ្យចាប់អារម្មណ៍ណាស់ថា ទោះបីជាមានការយល់ព្រមតាំងពីពេលដំបូងឲ្យមានការចូលរួមរបស់អន្តរជាតិនៅក្នុងដំណាក់កាលចោទប្រកាន់ក៏ដោយ ក៏ការសម្រេចឲ្យមានសហចៅក្រមនិងសហព្រះរាជអាជ្ញាបានបង្កឲ្យមានបញ្ហាធ្ងន់ធ្ងរច្រើន ហើយនេះជាបញ្ហាចុងក្រោយដែលត្រូវដោះស្រាយ ។ ទីមួយ វាជាការចាំបាច់ក្នុងការឈានទៅដល់កិច្ចព្រមព្រៀងស្តីពីប្រព័ន្ធច្បាប់ដែលត្រូវយកមកអនុវត្ត ។ ក្រុមអ្នកចរចារបស់អង្គការសហប្រជាជាតិហាក់ដូចជាមានចិត្តអន្ទះសាចង់រៀបចំនីតិវិធីព្រហ្មទណ្ឌនៃអង្គជំនុំជម្រះឲ្យស្របទៅតាមប្រព័ន្ធដែលបង្កើតឡើងដោយច្បាប់របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងប្រទេសរ៉្វាន់ដា ដែលនៅក្នុងនោះ រដ្ឋអាជ្ញាបំពេញតួនាទីទាំងក្នុងការចោទប្រកាន់និងការស៊ើបអង្កេត ។ នៅទីបញ្ចប់ ការទទូចរបស់កម្ពុជាឲ្យប្រើប្រាស់ប្រព័ន្ធរបស់ខ្លួនបាននាំឲ្យមានការទទូចរបស់អង្គការសហប្រជាជាតិឲ្យដាក់បញ្ចូលចៅក្រមស៊ើបអង្កេតអន្តរជាតិដែរ ។

នៅពេលដែលប្រព័ន្ធកម្ពុជាត្រូវបានជ្រើសយក ការធានាឯករាជ្យភាពរបស់បុគ្គលិកអន្តរជាតិគឺជាការសំខាន់ ។ យោងទៅតាមគម្រោងរបស់កម្ពុជាពីខាងដើម សហព្រះរាជអាជ្ញាត្រូវតែធ្វើការរួមគ្នានិងសម្រេចចិត្តរួមគ្នាជាឯកច្ឆ័ន្ទ ។ ហេតុដូច្នេះហើយទើបអង្គការសហប្រជាជាតិបារម្ភថា ព្រះរាជអាជ្ញាកម្ពុជាមានលទ្ធភាពការពារជនសង្ស័យដែលមានឥទ្ធិពលមួយចំនួនឲ្យរួចផុតពីការចោទប្រកាន់ ។ ជាថ្មីម្តងទៀត តាមរយៈការសម្រុះសម្រួលរបស់អាមេរិក នៅទីបញ្ចប់មានការមូលមតិគ្នាថា ក្នុងករណីដែលសហព្រះរាជអាជ្ញាមិនចុះសម្រុងគ្នា ការចោទប្រកាន់នឹងនៅតែបន្ត លុះណាតែព្រះរាជអាជ្ញាមួយរូបក្នុងចំណោមសហព្រះរាជអាជ្ញាទាំងពីរូបនេះស្នើឡើងថាការខ្វែងគំនិតគ្នានេះត្រូវតែដោះស្រាយតាមរយៈ "អង្គបុរេជំនុំជម្រះ" ដែលមានសមាសភាពចៅក្រមប្រាំរូប ដោយយកគំរូតាមនីតិវិធីរបស់អង្គជំនុំជម្រះ (មាត្រាទី២០) ។ ទោះជាយ៉ាងណាក៏ដោយ បើប្រៀបធៀបជាមួយអង្គជំនុំជម្រះ អង្គបុរេជំនុំជម្រះចាំបាច់ត្រូវការសំឡេងភាគច្រើនគ្រប់គ្រាន់ដើម្បីរាំងខ្ទប់ការចោទប្រកាន់ ។ សម្រាប់សហចៅក្រមស៊ើបអង្កេតក៏ត្រូវតែអនុវត្តនីតិវិធីដូចគ្នានេះដែរ (មាត្រាទី២៣) ។ ក៏ប៉ុន្តែមានការព្រួយបារម្ភថា ការបែងចែកក្រុមចោទប្រកាន់ច្រើននាំឲ្យមានជម្លោះនិងខ្ជះខ្ជាយពេលវេលា ជាពិសេសបើពិនិត្យទៅលើភាពមិនប្រាកដប្រជានៃស្ថានភាពពិតប្រាកដនៃនីតិវិធីព្រហ្មទណ្ឌកម្ពុជា ។

### ១) វិធានតែមួយពាក់ព័ន្ធទៅនឹងការចូលរួមរបស់អន្តរជាតិ

យោងទៅតាមសេចក្តីព្រាងលើអនុស្សរណៈយោគយល់ការចូលរួមរបស់អន្តរជាតិនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញស្ថិតក្រោមការគ្រប់គ្រងដោយវិធានមួយដែលរៀបចំឡើងក្នុងបំណងធានាឲ្យមានការគោរពទម្រង់អន្តរជាតិក្នុងការកាត់សេចក្តីមិនត្រឹមតែគោរពរាជរដ្ឋាភិបាលកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចៀសវាងនូវគ្រោះថ្នាក់នៃការធ្វើអន្តរាគមន៍ទ្វេភាគីដែលកាត់បន្ថយគុណភាពរបស់តុលាការនេះទៀតផង ។ ប្រការនេះនាំឲ្យមានរាប់បញ្ចូលវិធានការជាក់លាក់មួយចំនួនទាក់ទងទៅនឹងការជ្រើសរើសបុគ្គលិកអន្តរជាតិដែលត្រូវចូលរួមនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនិងនៅក្នុងផ្នែកហិរញ្ញវត្ថុនិងរដ្ឋបាលរបស់អង្គជំនុំជម្រះនេះ ។

រាល់បុគ្គលិកបរទេសសំខាន់ៗនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ (ចៅក្រម ព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេត) នឹងត្រូវបានតែងតាំង "សម្រាប់អំឡុងពេលដំណើរជំនុំជម្រះក្តី" ។ ប្រការ

នេះមិនបង្កើតឲ្យមានបញ្ហាជាដុំកំភួនប៉ុន្មានទេដោយសារតែច្បាប់កម្ពុជាបច្ចុប្បន្ននេះមិនទាមទារឲ្យបុគ្គលមានសញ្ជាតិជាកម្ពុជាកាន់មុខតំណែងបែបនេះទេ ។ ទោះជាយ៉ាងណាក៏ដោយ បញ្ហានីតិវិធីបានកើតឡើងដោយសារតែថា រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ តម្រូវឲ្យឧត្តមក្រុមប្រឹក្សាអង្គចៅក្រម "ធ្វើសំណើទៅព្រះមហាក្សត្រដើម្បីតែងតាំងចៅក្រមនិងព្រះរាជអាជ្ញានៅក្នុងសាលាក្តីគ្រប់ថ្នាក់" (មាត្រាទី១៣៨) ។ អាស្រ័យហេតុដូចនេះ រាជរដ្ឋាភិបាលបានទទូចថា បុគ្គលិកទាំងអស់នៃអង្គជំនុំជម្រះវិសាមញ្ញត្រូវតែតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម រាប់បញ្ចូលទាំងបុគ្គលិកបរទេសដែរ ។ នៅទីបញ្ចប់ ការសម្រុះសម្រួលគ្នាមួយត្រូវបានរកឃើញ គឺឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតែងតាំងបុគ្គលិកអន្តរជាតិចេញពីបញ្ជីឈ្មោះបេក្ខជនដែលលោកអគ្គ-លេខាធិការអង្គការសហប្រជាជាតិបានប្រគល់ឲ្យ ។ យោងតាមសំណើពីខាងដើមរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងបញ្ជីទាំងនេះត្រូវតែមានយ៉ាងហោចណាស់ព្រះរាជអាជ្ញាពីររូប ចៅក្រមស៊ើបអង្កេតពីររូប និងចៅក្រមកាត់ក្តីចំនួន១២រូប ។ ប្រសិនបើបុគ្គលិកណាម្នាក់ដែលត្រូវបានតែងតាំងរួចហើយប៉ុន្តែអវត្តមានដោយសារហេតុផលណាមួយ បុគ្គលិកនោះនឹងត្រូវជំនួសដោយអ្នកផ្សេងទៀតដែលជ្រើសរើសចេញពីបញ្ជីឈ្មោះរបស់អង្គការសហប្រជាជាតិដដែល មិនមែនជំនួសដោយបុគ្គលិកកម្ពុជាទេ ។

នៅក្នុងករណីដែលពុំមានសល់ឈ្មោះបេក្ខជននៅក្នុងបញ្ជីកន្លែងទំនេរនឹងត្រូវបំពេញដោយប្រភពផ្សេងៗទៀតដូចជាៈ ប្រភពទី១ "បេក្ខជនដែលណែនាំដោយរដ្ឋាភិបាលនៃរដ្ឋសមាជិករបស់អង្គការសហប្រជាជាតិ ឬអ្នកជំនាញខាងច្បាប់ជាជនជាតិផ្សេងៗដែលបានដាក់ពាក្យសុំជាលក្ខណៈបុគ្គល" ។ "ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមិនអាចជ្រើសរើសចៅក្រមកាត់ក្តី ចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាកម្ពុជា ជំនួសបានទេ" ។ បញ្ញត្តិនេះមិនត្រូវបានលើកឡើងនៅក្នុងសេចក្តីព្រាងអនុស្សរណៈយោគយល់ទេ ប៉ុន្តែនឹងត្រូវយកមកអនុវត្តនៅក្នុងករណីមានការដកថយរបស់អង្គការសហប្រជាជាតិ ដើម្បីចៀសវាងការអាក់ខានដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

ការិយាល័យរដ្ឋបាលពិសេសនឹងត្រូវបង្កើតឡើង ហើយការិយាល័យនេះទទួលខុសត្រូវតែមួយមុខគត់ គឺគ្រប់គ្រងបុគ្គលិកនៃអង្គជំនុំជម្រះវិសាមញ្ញ ។ ការិយាល័យរដ្ឋបាលត្រូវមានប្រធានជាជនជាតិកម្ពុជា និងអនុប្រធានជាជនបរទេស ។ អនុប្រធាននឹងទទួលបន្ទុកជ្រើសរើសបុគ្គលិករដ្ឋបាលអន្តរជាតិ និងចាត់ចែងមូលនិធិសម្រាប់អង្គជំនុំជម្រះ ។ ដោយយល់អំពីសារសំខាន់នៃតួនាទីអនុប្រធានការិយាល័យរដ្ឋបាលក្នុងការធានាឯករាជ្យភាពរបស់អង្គជំនុំជម្រះវិសាមញ្ញ អង្គការសហប្រជាជាតិស្នើសុំជ្រើសរើសតំណែងអនុប្រធានការិយាល័យរដ្ឋបាលដោយផ្ទាល់តែម្តង ។ ប្រការនេះនាំឲ្យច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញប្រើប្រាស់ពាក្យពេចន៍ខុសបន្តិចពីមុខតំណែងផ្សេងទៀត គឺៈ អនុប្រធានការិយាល័យរដ្ឋបាលត្រូវតែងតាំងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ និងមានការយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជា (មាត្រាទី៣១) ។

ចំនួនថវិកាសម្រាប់អង្គជំនុំជម្រះបានវិវត្តឡើងចុះទៅតាមការស្នើសុំរបស់អន្តរជាតិ ។ នៅក្នុងច្បាប់ចុងក្រោយសម្រាប់តុលាការខ្មែរក្រហម ថវិកាសម្រាប់ចំណាយគឺអាស្រ័យលើភាគីដែលបញ្ជូនបុគ្គលិកមកធ្វើការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនេះ ។ នេះរាប់បញ្ចូលទាំងសំណើរបស់អង្គការសហប្រជាជាតិដើម្បីជាការឆ្លើយតបទៅតាមសំណើរបស់កម្ពុជាដែលស្នើសុំតែងតាំងចៅក្រមរបស់ខ្លួនដោយមិនចាំបាច់មានការត្រួតពិនិត្យពីខាងក្រៅ ។ ដូច្នេះ ចៅក្រមកម្ពុជាស្ថិតនៅក្រោមការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋាភិបាលតែម្នាក់គត់ ។ ទាក់ទងទៅនឹងបុគ្គលិកអន្តរជាតិដែលអង្គការសហប្រជាជាតិបញ្ជូនមក ការចំណាយមិនមែនបានមកពីថវិកាអចិន្ត្រៃយ៍របស់អង្គការនេះទេ (មិនដូចនៅក្នុងតុលាការពិសេសពីលើកមុននោះទេ) ។ ថវិកានឹងបានមកពីមូលនិធិស្ម័គ្រចិត្តដែលបង្កើតឡើងដើម្បីទទួលជំនួយស្ម័គ្រចិត្តពីសំណាក់រដ្ឋទាំងឡាយ (មាត្រាទី៤៨) ។

ទោះជាមានមូលនិធិដាច់ដោយឡែកពីគ្នាសម្រាប់ចៅក្រមក៏ដោយ ក៏ច្បាប់តុលាការនេះបានដាក់របាំងការពារបញ្ហាពុករលួយរបស់ចៅក្រមក្នុងស្រុក ដោយបានសរសេរថា "អនុលោម

ទៅតាមច្បាប់នេះ ចៅក្រមទាំងអស់មានឋានៈនិងស្ថានភាពធ្វើការស្មើគ្នានៅគ្រប់ថ្នាក់នៃអង្គជំនុំជម្រះវិសាមញ្ញ" (មាត្រាទី១២) ។ ទោះជាយ៉ាងណាក៏ដោយ ទង្វើនេះអាចនាំឲ្យមានការបាត់បង់ឯករាជ្យភាពជាយថាហេតុទាក់ទងទៅនឹងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលគ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា គឺថាចៅក្រមក្នុងស្រុកនឹងសុះស្វែងរកមុខតំណែងណាមួយដែលទទួលបានប្រាក់កម្រៃខ្ពស់នៅក្នុងអង្គជំនុំជម្រះ ។ ជាងនេះទៅទៀតគ្មានសញ្ញាណាមួយបង្ហាញថាតើរាជរដ្ឋាភិបាលកម្ពុជានឹងផ្តល់ហិរញ្ញវត្ថុលើការចំណាយបន្ថែមយ៉ាងដូចម្តេចនោះទេ ។

នៅក្នុងការស្វែងរកលទ្ធភាពនិងប្រសិទ្ធភាពលើការចំណាយសេចក្តីព្រាងលើអនុស្សរណៈយោគយល់ស្នើសុំឲ្យចាប់ផ្តើមដំណើការជំនុំជម្រះក្តីអ្នកទាំងឡាយណាដែលបានចាប់ខ្លួនរួចហើយដោយមិនចាំបាច់រង់ចាំបញ្ចប់ការស៊ើបអង្កេតជនសង្ស័យណាផ្សេងទៀតឡើយ ។

### ក) ការលាយបញ្ចូលគ្នារវាងនីតិវិធីឧក្រិដ្ឋកម្មក្នុងស្រុកជាមួយនឹងគោលការណ៍អន្តរជាតិ

ការបង្កើតតុលាការក្នុងស្រុកដែលមានលក្ខណៈអន្តរជាតិនឹងបន្សល់ទុកនូវកេរមរតកយូរអង្វែងសម្រាប់តុលាការកម្ពុជានាពេលបច្ចុប្បន្ននេះ ។ ដោយសារតែប្រព័ន្ធតុលាការកម្ពុជាមិនទាន់បរាជ័យទាំងស្រុងនៅឡើយបើប្រៀបធៀបទៅនឹងប្រទេសផ្សេងទៀតដែលមានជម្លោះដែរ មាត្រាទី៣៣នៃច្បាប់តុលាការបានគូសបញ្ជាក់ថា អង្គជំនុំជម្រះវិសាមញ្ញនឹងអនុវត្តដំណើការជំនុំជម្រះស្របទៅតាមនីតិវិធីឧក្រិដ្ឋកម្មដែលមានស្រាប់របស់កម្ពុជា ប៉ុន្តែ"មានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ និងមានកិច្ចគាំពារជនរងគ្រោះនិងសាក្សី" ។ បើពិនិត្យមើលចំណុចខ្សោយបំផុតរបស់ប្រព័ន្ធតុលាការកម្ពុជា ភាពមិនស្របគ្នាលើពាក្យពេចន៍នេះត្រូវបានស្រាយបំភ្លឺតាមរយៈបញ្ញត្តិបន្ថែមថា "ប្រសិនបើចាំបាច់ និងប្រសិនបើមានចំណុចខ្វះខាតនៅក្នុងនីតិវិធីមានស្រាប់ អង្គជំនុំជម្រះវិសាមញ្ញអាចសុះស្វែងរកនៅក្នុងវិធាននីតិវិធីដែលបង្កើតឡើងនៅថ្នាក់អន្តរជាតិ ។ បើពិនិត្យមើលភាពមិនប្រាកដប្រជាជុំវិញខ្លឹមសារជាក់លាក់នៃនីតិវិធីឧក្រិដ្ឋកម្មកម្ពុជាដោយសារតែមានច្បាប់ត្រួតគ្នាច្រើនពេក អង្គជំនុំជម្រះនឹងមានឱកាសច្រើនដើម្បីធានាឲ្យមានដំណើការសមស្រប ជាពិសេសដូចដែលពាក្យពេចន៍នៅក្នុងមាត្រាទី៣៣អាចត្រូវបានបកស្រាយដោយរាប់បញ្ចូលគោលការណ៍ច្បាប់ទន់របស់អង្គការសហប្រជាជាតិទាក់ទងទៅនឹងសិទ្ធិមនុស្សនៅក្នុងផ្នែករដ្ឋបាលយុត្តិធម៌ ព្រមទាំងវិធាននីតិវិធីនិងភស្តុតាងរបស់តុលាការអន្តរជាតិផ្សេងៗទៀត ។

តាមការពិត ច្បាប់សម្រាប់អង្គជំនុំជម្រះវិសាមញ្ញលាយចម្រុះគ្នាទៅដោយនីតិវិធីកម្ពុជានិងគោលការណ៍អន្តរជាតិ ។ ទោះជារដ្ឋាភិបាលកម្ពុជាបានទទួលជោគជ័យនៅក្នុងការទាមទារឲ្យអនុវត្តប្រព័ន្ធយុត្តិធម៌ឧក្រិដ្ឋកម្មរបស់ខ្លួនក៏ដោយ ក៏អង្គការសហប្រជាជាតិបានស្នើសុំឲ្យអនុវត្តបញ្ហាមួយចំនួនតាមគំរូនីតិវិធីរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសុទ្ធសាធ ។ ជាងនេះទៅទៀត មាត្រាទី៣៥នៃច្បាប់នេះបានភ្ជាប់មកជាមួយនូវការធានាតិចតួចបំផុតដែលបានចែងនៅក្នុងមាត្រាទី១៤(២) និងមាត្រា១៤(៣) នៃអនុសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិស៊ីវិលនិងសិទ្ធិនយោបាយ ។ ការលាយបញ្ចូលគ្នានេះត្រូវបានអះអាងថា ខ្វីសមាសធាតុភាគច្រើនបំផុតពីប្រព័ន្ធដែលមានស្រាប់ ។ ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធកម្ពុជាដែលផុសចេញពីប្រព័ន្ធច្បាប់បារាំងបានផ្តល់សក្តានុពលខ្លាំងជាងដែនសមត្ថកិច្ចអន្តរជាតិដែលមាននាពេលបច្ចុប្បន្ន ជាពិសេសទាក់ទងទៅនឹងតួនាទីរបស់ជនរងគ្រោះ ។

### ក-១) ការលំបាកក្នុងការធ្វើឲ្យចុះសម្រុងគ្នាលើនីតិវិធីព្រហ្មទណ្ឌ

"អង្គបុរេជំនុំជម្រះ" ដែលបង្កើតឡើងដើម្បីដោះស្រាយភាពមិនចុះសម្រុងគ្នារវាងសហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេត ស្រដៀងគ្នាទៅនឹងអង្គការមួយដែលបង្កើតនៅក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិដើម្បីត្រួតពិនិត្យមើលដំណើរការស៊ើបអង្កេតរបស់ព្រះរាជអាជ្ញាក្នុងពេលអវត្តមានចៅក្រមស៊ើបអង្កេតណាម្នាក់ ។ នៅក្នុងប្រទេសកម្ពុជា ប្រព័ន្ធទាំងពីរនេះបានជាន់គ្នាយ៉ាងច្របូកច្របល់ ។

អង្គការសហប្រជាជាតិបានស្នើសុំថា ការជំនុំជម្រះកំបាំងមុខមិនអនុញ្ញាតឡើយនៅក្រោមច្បាប់អង្គជំនុំជម្រះវិសាមញ្ញនេះ

ទោះជានៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាមាននីតិវិធីនេះក៏ដោយ ។

លើសពីនេះទៀត រដ្ឋធម្មនុញ្ញកម្ពុជាហាមឃាត់ទោសប្រហារជីវិត ។ ជាលទ្ធផល ការដាក់ទោសខ្ពស់បំផុតដែលបានចែងនៅក្នុងមាត្រាទី៣៨និង៣៩នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញគឺទោសដាក់ពន្ធនាគារអស់មួយជីវិត ។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះវិសាមញ្ញនឹងមានយុត្តាធិការលើឧក្រិដ្ឋកម្មក្នុងស្រុកមួយចំនួនដែលធ្ងន់ធ្ងរ ដែលទោសប្រហារជីវិតអាចធ្វើទៅបានដោយអនុលោមទៅតាមក្រមព្រហ្មទណ្ឌកម្ពុជាដែលនៅជាធរមាននៅឡើយក្នុងឆ្នាំ១៩៧៥ ។ ទោះជារដ្ឋមន្ត្រីបានអះអាងក្នុងពេលពិភាក្សានៅក្នុងរដ្ឋសភាថា បញ្ញត្តិទូទៅនៅក្នុងមាត្រាទី៣៨នឹងអនុវត្តសម្រាប់ឧក្រិដ្ឋកម្មក្នុងស្រុកដែរក៏ដោយ ក៏ក្រុមប្រឹក្សាធម្មនុញ្ញបានបដិសេធមិនអនុម័តច្បាប់នេះលុះត្រាតែមានការស្រាយបំភ្លឺចំណុចនេះជាមុនសិន ។ បើពិនិត្យមើលគោលការណ៍ទូទៅនៃច្បាប់ឧក្រិដ្ឋកម្មដែលអំណោយផលដល់ជនជាប់ចោទសេចក្តីសម្រេចនេះហាក់ដូចជាគ្មានមូលដ្ឋានច្បាប់ទាល់តែសោះទៅលើបញ្ញត្តិនៃដំណើរជំនុំជម្រះក្តី ។ នៅក្នុងករណីជាច្រើន ច្បាប់នេះត្រូវបានបញ្ជូនទៅរដ្ឋសភាសាជាថ្មីម្តងទៀតបន្ទាប់ពីបានដាក់បន្ថែមទៅក្នុងមាត្រាទី៣នូវឃ្លាដូចខាងក្រោមៈ

*«ទោសបញ្ញត្តិក្នុងមាត្រាទី២០៩ ៥០០ ៥០៦ និង ៥០៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រូវកំណត់ទោសអតិបរមាត្រឹមដាក់ពន្ធនាគារអស់មួយជីវិត អនុលោមទៅតាមមាត្រាទី៣២នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបញ្ជាក់បន្ថែមដោយមាត្រាទី៣៨និងមាត្រាទី៣៩នៃច្បាប់នេះ» ។*

អាស្រ័យហេតុនេះ «ប្រសិនបើការប្រើពាក្យពេចន៍នៅក្នុងអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចគ្នានៅក្នុងអំពើប្រល័យពូជសាសន៍ ការធ្វើឲ្យភ័យខ្លាចនិងការសងសឹកក៏ប្រហែលជាត្រូវទទួលទោសទណ្ឌស្មើគ្នាដែរ» ។ ច្បាស់ណាស់ថា ការកាត់ទោសពីបទប្រល័យពូជសាសន៍បានផ្តល់ផលយ៉ាងប្រត្យក្សទាំងទៅលើសហគមន៍អន្តរជាតិនិងរដ្ឋាភិបាលកម្ពុជាដែលបានហៅខ្មែរក្រហមថាជា «បនប្រល័យពូជសាសន៍» កាលពី២០ឆ្នាំមុន ។

ទាក់ទងទៅនឹងសិទ្ធិរបស់ជនជាប់ចោទ ច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញបញ្ជាក់ច្បាស់អំពីសិទ្ធិទទួលជំនួយខបត្ថម្ភគាំទ្រពីសំណាក់មេធាវីដែលតែងតាំងដោយតុលាការ (មាត្រាទី២៤និងទី៣៥) ។ អង្គការសហប្រជាជាតិបានកត់សម្គាល់ថា ច្បាប់នេះមិនបញ្ជាក់ឲ្យបានច្បាស់អំពីសិទ្ធិរបស់ជនជាប់ចោទក្នុងការស្វែងរកមេធាវីតាមជម្រើសរបស់ខ្លួនដូចដែលមានចែងនៅក្នុងមាត្រាទី១៤នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិលនិងសិទ្ធិនយោបាយហើយជនជាប់ចោទក៏មិនមានសិទ្ធិជ្រើសរើសមេធាវីជាជនបរទេសដែរ ។ នៅពេលដែលសំណួរនេះត្រូវបានលើកឡើងនៅចំពោះមុខរដ្ឋសភាជាតិរដ្ឋមន្ត្រីបានឆ្លើយថា ជនជាប់ចោទមានសិទ្ធិជ្រើសរើសមេធាវីណាម្នាក់ដែលបានចុះឈ្មោះនៅក្នុងសមាគមមេធាវីកម្ពុជា ។ ជាងនេះទៅទៀតសិទ្ធិនេះបានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ឧក្រិដ្ឋកម្មរបស់កម្ពុជា ។ ឯកឧត្តម សុខ អាន បានបន្ថែមទៀតថា គ្មានអ្វីអាចរារាំងមេធាវីបរទេសដែលបានចុះឈ្មោះក្នុងសមាគមមេធាវីកម្ពុជារួចហើយមិនឲ្យជួយដល់មេធាវីកម្ពុជាទេ ។

### គ-២) ជនរងគ្រោះ

នៅក្នុងប្រព័ន្ធច្បាប់កម្ពុជាដែលផុសចេញពីប្រព័ន្ធច្បាប់បារាំង ជនរងគ្រោះនៃអំពើឧក្រិដ្ឋមួយអាចក្លាយ«ភាគីស៊ីវិល» នៅក្នុងដំណើការជំនុំជម្រះបទឧក្រិដ្ឋកម្ម ។ ការគោរពសិទ្ធិនេះនៅក្នុងការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមអាចជួយពង្រឹងឥទ្ធិពលប្រកបដោយអត្ថន័យច្បាស់លាស់នៅក្នុងការជំនុំជម្រះក្តី និងជំរុញឲ្យមានការផ្សះផ្សាជាតិ ។ ដូចគ្នានេះដែរ បណ្តឹងដែលធ្វើឡើងដោយជនរងគ្រោះអាចផ្តល់ការធានាបន្ថែមទៀតថា ការពិតមិនត្រូវបានយកមកបកស្រាយខុសដោយឈរលើហេតុផលនយោបាយឬមនោគមវិជ្ជាឡើយ ។ ការធានានេះមានការទទួលស្គាល់អំពីភាពទន់ខ្សោយនៅក្នុងប្រព័ន្ធច្បាប់ធម្មតាដែលលក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិបានផ្តល់តួនាទីដល់ជនរងគ្រោះកាន់តែច្រើនឡើងទោះជាលក្ខន្តិកៈនេះមិនអាចប្រៀបជាមួយនឹងសិទ្ធិភាគីស៊ីវិលពេញលេញក៏ដោយ ។ ច្បាប់តុលាការមិនបានផ្តល់អន្តរាគមន៍ពីសំណាក់ជនរងគ្រោះឡើយ ទោះជាសិទ្ធិនេះត្រូវបានធានាសម្រាប់អំពើឧក្រិដ្ឋកម្មក្នុងស្រុកដែលមានលក្ខណៈ

ស្រាលជាងក៏ដោយ ។ គ្មានខ្លឹមសារយោងត្រូវបានធ្វើឡើងទាក់ទងនឹងបណ្តឹងរបស់ភាគីស៊ីវិលទេ ប្រហែលជាដោយសារថាខ្លឹមសារយោងទូទៅទាក់ទងទៅនឹង“នីតិវិធីកម្ពុជាដែលកំពុងនៅជាធរមាន”បានគ្របដណ្តប់លើអន្តរាគមន៍របស់ភាគីស៊ីវិល ជាពិសេសចាប់តាំងពីពេលដែលមាត្រាទី៣៦និងទី៣៧នៃច្បាប់នេះគោរពសិទ្ធិជនរងគ្រោះក្នុងការប្តឹងឧទ្ធរណ៍អំពីសេចក្តីសម្រេចនៅឯសាលាដំបូង ។

ដោយឈរលើមូលដ្ឋានថា ការធ្វើអន្តរាគមន៍នេះជា“គ្រោះថ្នាក់ដ្ឋូនគ្នា”ដែលហាមឃាត់នៅក្នុងមាត្រាទី១៤នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិលនិងសិទ្ធិនយោបាយ វាច្បាស់ណាស់ថាការរិះគន់របស់មេធាវីច្បាប់ទៅលើការធ្វើអន្តរាគមន៍បែបនេះបណ្តាលមកពីមានការភ័ន្តច្រឡំចំពោះប្រព័ន្ធច្បាប់ស៊ីវិល ដែលតាមការពិតគ្មានអ្វីក្រៅតែពីរកមធ្យោបាយរៀបចំបណ្តឹងស៊ីវិលនៅក្នុងករណីដែលការបាត់បង់ឬការខូចខាតដោយសារឧក្រិដ្ឋកម្មណាមួយ ដើម្បីចៀសវាងការចំណាយនិងការលំបាកក្នុងការជំនុំជម្រះក្តីដាច់ដោយឡែកពីគ្នា ។

បើពិនិត្យមើលកម្រិតនៃអំពើឧក្រិដ្ឋកម្មដែលកំពុងតែពិភាក្សាមានការភ័យខ្លាចថា អង្គជំនុំជម្រះនឹងជាប់គាំងដោយសារតែមានអន្តរាគមន៍ជាលក្ខណៈបុគ្គលដ៏ច្រើនលើសលប់ ។ ដំណោះស្រាយមួយគឺការអនុវត្តន៍រួមគ្នានូវសិទ្ធិនេះតាមរយៈសមាគមជនរងគ្រោះដែលជាវិធីសាស្ត្រមួយដែលនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជាបច្ចុប្បន្ននេះមិនទាន់ទទួលស្គាល់នៅឡើយ ។ បន្ថែមលើនេះទៀត ការទាមទារដំងឹចិត្តនឹងជំពាក់ជំពិនជាមួយនឹងមាត្រាទី៣៨នៃច្បាប់នេះដែលរៀបចំឲ្យរដ្ឋរឹបអូសរាល់ទ្រព្យសម្បត្តិខុសច្បាប់របស់អ្នកទាំងឡាយណាដែលត្រូវអង្គជំនុំជម្រះកាត់ឲ្យជាប់ទោស ។ ទោះជាយ៉ាងណាក៏ដោយ វិធានការបែបនេះប្រហែលមិនមែនជាដំណោះស្រាយតែមួយគត់សម្រាប់ជនរងគ្រោះនោះទេ ព្រោះបណ្តឹងស៊ីវិលដូចគ្នានេះអាចធ្វើទៅបាននៅក្រោមនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា ហើយពេលវេលាក៏ប្រហែលជាមិនអស់ដែរ ព្រោះថាដែនអាជ្ញាយុកាលរបស់អង្គជំនុំជម្រះនេះអាចនឹងត្រូវបានពន្យារសម្រាប់បទឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ ប្រការនេះនឹងរក្សាទុកនូវគោលការណ៍ទាក់ទងទៅនឹងការផ្តល់សំណងដល់ជនរងគ្រោះដូចដែលបានពិភាក្សាពីខាងលើរួចមកហើយ ។

ទោះជាសំណើសុំសាលាជំនុំជម្រះក្តីបែបចម្រុះដែលគណបក្សទាំងពីរបានដាក់ជូនអង្គការសហប្រជាជាតិកាលពីឆ្នាំ១៩៩៩បានឆ្លើយតបទៅនឹងអ្វីដែលក្រុមអ្នកជំនាញការរបស់អង្គការសហប្រជាជាតិបានពិនិត្យពិចារណានិងបដិសេធចោលកាលពីឆ្នាំ១៩៩៨ក៏ដោយ ក៏នៅចុងបញ្ចប់រចនាសម្ព័ន្ធដែលភាគីទាំងពីរព្រមទទួលយក គឺសាលាជំនុំជម្រះក្តីក្នុងស្រុកមួយដែលមានលក្ខណៈអន្តរជាតិ ។ ក្រុមអ្នកជំនាញការបានប្រមើលអំពីការបង្កើតសាលាជំនុំជម្រះក្តីដែលស្ថិតនៅក្រោមការគ្រប់គ្រងនិងគាំពាររបស់អង្គការសហប្រជាជាតិ ។ លទ្ធផលគឺជាសាលាក្តីស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្ពុជាដោយមានការចូលរួមនិងគាំទ្រផ្នែកហិរញ្ញវត្ថុមួយផ្នែកធំមកពីអន្តរជាតិ ។

**(នៅមានត)**

**ជាទីដ ច័យ**


## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: dccam@online.com.kh*

*Home page: www.dccam.org*

# និយមន័យផ្លូវច្បាប់នៃអំពើប្រល័យពូជសាសន៍

ការសម្លាប់រង្គាលជីវិតមនុស្សថ្មីៗនេះនៅតំបន់ដាហ្វ៊ូរ រួមជាមួយនឹងភាពពេញនិយមនៃខ្សែភាពយន្តរឿង«សណ្ឋាគាររ៉្វាន់ដា» និងការប្រារព្ធខួបលើកទី៦០នៃការរំដោះជំរំសម្លាប់មនុស្ស «អូស្វីត» ពីកណ្តាប់ដៃរបស់ក្រុមណាហ្ស៊ីអាល្លឺម៉ង់ បានធ្វើឲ្យមានការផ្តោតអារម្មណ៍យ៉ាងខ្លាំងទៅលើសំណួរស្តីពីអំពើប្រល័យពូជសាសន៍ ។ តំបន់ដាហ្វ៊ូរស្ថិតនៅភាគខាងលិចប្រទេសស៊ូដង់ ។ គ្រាន់តែប្រមាណពីរឆ្នាំចុងក្រោយនេះ យ៉ាងហោចណាស់មានមនុស្ស៧ម៉ឺននាក់ត្រូវសម្លាប់នៅដាហ្វ៊ូរ និងជាង២លាននាក់ត្រូវបង្ខំឲ្យចាកចេញពីផ្ទះសម្បែង ។

ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០០៣ នៅក្នុងយុទ្ធនាការយោធាប្រឆាំងក្រុមឧទ្ទាមចំនួនពីរគឺ «កងទ័ពរំដោះប្រទេសស៊ូដង់» និង «ចលនាដើម្បីយុត្តិធម៌និងស្មើភាព» កងទ័ពរបស់រដ្ឋាភិបាលស៊ូដង់ និងកងជីវពលអារ៉ាប់ឈ្មោះ «ជែនចាវីដ» ដែលគាំទ្រដោយរដ្ឋាភិបាល បានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង «ការបោសសម្អាតជាតិពន្ធ» នៅក្នុងតំបន់ដាហ្វ៊ូរ ។ កងកម្លាំងរដ្ឋាភិបាលនិងកងជីវពលបានវាយប្រហារជាខ្សែសង្វាក់ទៅលើសហគមន៍ជនស៊ីវិលដែលមានអម្បូរដូចនឹងក្រុមឧទ្ទាម (ប្រជាជនស្បែកខ្មៅដែលមិនមែនអារ៉ាប់ ប្រជាជនស្បែកខ្មៅហ្វ៊ូរាហ្កាវ៉ា និងប្រជាជនស្បែកខ្មៅម៉ាសាលីត) ដោយបានសម្លាប់ ឆក់ប្លន់ រំលោភ បំផ្លិចបំផ្លាញផ្ទះសម្បែង និងបានបង្ខំប្រជាជនឲ្យចាកចេញពីផ្ទះសម្បែងអស់រាប់រយភូមិ ។ ប្រជាជនជាង១លាននាក់ដែលត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះសម្បែងរបស់ខ្លួន ឥឡូវនេះកំពុងតែប្រឈមមុខនឹងការបាត់បង់ជីវិតដោយកង្វះអាហារ និងជំងឺដោយសារតែរដ្ឋាភិបាលនិងក្រុមជីវពលជែនចាវីដ ព្យាយាមរារាំងមិនឲ្យជំនួយមនុស្សធម៌ធ្លាក់ដល់ដៃប្រជាជនទាំងនោះ ។ កងកម្លាំងដដែលនេះបានបំផ្លិចបំផ្លាញភូមិ និងផលដំណាំជាច្រើននៅតំបន់ដាហ្វ៊ូរ និងបានដាក់ថ្នាំបំពុលនៅក្នុងទឹក ។

ខ្សែភាពយន្តរឿង «សណ្ឋាគាររ៉្វាន់ដា» បានរៀបរាប់ពីអំពើយង់ឃ្នងប្រល័យពូជសាសន៍នៅក្នុងប្រទេសរ៉្វាន់ដាដែលប្រព្រឹត្តតែក្នុងរយៈពេល១០០ថ្ងៃប៉ុណ្ណោះ គិតចាប់ពីខែមេសា ឆ្នាំ១៩៩៤នៅពេលដែលកុលសម្ព័ន្ធអម្បូរ «ហ៊ូទូ» សម្លាប់រង្គាលលើអម្បូរ «ទុតស៊ី» នៅមុនពេលដែលឧទ្ទាមទុតស៊ីនៃ «រណសិរ្សស្នេហាជាតិរ៉្វាន់ដា» ដណ្តើមកាន់កាប់អំណាចវិញ ។ បើតាមការប៉ាន់ស្មាន ចំនួនមនុស្សស្លាប់មានប្រមាណ៨សែននាក់នៃជាតិពន្ធទុតស៊ីនិងជាតិពន្ធហ៊ូទូដែលមានគោលនយោបាយនិយមកណ្តាល ។ ភាគច្រើននៃអ្នកស្លាប់គឺត្រូវបានកាប់ចិញ្ច្រាំនឹងកាំបិតវែង ។ វ៉ាឌីអូ មៀល ខូលីន ដែលជាតួអង្គសំខាន់នៅក្នុងខ្សែភាពយន្តនេះបានអានឈ្មោះ អាស័យដ្ឋាន និងផ្លាកលេខសម្គាល់ខ្លួនរបស់ជនទុតស៊ី និងជនហ៊ូទូនិយមកណ្តាលជាច្រើននាក់ដែលត្រូវអម្បូរហ៊ូទូសម្លាប់ ។

ការសម្លាប់រង្គាលទាំងពីរលើកនេះដែលបានកើតឡើងក្នុងគម្លាតប្រមាណមួយទសវត្សរ៍ពីគ្នា គឺមិនមែនជាការសម្លាប់រង្គាលលើកទីមួយនៃសតវត្សរ៍ទី២០និង២១នេះទេ ។ នៅឆ្នាំ១៩១៥ ជនជាតិទួរគីបានសម្លាប់រង្គាលជនជាតិអាមេនីអស់ប្រមាណ១លាននាក់ ។ នៅទសវត្សរ៍ឆ្នាំ១៩៤០ក្រុមណាហ្ស៊ីអាល្លឺម៉ង់បានសម្លាប់ជនជាតិជ្វីហ្វអស់ជាង៦លាននាក់និងប្រហែល៥លាននាក់ទៀតនៃអម្បូរប៉ូឡូញ អម្បូររ៉ូម៉ា ជនកុម្មុយនិស្ត និងមនុស្សជាច្រើនទៀតដែលក្រុមណាហ្ស៊ីមិនត្រូវការ ។ នៅប្រទេសកម្ពុជានៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៧០ ប៉ុល ពត និងក្រុមខ្មែរក្រហមកុម្មុយនិស្តបានសម្លាប់ជីវិតប្រជាជនអស់ជិត២លាននាក់ (ចំនួនប្រជាជនសរុបមានតែ៧លាននាក់ប៉ុណ្ណោះ) នៃជនជាតិវៀតណាម ជនជាតិចិន ជនចាម ព្រះសង្ឃ និង «បញ្ញវន្ត»ជាច្រើន (ខ្មែរក្រហមបានកំណត់ថា «បញ្ញវន្ត» គឺអ្នកទាំងឡាយណាដែលចេះអានអក្សរនិងអ្នកដែលពាក់វ៉ែនតា) ។ នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ សាដាម ហ៊ូសេន បានប្រើឧស្ម័នបំពុលដើម្បីសម្លាប់ជនជាតិ «ឃឺត» អស់រាប់ម៉ឺននាក់ ។ នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ នៅក្នុងទីក្រុងស្រេប្រេនីកានៃកូសូវ៉ូនិងបូស្នៀ ជនមូស្លីមនិងក្រូអាតត្រូវអម្បូរស៊ែបសម្លាប់នៅក្នុង

ទ្រង់ទ្រាយធំ ។ ទាំងនេះគឺជាប្រវត្តិសាស្ត្រដ៏សោកសៅរបស់មនុស្សជាតិ ។

ភាគច្រើន សហគមន៍អន្តរជាតិបានត្រឹមតែថ្កោលទោសទង្វើឃោរឃៅទាំងនោះប៉ុណ្ណោះ ចំណែកអន្តរាគមន៍ដើម្បីបញ្ចប់ទង្វើនោះគតិចតួចបំផុត ។

ទោះបីជាយ៉ាងណាក៏ដោយ យើងមានច្បាប់អន្តរជាតិមួយដើម្បីប្រឆាំងនឹងទង្វើបែបនោះ ។ ច្បាប់អន្តរជាតិនោះគឺ "អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍" ។ សហរដ្ឋអាមេរិកចំណាយពេលអស់៤០ឆ្នាំទម្រាំតែអនុម័តអនុសញ្ញានេះបាន ។

ពាក្យថា "ប្រល័យពូជសាសន៍" (*Genocide*) ត្រូវបានបង្កើតឡើងជាលើកដំបូងដោយ រ៉ាហ្វែល លឹមគិន ដែលជាអ្នករួចរស់ជីវិតពីការកាប់សម្លាប់របស់ណាហ្ស៊ី ។ ពាក្យ "*Genocide*" មានប្រភពមកពីភាសាក្រិច "*geno*" មានន័យថា "កុលសម្ព័ន្ធ" និង "*cide*" បានមកពីពាក្យឡាតាំង "*caedre*" មានន័យថា "សម្លាប់" ។ ដូច្នេះពាក្យ "*Genocide*" មានន័យថា "ការសម្លាប់កុលសម្ព័ន្ធមួយ" ។

អំពើប្រល័យពូជសាសន៍ជាអំពើមួយក្នុងចំណោមអំពើខាងក្រោម ហើយដែលបានប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុងឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ÷

◆ សម្លាប់សមាជិកនៃក្រុម

◆ ការធ្វើឲ្យរបួសធ្ងន់ធ្ងរដល់រូបរាងកាយឬសតិបញ្ញានៃសមាជិកក្រុម

◆ ចេតនាធ្វើឲ្យក្រុមមួយទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុងឬមួយផ្នែក

◆ ការដាក់នូវវិធានការនានាដែលមានបំណងរារាំងមិនឲ្យមានការផ្តល់កំណើតទារក

◆ ការបញ្ជូនកុមារដោយបង្ខំពីក្រុមមួយទៅក្រុមមួយផ្សេងទៀត ។

ដើម្បីចាត់ទុកភាគីណាមួយថាបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ លុះត្រាតែភាគីនោះ ÷

១) អនុវត្តសកម្មភាពមួយឬច្រើននៃសកម្មភាពដែលបានរៀបរាប់ខាងលើ

២) មានចេតនាបំផ្លាញទាំងស្រុងឬមួយផ្នែក

៣) អនុវត្តទៅលើក្រុមដែលទទួលបានការការពារ ដូចជាក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា

ច្បាប់មិនតម្រូវថាទាល់តែមានការសម្លាប់រង្គាលក្រុមមួយទាំងស្រុងដូចជាការសម្លាប់រង្គាលជនជាតិជ្វីហ្វដោយក្រុមណាហ្ស៊ីទើបហៅថាអំពើប្រល័យពូជសាសន៍នោះទេ ដោយគ្រាន់តែតម្រូវថាសកម្មភាពនោះជាការប៉ុនប៉ងបំផ្លិចបំផ្លាញមួយផ្នែកធំនៃក្រុម ។

នេះគឺជាបញ្ហាដែលមានកន្លងមក ។ មុនដំបូងត្រូវតែបង្ហាញធាតុ "ចេតនា" បន្ទាប់មកត្រូវតែបង្ហាញធាតុ "មួយផ្នែកធំ" ។ តើ"មួយផ្នែកធំ"ប៉ុនណាទើបគ្រប់គ្រាន់អាចចាត់ទុកថាជាអំពើប្រល័យពូជសាសន៍បាន?

អនុសញ្ញាស្តីពី "ការបង្ការនិងផ្តន្ទាទោសចំពោះបទល្មើសប្រល័យពូជសាសន៍" ត្រូវបានអនុម័តដោយអង្គការសហប្រជាជាតិនៅក្នុងឆ្នាំ១៩៥១ ។ សហរដ្ឋអាមេរិកមិនបានផ្តល់សច្ចាប័នលើអនុសញ្ញានេះរហូតដល់ឆ្នាំ១៩៨៨ ។

នៅទីក្រុងនូរឹមប៊ឺក សាលាជំនុំជម្រះក្តីឧក្រិដ្ឋកម្មសង្គ្រាមលើក្រុមណាហ្ស៊ីត្រូវបានបង្កើតឡើងបន្ទាប់ពីសង្គ្រាមលោកលើកទី២ ដើម្បីដាក់ទណ្ឌកម្មដល់ជនដៃដល់ដែលប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ សាលាជំនុំជម្រះក្តីមួយស្រដៀងគ្នានេះត្រូវបានបង្កើតឡើងម្តងទៀតនៅតំបន់បាល់កង់នៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ។ សាលាជំនុំជម្រះក្តីឧក្រិដ្ឋកម្មសង្គ្រាមអចិន្ត្រៃយ៍របស់អង្គការសហប្រជាជាតិត្រូវបានបង្កើតឡើងនៅទីក្រុងឡាអេ ប្រទេសហុល្លង់នៅឆ្នាំ១៩៩៣ ។

នៅខណៈពេលដែលពិភពលោកហាក់បីដូចជានិយាយពីអំពើប្រល័យពូជសាសន៍នៅតំបន់ដាហ្វួរច្រើនជាងអំពើប្រល័យពូជសាសន៍ដែលកើតពីពេលកន្លងមក ប្រទេសភាគច្រើននៅតែមិនលូកដៃចូលដដែល ដោយរង់ចាំមើលឲ្យច្បាស់ថាអំពើប្រល័យពូជសាសន៍ពិតជាកើតមានមែនឬទេ ហើយខ្ញុំក៏នៅមិនទាន់ច្បាស់នៅឡើយ ។

**រ៉ែន រ៉ូប៊ីន**

# បុព្វហេតុនៃព្រឹត្តិការណ៍ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១: មិនមែនជាការប៉ះទង្គិចនៃអារ្យធម៌ទេ

ការវាយប្រហារកាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១ ទៅលើសហរដ្ឋអាមេរិក បានជំរុញឲ្យមានការពិភាក្សាជាច្រើន នៅតាមបណ្តាញផ្សព្វផ្សាយនានាអំពីសាសនាអ៊ីស្លាមនិងប្រទេសលោកខាងលិច ។ ទ្រឹស្តីមួយក្នុងចំណោមទ្រឹស្តីនានាដែលជំទាស់ខ្លាំងបំផុត ត្រូវបានលើកឡើងដោយអ្នកវិទ្យាសាស្ត្រនយោបាយនៅសាកលវិទ្យាល័យហាវ៉ឺដ សាមូអែល ភី ហាន់ធីងតុន នៅក្នុងនិក្ខេបបទរបស់គាត់ដែលមានចំណងជើងថា «ការប៉ះទង្គិចនៃអារ្យធម៌» ដែលចុះផ្សាយនៅក្នុងព្រឹត្តិបត្រ «កិច្ចការការបរទេស» នៅឆ្នាំ១៩៩៣ ។ ស្ទើរតែពេញនិក្ខេបបទរបស់គាត់ទាំងមូល ហាន់ធីងតុន បានព្យាករណ៍ទុកជាមុនអំពីជម្លោះដែលកាន់តែស្រួចស្រាល់ឡើងរវាងអារ្យធម៌ដែលខុសប្លែកគ្នា ជាពិសេសរវាងសាសនាអ៊ីស្លាមនិងលោកខាងលិច ហើយការលើកឡើងរបស់គាត់បានទទួលការរិះគន់កាន់តែច្រើនឡើងៗ ។

ហាន់ធីងតុន បានលើកឡើងថា «ភាពប្រេះស្រាំនៃអារ្យធម៌ទាំងឡាយនឹងក្លាយជាសមរភូមិនៅពេលអនាគត» ។ សារសំខាន់នៃការអះអាងរបស់ហាន់ធីងតុនគឺថា ស្នាមប្រេះស្រាំនៃអារ្យធម៌កំពុងតែចូលមកជំនួសព្រំដែននយោបាយនៃសង្គ្រាមត្រជាក់ ដែលជាចំណុចងាយបង្កជាវិបត្តិនិងការបង្ហូរឈាម ។

បើយោងទៅតាម ហាន់ធីងតុន ជំហានដំបូងនៃជម្លោះសកលលោកបង្កឡើងដោយអ្នកដឹកនាំរដ្ឋនិងមនោគមវិជ្ជាបន្តបន្ទាប់គ្នា ។ ជម្លោះទាំងអស់នេះគឺជាលទ្ធផលនៃការរីកចម្រើនរបស់អារ្យធម៌លោកខាងលិច ។ ហាន់ធីងតុន បានអះអាងទៀតថា នៅក្នុងយុគសម័យក្រោយសង្គ្រាមត្រជាក់ ជម្លោះនយោបាយពិភពលោកនឹងកកើតឡើងដោយសារការប៉ះទង្គិចនៃអារ្យធម៌ ។

ហាន់ធីងតុន មិនត្រឹមតែមានកំហុសចំពោះផ្នែកខ្លះនៃការពិតរបស់ប្រវត្តិសាស្ត្រដែលគាត់បានលើកឡើងប៉ុណ្ណោះទេ និក្ខេបបទរបស់គាត់មានគ្រោះថ្នាក់ដ៏ធំធេងប្រសិនបើត្រូវបានយកជាអនុសាសន៍សម្រាប់រៀបចំនយោបាយ ។ ប្រសិនបើថ្នាក់ដឹកនាំរបស់សហរដ្ឋអាមេរិកព្រមទទួលយកទស្សនៈបែបនេះ ហើយដាក់ចេញនិងអនុវត្តជាខ្សែសង្វាក់នូវគោលនយោបាយដែលមានមូលដ្ឋានលើនិក្ខេបបទរបស់ ហាន់ធីងតុន នោះប្រទេសដែលមិនមែនលោកខាងលិចនឹងបង្ខំចិត្តចាត់វិធានការប្រឆាំងតបវិញមិនខាន ។ ជាលទ្ធផល ការណ៍នេះនឹងនាំឲ្យមានផលប៉ះពាល់ជាបន្តបន្ទាប់មួយចំនួនដែលនឹងអាចធ្វើឲ្យ ហាន់ធីងតុន មើលឃើញភាពមិនត្រឹមត្រូវនៃការអះអាងរបស់គាត់ជាមិនខាន ។

ការសម្រេចចិត្តថាតើត្រូវយល់ស្របឬមិនយល់ស្របជាមួយនឹងការលើកឡើងរបស់ ហាន់ធីងតុន តម្រូវឲ្យមានការគិតគូរយ៉ាងប្រុងប្រយ័ត្ន ។ អត្ថបទមួយនេះនឹងជំទាស់ថាព្រឹត្តិការណ៍ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១ មិនមែនជាផ្នែកមួយនៃការប៉ះទង្គិចគ្នារវាងអ៊ីស្លាមនិងលោកខាងលិចទេ ។ អត្ថបទនេះនឹងលើកឡើងនូវសំណួរពីរដែលទាក់ទងគ្នា÷

- ◆ តើសាសនាអ៊ីស្លាមជាដើមហេតុបង្កជាព្រឹត្តិការណ៍ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១ មែនឬទេ?
- ◆ តើពិតជាមានអារ្យធម៌របស់អ៊ីស្លាមមែនឬទេ?

## ១) តើសាសនាអ៊ីស្លាមជាដើមហេតុបង្កជាព្រឹត្តិការណ៍ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១ មែនឬទេ?

សម្រាប់ ហាន់ធីងតុន សាសនាអ៊ីស្លាមគឺជាអ្វីដែលជនមូស្លីមប្រតិបត្តិ ។ អូសាម៉ា ប៊ីនឡាដិន និងបណ្តាញភេរវកម្មរបស់គាត់បានគិតថា សាសនាអ៊ីស្លាមគឺជាប្រភពចម្បងបំផុតនៃការវាយប្រហារថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១ ប៉ុន្តែអ្នកស្រាវជ្រាវជាន់ខ្ពស់របស់លោកខាងលិចនិងមជ្ឈិមបូព៌ា (ដូចជា អែកបាល់ អាម៉ាដ, ណម ឆមស្គី, ស្លាវ៉ូ ហ្ស៊ីហ្សិក, ម៉ាមូឌ មុាំដានី, និង អាហ្សាដ អាប៊ូខាលីល) មិនយល់ស្របនឹងការយល់ឃើញនេះទេ ។ ក្រុមអ្នកស្រាវជ្រាវទាំងនេះបានចង្អុលបង្ហាញថា ការដែល

សហរដ្ឋអាមេរិកបង្កើតក្រុមមូចាហ៊ីឌីនគឺជាមូលហេតុចម្បងបំផុតដែលបង្កជាព្រឹត្តិការណ៍ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១ ។ ប្រសិនបើសហរដ្ឋអាមេរិកមិនបានបង្កើតក្រុមមូចាហ៊ីឌីននោះនឹងមិនមានក្រុមមូចាហ៊ីឌីននិងក្រុមអាល់កៃដាទេ ហើយប្រសិនបើគ្មានក្រុមអាល់កៃដា ក៏គ្មានការវាយប្រហារអគារពាណិជ្ជកម្មនៅទីក្រុងញូវយ៉កដែរ ។

ការគាំទ្ររបស់សហរដ្ឋអាមេរិកចំពោះក្រុមមូចាហ៊ីឌីនបានចាប់ផ្តើមឡើងនៅក្នុងអំឡុងពេលសង្គ្រាមត្រជាក់ ។ នៅឆ្នាំ១៩៨៦ សភារបស់សហរដ្ឋអាមេរិកបានអនុម័តផ្តល់ការគាំទ្រទាំងផ្នែកយោធានិងហិរញ្ញវត្ថុទៅឲ្យចលនាប្រឆាំងសូវៀតនៅក្នុងប្រទេសអាហ្វហ្កានីស្ថាន ។ ជាងនេះទៅទៀត ភ្នាក់ងារសេ.អ៊ី.អារបស់សហរដ្ឋអាមេរិកបានជួយជ្រើសរើសជនមូស្លីមជ្រុលនិយមនៅទូទាំងពិភពលោកឲ្យមកហ្វឹកហាត់នៅក្នុងប្រទេសប៉ាគីស្ថាននិងបានសហការជាមួយក្រុមមូចាហ៊ីឌីននៅក្នុងប្រទេសអាហ្វហ្កានីស្ថាន ។ នេះគឺជាលើកទីមួយដែលសង្គ្រាមប្រពៃណីមូស្លីមឬជីហាដ (សង្គ្រាមសាសនា) ដែលបានបាត់រូបរាងអស់រយៈពេលរាប់សតវត្សរ៍មកហើយបានមកបម្រើនយោបាយជាមួយនឹងការជួយជ្រោមជ្រែងពីសំណាក់សហរដ្ឋអាមេរិក ។ នៅពេលនោះ ក្រុមមូចាហ៊ីឌីនគឺជាប្រតិបត្តិការសម្ងាត់ធំបំផុតនៅក្នុងប្រវត្តិសាស្ត្ររបស់ក្រុមសេ.អ៊ី.អាក្នុងការប្រយុទ្ធប្រឆាំងនឹងរបបកុម្មុយនិស្តនៅក្នុងប្រទេសអាហ្វហ្កានីស្ថាននិងកងកម្លាំងរបស់សូវៀតដែលគាំទ្ររបបនោះ ។ គ្រាន់តែនៅក្នុងឆ្នាំសារពើពន្ធ១៩៨៧ប៉ុណ្ណោះ ការគាំទ្រផ្នែកយោធារបស់សហរដ្ឋអាមេរិកចំពោះក្រុមមូចាហ៊ីឌីនមានតម្លៃរហូតដល់ទៅ៦៦០លានដុល្លារ ។ លើសពីនេះទៅទៀត ក្រុមមូចាហ៊ីឌីនបានទទួលការគាំទ្រជាសាធារណៈ ។ ជាក់ស្តែងនៅក្នុងឆ្នាំ១៩៨៥ លោកប្រធានាធិបតីរ៉ូណាល់ រីហ្គេន បានអញ្ជើញគណៈប្រតិភូរបស់មូចាហ៊ីឌីន ទៅទស្សនកិច្ចនៅវិមានប្រធានាធិបតី ។ នៅពេលថ្លែងទៅកាន់អ្នកយកសារព័ត៌មាន លោកប្រធានាធិបតីបានហៅភ្ញៀវរបស់គាត់ថាជា "អ្នកតស៊ូដើម្បីសន្តិភាព" ។ អូសាម៉ា ប៊ីនឡាដិន ក៏បានគោរពសរសើរចំពោះសហរដ្ឋអាមេរិកដែលបានជួយគាំទ្រគាត់ក្នុងការបង្កើតក្រុមមូចាហ៊ីឌីន ។ គាត់បានថ្លែងថា "ខ្ញុំបានបង្កើតជំរំទីមួយរបស់ខ្ញុំជាកន្លែងដែលអ្នកស្ម័គ្រចិត្តទាំងឡាយបានទទួលការបង្ហឹកដោយជនជាតិប៉ាគីស្ថាននិងភ្នាក់ងារសហរដ្ឋអាមេរិក ។ យើងបានទទួលការឧបត្ថម្ភគ្រឿងសព្វាវុធពីអាមេរិកនិងទទួលការឧបត្ថម្ភថវិកាពីអារ៉ាប៊ីសាអ៊ូឌីត" ។

ប៊ីនឡាដិន បានចូលរួមនៅក្នុងក្រុមមូចាហ៊ីឌីននៅឆ្នាំ១៩៨០ ពេលដែលមានអាយុ២៣ឆ្នាំ ។ គាត់បានក្លាយជាមេដឹកនាំក្រុមនេះបន្ទាប់ពីពេលដែលកងទ័ពសូវៀតបានដកចេញពីប្រទេសអាហ្វហ្កានីស្ថាននៅខែមេសា ឆ្នាំ១៩៨៨ ។ មួយឆ្នាំក្រោយមកប៊ីនឡាដិន បានបង្កើតក្រុមអាល់កៃដា ។ ក្រុមនេះបានប្រើប្រាស់រូងក្រោមដីដ៏ខ្វាត់ខ្វែងកប់យ៉ាងជ្រៅនៅក្រោមជួរភ្នំនៅជិតព្រំដែនប៉ាគីស្ថានធ្វើជាបន្ទាយ ។ បន្ទាយនេះជាកន្លែងរក្សាអាវុធដ៏ធំ ជាកន្លែងហ្វឹកហ្វឺនកងកម្លាំង និងជាមជ្ឈមណ្ឌលសុខភាពរបស់ក្រុមមូចាហ៊ីឌីនក្រោមការឧបត្ថម្ភរបស់សេ.អ៊ី.អា ។ នៅខែសីហា ឆ្នាំ១៩៩០ អ៊ីរ៉ាក់បានឈ្លានពានប្រទេសគុយវ៉ែត ។ ប៊ីនឡាដិន និងមេដឹកនាំសាសនាអ៊ីស្លាមមួយចំនួន ចាប់ផ្តើមមិនសប្បាយចិត្តនិងបានថ្កោលទោសសហរដ្ឋអាមេរិកបន្ទាប់ពីប្រទេសអារ៉ាប៊ីសាអ៊ូឌីតយល់ព្រមអនុញ្ញាតឲ្យកងទ័ពរបស់សហរដ្ឋអាមេរិកបោះទីតាំងមូលដ្ឋានយោធានៅលើប្រទេសរបស់ខ្លួនដែលត្រូវបានចាត់ទុកថាជាដែនដីស័ក្តិសិទ្ធិរបស់សាសនាអ៊ីស្លាម ។ ចាប់តាំងពីពេលនោះមក ថ្នាក់ដឹកនាំរបស់អាល់កៃដាបានចេញបទបញ្ជាសាសនាអ៊ីស្លាមមួយអំពាវនាវឲ្យធ្វើសង្គ្រាមសាសនាប្រឆាំងនឹងសហរដ្ឋអាមេរិក ។ ជាឧទាហរណ៍ នៅក្នុងបទបញ្ជាសាសនាអ៊ីស្លាមមួយដែលចេញនៅឆ្នាំ១៩៩៦ ប៊ីនឡាដិន បានហៅសហរដ្ឋអាមេរិកថាជា"ក្បាលរបស់សត្វពស់" ដែលត្រូវតែកាត់ចោល ។ ពេលវេលាកាន់តែទៅមុខ កំហឹងនិងការស្អប់របស់ថ្នាក់ដឹកនាំអាល់កាអ៊ីដាចំពោះសហរដ្ឋអាមេរិកកាន់តែជ្រាលជ្រៅទៅៗ ។ នៅក្នុងឆ្នាំ១៩៩៨ ប៊ីនឡាដិន បានប្រកាសសង្គ្រាមសាសនាប្រឆាំងនឹង "ជនជាតិជ្វីហ្វនិងអ្នកដែលឈ្លានពានដែនដីស័ក្តិសិទ្ធិ" ។ ប៊ីនឡាដិន បានជំរុញឲ្យជនមូស្លីមវាយប្រហារទៅលើ "ជនជាតិអាមេរិកនិងសម្ព័ន្ធមិត្ត ទាំងជនស៊ីវិលនិងយោធា" ។ ប៊ីនឡាដេន

បានចង្អុលបង្ហាញមូលហេតុសំខាន់ចំនួន៤នៅពីក្រោយសង្គ្រាមសាសនានេះ គឺៈ ការតាំងមូលដ្ឋានទ័ពរបស់សហរដ្ឋអាមេរិកនៅក្នុងទឹកដីអារ៉ាប៊ីសាអ៊ូឌីត, ការគាំទ្ររបស់អង្គការសហប្រជាជាតិក្នុងការដាក់ទណ្ឌកម្មប្រឆាំងអ៊ីរ៉ាក់, ការគាំទ្ររបបជិះជាន់នៅអារ៉ាប់, និងការគាំទ្រអ៊ីស្រាអែលខាងវិស័យយោធា ។ អែកបាល់ អាម៉ាដ, ណម ឆមស្គី, ស្វាវ៉ូជេ ហ្ស៊ីហ្សិក, ម៉ាំដានី, និង អាប៊ូខាលីល ហាក់បីដូចជាយល់ស្របជាមួយគំនិតរបស់ ប៊ីនឡាដិន ។ នៅពេលដែល ប៊ីនឡាដិន លេចមុខនៅលើកញ្ចក់ទូរទស្សន៍អាល់ហ្សាសៀរ៉ានៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៤ ពោលគឺ៤ថ្ងៃមុនពេលបោះឆ្នោតជ្រើសរើសប្រធានាធិបតីរបស់សហរដ្ឋអាមេរិក គាត់បានអះអាងសាជាថ្មីអំពីមូលហេតុនៃការវាយប្រហារនៅថ្ងៃទី១១ ខែកញ្ញា ។ ប៊ីនឡាដិន បាននិយាយថា គាត់ជាអ្នកទទួលខុសត្រូវចំពោះការវាយប្រហារអគារពាណិជ្ជកម្មនៅទីក្រុងញូវយ៉ក ។ គាត់បានបន្ថែមទៀតថា គាត់ចង់ឲ្យសហរដ្ឋអាមេរិកភ្លក្សរសជាតិ "ដូចដែលយើងធ្លាប់បានភ្លក្សអំឡុងពេលអ៊ីស្រាអែលឈ្លានពានលីបង់នៅឆ្នាំ១៩៨២" ។

នៅក្នុងអត្ថបទអំពីទស្សនៈរបស់ជនជាតិអាមេរិកចំពោះការវាយប្រហារថ្ងៃទី១១ ខែកញ្ញា ទៅលើទឹកដីអាមេរិក ហារី ជ្រេាន បានថ្កោលទោសការវាយប្រហារនោះ ។ ប៉ុន្តែ គាត់ហាក់ដូចជាយល់ស្របជាមួយ ប៊ីនឡាដិន អំពីនយោបាយក្រៅប្រទេសរបស់សហរដ្ឋអាមេរិកដែលហាក់បីដូចជាមានលក្ខណៈឈ្លានពាន ។ គាត់បានសរសេរថា "ការវាយប្រហារភេរវកម្មទៅលើសហរដ្ឋអាមេរិកគឺជាមហាសោកនាដកម្មមួយ ប៉ុន្តែនេះមិនមែនជាការណ៍ដែលគួរឲ្យភ្ញាក់ផ្អើលនោះទេ... នយោបាយក្រៅប្រទេសរបស់យើងបានឆ្លងអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ ។ វាគឺជាបញ្ហាពេលវេលាតែមួយគត់ រហូតដល់ជនជាតិអាមេរិកជួបប្រទះពេលវេលានេះដោយខ្លួនឯង ។ វាជាសោកនាដកម្មដ៏គួរឲ្យសង្វេគមួយ នៅពេលដែលអ្នកគ្មានកំហុសទទួលរងការឈឺចាប់ជាញឹកញយដោយសារតែបាបកម្មរបស់អ្នកដែលធ្វើខុស" ។

សម្រាប់ជនជ្រុលនិយមដូចជា ប៊ីនឡាដិន និងមនុស្សរបស់គាត់ ព្រឹត្តិការណ៍ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១ ជាសង្គ្រាមសាសនាអ៊ីស្លាមប្រឆាំងនឹងសហរដ្ឋអាមេរិក ។ នៅក្នុងសេចក្តីថ្លែងការណ៍ចេញបទបញ្ជាសាសនាអ៊ីស្លាមប្រឆាំងនឹងជនជាតិជ្វីហ្វនិងអ្នកដែលឈ្លានពានដែនដីស័ក្តិសិទ្ធិកាលពីខែកុម្ភៈឆ្នាំ១៩៩៨ ប៊ីនឡាដិន បានអះអាងថា "បទបញ្ជាឲ្យសម្លាប់ជនជាតិអាមេរិកនិងសម្ព័ន្ធមិត្តទាំងស៊ីវិលនិងយោធា គឺជាកាតព្វកិច្ចរបស់ជនមូស្លីមគ្រប់រូបនៅគ្រប់ប្រទេសទាំងអស់ ដើម្បីរំដោះព្រះវិហារអាល់អាក់សានិងព្រះវិហារស័ក្តិសិទ្ធិ "មិកកា" ពីកណ្តាប់ដៃរបស់អាមេរិកនិងសម្ព័ន្ធមិត្ត និងដើម្បីឲ្យកងទ័ពរបស់ប្រទេសទាំងនោះដកចេញពីទឹកដីអ៊ីស្លាមទាំងអស់ ដើម្បីឲ្យប្រទេសទាំងអស់នោះចាញ់សង្គ្រាមនិងមិនអាចគំរាមកំហែងជនមូស្លីមណាម្នាក់បាន" ។ នេះគឺជាសង្គ្រាមរវាងសាសនាអ៊ីស្លាមនិងលោកខាងលិច ។

ជនមូស្លីមខ្លះបានយល់ស្របជាមួយ ប៊ីនឡាដិន ហើយថែមទាំងបានកោតសរសើរគាត់ទៀតផង ។ ភ័ស្តុតាងល្អបំផុតគឺអាចរកឃើញនៅក្នុងសារព័ត៌មានរបស់អារ៉ាប់ បន្ទាប់ពីការវាយប្រហារនោះ ។ ជាក់ស្តែង កាសែតឌីណេស្សិនរបស់ប៉ាគីស្ថានបានបញ្ជាក់ថាៈ "ថ្ងៃទី១១ ខែកញ្ញា គឺមិនមែនជាភេរវកម្មដែលមិនចេះគិតនោះទេ ។ វាគឺជាការឆ្លើយតប ការសងសឹក និងការដាក់ទណ្ឌកម្ម" ។ ទោះបីជាយ៉ាងណាក៏ដោយ ជនមូស្លីមភាគច្រើននៅក្នុងពិភពលោកមិនយល់ស្រប និងបានថ្កោលទោសការវាយប្រហារភេរវកម្មថ្ងៃទី១១ ខែកញ្ញា ។ អាយ៉េ ណេអឺ ដែលជាអតីតនាយកអង្គការឃ្លាំមើលសិទ្ធិមនុស្សបានពន្យល់ថា វិបត្តិថ្ងៃទី១១ ខែកញ្ញា មិនមែនមានប្រភពពីសាសនាអ៊ីស្លាមទេ ប៉ុន្តែមានប្រភពពី "អ្នកជឿស៊ប់និងអ្នកជ្រុលនិយមដែលជាដៃគូសម័យថ្មីរបស់ណាហ្ស៊ី" ដែលបានចាត់ទុកភាពទំនើបជាសត្រូវរបស់ខ្លួន ។

ជនមូស្លីមនិយមកណ្តាលបានយល់ស្របជាមួយនឹងការយល់ឃើញរបស់ ណេអឺ ។ ក្រុមនេះបានលើកឡើងថា អ្វីដែលជនមូស្លីមមួយចំនួនបាននិងកំពុងតែធ្វើក្នុងនាមសាសនាអ៊ីស្លាមនោះគឺមិនមានអ្វីទាក់ទងទៅនឹងសាសនាអ៊ីស្លាមទេ ។ សម្រាប់ក្រុមនេះ ប៊ីនឡាដិន មិនមែនជាវីរបុរសសាសនាទេ ប៉ុន្តែជាជនជ្រុលនិយមនិងជាសត្រូវរបស់ជនមូស្លីមដែលស្រលាញ់សន្តិភាព ។ ជនមូស្លីមកណ្តាលក៏បានថ្កោលទោស ប៊ីនឡាដិន និងជនជ្រុល

និយមទាំងឡាយដែលបានយកសាសនាមកបញ្ចូលគ្នាជាមួយនយោបាយដើម្បីបម្រើឲ្យមូលហេតុនយោបាយ ។ ក្រុមនេះបានចង្អុលបង្ហាញថា នយោបាយរបស់ ប៊ីនឡាដិន និងអាល់កៃដា បានអះអាងអំពីសង្គ្រាមសាសនាឬជីហាដប្រឆាំងនឹងសត្រូវរបស់សាសនាអ៊ីស្លាម ប៉ុន្តែតាមពិតពាក្យថា "ជីហាដ" មានន័យថាជា "ការតស៊ូ" មិនមែនមានន័យថាជាសង្គ្រាមសាសនានោះទេ ។ សង្គ្រាមសាសនាមិនដែលមាននិយាយនៅក្នុងគម្ពីរគូរៈអានទេ ។ ពាក្យថា ជីហាដ បើតាមទស្សនៈអ៊ីស្លាមអាចជា ជីហាដអាក់ប៊ើរ (*the greater Jihad* មានន័យថាជាការតស៊ូប្រឆាំងនឹងភាពទន់ខ្សោយរបស់ខ្លួនឯង) និង ជីហាដអាសហ្គា (*the lesser Jihad* គឺការពារខ្លួនឯង) ។ សម្រាប់ អូសាម៉ា ប៊ីនឡាដិន និងជនមូស្លីមជ្រុលនិយម ជីហាដអាសហ្គាបែរជាមានន័យយ៉ាងសាមញ្ញថាជាសង្គ្រាមសាសនាដែលមានចែងនៅក្នុងគម្ពីរគូរៈអាន ។ ជនមូស្លីមនិយមកណ្តាលបានចង្អុលបង្ហាញថា ពាក្យប្រៀនប្រដៅរបស់សាសនាអ៊ីស្លាមបានហាមឃាត់មិនឲ្យមានការសម្លាប់ជនស៊ីវិលទេ ។ សាសនាអ៊ីស្លាមមានប្រពៃណីអត់ឱននិងការដឹកនាំបែបកណ្តាល ជាក់ស្តែងការគ្រប់គ្រងបែបមូស្លីមនៅប្រទេសអេស្ប៉ាញកាលពីសតវត្សទី៩ និងទី១០ ព្រមទាំងពហុនិយមនិងភាពចម្រុះវប្បធម៌របស់ចក្រភពអូតូម៉ង់ ។ អាប៊ូខាលីល បានពន្យល់ថាមានជនមូស្លីមម្នាក់បានទៅប្រាប់អ្នកនាំសាររបស់ព្រះជាម្ចាស់អំពីការសម្រេចចិត្តរបស់គាត់ក្នុងការកាន់អាវុធប្រយុទ្ធនៅក្នុងសមរភូមិដើម្បីការពារសាសនាអ៊ីស្លាម ។ អ្នកនាំសាររបស់ព្រះជាម្ចាស់បានផ្តល់ដំបូន្មានទៅឲ្យបុរសនោះឲ្យធ្វើជីហាដ (ការតស៊ូ) "ដើម្បីឪពុកម្តាយរបស់គាត់" មានន័យថាការថែរក្សាឪពុកម្តាយ



ចាស់ជរារបស់គាត់ទើបជាជីហាដពិតប្រាកដ ។

សរុបមក ជនអ៊ីស្លាមជ្រុលនិយមដូចជា អូសាម៉ា ប៊ីនឡាដិន មិនមែនតំណាងឲ្យសាសនាអ៊ីស្លាមដែលមានលក្ខណៈជាប្រវត្តិសាស្ត្រនោះទេ សូម្បីតែនៅក្នុងទម្រង់ដ៏ចម្រូងចម្រាស់របស់សាសនានេះក៏ដោយ ។ ភាពជ្រុលនិយមរបស់ ប៊ីនឡាដិន គឺចង់បង្កើតសាសនាអ៊ីស្លាមមួយប្រភេទបន្ទាប់ពីគំរូរបស់រដ្ឋាភិបាលអាហ្វហ្កានីស្ថាន ។ ភាពជ្រុលនិយមនេះក៏យកគំរូតាមរដ្ឋាភិបាលជ្រុលនិយមស៊ូដង់ដែលបានបង្កើតសង្គ្រាមភេរវកម្មប្រឆាំងនឹងអ្នកកាន់សាសនាគ្រិស្តរាប់លាននាក់នៅក្នុងប្រទេស ។ ភាពជ្រុលនិយមក្នុងការប៉ុនប៉ងបង្កើតសាសនាអ៊ីស្លាមមួយប្រភេទទៀតគឺរំលោភទៅលើច្បាប់របស់សាសនាអ៊ីស្លាមដែលគោរពដោយជនមូស្លីមភាគច្រើន ។ ភាពជ្រុលនិយមនេះបាន “សើចចំអកឲ្យភាពសុខដុមរមនានៃសន្តិភាពនិងការអត់ឱន”ដែលជានិមិត្តរូបឲ្យភាគច្រើននៃប្រវត្តិសាស្ត្រសាសនាអ៊ីស្លាម ។

ដូចដែលបានកត់សម្គាល់នៅក្នុងសាសនានេះ ការគាំទ្ររបស់សហរដ្ឋអាមេរិកចំពោះក្រុមមូចាហ៊ីឌីនគឺជាបុព្វហេតុចម្បងនៃការវាយប្រហារថ្ងៃទី១១ ខែកញ្ញា ។ ប្រសិនបើសហរដ្ឋអាមេរិកមិនបានបង្កើតក្រុមមូចាហ៊ីឌីន នោះក៏គ្មានក្រុមអាល់កៃដា ហើយក៏គ្មានការវាយប្រហារអគារពាណិជ្ជកម្មនៅទីក្រុងញូវយ៉ករបស់សហរដ្ឋអាមេរិកដែរ ។

មូលហេតុសំខាន់មួយទៀតគឺនយោបាយក្រៅប្រទេសរបស់សហរដ្ឋអាមេរិកចំពោះតំបន់មជ្ឈិមបូព៌ា ។ នយោបាយនេះមិនត្រឹមតែបណ្តាលឲ្យអ្នករស់នៅតំបន់មជ្ឈិមបូព៌ាអស់សង្ឃឹមប៉ុណ្ណោះទេ ថែមទាំងខឹងសម្បាចំពោះសហរដ្ឋអាមេរិកថែមទៀត ។ ជំពូកនេះបានរៀបរាប់អំពីមូលហេតុចម្បងៗពីរនៃការវាយប្រហារថ្ងៃទី១១ ខែកញ្ញា ប្រឆាំងនឹងសហរដ្ឋអាមេរិក ហើយជំពូកបន្ទាប់ទៅទៀតនេះនឹងពិភាក្សាអំពីអារ្យធម៌របស់សាសនាអ៊ីស្លាម ។

## ២) តើអារ្យធម៌របស់អ៊ីស្លាមពិតជាមានមែនឬទេ?

ហាន់ធីងតុន បានឲ្យនិយមន័យអារ្យធម៌ថាជា “បណ្តុំមនុស្សដែលមានវប្បធម៌ខ្ពស់បំផុត ហើយសញ្ញាណនៃវប្បធម៌ទាំងអស់នេះបានបែងចែកដាច់ពីគ្នារវាងមនុស្សនិងពពួកសត្វមានជីវិតផ្សេងទៀត ។ ពាក្យ“អារ្យធម៌”ត្រូវបានឲ្យនិយមន័យដោយផ្អែកលើធាតុផ្សំជាទូទៅមានដូចជា ភាសា ប្រវត្តិសាស្ត្រ សាសនា ទំនៀមទម្លាប់ ស្ថាប័ន និងទៅលើលក្ខណៈសម្គាល់ផ្ទាល់ខ្លួនរបស់មនុស្ស” ។ សម្រាប់ ហាន់ធីងតុន អារ្យធម៌ចម្បងៗមានចំនួន៧ ឬ៨ ដូចជាៈ អារ្យធម៌លោកខាងលិច អារ្យធម៌អ៊ីស្លាម អារ្យធម៌ហិណ្ឌូ អារ្យធម៌ចិន អារ្យធម៌ជប៉ុន និងអារ្យធម៌ស្លាវិក-អ័រតូដុក ដែលជាអារ្យធម៌របស់អាមេរិកឡាទីននិងអាចជារបស់អាហ្វ្រិកដែរ ។ អារ្យធម៌ទាំង៨នេះមានទម្រង់ស្នូលរបស់ខ្លួនលើកលែងតែអារ្យធម៌របស់អាមេរិកឡាទីន អាហ្វ្រិក និងអ៊ីស្លាម ។ ផ្ទុយទៅវិញ អែដវឺត ដាប់ប៊ីលយូ សេដ និង អាប៊ូខាលីល មិនយល់ស្របជាមួយនឹងគំនិតរបស់ ហាន់ធីងតុន ទេ ។ ការរិះគន់របស់អ្នកទាំងពីរទៅលើនិក្ខេបបទរបស់ ហាន់ធីងតុន គឺផ្តោតទៅលើទំនាក់ទំនងរវាងវប្បធម៌និងអារ្យធម៌ ។ អ្នកទាំងពីរជំទាស់ថា វប្បធម៌និងអារ្យធម៌មានទំនាក់ទំនងគ្នា ហើយរាល់ការប៉ុនប៉ងទាំងឡាយដើម្បីស្វែងយល់ពីពិភពលោកសព្វថ្ងៃនេះនៅក្នុងបរិបទវប្បធម៌និងនយោបាយគឺមិនត្រឹមត្រូវទេ ។ សេដ បានពន្យល់ថា វប្បធម៌ត្រូវបានយល់ថាជាធាតុចម្រុះដែលមានច្រើនបំផុត ។ អំពីទំនាក់ទំនងរវាងវប្បធម៌និងអារ្យធម៌ សេដ បានបំភ្លឺថា វប្បធម៌និងអារ្យធម៌មាន“ទំនាក់ទំនងនឹងគ្នានិងពឹងផ្អែកគ្នាទៅវិញទៅមកដែលពិបាកនឹងបរិយាយពីភាពខុសគ្នា” ។ ហេតុដូច្នេះ ការនិយាយអំពីអារ្យធម៌អ៊ីស្លាមឬអារ្យធម៌លោកខាងលិចគឺមានភាពជ្រុលនិយម ។ សេដ បានចង្អុលបង្ហាញថា “នេះគឺការពិតចំពោះសហរដ្ឋអាមេរិក ហើយការពិតនេះមិនអាចបរិយាយឲ្យពិស្តារបានទេសព្វថ្ងៃនេះ លើកលែងតែប្រវត្តិសាស្ត្រដ៏មានបញ្ហានៃការធ្វើចម្បាំង ការសម្លាប់រង្គាល និងជោគជ័យនយោបាយនិងវប្បធម៌សំខាន់ៗ ។

ការរិះគន់របស់ អេមរ៉ាន ឃ្មីរស៊ី និង ម៉ៃឃើល អេ សែល និងការរិះគន់របស់ អែកបាល់ អាម៉ាដ ចំពោះការអះអាងរបស់ហាន់ធីងតុន គឺមានមូលដ្ឋាននៅលើអត្តិភាពរបស់រដ្ឋ ។ អ្នករិះគន់ទាំងបីរូបបានអះអាងថា រដ្ឋដើរតួនាទីយ៉ាងសកម្មនៅក្នុងពិភពនយោបាយ ។ អ្នកទាំងបីបានចង្អុលបង្ហាញថា ពិភពលោកដែល

មានជនមូស្លីមជាងមួយពាន់លាននាក់ដែលភាគច្រើនមិនមែនជាជនជាតិអារ៉ាប់ គឺខុសប្លែកគ្នាយ៉ាងខ្លាំងហើយមានអាទិភាពនិងវប្បធម៌ផ្សេងៗគ្នា ។ ជាងនេះទៅទៀត ពិភពរបស់មូស្លីមក៏ដូចជាផ្នែកផ្សេងៗទៀតនៃពិភពលោកដែរ គឺគ្របដណ្តប់ដោយរដ្ឋដែលជំរុញដោយផលប្រយោជន៍ផ្ទាល់ខ្លួន ហើយដែលភាគច្រើនតែងតែមានជម្លោះនឹងគ្នាច្រើនជាងរដ្ឋនៅលោកខាងលិច ។ ជាក់ស្តែង ជម្លោះរវាងនិកាយផ្សេងៗរបស់សាសនាអ៊ីស្លាមដូចជារវាងនិកាយស៊ុននីនិងនិកាយស៊ីអ៊ីត ឬរវាងជនមូស្លីមនិយមកណ្តាលនិងជនមូស្លីមនិយមជ្រុល ។

បើយោងទៅតាម ម៉ាំដានី ជនមូស្លីមនិយមជ្រុលមាននៅក្នុងសាសនាអ៊ីស្លាមនិកាយវ៉ាហាប៊ីដែលភាគច្រើនរស់នៅក្នុងប្រទេសអារ៉ាប៊ីសាអ៊ូឌីត ជាប្រទេសដែល អូសាម៉ា ប៊ីនឡាដិន ចាប់កំណើតនិងធំធាត់ ។ សាសនាអ៊ីស្លាមនិកាយវ៉ាហាប៊ីគឺជានិកាយស៊ុននីដែលប្រកាន់វិន័យចាស់ដ៏តឹងរ៉ឹងដែលត្រូវបាននាំទៅផ្សព្វផ្សាយជាលើកដំបូងនៅអាហ្វហ្កានីស្ថាន និងបន្ទាប់មកនៅសហរដ្ឋអាមេរិក ។ ចំពោះ ម៉ាំដានី អំពើភេរវកម្មគឺជាការយល់ឃើញតាមន័យត្រង់របស់សាសនាអ៊ីស្លាមនិកាយវ៉ាហាប៊ី មិនមែនរបស់សាសនាអ៊ីស្លាមទាំងមូលនោះទេ ។ គាត់បានបន្ថែមទៀតថា កម្លាំងរបស់ ប៊ីនឡាដិន បានមកពីសេចក្តីថ្លែងការណ៍បែបនយោបាយជាជាងបានមកពីសាសនា ។ ភាពជ្រុលនិយមរបស់ ប៊ីនឡាដិន គឺភាគច្រើនដូចគ្នាទៅនឹង ស្តាលីន អ៊ីត្លែរ និង ម៉ៅ ច្រើនជាងដូចសាសនាអ៊ីស្លាម ។ ប៊ីនឡាដិន ចង់ប្រើប្រាស់សាសនាដើម្បីគោលបំណងបដិវត្តន៍ ហើយទាំងប៊ីនឡាដិន ទាំង ស្តាលីន អ៊ីត្លែរ និងម៉ៅ ហាក់បីដូចជាបានធ្វើសង្គ្រាមជាមួយប្រជាជនខ្លួនឯង ។ ប៊ីនឡាដិន និងអ្នកដើរតាមគាត់គឺជាមនុស្សអាក្រក់ ប៉ុន្តែសាសនាអ៊ីស្លាមមិនមែនអាក្រក់ទេ ។

ជាងនេះទៅទៀត ភេរវករក៏បានរៀបចំផែនការវាយប្រហារភេរវកម្មទៅលើរដ្ឋាភិបាលមូស្លីមជាច្រើន រួមទាំងរដ្ឋាភិបាលអារ៉ាប៊ីសាអ៊ូឌីតនិងអេហ្ស៊ីបផង ។ សំខាន់ជាងនេះទៀត ប្រទេសមូស្លីមជាច្រើនបានគាំទ្រសង្គ្រាមប្រឆាំងភេរវកម្មរបស់សហរដ្ឋអាមេរិក និងបានចូលរួមជាមួយក្រុមសម្ព័ន្ធមិត្តដែលដឹកនាំដោយសហរដ្ឋអាមេរិកដើម្បីប្រយុទ្ធជាមួយក្រុមអាល់កៃដាទៀតផង មានដូចជា ប្រទេសប៉ាគីស្ថាន ឥណ្ឌូនេស៊ី និងអាល់ហ្សេរីជាដើម ។ ប្រទេសមូស្លីមទាំងនោះចូលរួមសង្គ្រាមប្រឆាំងភេរវកម្មជាមួយសហរដ្ឋអាមេរិក ដោយសារតែប្រទេសទាំងនោះដឹងថា ប្រតិបត្តិការយោធារបស់សហរដ្ឋអាមេរិកគឺដើម្បីការពារនិងជួយសង្គ្រោះជនមូស្លីម ។ ឧទាហរណ៍ដ៏ជាក់ច្បាស់គឺអន្តរាគមន៍របស់សហរដ្ឋអាមេរិកដើម្បីបញ្ចប់ការឈ្លានពានរបស់អ៊ីរ៉ាក់ទៅលើប្រទេសគុយវ៉ែតនៅក្នុងឆ្នាំ១៩៩១ និងក្រោយមកទៀតអន្តរាគមន៍ឆ្នាំ១៩៩៩ ដើម្បីបញ្ចប់"ការបោសសម្អាតជាតិពន្ធ"មូស្លីមដោយជនជាតិស៊ែបដែលកាន់សាសនាគ្រិស្តនៅកូសូវ៉ូ ។

ជាចុងបញ្ចប់ បទសុន្ទរកថារបស់លោកប្រធានាធិបតី ចច ដាប់ប៊ែលយូ ប៊ូស អំពីសង្គ្រាមប្រឆាំងភេរវកម្ម គឺជាឧទាហរណ៍ដ៏ច្បាស់មួយទៀតក្នុងការបង្ហាញចេតនាបង្កើនទំនាក់ទំនងល្អរវាងសាសនាអ៊ីស្លាមនិងលោកខាងលិច ។ លោកប្រធានាធិបតីបានបន្ថែមថា សង្គ្រាមដែលដឹកនាំដោយសហរដ្ឋអាមេរិកគឺមិនមែនប្រឆាំងនឹងសាសនាអ៊ីស្លាមទេ ។ "សត្រូវរបស់អាមេរិកគឺមិនមែនជាមិត្តភក្តិមូស្លីមរបស់យើងទេ ហើយក៏មិនមែនជាមិត្តភក្តិអារ៉ាប់របស់យើងដែរ ។ សត្រូវរបស់យើងគឺជាបណ្តាញភេរវកម្មជ្រុលនិយមនិងរដ្ឋាភិបាលទាំងឡាយដែលគាំទ្របណ្តាញនេះ" ។

អាប៊ូខាលីល និង ម៉ាំដានី បានចង្អុលបង្ហាញថា កម្លាំងសំខាន់ៗដែលបន្ថែមទៅលើកម្លាំងរបស់ ប៊ីនឡាដិន និងអ្នកដើរតាមគាត់ គឺមិនមែនដោយសារសាសនាទេ ប៉ុន្តែដោយសារសេចក្តីថ្លែងការណ៍បែបនយោបាយអំពីការស្លាប់និងការឈឺចាប់ដែលបង្កឡើងដោយសហរដ្ឋអាមេរិកនិងសម្ព័ន្ធមិត្ត ។

## សេចក្តីសន្និដ្ឋាន

ដូចដែលបានបង្ហាញនៅក្នុងសេចក្តីផ្តើម ប្រព័ន្ធផ្សព្វផ្សាយមានតួនាទីសំខាន់ណាស់នៅក្នុងការធ្វើឲ្យកើតមានឡើងនូវវិបត្តិថ្ងៃទី១១ ខែកញ្ញា ។ ជាអកុសល ទាំងប្រព័ន្ធផ្សព្វផ្សាយរបស់លោកខាងលិចនិងអារ៉ាប់មិនមានចំណាប់អារម្មណ៍ក្នុងការបង្ហាញឲ្យឃើញពីភាពខុសគ្នារវាងសាសនាអ៊ីស្លាមនិងភេរវករ ឬរវាងលោកខាងលិចនិងសង្គ្រាមប្រឆាំងភេរវកម្ម ហើយព្រមទាំងមាន

ឆន្ទៈក្នុងការធ្វើឲ្យកើតឡើងនូវទស្សនៈដែលថាសាសនាអ៊ីស្លាម កំពុងតែធ្វើសង្គ្រាមជាមួយលោកខាងលិច ។ ជាងនេះទៅទៀត ប្រព័ន្ធផ្សព្វផ្សាយទាំងនេះបានធ្វើវិភាគពិភពលោកជាផ្នែកខាងកើតនិងខាងលិច ។ ថែដ ឧបភែល អ្នកផ្សាយពត៌មានរបស់ស្ថានីយ៍ទូរទស្សន៍អេប៊ីស៊ី បានសន្និដ្ឋានអំពីទំនាក់ទំនងរវាងស្ថានីយ៍ទូរទស្សន៍និងភេរវកម្មថាៈ

“ប្រសិនបើគ្មានស្ថានីយ៍ទូរទស្សន៍ ភេរវកម្មនឹងដូចជាដើមឈើដែលដួលរលំនៅក្នុងព្រៃដូច្នោះដែរ ។ គ្មាននរណាដឹង គ្មាននរណាឮ ហេតុដូច្នេះវាគ្មានមូលហេតុនឹងឲ្យភេរវកម្មកើតមាននោះទេ ។ ហើយប្រសិនបើគ្មានភេរវកម្ម ស្ថានីយទូរទស្សន៍ហាក់បីដូចជាបាត់បង់ព្រឹត្តិការណ៍ដ៏គួរឲ្យចាប់អារម្មណ៍បំផុតមួយ ។”

ទាក់ទងទៅនឹងប្រព័ន្ធផ្សព្វផ្សាយនិងការវាយប្រហារថ្ងៃទី១១ ខែកញ្ញា ទៅលើសហរដ្ឋអាមេរិក សាយែដ មែនសួហ៊ូសេន បានអះអាងថា ប្រព័ន្ធផ្សព្វផ្សាយបានបង្កើត“ភាពសមស្របគ្នា ដែលទាំងពីរនេះត្រូវបានជំរុញដោយរូបភាពហិង្សាយ៉ាងព្រៃផ្សៃ” ។ ហេតុដូច្នេះហើយ សកម្មភាពពេញនិយមរបស់ជនមូស្លីមត្រូវបានជំរុញដោយពត៌មានដែលផ្តោតលើអំពើហិង្សាដែលបង្កឡើងដោយក្រុមជនមូស្លីមខ្លះៗទាំងនៅក្នុងប្រទេសអ៊ីរ៉ាក់និងប៉ាឡេស្ទីន និងជួនកាលនៅកន្លែងផ្សេងៗទៀតក្នុងពិភពលោក អាស្រ័យទៅលើ“តម្លៃនៃពត៌មានអំពីការវាយប្រហារនេះ ។ មនុស្សមួយចំនួនដែលអះអាងថាខ្លួនជាអ្នកជំនាញការបានបន្តនិយាយបង្កាច់បង្ខូចជនមូស្លីមតាមរយៈការអធិប្បាយថាជនមូស្លីមទាំងអស់ជាភេរវជនឬអ្នកគាំទ្រភេរវជន ហើយការនិយាយបែបនេះធ្វើឲ្យស្ថានភាពកាន់តែអាក្រក់ឡើង ។ ”

តាមរយៈសញ្ញាដូចគ្នានេះដែរ ជនមូស្លីមកំពុងតែទទួលយកនូវរូបភាពយ៉ាងសម្បើមនិងជាបន្តបន្ទាប់អំពីរឿងរ៉ាវដែលទាហានអ៊ីស្រាអែលវាយប្រហារនិងសម្លាប់ជនជាតិប៉ាឡេស្ទីនឬទាហានរបស់សហរដ្ឋអាមេរិកដែលអនុវត្តដូចគ្នាចំពោះជនជាតិអ៊ីរ៉ាក់ ។ ហេតុដូច្នេះហើយ ជនមូស្លីមមានអារម្មណ៍ថា សង្គ្រាមនេះគឺប្រឆាំងនឹងជនមូស្លីម ។ នៅទីបញ្ចប់ ជនមូស្លីមទាំងនោះគិតថា ការវាយប្រហារទៅលើសហរដ្ឋអាមេរិកគឺវាយប្រហារដើម្បីសាសនាអ៊ីស្លាម “ហើយសកម្មភាពរបស់ជនមូស្លីមបើទោះបីជាសាហាវយ៉ាងណាក៏ប្រហែលជាអាចដោះសាបាន” ។ ជាក់ស្តែង កាសែតញូវយ៉កថែមបានសារភាពថា ខ្លួនក៏រួមចំណែកទទួលខុសត្រូវចំពោះការបកស្រាយមិនត្រឹមត្រូវបែបនោះយ៉ាងហោចណាស់ចំពោះការណ៍ដែលខ្លួនខកខាននៅក្នុងតបតចំពោះការអះអាងជាច្រើនដែលធ្វើឡើងដោយរដ្ឋបាលរបស់លោកប៊ូស ។

ហាន់ធីងតុន ក៏បានលើកឡើងអំពីលោកខាងលិចនិងសាសនាអ៊ីស្លាម ដោយបានចង្អុលបង្ហាញអំពីចំណុចខុសគ្នាសំខាន់ៗនៃវប្បធម៌និងសាសនារបស់លោកខាងលិចនិងពិភពអ៊ីស្លាម ។ ហាន់ធីងតុន ហាក់ដូចជាបានបែងចែកលោកខាងលិចពីអ៊ីស្លាមដូចជាបែងចែកខ្ពស់និងទាប ឬភាពបរិសុទ្ធនិងភាពក្រខ្វក់ ។ និយាយម្យ៉ាងទៀត គាត់ហាក់បីដូចជាគិតថាលោកខាងលិចជាជនអាណានិគមស្បែកសដែលបានចាត់ទុកជនជាតិឥណ្ឌាជាមនុស្សសាហាវ ។ បើតាម ហ្គារីក បេលលី ការអះអាងរបស់ ហាន់ធីងតុន អំពីលោកខាងលិចនិងសាសនាអ៊ីស្លាមត្រូវបានហៅថាជាការយល់ឃើញជ្រុលហួសហេតុមួយដែលថាជាតិសាសន៍ខ្លួនប្រសើរជាងជាតិសាសន៍ដទៃទៀត ។ ហ្ស៊ីហ្សិក និង ម៉ៃឃើល ហ្វូខូល បានពន្យល់អំពីការអះអាងរបស់ ហាន់ធីងតុន អំពីលោកខាងលិចនិងសាសនាអ៊ីស្លាម ដោយប្រើប្រាស់ទំនាក់ទំនងរវាង“អំណាច” និង“ការពិត” ។ អ្នកទាំងពីរនេះបានអះអាងថា “ការពិត” ជាទូទៅត្រូវបានឲ្យនិយមន័យដោយអ្នកមានអំណាច ។ អ្នកទាំងពីរក៏បានចង្អុលបង្ហាញថា អ្នកមានអំណាចបានប្រើប្រាស់ការពិតដើម្បីបង្កើតនយោបាយជាទូទៅ ហើយនៅទីបញ្ចប់បានគំរាមកំហែងនិងជិះជាន់អ្នកគ្មានអំណាច ។

ប្រសិនបើនយោបាយក្រៅប្រទេសរបស់អាមេរិកផ្អែកលើការវិភាគរបស់ ហាន់ធីងតុន និងផ្អែកលើរឿងមិនពិតដែលបង្កើតឡើងដោយប្រព័ន្ធផ្សព្វផ្សាយ នោះនយោបាយនេះប្រាកដជាឈរលើមូលដ្ឋានមួយសំដៅធ្វើឲ្យខូចអត្តន័យនិងបង្វែរទស្សនៈរបស់សាសនាអ៊ីស្លាម (និងជំនឿសាសនាជាទូទៅ) ព្រមទាំងបានបង្កើតឲ្យមានការប្រឈមមុខរវាងប្រទេសមូស្លីមនិងលោកខាង

លិច ។ ក្រៅពីនេះ សហរដ្ឋអាមេរិកគួរតែសហការជាមួយក្រុមមូស្លីមនិយមកណ្តាលដើម្បីបំបែកអំណាចរបស់ក្រុមមូស្លីមជ្រុលនិយម ។ សំខាន់ជាងនេះទៅទៀត ដើម្បីបន្តបង្ហាញពីភាពខុសគ្នារវាងភេរវកម្មនិងសាសនាអ៊ីស្លាម សហរដ្ឋអាមេរិកបានជួយធ្វើឲ្យស្របច្បាប់នូវប្រពៃណីសន្តិភាពទាំងឡាយរបស់សាសនាអ៊ីស្លាមរួមទាំងប្រពៃណីដែលប្រឆាំងនឹងភាពជ្រុលនិយម ។ ការណ៍នេះបណ្តាលឲ្យសហរដ្ឋអាមេរិកអាចធ្វើឲ្យភេរវករនៅឯកោនិងចុះចាញ់ ហើយស្របពេលជាមួយគ្នានេះ ក៏បានបង្កើតកម្មវិធីផ្សេងៗដើម្បីកាត់បន្ថយភាពជ្រុលនិយមនៅក្នុងសាសនាអ៊ីស្លាម ។

ជាងនេះទៅទៀត សហរដ្ឋអាមេរិកគួរតែចៀសវាងភាពជ្រុលហួសហេតុនៃការអនុវត្តបទដ្ឋានទ្វេដង ។ អែកបាល់ អាម៉ាដ បាននិយាយថា ប្រសិនបើសហរដ្ឋអាមេរិកនៅតែបន្តអនុវត្តបទដ្ឋានទ្វេដងទៀត «សហរដ្ឋអាមេរិកនឹងទទួលរងការជះត្រឡប់មកវិញនូវបទដ្ឋាននេះជាមិនខាន» ។ អែកបាល់ អាម៉ាដ ក៏បានស្នើសុំឲ្យសហរដ្ឋអាមេរិកយកករណីរបស់ប្រទេសអ៊ីស្រាអែលមកពិចារណាផង ។ សហរដ្ឋអាមេរិកមិនគួរអនុញ្ញាតឲ្យយោធាអ៊ីស្រាអែលគ្រប់គ្រងលើប្រជាជនប៉ាឡេស្ទីនទៀតទេ ។ សហរដ្ឋអាមេរិកគួរតែនាំអ៊ីស្រាអែលនិងប៉ាឡេស្ទីនទៅកាន់តុចរចាសន្តិភាពនិងបញ្ចប់ជម្លោះទឹកដីកាន់តែឆាប់កាន់តែប្រសើរ ។ សង្គ្រាមនេះគឺមានផលអាក្រក់ចំពោះប្រទេសអ៊ីស្រាអែល ប្រទេសប៉ាឡេស្ទីន និងសហរដ្ឋអាមេរិក ។ សហរដ្ឋអាមេរិកក៏គួរតែជួយនាំយកលទ្ធិប្រជាធិបតេយ្យដ៏ពិតប្រាកដមួយទៅកាន់ប្រទេសអាហ្វហ្គានីស្ថាននិងប្រទេសអ៊ីរ៉ាក់ ។ ស្ថិរភាពនិងការកសាងប្រទេសនៅក្នុងប្រទេសទាំងពីរនេះនឹងជួយកាត់បន្ថយការគំរាមកំហែងផ្នែកសន្តិសុខពីសំណាក់ជនអ៊ីស្លាមជ្រុលនិយមចំពោះលោកខាងលិច និងជាពិសេសចំពោះសហរដ្ឋអាមេរិក ។ អាប៊ូខាលីលបានសន្និដ្ឋានថា «ការកែប្រែគោលនយោបាយទាំងនោះនឹងអាចជួយធ្វើឲ្យប្រសើរឡើងនូវស្ថានភាពរស់នៅរបស់មនុស្សរាប់លាននាក់នៅលើពិភពលោកនេះ នឹងអាចជួយបង្កើតឲ្យមាននូវសន្តិភាពនិងសុវត្ថិភាពដែលមិនអាចសម្រេចបានតាមរយៈយុទ្ធនាការយោធា» ។ អែកបាល់ អាម៉ាដ បាននិយាយយ៉ាងច្រើនដោយផ្តោតទៅលើចំណុចសំខាន់ «ភេរវកម្មគឺជាបញ្ហានយោបាយដែលត្រូវតែរកដំណោះស្រាយបែបនយោបាយនិងតាមរយៈការទូត» ។ ជាចុងក្រោយ ចំណុចសំខាន់បំផុតសម្រាប់គ្រប់គ្នាទាំងជនមូស្លីមនិងអ្នកបស្ចិមប្រទេសនោះគឺត្រូវតែជឿជាក់ថាមិនមាន«ការប៉ះទង្គិចនៃអារ្យធម៌»រវាងលោកខាងលិចនិងសាសនាអ៊ីស្លាមទេ ហើយយើងត្រូវតែរក្សាកុំឲ្យមានការប៉ះទង្គិចអារ្យធម៌នេះ ។

**អៀវ ម៉េងទ្រី**

# សេចក្តីប្រកាសរកបងប្អូន

នាងខ្ញុំឈ្មោះ លាវ សាមឿន អាយុ៤៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិក្រាំងដូង ឃុំសំរោង ស្រុកបន្ទាយមាស ខេត្តកំពត ។ ឪពុកឈ្មោះ លាវ ឡៃ (ស្លាប់) និងម្តាយឈ្មោះ ណុប សប (ស្លាប់ឆ្នាំ២០០២) ។ នាងខ្ញុំមានបងប្អូនប្រាំបីនាក់ៈ ១)លាវ ស៊ីណៃ ភេទស្រី (បាត់ខ្លួន) ២)រូបនាងខ្ញុំ លាវ សាមឿន ៣)លាវ ប៉ក់ ភេទប្រុស ៤)លាវ ប៉ោក ភេទប្រុស ៥)លាវ ពីន ភេទប្រុស ៦)លាវ ស្រី ភេទស្រី ៧) លាវ ចិន ភេទស្រី និង ៨)លាវ មន ភេទស្រី ។

នាងខ្ញុំសុំសួររកបងស្រីឈ្មោះ លាវ ស៊ីណៃ ដែលបានចូលបដិវត្តន៍ខ្មែរក្រហមនៅខេត្តកំពតក្នុងឆ្នាំ១៩៧៥ ក្រោយមកអង្គការផ្សំផ្គុំគាត់ឲ្យមានគ្រួសារ ។ នាងខ្ញុំក៏បានបែកពីគាត់តាំងពីពេលនោះមក ។ រហូតមកដល់សព្វថ្ងៃនេះនាងខ្ញុំមិនដែលបានទទួលដំណឹងអ្វីសោះពីគាត់ ។ ប្រសិនបើបងប្អូនឬញាតិមិត្តណាបានស្គាល់ឬបានឮដំណឹងអំពីឈ្មោះខាងលើនេះ សូមមេត្តាផ្តល់ព័ត៌មានមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ឬតាមទូរស័ព្ទលេខ (៨៥៥) ០២៣ ២១១ ៨៧៥ ។

សូមអរគុណ ។

# ការប្រល័យពូជសាសន៍ខ្លួនឯង

នៅក្នុងយោបល់ទៅលើសៀវភៅ«ការផ្សះផ្សានៅកម្ពុជា» របស់ ស៊ូហ្សាណា លីនតុន បណ្ឌិត អេនឌ្រូ រីដប៊ី បានប្រើពាក្យ «ប្រល័យពូជសាសន៍ខ្លួនឯង» *(Auto-Genocide)* ។ ជាការពិត ពាក្យនេះត្រូវបានប្រើប្រាស់ជាច្រើនលើកច្រើនសាណាស់មក ហើយដើម្បីបរិយាយអំពីសកម្មភាពនៅក្នុងរបបខ្មែរក្រហម ប៉ុន្តែនៅពេលដែលខ្ញុំដឹងកាន់តែច្រើនអំពីរបៀបដែលខ្មែរក្រហម ទទួលជ័យជម្នះនិងថែរក្សាអំណាច ខ្ញុំស្អប់ពាក្យនេះកាន់តែខ្លាំង ។ មិនមានអ្វីដែលហៅថា «ខ្លួនឯង» នោះទេនៅក្នុងអំពើមហាប្រល័យដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ តើយើងហៅបដិវត្តវប្បធម៌ម៉ៅរបស់ចិនថាជា «ការប្រល័យពូជសាសន៍ខ្លួនឯង» ដែរឬ? តើយើងហៅការបោសសម្អាតរបស់ស្តាលីនថាជា «ការប្រល័យពូជសាសន៍ខ្លួនឯង»ដែរឬ? ហេតុអ្វីបានជាមិនហៅដូច្នេះ?

ខ្ញុំគិតថាពាក្យ «ប្រល័យពូជសាសន៍ខ្លួនឯង» ដ៏គួរឲ្យអស់សំណើចនេះប្រហែលជាត្រូវបានយកមកប្រើប្រាស់ដោយសារមូលហេតុដ៏សាមញ្ញមួយដែលថា អ្នកសង្កេតការណ៍ក្រៅប្រទេសទៅលើសង្គ្រាមស៊ីវិលនៅកម្ពុជាដែលបានអបអរសាទរខ្មែរក្រហម និងបានហៅខ្មែរក្រហមនៅពេលនោះថាជា«អ្នករំដោះ» បានបដិសេធមិនទទួលស្គាល់ការពិតដែលថាមហាប្រល័យដែលប្រព្រឹត្តដោយរបបខ្មែរក្រហមគឺជាក់ច្បាស់ណាស់ជាអ្វីដែលត្រូវបានរំពឹងទុកជាមុនថាប្រាកដជាកើតឡើង ព្រោះជាទូទៅរបបកុម្មុយនិស្តតែងតែធ្វើរបៀបនេះដើម្បីដណ្តើមនិងកាន់កាប់អំណាច ។

ឧក្រិដ្ឋកម្មទាំងនេះគឺជាលទ្ធផលដ៏សមហេតុផលនៃផែនការមួយ ហើយមិនមែនទើបតែកើតឡើងទេ ។ ខ្ញុំគិតថាគួរតែមានកិច្ចខិតខំប្រឹងប្រែងមួយដើម្បីលុបបំបាត់ពាក្យនេះ ។ ពាក្យនេះគ្រាន់តែធ្វើឲ្យមានភាពស្រពេចស្រពិលតែប៉ុណ្ណោះ ។

ខ្ញុំហាក់បីដូចជាយល់ស្របជាមួយយោបល់របស់ ចូហាន់សាន់ ដែលថា មានឥរិយាបថជាច្រើនដែលបញ្ចេញដោយអ្នកដែលធ្លាប់គាំទ្រខ្មែរក្រហម (ដូចជា ប៉ែន ឃៀរនិន, ម៉ៃឃើល វីកឃឺរី ជាដើម) នៅពេលដែលអ្នកទាំងនេះជាសម្ព័ន្ធមិត្តរបស់ជនកុម្មុយនិស្តវៀតណាម ។ ខ្ញុំគិតថាមានអគតិជាច្រើននៅក្នុងចំណោមបញ្ញវ័ន្តទាំងនេះ ដោយសារតែអ្នកទាំងនេះបណ្តោយឲ្យមនោគមវិជ្ជាគ្របដណ្តប់លើចំណេះដឹងដ៏ជ្រៅជ្រះរបស់ខ្លួន ។ មានទិដ្ឋភាពផ្សេងទៀតដែលមានមូលដ្ឋាននៅលើមនោគមវិជ្ជាពោលគឺអ្វីដែលខ្ញុំហៅថា«ការធ្វើឲ្យមនុស្សអាក្រក់ក្លាយទៅជាមនុស្សអាក្រក់» ។ និយាយម្យ៉ាងទៀត បញ្ញវន្តទាំងនេះមានចេតនាពិសេសមួយក្នុងការធ្វើឲ្យពិភពលោកមើលឃើញថាឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមជាលទ្ធផលនៃការប្រព្រឹត្តរបស់ជនជាតិខ្មែរទៅលើជនជាតិខ្មែរខ្លួនឯង ដោយសង្ឃឹមថា ពិភពលោកនឹងមើលមិនឃើញឧក្រិដ្ឋកម្មដែលមានលក្ខណៈស្រាលជាងឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ហើយដែលប្រព្រឹត្តឡើងដោយជនជាតិវៀតណាមទៅលើជនជាតិខ្មែរ ។ ការប្រព្រឹត្តរបស់ជនជាតិវៀតណាមគឺមិនខុសអ្វីពីអំពើប្រល័យពូជសាសន៍ដែលឲ្យនិយមន័យដោយអនុសញ្ញាក្រុងហ្សឺណែវស្តីពីអំពើប្រល័យពូជសាសន៍ទេ ។

ការប្រព្រឹត្តរបស់វៀតណាមគឺជា«វៀតណាមូបនីយកម្ម» ទៅលើជនជាតិកម្ពុជា (ការគាបសង្កត់ទៅលើវប្បធម៌មួយផ្សេងទៀត) ដែលកំពុងតែត្រូវបានលើកយកមកពិភាក្សាកាន់តែបើកចំហឡើងដោយបញ្ញវន្តមួយចំនួនដូចជា ហ៊ីលីព សត, អេវ៉ាន ហ្គុតតេសមែន, ម៉ារី អាឡិកហ្សង់ឌ្រីន ម៉ាទីន ។

នេះជាមូលហេតុដែលខ្ញុំព្យាយាមស្វែងរកថាអ្នកណាខ្លះបាននិយាយអ្វី និងដោយសារមូលហេតុអ្វីដែលធ្វើឲ្យអ្នកនោះនិយាយយ៉ាងដូច្នេះ ។ ការការពារការពិតអំពីសោកនាដកម្មនៅកម្ពុជាពិតជាមានសារសំខាន់ណាស់ ។

ផ្ទុយមកវិញ នៅពេលដែលការជ្រើសរើសពាក្យ «ប្រល័យពូជសាសន៍»មានសារសំខាន់ក្នុងន័យជានិមិត្តរូបនិងន័យច្បាប់ គ្រប់ៗគ្នាយល់ស្របថាមានអំពើមហាប្រល័យនៅក្នុងប្រទេស

កម្ពុជា ហើយថាជនដែលត្រូវតែទទួលខុសត្រូវចំពោះទង្វើនេះ ។

អ្នកទាំងអស់គ្នាមិនគួរបំភ្លេចទេថា ជនជាតិកម្ពុជាជាអ្នកដែលមានចំណែកមួយធំបំផុតនៅក្នុងការទទួលរងអំពើមហាប្រល័យព្រៃផ្សៃបំផុតនៅក្នុងប្រវត្តិសាស្ត្រទំនើបនេះ ។ ប្រទេសវៀតណាមមិនមែនជាអ្នកជិតខាងដែលមិនមានកំហុសដូចដែលប្រទេសនេះតែងតែអះអាងជាញឹកញាប់ និងដូចដែលត្រូវបានគាំទ្រដោយបញ្ញវន្តមួយចំនួនដែលមានទំនោរទៅខាងឆ្វេងទេ ។

**ធិត្យ ណារ៉ាញ់ គីរី**

# ការិយាល័យពត៌មានសាធារណៈ

«ការិយាល័យពត៌មានសាធារណៈ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យនិងព្រឹត្តិការណ៍វិវត្តន៍នៃសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាមជ្ឈមណ្ឌលដែលប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យពត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមានៈ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ពត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

«ការិយាល័យពត៌មានសាធារណៈ» មានផ្តល់ជូននូវសេវា៤យ៉ាងៈ

**១) បណ្ណាល័យ :** នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

វគ្គបណ្តុះបណ្តាលច្បាប់អន្តរជាតិ នៅការិយាល័យពត៌មានសាធារណៈ



**២) មជ្ឈមណ្ឌលអប់រំ :** មជ្ឈមណ្ឌលនេះមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម សាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមនិងអំពីប្រធានបទដទៃៗទៀត ។

**៣) ក្រុមការងារផ្នែកតុលាការ :** ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការក៏ដូចជាដល់សាធារណជនទូទៅដែរ ។

**៤) ហាងកាហ្វេ :** មជ្ឈមណ្ឌលយើងខ្ញុំមានហាងកាហ្វេសម្រាប់បម្រើសេវាភេសជ្ជៈនិងចំណីអាហារជូនលោកអ្នក ។

ភាពយន្តឯកសារអំពីខ្មែរក្រហម មានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង ៩ព្រឹក និង ៣រសៀល ។

ការិយាល័យពត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសារធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើងៈ ភារម្យ ឬ ពិដោរ តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# ជីវិតក្នុងភាពនឹងថ្កល់

**ចាន់ លាង**
**សមាជិកគណៈកម្មាធិការកងកាត់ដេរ**

*(បទសម្ភាសន៍ជាមួយប្អូនស្រីឈ្មោះ ចាន់ សុខគីម អាយុ៤៧ឆ្នាំ នៅស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម)*

ឪពុកម្តាយខ្ញុំមានកូនប្រាំពីរនាក់ ។ បងប្អូនរបស់ខ្ញុំទាំងអស់ចូលបដិវត្តន៍ខ្មែរក្រហមនៅឆ្នាំ១៩៧០ លើកលែងតែខ្ញុំនិងបងស្រីខ្ញុំម្នាក់ឈ្មោះ នឿង ។ បងនឿង ចង់ចូលបដិវត្តន៍ដែរ ប៉ុន្តែប្តីរបស់គាត់មិនយល់ព្រម ។ ឪពុកម្តាយខ្ញុំក៏មិនឲ្យខ្ញុំទៅ ព្រោះកាលណោះខ្ញុំនៅក្មេងពេក ។ ក្រោយមកខ្ញុំបានចូលរួមបដិវត្តន៍ដែរនៅឆ្នាំ១៩៧៤ ។ សាលារៀនត្រូវបិទទ្វារតាំងតែពីឆ្នាំ១៩៧០ម្ល៉េះ ។ កាលណោះបងៗរបស់ខ្ញុំរៀនពេទ្យជាមួយខ្មែរក្រហម ហើយខ្ញុំចង់រៀនពេទ្យដូចគាត់ដែរ ។

បងលាង ប្រលងធ្លាក់ឌីប្លូម ។ ក្រោយមកគាត់ក៏ភ្ជាប់ពាក្យ ។ គាត់រៀបការជាមួយបងញ៉ែម នៅឆ្នាំ១៩៦៧ ។ បងញ៉ែម ធ្វើការឲ្យក្រុមហ៊ុននាំចូលគ្រឿងបន្លាស់ម៉ូតូ ។ បងលាង មានកូនប្រុសដំបូងនៅឆ្នាំ១៩៦៨ ។ ក្រោយពីរដ្ឋប្រហាររបស់លន់ណុល គាត់និងបងញ៉ែម បានចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។

នៅឆ្នាំ១៩៧៥ បងលាង និងប្តីគាត់ ត្រូវបញ្ជូនទៅភ្នំពេញ ហើយខ្ញុំក៏ទៅជាមួយគាត់ដែរ ។ បងលាង ធ្វើការនៅកងដេរខោអាវនៅអូរឫស្សី ឯបងថ្លៃខ្ញុំនិងខ្ញុំទៅខាងផ្សារចាស់ ។ បងថ្លៃខ្ញុំជាបុគ្គលិកនៅក្រសួងពាណិជ្ជកម្ម ខ្ញុំជាចុងភៅនៅទីនោះ ។

នៅឆ្នាំ១៩៧៦ខ្មែរក្រហមបញ្ជូន បងញ៉ែម ទៅប្រទេសចិនរយៈពេលមួយខែ ។ ពេលគាត់ត្រឡប់មកវិញបាន៦-៧ថ្ងៃ ខ្មែរក្រហមចាប់ខ្លួនគាត់នៅរោងបាយផ្សារចាស់ ។ កាលណោះ បងញ៉ែម ពរកូនប្រុសទីបីរបស់គាត់ ដើរមកប្រាប់ខ្ញុំអំពីរឿងអង្គការហៅគាត់ ។ គាត់និយាយថា បើអង្គការហៅគាត់ត្រូវតែទៅ ។ ប្រហែលពីរខែក្រោយមក បងស្រីខ្ញុំក៏ត្រូវអង្គការចាប់ខ្លួនដែរ ។ បងស្រីខ្ញុំមានកូនប្រុសពីរនាក់ទៀតធ្វើនៅកងកុមារ ប៉ុន្តែ



រូបខាងឆ្វេង: ចាន់ លាង មានផ្ទៃពោះ៦ខែ ថតនៅកំពង់សោម ក្នុងឆ្នាំ១៩៧៥

ខ្មែរក្រហមចាប់តែកូនពីរនាក់ដែលនៅផ្ទះជាមួយគាត់ ។ កូនពៅមានអាយុមិនដល់មួយខួបផង ។

ខ្មែរក្រហមបើកប្រជុំនៅផ្សារចាស់ ហើយប្រាប់យើងថា បងស្រីខ្ញុំនិងប្តីគាត់លួចលាក់ចិញ្ចឹមខ្មាំង ។ អង្គការថាបងស្រីខ្ញុំជាខ្មែរបណ្តាញកា.ហ្សេ.បេ ឯបងថ្លៃខ្ញុំជាខ្មែរសេ.អ៊ី.អា ។ ខ្ញុំវង្វេងអស់ហើយ ព្រោះបងស្រីខ្ញុំកាន់តំណែងខ្ពស់ដែរ ។ ខ្មែរក្រហមរិះគន់ខ្ញុំជាច្រើនលើកច្រើនសា ។ខ្ញុំបានសារភាពទទួលគ្រប់កំហុសទាំងអស់ ។

បន្ទាប់មកទៀត ខ្មែរក្រហមផ្លាស់ខ្ញុំឲ្យទៅកងចល័តនៅផ្សារចាស់ដោយសារខ្ញុំជាចុងភៅ ខ្ញុំយល់ថាប្រហែលជាគេខ្លាចខ្ញុំដាក់ថ្នាំបំពុលក្នុងបាយម្ហូបហើយមើលទៅ ។ ការងារនៅកងចល័តលំបាកខ្លាំងណាស់ ហើយគ្មានអាហារគ្រប់គ្រាន់ទៀត ។ ខ្ញុំទៅ

ជាបាក់កម្លាំងល្ហិតល្ហៃ ។ អ្នកនៅកងចល័តជាមួយខ្ញុំដឹងពីរឿងបងស្រីខ្ញុំ ម្ល៉ោះហើយគ្មាននរណានិយាយរកខ្ញុំទេ ។ ខ្ញុំមានអារម្មណ៍ឯកោណាស់ ។ ក្រោយមក អង្គការបញ្ជូនខ្ញុំទៅធ្វើផ្លូវដែកនៅពេជ្រនិល ខេត្តកំពង់ស្ពឺ ។ ភាគច្រើនអ្នកដែលនៅទីនោះសុទ្ធសឹងតែជាអ្នកទោស ។ ខ្មែរក្រហមតែងតែទិតៀនយើងថាមិនខំប្រឹងធ្វើការ ។

ពេលវៀតណាមចូល ខ្មែរក្រហមបានជម្លៀសខ្ញុំទៅសហករណ៍មួយនៅខេត្តបាត់ដំបងជិតព្រំដែនថៃ ។ ខ្ញុំលួចរត់ពីបាត់ដំបងហើយដើរអស់ជាងកន្លះខែទើបដល់ផ្ទះ ។ ខ្ញុំភ័យខ្លាចព្រោះឃើញមានកងទ័ពវៀតណាមច្រើនណាស់ ។ ខ្មែរក្រហមបានប្រាប់យើងថាវៀតណាមនឹងបាញ់សម្លាប់អ្នកណាដែលពាក់ខោអាវខ្មៅ ប៉ុន្តែតាមពិតអត់ទេ ។

តាមផ្លូវទៅផ្ទះ ខ្ញុំឈប់សំចតនៅភូមិកំណើតរបស់បងថ្លៃខ្ញុំ ។ បងប្អូនរបស់គាត់បានប្រាប់ខ្ញុំថា ឪពុកម្តាយខ្ញុំត្រូវអង្គការសម្លាប់ចោលកាលពីឆ្នាំ១៩៧៧អស់ហើយ ។ ខ្មែរក្រហមចោទឪពុកម្តាយខ្ញុំថាជាប់និន្នាការពីរបបមុនៗ ។ ព្រួយខ្លោចខ្លោះខ្ញុំក៏មិនទៅផ្ទះពុកម៉ែខ្ញុំទេ ។ ខ្ញុំទៅជាទុកព្រួយល្វីល្វើអស់ហើយ ។

បងប្រុសរបស់ខ្ញុំឈ្មោះ ថ្វាន់ បានដឹងពីការចាប់ខ្លួនបងស្រីខ្ញុំ ហើយដឹងមុនថាខ្មែរក្រហមតាមដានគាត់ ។ គាត់ក៏រត់ទៅផ្ទះវិញ ប៉ុន្តែត្រូវខ្មែរក្រហមចាប់បាន ហើយយកទៅសម្លាប់ជាមួយឪពុកម្តាយខ្ញុំតែម្តង ។ បងប្រុសខ្ញុំពីរនាក់ទៀតស្លាប់នៅសមរភូមិប្រយុទ្ធជាមួយទាហានលន់ណុល ។

ខ្ញុំមានវិប្បដិសារីណាស់ដែលត្រូវខ្មែរក្រហមបោកប្រាស ។ ខ្ញុំបានលះបង់អ្វីៗទាំងអស់ដើម្បីបម្រើបដិវត្តន៍ រួមទាំងសុភមង្គលជាមួយឪពុកម្តាយខ្ញុំ ។ ខ្ញុំសង្ឃឹមថាខ្ញុំអាចរំដោះប្រទេសបាន និងនាំប្រទេសជាតិទៅរកភាពថ្កុំថ្កើងរុងរឿង ប៉ុន្តែខ្មែរក្រហមបែរជាសម្លាប់ឪពុកម្តាយនិងបងប្អូនខ្ញុំស្ទើរតែគ្មានសល់ ។

◆◆◆

## អេង សំអុល

## ពេទ្យ

*(បទសម្ភាសន៍ជាមួយប្អូនស្រីឈ្មោះ អេង ស៊ីធិន អាយុ៤៧ឆ្នាំ នៅស្រុកកងមាស ខេត្តកំពង់ចាម)*



*អេង សំអុល ថតកាលអាយុ១២ឆ្នាំ*

បងសំអុល រៀនរហូតដល់អាយុ១៨ឆ្នាំ ។ ក្រោយមកគាត់បានចូលបួសនៅវត្តបានជាងមួយឆ្នាំ ។ ពេលដែលសាលារៀននិងវត្តអារាមត្រូវបិទទ្វារ គាត់ត្រូវខ្មែរក្រហមបង្ខំឲ្យដោះស្បង់ចីពរចោល ។ ខ្មែរក្រហមមិនគោរពព្រះពុទ្ធសាសនាទេ ថែមទាំងចង់លុបបំបាត់ចោលឲ្យសូន្យតែម្តង ។ ខ្មែរក្រហមមិនត្រូវការឲ្យមានព្រះសង្ឃ មិនចង់ឲ្យប្រជាជនប្រារព្ធពិធីបុណ្យទានអ្វីទាំងអស់ ។ ព្រះសង្ឃមួយអង្គនៅភូមិខ្ញុំបដិសេធមិនព្រមសឹក ។ ខ្មែរក្រហមចូលមកទាំងកណ្តាលអាធ្រាត្រ ចាប់លោកចងនឹងដើមចេកហើយសម្លាប់ចោល ។

បងសំអុល ចូលធ្វើបដិវត្តន៍នៅឆ្នាំ១៩៧២ គឺពេលដែល



*អេង សំអុល ពេលបួសជាសង្ឃ*



*អេង សំអុល ពេលធ្វើជាកងទ័ពខ្មែរក្រហម*

គាត់អាយុបាន២០ឆ្នាំ ។ គាត់ត្រូវឈ្មោះ យឹម កេណ្ឌយកទៅ ។ យឹម ក៏ត្រូវខ្មែរក្រហមជ្រើកពីលោកដែរ ។ មុនដំបូងអង្គការចាត់ឲ្យបងខ្ញុំធ្វើកងទ័ព ប៉ុន្តែគាត់មិនព្រម ។ គាត់និយាយថា បើឲ្យគាត់ធ្វើពេទ្យកងទ័ពទើបគាត់ព្រម ។ ដោយសារបងខ្ញុំមិនមានជំនាញពេទ្យអ្វីបន្តិចសោះ ដូច្នេះគាត់ត្រូវរៀនសូត្រអស់រយៈពេលជាងមួយឆ្នាំ ។ ក្រោយពីនោះ គាត់ផ្លាស់ចុះឡើងរហូត ។ គាត់នៅកប់ស្រូវ(ជាយក្រុងភ្នំពេញ) បានប្រហែល៣ឆ្នាំក៏ទៅនៅភ្នំពេញមុនពេលដែលគាត់បាត់ខ្លួន ។

គាត់ផ្តល់ដំណឹងឲ្យឪពុកម្តាយមិនដែលខាន ហើយមកលេងផ្ទះបានពីរដងដែរ ។ លើកដំបូង គាត់មកមុនពេលខ្មែរក្រហមរំដោះភ្នំពេញបាន ។ គាត់មកជាមួយនឹងប្រធានពេទ្យម្នាក់ ។ គាត់មកលេងបានតែពេលថ្ងៃ មិនបានសម្រាកនៅផ្ទះពេលយប់ទេ ។

លើកទីពីរគឺនៅឆ្នាំ១៩៧៥ គាត់ជិះកង់មកលេងផ្ទះតែម្នាក់ឯង ។ គាត់យកឪឡឹកទុំមកផ្ញើពុកម៉ែ ប៉ុន្តែនៅតាមផ្លូវមានអ៊ំម្នាក់សុំឪឡឹកនោះពីគាត់ ។ ដោយឃើញអ៊ំនោះមានរូបរាងស្គាំងស្គមពេក គាត់ក៏ឲ្យឪឡឹកទៅអ៊ំនោះទៅ ។ មកលេងលើកនោះក៏បងសំអុល មិនបានសម្រាកនៅផ្ទះពេលយប់ដែរ ។ គាត់បានយករូបថតរបស់គាត់មកឲ្យយើង ហើយប្រាប់ថា "ឲ្យទុកគ្រាន់មើលលេង" ។ គាត់និយាយប្រាប់អំពីការងាររបស់គាត់ដែរ ប៉ុន្តែមិនច្រើនទេ ព្រោះឪពុកខ្ញុំមិនចូលចិត្តស្តាប់ ។ ឪពុកខ្ញុំតែងតែប្រឆាំងនឹងខ្មែរក្រហម ។ បងប្រុសខ្ញុំប្រាប់គាត់ថា "ពុកធ្វើតាមតែបញ្ជាអង្គការទៅ កុំរឹងទទឹងឲ្យសោះ" ។ នៅឆ្នាំ១៩៧៨ បងសំអុល បានសរសេរសំបុត្រមួយផ្ញើឲ្យឪពុកខ្ញុំ ប្រាប់គាត់កុំឲ្យរអ៊ូរទាំ បើមិនដូច្នោះទេអង្គការសម្លាប់ចោលហើយ ។ យើងមិនបានតបសំបុត្រទៅវិញទេ ព្រោះខ្លាច ។

នៅឆ្នាំ១៩៧៦ឬ១៩៧៧ ក្រុមគ្រួសារខ្ញុំត្រូវជម្លៀសចេញពីភូមិទៅរាយប៉ាយ ក្នុងស្រុកកងមាស (ខេត្តកំពង់ចាម) ។ អ្នកដែលមិនចង់ចូលរួមបដិវត្តន៍ត្រូវខ្មែរក្រហមចាត់ទុកថាជាអ្នកថ្មីនិងត្រូវជម្លៀសចេញ ។ អ្នកភូមិខ្ញុំភាគច្រើនក៏ទៅទីនោះដែរ ។ អង្គការចោទយើងថាសិស្សវណ្ណៈខ្ពស់ ។ បើអ្នកណាប្រកែកមិនចូលរួម ពិតជាត្រូវខ្មែរក្រហមចាប់ចងវាយធ្វើទារុណកម្ម ព្រោះមិនគោរពបញ្ជារបស់អង្គការ ។ ខ្ញុំបានឃើញបុរសម្នាក់រត់គេចពីខ្មែរក្រហមសំដៅទៅផ្ទះ ។ ខ្មែរក្រហមចាប់គាត់បាន សម្លាប់គាត់នៅឯច្រាំងទន្លេ ហើយក្រោយមកសម្លាប់ឪពុកម្តាយបងប្អូនរបស់គាត់ទៀត ។

ខ្ញុំរែកដីនិងស្ទូងស្រូវនៅកងចល័ត ។ កាលណោះឪពុកម្តាយខ្ញុំក៏នៅទីនោះដែរ ។ ម្តាយខ្ញុំត្រូវអង្គការចាត់តាំងឲ្យទៅបេះពោត ។ នៅឆ្នាំ១៩៧៨ ម្តាយខ្ញុំឃ្លានពេកក៏លួចពោតហូបឆៅខ្លះនិងទុកខ្លះឲ្យឪពុកខ្ញុំ ។ ខ្មែរក្រហមហៀបនឹងយកម្តាយខ្ញុំទៅរៀនសូត្រទៅហើយ ប៉ុន្តែគាត់បានសុំទោស ហើយបានឲ្យខ្សែយមួយទៅខ្មែរក្រហមទើបគាត់រួចខ្លួន ។ គ្មានអ្នកណាអាចជួយយើងបានទេ ព្រោះយើងជាអ្នក១៧មេសា (ប្រជាជនថ្មី) សូម្បីតែអ្នកធ្វើការឲ្យខ្មែរក្រហមក៏មិនអាចជួយក្រុមគ្រួសារខ្លួនឯងបានផង ។

ឪពុកម្តាយខ្ញុំមានកូន៩នាក់ ក្នុងនោះ៣នាក់ត្រូវខ្មែរក្រហមសម្លាប់ចោល ។ បងស្រីខ្ញុំឈ្មោះ ង៉ុក សាត និងប្តីរបស់គាត់ជាពេទ្យនៅក្នុងរបបលន់ណុល ។ អ្នកទាំងពីរត្រូវខ្មែរក្រហមសម្លាប់ ។ កូនប្រុសច្បងរបស់បងសាត ធ្វើការនៅកងចល័តបានបាត់ខ្លួន

ហើយកូនរបស់គាត់ពីរនាក់ទៀតស្លាប់ដោយខ្វះអាហារ ។ ប្អូនស្រីខ្ញុំឈ្មោះ អេង អូវ ជាអ្នក១៧មេសា ក៏ត្រូវអង្គការសម្លាប់ដែរ ។ ក្នុងចំណោមបងប្អូនខ្ញុំមានតែ បងសំអុល តែម្នាក់ទេដែលស្លាប់ពេលធ្វើបដិវត្តន៍ ។

◆◆◆

## ណុប ង៉ាន ហៅ ស
## កម្មកររោងចក្រយន្តហោះ

*(បទសម្ភាសន៍ជាមួយប្អូនស្រីឈ្មោះ ង៉ែត សុខ អាយុ៥៦ឆ្នាំ នៅស្រុកដូនកែវ ខេត្តតាកែវ)*


ណុប ង៉ាន ថតក្នុងឆ្នាំ១៩៧២

នៅឆ្នាំ១៩៦៤ បងស អាយុប្រហែល១៨-១៩ឆ្នាំ គាត់ធ្វើជាទាហានលន់ណុល ។ គាត់ចង់ធ្វើការងារនេះនិងបានសុំការអនុញ្ញាតពីឪពុកម្តាយ ដើម្បីបម្រើកងទ័ព ។ គាត់មានស័ក្តិជាអនុសេនីយ៍ទោបានប្រហែលបីឬបួនឆ្នាំ ។ ក្រោយមក បងស ត្រូវផ្លាស់ចេញពីកងយោធភូមិភាគត្រាំខ្នារមកនៅភ្នំពេញវិញ ។ ដោយសារផ្ទះរបស់យើងឆេះខ្ទេចខ្ទីនៅពេលដែលទាហានច្បាំងគ្នា យើងក៏មកនៅជាមួយ បងស ឯផ្ទះជួលនៅភ្នំពេញ ។

នាឆ្នាំ១៩៧៣ បងស បានទៅហាត់រៀនតែក្បាន់ដូនៅតែវ៉ាន់អស់រយៈពេលជាងបីខែ ។ គាត់នៅតែបន្តធ្វើទាហានទៀត ប៉ុន្តែគាត់រកចំណូលសម្រាប់ផ្គត់ផ្គង់គ្រួសាររបស់គាត់មិនគ្រប់ទេ ។ ដោយគាត់ចេះវាយតប់យ៉ាងពូកែ គាត់បានក្លាយខ្លួនជាតួកុនលំដាប់លេខពីរ ។ តួឯកនៅក្នុងខ្សែភាពយន្តដែលគាត់សម្តែងគឺ គង់ សំអឿន និង ណុប ណៃម ។ ខ្ញុំបានមើលបីរឿងក្នុងចំណោមកុន៧រឿងដែលគាត់បានសម្តែងគឺរឿង«ពេលកន្ទ្រើបយំក្រមុំជ្រួល» «ប៉េងប៉ោះនិងកម្លោះត្រីឆ្កៀត», និងរឿង «សូមពុកអាណិតម៉ែផង» ។ នៅក្នុងរឿងទាំងនោះមានប្រុសៗចាប់ស្រីៗយកទៅចងហើយ បងស ជាតួទៅជួយនាងៗទាំងនោះ ។

យើងត្រូវជម្លៀសចេញពីភ្នំពេញនៅថ្ងៃបន្ទាប់ពីថ្ងៃ១៧មេសា ។ ខ្មែរក្រហមប្រាប់ថាយើងត្រូវតែចេញព្រោះអាមេរិកាំងនឹងមកទម្លាក់គ្រាប់បែក ។ ក្រុមគ្រួសារខ្ញុំបានធ្វើដំណើរទៅស្រុកកំណើតរបស់ជីតាខ្ញុំនៅខេត្តកំពង់ស្ពឺ ។ ខ្ញុំដឹកដីនិងស្ទូងស្រូវ ។ មនុស្សចាស់ធ្វើការតាមដែលអាចធ្វើទៅបាន ភាគច្រើនគឺគាស់គល់ឈើ ។

យើងរស់នៅក្នុងខ្ទមតូចមួយប្រក់ស្លឹកដូង ។ ខ្ញុំនៅជាមួយប្តី បងស នៅជាមួយឪពុកម្តាយនិងបងប្អូននៅលីវប៉ុន្មាននាក់ទៀត ។ គាត់ស្ទូងនិងដឹកជញ្ជូនស្រូវ ។ ខ្មែរក្រហមសួរ បងស ម្តងហើយម្តងទៀតអំពីការងាររបស់គាត់ ។ ខ្មែរក្រហមនិយាយថា បងស គឺជាកីឡាករ ។ នៅទីបំផុត បងស គិតថាអង្គការពិតជាជឿថាគាត់ជាកសិករធម្មតាមែន ។

ថ្ងៃមួយនៅឆ្នាំ១៩៧៦ ខ្មែរក្រហមយក បងស ទៅដោយប្រាប់គាត់ថាយកទៅឲ្យចូលកងពិសេស ។ អង្គការហៅតែគាត់ម្នាក់ប៉ុណ្ណោះ ។ ក្រោយមក គណៈភូមិបានប្រាប់ខ្ញុំថា «បងប្រុសឯងត្រូវអង្គការយកទៅហើយ» ។ ខ្ញុំមិនអាចយំនៅមុខចំណោមមនុស្សបានទេ ។ កាលណោះបើហ៊ានយំ អង្គការពិតជាសម្លាប់ខ្ញុំចោលជាមិនខាន ។

ខ្ញុំមិនបានជួប បងស ទៀតទេ ។ ខ្ញុំបានទុករូបថតគាត់នៅជាប់នឹងអាវជានិច្ចនៅក្នុងរបបប៉ុលពត ។ ខ្ញុំនៅមានរូបថតគាត់ស្លៀកពាក់ទាហានមួយសន្លឹកទៀត តែវាត្រូវបំផ្លាញអស់ហើយ ។ ក្រោយឆ្នាំ១៩៧៩ មានមិត្តភក្តិម្នាក់របស់ បងស ដែលធ្លាប់ធ្វើ

ទាហានជាមួយគ្នានិយាយថា គាត់បានឃើញរូបថត បងស នៅគុកទួលស្លែង ។ គ្រាន់តែគិតដល់រឿងនេះធ្វើឲ្យខ្ញុំឈឺតែម្តង អ៊ីចឹងហើយទើបខ្ញុំមិនដែលទៅទីនោះម្តងណាសោះ ។

ឪពុកខ្ញុំស្លាប់នៅឆ្នាំ១៩៧៧ ដោយសារគាត់ឥតមានអីហូប ។ អង្គការមិនអនុញ្ញាតិឲ្យគាត់សម្រាកនៅផ្ទះទេ ប៉ុន្តែបញ្ជូនគាត់ទៅមន្ទីរពេទ្យ ហើយគាត់ក៏ស្លាប់នៅទីនោះទៅ ។

ក្នុងរបបប៉ុលពត ខ្ញុំមានកូនពីរនាក់ ។ កូនប្អូននៅជាមួយខ្ញុំ ឯកូនបងឈ្មោះ ផល្លី នៅកងកុមារ ។ នាងស្លាប់ក្នុងអាយុ១០ឆ្នាំ ។ កាលណោះអង្គការឲ្យនាងកាប់ដំបូកកណ្តៀរ ។ នាងគ្មានស្ល ម្បីតែទឹកដីក ។

រសៀលមួយ ខ្ញុំនិងប្តីខ្ញុំឈ្មោះ ឌុក ហួន កំពុងតែធ្វើការជាមួយគ្នា គាត់ជាអ្នកកាប់ដី ខ្ញុំជាអ្នករែក ។ ខ្មែរក្រហមហៅគាត់និងប្រជាជន៤៧នាក់ទៀតទៅជួយភ្ជួររាស្រែដោយនិយាយថា ត្រូវការកម្លាំងបន្ថែម ។ ខ្ញុំរៀបចំបង្វិចខោអាវឲ្យគាត់ ហើយគាត់ក៏ចេញទៅ ។ តាំងពីនោះមកខ្ញុំលែងបានជួបគាត់រហូត ។

◆◆◆

# ឈឹម វ៉ាន់ឌី
# អ្នកចម្រៀង

*(បទសម្ភាសន៍ជាមួយប្អូនប្រុសឈ្មោះ ឈឹម សារ័ត្ន អាយុ៣៩ឆ្នាំ និងបងថ្លៃស្រីឈ្មោះ សុខ កាន អាយុ៥១ឆ្នាំ នៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម)*

**ឈឹម សារ័ត្នៈ** ខ្ញុំមានបងប្អូន៦នាក់ បីនាក់នៅរស់ ។ បងបង្អស់ឈ្មោះ ស្រឿ បាត់ខ្លួន, បងបន្ទាប់ឈ្មោះ វឿន ស្លាប់នៅសមរភូមិ, បងទីបីឈ្មោះ វ៉ាន់ឌី ហៅ ឌី ។ បងឌី ជាសិល្បករនៅក្នុងរបបខ្មែរក្រហម ។ គាត់បែបអាយុ៥០ឆ្នាំហើយមកទល់ឥឡូវ ។ គាត់ច្រៀងក៏ពីរោះ រូបក៏ស្អាត ។

មានមនុស្ស៤-៥នាក់មកពីទីរួមខេត្ត ហើយប្រាប់អ្នកភូមិខ្ញុំថាអ្នកណាច្រៀងពីរោះជាងគេនឹងបានទៅ ។ ស្រីៗជាច្រើននាក់បានសាកដែរ ប៉ុន្តែចាញ់ បងឌី ទាំងអស់ ។ ឪពុកម្តាយខ្ញុំមិនចង់ឲ្យបងឌី ចូលរួមបដិវត្តន៍ទេ ព្រោះខ្លាចបែកពីកូន មិនចង់ឲ្យកូនទៅណាឆ្ងាយពីខ្លួន ។ អ្នកនៅខេត្តទុកពេលឲ្យគាត់ពីរបីថ្ងៃដើម្បីសម្រេចចិត្ត



រាប់ពីឆ្វេងទី៣ នៃជួរខាងលើៈ ឈឹម វ៉ាន់ឌី

ប៉ុន្តែបើយើងនិយាយថាមិនព្រមចូលរួមគេនឹងបង្ខំជាមិនខាន ។

បងឌី ហាត់នៅក្នុងវត្តរាល់ថ្ងៃតាំងពីម៉ោង៦-៧ល្ងាចដល់ម៉ោង១០យប់ ។ ប្រហែលឆ្នាំ១៩៧២-៧៣ ខ្មែរក្រហមបញ្ជូនគាត់ទៅភ្នំពេញ ។ មុនពេលបាត់ខ្លួនគាត់បានមកលេងផ្ទះម្តងដែរកាលឆ្នាំ១៩៧៥ ។ គាត់មកបានបីថ្ងៃ ។ គាត់បានជជែកជាមួយពុកម៉ែ ប៉ុន្តែកាលណោះខ្ញុំនៅតូចមិនបានស្តាប់យល់ដឹងរឿងអ្វីដែលគាត់និយាយទេ ។

បងឿន សម្តែងជាមួយ បងឌី ដែរ ប៉ុន្តែក្រោយមកអង្គការបញ្ជូនគាត់ទៅសមរភូមិ ។ ក្រោយពេល បងឿន ស្លាប់បានបីបួនថ្ងៃ អង្គការបានផ្ញើសំបុត្រមកប្រាប់យើងពីរឿងនេះដែរ ។

កាលជំនាន់ប៉ុលពត ខ្ញុំធ្វើជាមេក្រុមកុមារ ។ ខ្ញុំដើរប្រមូលចំបើងនិងអាចម៍គោជាមួយក្មេងៗឯទៀត ។ យើងចេញទៅស្រែរាល់ៗព្រឹក មិនបានឃើញមុខម៉ែឪយ៉ាងម៉េចទេ ។ ខ្ញុំគិតថាអង្គការពិតជាមិនបញ្ជូនខ្ញុំទៅសមរភូមិទេ ដោយហេតុថាខ្ញុំមានរោគខ្វួរឆ្អឹងខ្នងតាំងពីអាយុ៣ឆ្នាំ ។

ខ្ញុំសប្បាយចិត្តណាស់ពេលដែលខ្មែរក្រហមរំដោះភូមិខ្ញុំបាន ។ ទាហានលន់ណុលបានមកទម្លាក់គ្រាប់បែកជាច្រើនលើកច្រើនសា ។ ពេលគ្រាប់បែកធ្លាក់មក ខ្ញុំពួននៅក្នុងលេណដ្ឋាន ។ មានពេលមួយនោះ សិស្សសាលាជាច្រើននាក់បានស្លាប់ពេលដែលដើរចេញពីសាលាត្រឡប់ទៅផ្ទះវិញ ។

ខ្ញុំនឹកបងប្រុសបងស្រីខ្ញុំណាស់ ជាពិសេសពេលដែលឃើញអ្នកជិតខាងរស់នៅជួបជុំគ្នា ឯខ្ញុំបែរជានៅឯកោម្នាក់ឯង ។

***សុខ កានៈ*** បង ឈឹម ស្រឿ និងខ្ញុំ រៀបការនៅឆ្នាំ១៩៧០ ។ ប្រាំឆ្នាំក្រោយមក គាត់ត្រូវបង្ខំឲ្យចូលបដិវត្តន៍ខ្មែរក្រហម ។ គាត់ជាអ្នកលេងឃឹម ។ ខ្មែរក្រហមបញ្ជូនគាត់ទៅភ្នំពេញសម្តែងឲ្យកងទ័ពមើល ។ ឆ្នាំ១៩៧៧គាត់បាត់ខ្លួន ។

មុនពេលគាត់បាត់ខ្លួន គាត់មកលេងខ្ញុំបានតែម្តងគត់ ។ កាលណោះគាត់ចង់យកខ្ញុំទៅនៅភ្នំពេញជាមួយ ប៉ុន្តែខ្ញុំមិនចង់ទៅ ព្រោះខ្ញុំមានផ្ទៃពោះចាស់ខែផងនិងមានកូនតូចផង ហើយស្ថានការណ៍នៅភ្នំពេញមិនសូវស្រួលទៀត ។ ក្រោយពេលខ្ញុំឆ្លងទន្លេរួច គាត់ត្រឡប់មកម្តងទៀត សុំឲ្យខ្ញុំទៅនៅជាមួយគាត់ ។ ពេលនោះសុខភាពខ្ញុំមិនសូវល្អ ខ្ញុំក៏បដិសេធ ។ គាត់ក៏ត្រឡប់ទៅភ្នំពេញវិញហើយបាត់ខ្លួនទៅ ។ ខ្ញុំឮថាគាត់ឈប់លេងភ្លេងបែរមកធ្វើការរោងចក្រវិញ ។ ខ្ញុំនឹកគាត់ជាពិសេសពេលដែលឮសូរភ្លេងការម្តងៗ ។

នៅឆ្នាំ១៩៧៧ ខ្ញុំឃើញខ្មែរក្រហមចាប់ខ្លួនប្រជាជនដែលគ្មានកំហុសអ្វីសោះ ។ ខ្មែរក្រហមចាប់អ្នកទាំងនោះដាក់រទេះ ប៉ុន្តែខ្ញុំមិនដឹងថាយកទៅណាទេ ។ ខ្មែរក្រហមប្រាប់អ្នកនៅលើរទេះថាអង្គការយកទៅនៅភូមិថ្មី ។ ពេលរទេះត្រឡប់មកភូមិវិញ សូម្បីតែម្នាក់ក៏គ្មាននៅផង ។ ភ្លាមៗបន្ទាប់ពីនោះ ខ្មែរក្រហមចាប់ផ្តើមចែកខោអាវឲ្យអ្នកភូមិ ។ គ្មានអ្នកណាមួយលើករឿងនេះមកនិយាយទេ ព្រោះបើអង្គការឮយើងពិតជាត្រូវយកទៅសម្លាប់ចោលហើយ ។

◆◆◆

## ភិន លី
## ពេទ្យនៅកងពល១៧០

*(បទសម្ភាសន៍ជាមួយសាមីខ្លួននៅស្រុកស្អាង ខេត្តកណ្តាល)*



ភិន លី អាយុ២៥ឆ្នាំ ថតក្នុងឆ្នាំ១៩៧៥ មុនពេលខ្មែរក្រហមកាន់អំណាចបានបន្តិច

ខ្ញុំចូលធ្វើបដិវត្តន៍នៅឆ្នាំ១៩៧២ ក្រោយពេលខ្មែរក្រហមចូលមកកាន់កាប់ភូមិខ្ញុំ ។ ខ្ញុំរំភើបពេលឮប្រធានភូមិប្រាប់ថានៅភូមិភាគបូព៌ាត្រូវការពេទ្យ ។ ម្យ៉ាងទៀតខ្ញុំគិតថានៅផ្ទះក៏គ្មានការងារធ្វើដែរ ។ មនុស្សច្រើនណាស់ចូលធ្វើបដិវត្តន៍ រាប់ទាំងបងប្អូនប្រុសស្រីទាំងអស់របស់ខ្ញុំ ។ ប្រុសៗធ្វើកងទ័ព ស្រីៗធ្វើពេទ្យ ។

ចាប់ពីពេលនោះមកខ្ញុំមិនបានទទួលការអនុញ្ញាតឲ្យមកលេងផ្ទះ ឬក៏សរសេរសំបុត្រមកឪពុកម្ដាយទេ ។ អង្គការនិយាយថា ចាំបាច់មកលេងធ្វើអ្វី បើម្ដាយឪពុកខ្ញុំរស់នៅសុខសប្បាយមានហូបគ្រប់គ្រាន់នោះ ។

ដំបូងខ្ញុំធ្វើនៅពេទ្យបូព៌ាក្បែរភូមិខ្ញុំ ។ ខ្ញុំព្យាបាលកងទ័ពត្រូវរបួសនិងមានជំងឺគ្រុនចាញ់ ។ នៅឆ្នាំ១៩៧៤ ដោយមានការច្បាំងគ្នា កងខ្ញុំត្រូវបញ្ជូនទៅព្រែកប្រាខាងត្បូងភ្នំពេញ ។

ឈ្មោះ ចាន់ ចក្រី ជាប្រធានកងពល១៧០របស់ខ្ញុំ ។ ខ្មែរក្រហមចាប់គាត់នៅឆ្នាំ១៩៧៧ ដោយចោទគាត់ថាចូលដៃជាមួយវៀតណាម ។ តាមការពិតគាត់ជាមនុស្សសុភាពត្រឹមត្រូវ គាត់មិនបានចូលដៃជាមួយវៀតណាមទេ ។ ក្រោយពីនោះ អង្គការចោទខ្ញុំថាបានចូលរួមជាមួយចក្រី ហើយបញ្ជូនខ្ញុំនិងអ្នកនៅកងជាមួយខ្ញុំប៉ុន្មាននាក់ទៀតទៅគុកព្រៃសដើម្បីរៀនសូត្រ ។

ខ្ញុំមិនបានធ្វើអ្វីខុសទាល់តែសោះ ។ រយៈពេលដែលខ្ញុំនៅព្រៃស ប្រធានគុកនិយាយថា បើអ្នកណាធ្វើខុសអ្វីមួយនឹងត្រូវស្លាប់ ។ ឮដូច្នោះខ្ញុំយល់ការណ៍ ហើយខំប្រឹងធ្វើការដើម្បីរស់ ។

នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវអង្គការបញ្ជូនទៅកាប់ឈើនៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ។ អង្គការបញ្ជូនមនុស្សជាច្រើននាក់ទៅទីនោះដើម្បីកសាង ។ ភាគច្រើនគឺអ្នកមកពីកងពល១៧០តែម្ដង ។ អ្នកទាំងនោះត្រូវចោទថាក្បត់នឹងអង្គការ ។

ពេលវៀតណាមចូល យើងរត់ចូលព្រៃ ។ ខ្ញុំដើរតាមព្រំដែនថៃរហូតដល់ហើមជើង ។ មានអ្នកប្រាប់ថា បើខ្ញុំហ៊ានត្រឡប់ទៅផ្ទះវិញ ខ្មែរក្រហមនឹងសម្លាប់ខ្ញុំ ។ ខ្ញុំនឹកឪពុកម្ដាយណាស់ ។ ខ្ញុំក៏បញ្ចុះបញ្ចូលប្ដីខ្ញុំឲ្យត្រឡប់មកផ្ទះវិញ កាលណោះគឺឆ្នាំ១៩៨២ ។ ពេលមកដល់ភូមិ ខ្ញុំអត់ឃើញបងប្អូនណាម្នាក់សោះ ។ ពីរបីឆ្នាំក្រោយមកទើបប្អូនស្រីខ្ញុំមកភូមិវិញ ហើយក្រោយមកប្អូនប្រុសខ្ញុំម្នាក់ទៀតក៏មកវិញដែរ ។ ប្អូនខ្ញុំម្នាក់បានស្លាប់ ហើយពីរនាក់ទៀតបាត់ខ្លួនអំឡុងពេលធ្វើបដិវត្តន៍ ។

◆◆◆



នារីខ្មែរក្រហមនៅក្នុងរោងបាយ

# ជួន ប៊ុនថានៈ ឪពុកខ្ញុំគ្មានកំហុសទេ

ជួន ប៊ុនថាន អាយុ៤៣ឆ្នាំ ថ្វាយបង្គំរូបថតឪពុកដែលបិទជាប់នឹងប្រវត្តិរូប ហើយនិយាយទាំងសំឡេងញ័រៗថា "ប៉ាអើយប៉ា! មិនដឹងជាប៉ាវេទនាយ៉ាងណាទេមុននឹងគេសម្លាប់" ។ ឪពុករបស់ ប៊ុនថាន ឈ្មោះ គង់ ទៀង ត្រូវខ្មែរក្រហមចាប់ខ្លួនឃុំឃាំងនិងសម្លាប់នៅមន្ទីរ ស-២១ ។


គង់ ទៀង នៅក្នុងមន្ទីរស២១

គង់ ទៀង គឺជាអតីតកីឡាករប្រណាំងកង់នៅក្នុងសង្គមរាស្ត្រនិយម ។ ឈប់ពីអាជីពជាអ្នកប្រណាំងកង់ ទៀង ប្រកបរបរធ្វើស្រែចម្ការ និងរត់រ៉ឺម៉កនៅភូមិកំណើតគឺភូមិព្រែកឯង ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ ទៀង មានប្រពន្ធឈ្មោះ ឈឹម រ៉េត និងមានកូនស្រីពីរនាក់ ។

ក្រុមគ្រួសាររបស់ គង់ ទៀង បានភៀសខ្លួនមករស់នៅទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៤ ដើម្បីគេចពីសង្គ្រាមដែលឆាបឆេះភូមិកំណើតរបស់គាត់ ។ បន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះនិងចាប់ផ្តើមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ក្រុមគ្រួសាររបស់ ទៀង វិលទៅរស់នៅភូមិកំណើតវិញ ប៉ុន្តែត្រូវខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅភូមិកំពង់ត្រាំ ស្រុកពារាំង ខេត្តព្រៃវែង ។

បើតាមការចងចាំរបស់ ប៊ុនថាន ដែលជាកូនស្រីពៅ គង់ ទៀង ត្រូវខ្មែរក្រហមចាប់ខ្លួននៅពាក់កណ្តាលឆ្នាំ១៩៧៧ ។ កាលណោះជិតដល់រដូវទឹកឡើង អង្គការបានចេញបញ្ជាឲ្យ គង់ ទៀង ទៅដឹកអំបិលនៅសហករណ៍ផ្សេង ។ ទៀង រាវលៀសបានមួយថង់ធំគិតថានឹងយកទៅផ្ញើប្រជាជននៅកន្លែងដែលខ្លួននឹងទៅដឹកអំបិល ។ តាំងពីពេលដែល គង់ ទៀង ចេញទៅដឹកអំបិល មិនឃើញគាត់វិលត្រឡប់មកផ្ទះវិញសោះ ។ ការបញ្ជូន គង់ ទៀង ទៅដឹកអំបិលគឺធ្វើឡើងមិនយូរប៉ុន្មានបន្ទាប់ពីការចាប់ខ្លួនបុរសម្នាក់ឈ្មោះ យិន ស៊ុំ នៅក្នុងភូមិជាមួយគ្នា ។ នៅក្នុងសេចក្តីសង្ខេបចម្លើយសារភាពរបស់ គង់ ទៀង នៅមន្ទីរ ស-២១ អ្នកកត់ត្រាឯកសារបានសរសេរថា "មូលហេតុដែលអង្គការចាប់ខ្លួនៈ ១) យិន ស៊ុំ ឆ្លើយដាក់ ២) ដោយនិយាយពីរឿងថាមានបក្សខាងសម្តេច ខាងហ៊ូនីម និងខាងខៀវ សំផន (ហើយវាថាបើមានខាងសម្តេចវាចូលខាងសម្តេចហើយ) ហើយបំផុសគេបាន៨នាក់ឲ្យជឿតាម ។"

ប៊ុនថា រំឭកអំពីយប់មុនពេលដែលឪពុកចេញទៅដឹកអំបិលថា "គេប្រាប់មុនថាឲ្យទៅដឹកអំបិល ។ ម៉ាក់រៀបចំឥវ៉ាន់ឲ្យ ។ ម៉ាក់ដឹងសភាពការណ៍អត់ស្រួលទៀត គាត់ប្រាប់ថារៀបឥវ៉ាន់ឲ្យហ្នឹងឲ្យគាត់គេចខ្លួន ថាឲ្យទៅមែនប៉ុន្តែឲ្យគេច កុំឲ្យទៅតាមគេពេក ។ ប៉ាថា វាមិនដែលស្អីទេ ខ្ញាំងណាស់គេគ្រាន់តែអប់រំកសាងយើង ។ ប៉ុន្តែម៉ាក់ថាឯងត្រូវតែប្រយ័ត្នខ្លួនណា ។ ប៉ាថា កុំភ័យ មើលថែកូនថែម៉ែទៅ ។ យប់ហ្នឹងគាត់បែបសម្រាន្តអត់លក់ទេ ។ គាត់យកគល់រាំងដែលគាស់ពីថ្ងៃមកដុត ហើយគាត់ខ្សឹបជាមួយម៉ាក់រអ៊ូៗ អត់ហ៊ាននិយាយឲ្យពុៗទេ គាត់ដេញខ្ញុំឲ្យទៅដេក ខ្លាចឈឺ ។ កាលហ្នឹងខ្ញុំនៅតូចអាយុប្រហែលជាង១០ឆ្នាំ ។ មិនដឹងយ៉ាងម៉េចទេ ស្រាប់តែភ្លឺឡើងខ្ញុំរង់ចាំជូនដំណើរប៉ា ទីបំផុតអត់បានជូនទេ ។ ព្រលឹមឡើងខ្ញុំសួរ ម៉ាក់ថាប៉ាទៅបាត់ហើយ ។" ប៊ុនថាន អង្អែលរូបថតឪពុកហើយពោលបន្ត "គេប្រាប់ថាមិនបាច់យកអីទៅទេ បានជាខ្ញុំនៅចាំក្តុកក្តួលក្នុងចិត្ត យកតែកម្មសិទ្ធិមួយស្បោងតូច ។ ឥឡូវមិនបាច់បានស្បោងមួយមកវិញទេ សូម្បីតែធាតុមួយកញ្ចប់មកវិញក៏អត់បានដែរ ។"

បន្ទាប់ពីយក គង់ ទៀង ទៅបានប្រហែលជាងមួយឆ្នាំ នៅដើមរដូវទឹកឡើងក្នុងឆ្នាំ១៩៧៨ អង្គការមានផែនការយកប្រពន្ធនិងកូនរបស់គាត់ដែលនៅសល់ទៅសម្លាប់ទៀត ។ ប្រជាជនមូលដ្ឋានដែលបានដឹងរឿងនេះជាមុនបានលួចខ្សឹបប្រាប់ ឈឹម រ៉េត ។ ឈឹម រ៉េត បាននាំកូនស្រីពៅរត់គេចខ្លួន ដោយទុកចោលកូនស្រីច្បងនៅកងចល័ត ។ ប៊ុនថាន រំឭកហេតុការណ៍ក្នុងពេលរត់ភៀសខ្លួនថា "គេថាម្តងនេះគេយកទៅហើយអ្នកនៅសល់ទាំង

# ជីវិតក្នុងភាពនឹងថ្កល់

**ចាន់ លាង**
**សមាជិកគណៈកម្មាធិការកងកាត់ដេរ**

*(បទសម្ភាសន៍ជាមួយប្អូនស្រីឈ្មោះ ចាន់ សុខគីម អាយុ៤៧ឆ្នាំ នៅស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម)*

ឪពុកម្តាយខ្ញុំមានកូនប្រាំពីរនាក់ ។ បងប្អូនរបស់ខ្ញុំទាំងអស់ចូលបដិវត្តន៍ខ្មែរក្រហមនៅឆ្នាំ១៩៧០ លើកលែងតែខ្ញុំនិងបងស្រីខ្ញុំម្នាក់ឈ្មោះ នឿង ។ បងនឿង ចង់ចូលបដិវត្តន៍ដែរ ប៉ុន្តែប្តីរបស់គាត់មិនយល់ព្រម ។ ឪពុកម្តាយខ្ញុំក៏មិនឲ្យខ្ញុំទៅ ព្រោះកាលណោះខ្ញុំនៅក្មេងពេក ។ ក្រោយមកខ្ញុំបានចូលរួមបដិវត្តន៍ដែរនៅឆ្នាំ១៩៧៤ ។ សាលារៀនត្រូវបិទទ្វារតាំងតែពីឆ្នាំ១៩៧០ម៉្លេះ ។ កាលណោះបងៗរបស់ខ្ញុំរៀនពេទ្យជាមួយខ្មែរក្រហម ហើយខ្ញុំចង់រៀនពេទ្យដូចគាត់ដែរ ។

បងលាង ប្រលងធ្លាក់ឌីប្លូម ។ ក្រោយមកគាត់ក៏ភ្ជាប់ពាក្យ ។ គាត់រៀបការជាមួយបងញ៉ែម នៅឆ្នាំ១៩៦៧ ។ បងញ៉ែម ធ្វើការឲ្យក្រុមហ៊ុននាំចូលគ្រឿងបន្លាស់ម៉ូតូ ។ បងលាង មានកូនប្រុសដំបូងនៅឆ្នាំ១៩៦៨ ។ ក្រោយពីរដ្ឋប្រហាររបស់លន់ណុល គាត់និងបងញ៉ែម បានចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។

នៅឆ្នាំ១៩៧៥ បងលាង និងប្តីគាត់ ត្រូវបញ្ជូនទៅភ្នំពេញ ហើយខ្ញុំក៏ទៅជាមួយគាត់ដែរ ។ បងលាង ធ្វើការនៅកងដេរខោអាវនៅអូរឫស្សី ឯបងថ្លៃខ្ញុំនិងខ្ញុំទៅខាងផ្សារចាស់ ។ បងថ្លៃខ្ញុំជាបុគ្គលិកនៅក្រសួងពាណិជ្ជកម្ម ខ្ញុំជាចុងភៅនៅទីនោះ ។

នៅឆ្នាំ១៩៧៦ខ្មែរក្រហមបញ្ជូន បងញ៉ែម ទៅប្រទេសចិនរយៈពេលមួយខែ ។ ពេលគាត់ត្រឡប់មកវិញបាន៦-៧ថ្ងៃ ខ្មែរក្រហមចាប់ខ្លួនគាត់នៅរោងបាយផ្សារចាស់ ។ កាលណោះបងញ៉ែម ពរកូនប្រុសទីបីរបស់គាត់ ដើរមកប្រាប់ខ្ញុំអំពីរឿងអង្គការហៅគាត់ ។ គាត់និយាយថា បើអង្គការហៅគាត់ត្រូវតែទៅ ។ ប្រហែលពីរខែក្រោយមក បងស្រីខ្ញុំក៏ត្រូវអង្គការចាប់ខ្លួនដែរ ។ បងស្រីខ្ញុំមានកូនប្រុសពីរនាក់ទៀតធ្វើនៅកងកុមារ ប៉ុន្តែ


រូបខាងឆ្វេង៖ ចាន់ លាង មានផ្ទៃពោះ៦ខែ ថតនៅកំពង់សោម ក្នុងឆ្នាំ១៩៧៥

ខ្មែរក្រហមចាប់តែកូនពីរនាក់ដែលនៅផ្ទះជាមួយគាត់ ។ កូនពៅមានអាយុមិនដល់មួយខួបផង ។

ខ្មែរក្រហមបើកប្រជុំនៅផ្សារចាស់ ហើយប្រាប់យើងថា បងស្រីខ្ញុំនិងប្តីគាត់លួចលាក់ចិញ្ចឹមខ្មាំង ។ អង្គការថាបងស្រីខ្ញុំជាខ្សែបណ្តាញកា.ហ្សេ.បេ ឯបងថ្លៃខ្ញុំជាខ្សែសេ.អ៊ី.អា ។ ខ្ញុំវង្វេងអស់ហើយ ព្រោះបងស្រីខ្ញុំកាន់តំណែងខ្ពស់ដែរ ។ ខ្មែរក្រហមរិះគន់ខ្ញុំជាច្រើនលើកច្រើនសា ។ ខ្ញុំបានសារភាពទទួលគ្រប់កំហុសទាំងអស់ ។

បន្ទាប់មកទៀត ខ្មែរក្រហមផ្លាស់ខ្ញុំឲ្យទៅកងចល័តនៅផ្សារចាស់ដោយសារខ្ញុំជាចុងភៅ ខ្ញុំយល់ថាប្រហែលជាគេខ្លាចខ្ញុំដាក់ថ្នាំបំពុលក្នុងបាយម្ហូបហើយមើលទៅ ។ ការងារនៅកងចល័តលំបាកខ្លាំងណាស់ ហើយគ្មានអាហារគ្រប់គ្រាន់ទៀត ។ ខ្ញុំទៅ

ប៉ុន្មាន ។ មានអ្នកមូលដ្ឋានចិត្តល្អ គេលួចប្រាប់ម៉ាក់ ។ ខ្ញុំត្រូវទៅមើលគោឆ្ងាយ ហើយម៉ាក់ត្រូវទៅកាច់ពោត ប៉ុន្តែមុនទៅកាច់ហ្នឹងគាត់ប្រាប់ខ្ញុំថា កូនឯងកុំយកគោទៅចងឆ្ងាយពេក ព្រោះយើងត្រូវរត់ ។ ខ្ញុំថារត់ទៅណា ខ្ញុំអត់ដឹង ។ កូនពូខ្ញុំវាយំឱបខ្ញុំនៅក្នុងព្រៃថាយើងបែកគ្នាហើយ ។ ពេលយប់ម៉ាក់នាំខ្ញុំរត់ទៅជាមួយមីងខ្ញុំនិងកូនៗគាត់តូចៗ ហែលឆ្លងទឹកទន្លេតូច ខ្ញុំអត់ចេះហែលទឹកទេ ម៉ាក់ខ្ញុំយកក្មេងៗហែលទៅមុនអស់ ទុកខ្ញុំនៅក្រោយម្នាក់ឯង ។ កាលហ្នឹងបើឈ្លបដើរមក តាមមាត់កំពង់ឃើញយើងវាវ៉ៃយើងហើយ ។ ខ្ញុំភ័យ ពេកខ្ញុំស្រែកយំ ម៉ាក់សម្លុតខ្ញុំពីត្រើយខាងនោះមកថា កុំយំ» ។

ឆ្លងផុតទន្លេតូច ក្រុម អ្នកភៀសខ្លួនធ្វើដំណើរបន្តរំលងជាច្រើនភូមិទៅដល់ ភូមិព្រៃក្មេង និងបានសុំប្រធានភូមិដើម្បីស្នាក់នៅ ទីនោះ ប៉ុន្តែប្រធានភូមិមិនអនុញ្ញាត ហើយឲ្យនីរសារ ជូនទៅភូមិទួលទ្រា ។ ប៉ុន ថាន រៀបរាប់បន្តទៀតថាៈ «រត់ទៅដល់ភូមិព្រៃក្មេង អ្នកនៅភូមិនោះឃើញខ្ញុំ សម្បុរស គេថាច្បាស់ជាកូនមេកងហើយ ។ ម៉ាក់ថាមិនមែនប្រពន្ធមេកងទេ ប្ដីខ្ញុំគេយកទៅដឹកអំបិលបាត់មិនទាន់ឃើញមកវិញផង ។ គេនៅសង្ស័យទៀតណា៎ គេថាមិនមែនទេអ្ហី យោធាជម្រិតសួរផង អ្នកភូមិជម្រិតសួរផង ។ កាលហ្នឹងបូព៊ាក្បត់ គេថាយើងប្រហែលជាប្រពន្ធប្រធានភូមិហើយ តែម៉ាក់ថាមិនមែនទេ ។ ដល់ពេលល្ងាចគេធ្វើម្ហូបឲ្យហូប ម៉ាក់ចង់ភ័យទៀត ។ ដល់ហើយគេបញ្ជូនយើងទៅភូមិទួលទ្រា មាននីរសារគេនាំទៅ ដើរលេចព្រៃចូលវាល ម៉ាក់ថាច្បាស់ជាគេវ៉ៃចោលហើយ ព្រោះគេបណ្ដើរមានស្ពាយកាំភ្លើង ។ ទៅដល់ភូមិទួលទ្រាគេឲ្យនៅក្នុងខ្ទមមួយគ្នា៥នាក់ ។ ដល់យប់បន្តិចគេមកគោះទ្វារ ម៉ាក់អត់ហ៊ានបើកទ្វារសោះ គាត់ទន្ទេញធម៌

# អ្នកស្លាប់ ស្លាប់ទាំងបិទភ្នែកមិនជិត
# អ្នកនៅសោកសៅ រស់នៅទាំងវេទនា

ខ្ញុំកើតនៅខែកញ្ញា ឆ្នាំ១៩៦២ នៅភូមិស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ នៅឆ្នាំ១៩៧២ សង្គ្រាមរវាងកងទ័ពខ្មែរក្រហមនិងទាហានកន្សែងខៀវរបស់សេនាប្រមុខ លន់ ណុល បានកម្ទេចទីនេះក្លាយជាដេះដង់ ។

ពេលនោះគ្រួសារខ្ញុំបង្ខំចិត្តភៀសខ្លួនមកនៅភូមិអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្ដាល ។ យើងរស់នៅទីនោះបានតែ១ឆ្នាំទេ ដោយសារថាសភាពការណ៍មិនសូវស្រួល កងទ័ពខ្មែរក្រហមតែងឆ្មក់ចូលជាញឹកញាប់ ។ ម្ដាយខ្ញុំបានផ្លាស់មកនៅសង្កាត់គីឡូម៉ែត្រលេខ៤ ក្រុងភ្នំពេញជាមួយបងខ្ញុំម្នាក់ដែលមានមុខងារជាអនុសេនីយ៍ឯកបើកយន្តហោះប្រដេញកងទ័ពអាកាសក្នុងរបបសាធារណរដ្ឋខ្មែរ ។

ឆ្នាំ១៩៧៤ក្រុងភ្នំពេញមានភាពវឹកវរជ្រួលច្របល់យ៉ាងខ្លាំង ។ ទ័ពខ្មែរក្រហមហ៊ុមព័ទ្ធស្ទើរជុំវិញទីក្រុង ហើយតំបន់ខ្លះត្រូវទទួលរងនូវគ្រាប់ផ្លោងជារៀងរាល់ថ្ងៃ ។ ឪពុកខ្ញុំនិងបងប្រុសខ្ញុំបានពិភាក្សាគ្នាថា យើងគួរតែចាកចេញពីទីក្រុងភ្នំពេញទៅរស់នៅសហរដ្ឋអាមេរិក ព្រោះគាត់ដឹងថាពេលខាងមុខ កងទ័ពខ្មែរក្រហមនឹងបានជ័យជម្នះ ហើយនឹងសម្លាប់ប្រជាជននៅទីនេះមិនខានឡើយ ។ ម្ដាយខ្ញុំបានបដិសេធពុំព្រមទៅទេ គាត់ថែមទាំងពន្យល់ទៅបងប្រុសខ្ញុំវិញថា មិនចាកចេញពីស្រុកកំណើតទេ ។ គាត់ថាគេធ្វើសង្គ្រាមដើម្បីរំដោះជាតិ គេមិនសម្លាប់ប្រជាជនទេ ។ ម្ដាយខ្ញុំយល់ដូចនេះដោយសារគាត់ស្ដាប់វិទ្យុខ្មែរក្រហមនិងវិទ្យុប៉េកាំង ។

### ការដួលរលំនៃរបបសាធារណរដ្ឋខ្មែរ

នៅល្ងាចថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ រថក្រោះបើកយ៉ាងគគ្រឹកគគ្រេងដកថយពីខ្សែត្រៀមចូលមកកណ្ដាលទីក្រុងភ្នំពេញ ។ នេះជាការទម្លាក់អាវុធរបស់ទាហាន លន់ ណុល ។

ឈានចូលដល់ថ្ងៃទី១៧ ខែមេសា វេលាម៉ោង៤ទៀបភ្លឺ សំឡេងគ្រាប់ផ្លោងលាយឡំជាមួយគ្រាប់កាំភ្លើងដៃ និងសម្រែករបស់កងទ័ពខ្មែរក្រហមបានសម្រុកចូលទីក្រុងភ្នំពេញ ។ ព្រលឹមស្រាងៗ ឡើងកងទ័ពឯកសណ្ឋានខ្មៅដើរជាក្រុមតាមដងវិថី

សហព័ន្ធរុស្ស៊ី ។ ក្រុមសាស្ត្រាចារ្យ និស្សិត ប្រជាជន ឈរអមសងខាងផ្លូវយ៉ាងកុះករ លើកគ្រវីទង់ពណ៌ស ព្រមទាំងស្រែកជយឃោសទទួលកងទ័ពរំដោះ ។

## សភាពការណ៍ប្រែប្រួល

បន្ទាប់ពីអបអរសាទរទទួលអំណរជ័យជម្នះរបស់កងទ័ពរំដោះកន្លងទៅ សភាពស្ងប់ស្ងាត់ក៏ចាប់ផ្តើមឡើង ។ នៅវេលាម៉ោង ២រសៀលថ្ងៃដដែល កងទ័ពខ្មែរក្រហមកាន់ឧបករណ៍បំពងសំឡេងនិងអាវុធជាប់ដៃ ស្រែកប្រកាសឲ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញដោយបញ្ជាក់ថា អាមេរិកនឹងមកទម្លាក់គ្រាប់បែក ។ ពេលនោះប្រជាជនបានធ្វើដំណើរយ៉ាងកកកុញនៅតាមវិថីកម្ពុជាក្រោមឆ្ពោះទៅទិសខាងលិច ។ ក្រុមគ្រួសាររបស់ខ្ញុំរុញរថយន្តសន្សឹមៗក្នុងចំណោមមនុស្សណែនណាន់តាន់តាប់ រហូតដល់ព្រលប់ទើបសម្រាកនៅខាងកើតផ្សារទឹកថ្លា ។ ព្រលឹមស្រាងៗក្រុមកងទ័ពអាវខ្មៅបណ្តេញយើងឲ្យធ្វើដំណើរទៅមុខទៀត ។ ក្នុងពេលធ្វើដំណើរ ខ្ញុំឮតែសំឡេងយំលាយឡំនឹងសំឡេងថ្ងូរនៃអ្នកជំងឺដែលដេកលើរទេះរុញ និងសម្រែករកឪពុកម្តាយបងប្អូន ។ នៅតាមអមសងខាងផ្លូវ ខ្ញុំប្រទះឃើញសាកសពជាច្រើន ខ្លះមានឯកសណ្ឋានជាទាហាន ខ្លះជាប្រជាជន ដេកស្លាប់ក្នុងថ្លុកឈាមក្រោមកំដៅថ្ងៃខែចេត្រគួរឲ្យអាណោចអាធ័មណាស់ ។ ពេលខ្លះខ្ញុំឃើញកងទ័ពខ្មែរក្រហមស្ទើយកម៉ូតូ នាឡិកា ឬសម្ភារផ្សេងៗពីប្រជាជនប្រៀបដូចជាការប្លន់ ហើយខ្ញុំឃើញខ្មែរក្រហមចងមនុស្សស្លៀកតែខោខ្លីបណ្តើរទាំងហ្វូងមិនដឹងជាយកទៅណា ។

បងខ្ញុំប្រាប់ថា "នេះហើយជារបបកុម្មុយនិស្ត" ។ ធ្វើដំណើរពេញមួយថ្ងៃ ក្រោយពេលព្រះអាទិត្យលិចបាត់ទៅ ក្រុមគ្រួសារខ្ញុំបានមកដល់ស្ពឹងកំពង់ទួល ។ យើងបានសម្រាកនៅទីនោះមួយយប់ ។ ក្រោយបាយពេលរួច បងៗខ្ញុំបានប្រមូលសម្លៀកបំពាក់ទាហាន យកទៅបោះចោលនៅតាមគុម្ពោតព្រៃមាត់ស្ទឹង ។ មកដល់ថ្ងៃទី៣ ក្រុមគ្រួសារខ្ញុំបានធ្វើដំណើរដល់ស្រុកត្រាំខ្នារ នៅពេលនោះ អង្គការដកយករថយន្តរបស់យើងនិងសម្ភារមួយចំនួន ។ បងខ្ញុំបានសម្រេចចិត្តតាមម្តាយខ្ញុំធ្វើដំណើរបន្តទៅភ្នំស្រង់ដែលជាស្រុកកំណើតរបស់ម្តាយខ្ញុំ ។

## ផែនការប្រមូលផ្តុំប្រជាជន១៧មេសា

សង្គ្រាមបានបញ្ចប់ ។ គ្រួសារខ្ញុំក៏ដូចជាគ្រួសារប្រជាជនដទៃទៀតដែលមកពីភ្នំពេញ សង្ឃឹមថានឹងរស់នៅយ៉ាងសុខសាន្តនៅលើទឹកដីស្រុកកំណើត ។ ផ្ទុយទៅវិញ យើងត្រូវអង្គការប្រមូលគ្រួសារណាដែលមកពីភ្នំពេញឲ្យទៅរស់នៅភូមិថ្មីដោយឡែកពីប្រជាជនចាស់(ប្រជាជនមូលដ្ឋាន) និងឋិតនៅក្រោមការតាមដានស្រង់ប្រវត្តិរូបរកអ្នកដែលមាននិន្នាការជាអតីតមន្ត្រីរាជការ ទាហាន លន់ណុល ហើយត្រូវអង្គការបញ្ជូនឲ្យទៅទទួលសម្តេចឪ ។ ក្រោយមកគ្រួសារទាំងនេះត្រូវអង្គការយកទៅសម្លាប់ទាំងអស់ ។

## ឃុំផុងអន្លង់មរណៈ

ជីវិតប្រជាជន១៧មេសា ដូចជាជីវិតសត្វដែលរស់នៅក្រោមការតាមដានរបស់អង្គការ និងរង់ចាំតែថ្ងៃដែលអង្គការយកទៅសម្លាប់ប៉ុណ្ណោះ ។ គ្រួសារខ្ញុំនៅក្នុងភូមិថ្មីរយៈពេល២ខែ អង្គការបញ្ជូនទៅឲ្យរស់នៅក្នុងភូមិថ្មីមួយទៀតនៅកណ្តាលព្រៃនៃទឹកដីឃុំផុងដែលជាកន្លែងលត់ដំមួយដ៏ធំរបស់ស្រុក៥៣ ។ អ្នកដែលត្រូវបញ្ជូនមកដល់ទីនេះមិនដែលបានត្រឡប់ទៅវិញទេ ដោយសារនៅទីនោះជាតំបន់ចាញ់ សម្បូរសត្វសាហាវនិងគ្មានអាហារគ្រប់គ្រាន់ដូចជានៅមន្ទីរតាអែ សូម្បីតែដំឡូងក៏ដាំលើរណ្តៅខ្មោចដែរ ពេលដកដំឡូងឡើងដោយទាំងឆ្អឹងខ្មោចមកជាមួយក៏មាន ។

បន្ទាប់ពីទៅដល់ទីនោះ ក្រុមគ្រួសារខ្ញុំដ៏ដូចជាគ្រួសារឯទៀតត្រូវបាត់បង់សមាជិកស្លាប់ជារៀងរាល់ថ្ងៃ ដោយជំងឺគ្មានថ្នាំព្យាបាល ។ មនុស្សរាប់រយនាក់បាក់កម្លាំង ខ្លះហើម ខ្លះគ្រុនចាញ់ហើមស្គីង អង្គុយបញ្ឈរក្បាលជង្គង់ទាំងពីរស្មើក្បាល ។ ក្រុមឈ្លបក្មេងៗតែងតែសើចចំអក ហើយហៅយើងថា "ពួកអាសម័យ ពួកអាកម្លាំងទី៣ អាឪលអំប៉ាប់(អា១៧)" ។

នៅទីនេះក្មួយជាទីស្រលាញ់របស់ខ្ញុំពីរនាក់ស្លាប់ដោយជំងឺរាក ចំណែករូបខ្ញុំនិងបងៗខ្ញុំគ្រុនចាញ់ញាក់ជារៀងរាល់ថ្ងៃ ហើយខំធ្វើការមិនហ៊ានឈប់ព្រោះខ្លាចអង្គការយកទៅសម្លាប់ ។

ព្រឹកមួយឈ្លបប្រាប់ថា អង្គការឲ្យប្រជាជនទាំងអស់ទៅ

ចូលរួមមហាសន្និបាត ។ ពេលនោះគ្រប់ៗគ្រួសារដឹងថា អង្គការប្រមូលប្រជាជនយកទៅសម្លាប់ហើយ ។ ខ្លះយកកាំបិតពូថៅឬសម្ភារមុតៗទៅតាមដើម្បីការពារខ្លួន ។ បងស្រីម្នាក់មានផ្ទៃពោះប្រាំពីរខែឃ្លូរបង្ខិចចេញពីខ្ទម ស្រាប់តែឈ្លបម្នាក់ស្ទុះទៅឆក់យកបង្ខិចនោះ រួចទាត់ផាក់និងវាយគាត់នឹងស្នូកកាំភ្លើង រហូតដល់គាត់ហូរឈាមប្រឡាក់ដោកសម្លៀកបំពាក់ ។ ឃើញដូច្នេះប្ដីរបស់គាត់ក៏រត់ទៅលើកពរត់គេចចូលទៅក្នុងហ្វូងមនុស្សរាប់ពាន់នាក់ ។ ហ្វូងប្រជាជនបានចលាចលឆ្លាយចេញពីព្រៃនោះមកផ្លូវលំមួយឆ្ពោះមករកភូមិស្វាបលែង ។

ថ្ងៃរសៀលបន្តិច មានម៉ូតូហុងដាសេអិលមួយជិះមកស្ទាក់ក្បួន ។ អ្នកខ្លះស្គាល់អ្នកជិះនោះថាជា តាអែ ប្រធានស្រុក៥៣ ។ តាអែ ប្រាប់កងឈ្លបដែលកំពុងតែភ្ជង់បណ្ដើរហ្វូងមនុស្សឲ្យបំបែកប្រជាជនទាំងអស់នេះឲ្យចូលរស់នៅតាមភូមិវិញ ។

## ផែនការពន្យារដើម្បីងាយស្រួលសម្លាប់

ក្រោយពីទទួលផែនការរបស់ តាអែ គណៈស្រុក៥៣បានបញ្ជូនប្រជាជនថ្មីទាំងអស់ឲ្យចូលទៅរស់នៅតាមភូមិជាមួយប្រជាជនចាស់ទូទាំងស្រុក៥៣ (ស្រុកគងពិសី) ។

គ្រួសារខ្ញុំនិងគ្រួសារមួយចំនួនត្រូវអង្គការបញ្ជូនទៅនៅភូមិមួយឈ្មោះភូមិក្រោលក្រសាំង ឃុំកក ខេត្តកំពង់ស្ពឺ ។ ប្រជាជនដែលរស់នៅទីនេះចាត់ទុកប្រជាជនមកពីភ្នំពេញជាប្រជាជនបញ្ញើ ។

ខ្ញុំត្រូវទៅរស់នៅក្នុងកងចល័តកុមារឃុំ ។ ពេលនឹកក្ដួយនិងឪពុកម្ដាយបងប្អូនខ្លាំងពេក ខ្ញុំលួចរត់មកផ្ទះនៅពេលយប់ឆ្លងកាត់ព្រៃជួបរណ្ដៅខ្មោចមានដំបងប្រឡាក់ឈាមដែលទើបនឹងវាយមនុស្សចោលថ្មីៗក៏មាន ។ យប់មួយខ្ញុំឮប្រធានកងខ្ញុំឈ្មោះ មិត្តសំ និយាយប្រាប់គ្នាថា ខ្លួនទើបតែមកពីវាយខ្មាំងចោលគ្រួសារប្រជាជន១៧មេសាឈ្មោះ ថា ដោយវាយឲ្យឆ្លើយថាពាក់ស័ក្ដពាសេ.អ៊ី.អារបស់អាមេរិក ។

ថ្ងៃមួយ កងរបស់ខ្ញុំត្រូវអង្គការបញ្ជូនទៅដាក់នៅស្ទឹងលើដើម្បីដាំដំឡូងនិងធ្វើព្រៃពោត ។ ខ្ញុំប្រទះឃើញទិដ្ឋភាពជាច្រើនគួរឲ្យស្លុត ។ នោះគឺកន្ទៃងវះពោះមនុស្សយកប្រមាត់ ។ ស្នាមឈាមប្រឡាក់ជាប់នឹងដើមពន្ល រណ្ដៅសាកសពនិងលលាដ៍ក្បាលនៅរាយពាសពេញព្រៃ ។ កុមារមូលដ្ឋានប្រាប់ខ្ញុំថា ទីនេះជាមន្ទីររបស់ មិត្តភាព គណៈតំបន់៣៣ (ខេត្តកំពង់ស្ពឺ) ។ ទាហានឬប្រជាជនដែលចាត់ទុកជាឈ្លើយសឹកត្រូវបានបញ្ជូនមកមន្ទីរមិត្តភាព ឬបញ្ជូនទៅមន្ទីរតាអែឲ្យធ្វើការធ្ងន់ៗបាក់កម្លាំងទើបយកទៅសម្លាប់ចោល ។ បើអ្នកទោសនៅមានកម្លាំង សាច់ស្អាតឈ្លបយកទៅវះពោះទាំងរស់យកប្រមាត់ ។ ខ្លះចាប់ចងជើងព្យួរនឹងដើមឈើយោលរហូតទាល់តែស្លាប់ ជួនកាលបណ្ដើររត់ទាំងហ្វូង ទើបបាញ់រះសម្លាប់ ។ សាកសពត្រូវសត្វជ្រូក ឆ្កែព្រៃអូសស៊ី ធ្អឹងនៅពាសពេញព្រៃ (ព្រៃខាងជើងភ្នំក្រាំង) ។ ក្មេងតូចៗត្រូវចាប់បញ្ចូលទៅក្នុងលេណដ្ឋានចាស់ៗរួចគរខ្សាច់ដុតទាំងរស់ ។

## ដំណឹងគួរឲ្យរន្ធត់

ដើមឆ្នាំ១៩៧៧ នៅរដូវចម្រូតកងចល័តរបស់បងខ្ញុំត្រូវមកច្រូតស្រូវនៅភូមិត្រពាំងពើក ។ ខ្ញុំនឹកបងប្រុសខ្ញុំពេកពេលសម្រាកថ្ងៃត្រង់ខ្ញុំរត់ទៅរកគាត់ ប៉ុន្តែអកុសល ពេលទៅដល់ បងម្នាក់ឈ្មោះ សឹន ប្រាប់ថា “អាហេង(បងប្រុសខ្ញុំ) ត្រូវមិត្តចន ប្រធានសាខាឃុំហៅយកទៅសម្លាប់កាលពីល្ងាចមិញនេះ ខោអាវគាត់គេចែកគ្នាអស់ទៅហើយ ។ កូនគាត់នៅភូមិត្រូវមិត្តនឹម ប្រមូលយកទៅសម្លាប់នៅឯទួលខ្មោច ។ ចំណែកឪពុកម្ដាយឯង មិត្តនាង ប្រុងយកទៅសម្លាប់ដែរ ប៉ុន្តែ មិត្តហៀងថាគ្មានរទេះដឹកទេព្រោះគាត់ឈឺដើរមិនរួច ទុកឲ្យស្លាប់ខ្លួនឯងទៅ ។ ប្អូនឯងប្រយ័ត្នខំប្រឹងធ្វើការលត់ដំខ្លួនតាមអង្គការ” ។

## ទុក្ខជួនទុក្ខ

ព្រឹកថ្ងៃបន្ទាប់ កុមារនៅកងជាមួយខ្ញុំដែលទើបត្រឡប់មកពីភូមិបានសួរខ្ញុំថា “មានឮស្នូរកាំភ្លើងទេពេលមុននេះបន្តិច? កងឈ្លបដេញបាញ់ បងហាក់ បងរបស់ឯងស្លាប់បាត់ទៅហើយ ។ ខ្មោចគាត់នៅចោលក្រោមដើមក្ដុលខាងត្បូងភូមិថ្នល់ដាច់ គ្មាននរណាហ៊ានទៅមើលទេ ព្រោះអង្គការចោទគាត់ថាជាសេ.អ៊ី.អាខ្មាំងបង្កប់នៅក្នុងមូលដ្ឋាន” ។

តើមានអ្វីកើតឡើងទៀតនៅថ្ងៃខាងមុខបន្ទាប់ពីបងៗ

និងក្មួយៗជាទីស្រឡាញ់របស់ខ្ញុំត្រូវសម្លាប់? ឪពុកម្តាយខ្ញុំឈឺដើរមិនរួច គ្មានអ្វីហូបនិងគ្មានអ្នកមើលថែ ។ ចំណែកខ្លួនឯងរស់រង់ចាំតែថ្ងៃអង្គការយកទៅសម្លាប់ ។ អង្គការអនុវត្តពាក្យស្លោក "ដកស្មៅត្រូវដកទាំងឫស" ។ ម្តងនោះ នៅក្នុងកងគ្មានអង្ករដាំបបរទេ ប្រធានកងបានស្នើឲ្យទៅរកជំឡូងតាមសហករណ៍ ។ ខ្ញុំបានលួចចូលទៅមើលឪពុកម្តាយខ្ញុំ ។ អ្វីដែលគួរឲ្យខ្លោចផ្សានោះគឺម្តាយខ្ញុំឈឺភ្នែករាវពពើម ហើយអង្គការឲ្យគាត់មើលក្មេងតូចៗពីរនាក់ទៀត ។ ម្តាយខ្ញុំនិយាយប្រាប់ថា "ពេលដឹងថាកូនត្រូវគេសម្លាប់ ឯចៅនៅរស់ជាមួយក៏គេមិនទុកទៀត ឪពុករបស់ឯងបរទេះមកពីស្ទឹងស្ពុតឈឺដេកលើរនាបរហូត ។ ពេលម៉ែទៅសុំបបរយកមកឲ្យគាត់ សេដ្ឋកិច្ច មិត្តមាំង និងយាយម៉ុន ជេរស្តីឲ្យម៉ែ ជួនកាលលើកវែករកវាយម៉ែ ហើយជេរម៉ែថា បើខ្វាំងស៊ីធ្វើអ្វី" ។

ខ្ញុំចូលទៅរកឪពុកខ្ញុំនៅក្នុងខ្ទមងងឹត សម្លឹងទៅរកគាត់តាមពន្លឺថ្ងៃដែលចាំងចូលតាមដំបូលនិងជញ្ជាំងដែលធ្លុះធ្លាយ ខ្ញុំឃើញគាត់សម្រាន្តនៅលើរនាបឫស្សី ខាងក្រោមមានរណ្តៅលាមកនិងជេះព្រោះគាត់ងើបមិនរួច ។ ខ្ញុំលូកដៃប្រប៉ាច់ជើងគាត់ប៉ះឆ្អឹងខ្នងដូចជាមុខកាំបិត គាត់សួរទាំងសំឡេងខ្សាវៗថា "នរណា?" ខ្ញុំឆ្លើយថា "ខ្ញុំផ្លួន" គាត់ហាមាត់ម្ហូបៗដកខ្យល់និយាយថា "ផ្លួន មានអីហូបទេ ឲ្យពុកហូបផងពុកហេវណាស់" ។ គាត់និយាយលែងរួចដោយអត់គឃ្លូស ។ ព្រសម្តីគាត់ធ្វើឲ្យខ្ញុំអាណិតខ្លោចចិត្តស្ទើរបាត់វិញ្ញាណ ហើយសួរខ្លួនឯងថាតើរកថ្នាំពេទ្យអ្វីឲ្យគាត់ហូបនៅឯណា? បើខ្លួនឯងនៅឯកងមិនដែលឃើញឬស្គាល់ថ្នាំពេទ្យ អាហារក៏គ្មានផងនោះ ។ ដោយមិនអាចនៅយូរបាន ខ្ញុំក៏យកក្បាលខ្ញុំដាក់ក្រោមជើងគាត់ យកដៃស្ទាបគាត់ជាលើកចុងក្រោយ រួចខ្ញុំលាម្តាយចេញទៅ ។

មួយខែក្រោយមក កុមារីម្នាក់មកពីភូមិប្រាប់ខ្ញុំថា ឪពុកខ្ញុំស្លាប់ហើយ ។ ខ្ញុំបានសុំប្រធានកងខ្ញុំឈ្មោះ មិត្តសំ ទៅមើលគាត់ ប៉ុន្តែមិត្តសំ ឆ្លើយថា "ទៅមើលធ្វើអ្វីបើគាត់ស្លាប់ទៅហើយនោះ" ។ ខ្ញុំដាច់ចិត្តរត់ទៅមើលសពឪពុកដោយមិនខ្លាចស្លាប់ឡើយ ប៉ុន្តែពេលទៅដល់សាកសពរបស់គាត់ត្រូវអ្នកភូមិយកទៅកប់បាត់ទៅហើយ ។ ជួនគ្នានោះដែរបងស្រីខ្ញុំម្នាក់កំពុងពកូនឈរមើលការបញ្ចុះសពឪពុក ត្រូវ យាយប៉ុន តាមមកហៅថា "នាង ហៀង អង្គការចាត់តាំងនាងឲ្យទៅកើបអាចម៍គោនៅក្រោលឯជើងភ្នំឥឡូវនេះ ។ យកខោអាវទៅផងព្រោះទីនោះរវល់ណាស់" ។ បងស្រីខ្ញុំឮដូច្នេះ ភ័យញ័រទទ្រើកស្ទើរធ្លាក់កូនពីដៃ ព្រោះគាត់ដឹងថា យាយប៉ុន ហៅនរណាម្នាក់ទៅហើយ អ្នកនោះមិនដែលគេចរួចពីការយកទៅសម្លាប់ចោលទេ ។ មួយស្របក់ក្រោយមក មានរទេះគោដឹកក្មេងៗប្រលែងគ្នាពេញនៅលើរទេះឯម្តាយដឹងខ្លួនថាត្រូវយកទៅសម្លាប់ ទទូក្រមាយំដើរអមសងខាង ។ នៅខាងក្រោយរទេះមានឈ្លបបីនាក់ស្ពាយកាំភ្លើងដើរតាម ។ ខ្ញុំស្គាល់ម្នាក់មាឌធំនោះគឺ អាជឹម ជាឈ្លបឃុំ ។ ពេលដែលរទេះគោមកដល់មុខផ្ទះខ្ញុំ យាយប៉ុន ស្រែកបន្ទំបងស្រីខ្ញុំថា "ទៅ! គេមកដល់ហើយ" ។ បងស្រីខ្ញុំនៅពេលនោះហើមជងឈានជើងស្ទើរពុំរួច ។ យាយប៉ុន ស្ទុះទៅអូសដៃគាត់ឲ្យធ្វើដំណើរតាមរទេះគោសំដៅទៅព្រៃជើងភ្នំ ។ ខ្ញុំតាមសម្លឹងមើលគាត់គួរឲ្យខ្លោចផ្សា ព្រោះមិនអាចជួយគាត់បាន ។ តាំងពីពេលនោះមកខ្ញុំលែងបានឃើញមុខបងស្រីរហូត មិនដឹងថាអង្គការយកទៅសម្លាប់នៅទីណាទេ ។ រសៀលបន្តិចមានបុរសពីរនាក់ជាប្រធានកងបានមករើកកាយយករបស់របរនៅក្នុងផ្ទះម្តាយរបស់ខ្ញុំដោយប្រាប់ថា នាងហៀង ឲ្យមកយក ។

អ្នកស្លាប់ ស្លាប់ទាំងបិទភ្នែកមិនជិត អ្នកនៅសោកសៅរស់នៅទាំងវេទនារង់ចាំវេនរបស់ខ្លួន ។ ឪពុក បងៗ និងក្មួយៗស្លាប់អស់ម្តាយខ្ញុំត្រូវរស់នៅឯកោ ភ្នែកឡើងបាយ ឈឺមើលអ្វីសឹងតែមិនឃើញ ត្រូវបង្ខំឲ្យធ្វើការគ្មានពេលសម្រាកទៀត ។ ចំណែកខ្ញុំត្រូវត្រឡប់ទៅកងវិញមិនដឹងថា ត្រូវប្រធានកងធ្វើទារុណកម្ម ឬយកទៅសម្លាប់ឡើយ ។ ភ័ព្វសំណាងល្អ ពេលទៅដល់កង ប្រធានកងចាស់ត្រូវជំនួសដោយប្រធានកងថ្មី និងផ្លាស់ទៅដឹកប្រឡាយនៅឯភូមិខ្នងជាកន្លែងដែលអង្គការដាក់ទិសឲ្យសម្រុកធ្វើការទាំងថ្ងៃទាំងយប់ គឺពីម៉ោង១៨ល្ងាចដល់ម៉ោងពីរទៀបភ្លឺ ។ ពេលទៅធ្វើការម្តងៗ ម្នាក់ៗត្រូវដើររើសធាងត្នោតឲ្យបានពីរធាងសម្រាប់ដុតបំភ្លឺក្នុងពេលជីកប្រឡាយ ។

ថ្ងៃមួយស្នូរកាំភ្លើងព្យ៉ាងខ្លាំងនៅទិសខាងកើត ប្រធានកងទាំងអស់មកប្រជុំឯទីស្នាក់ការឃុំ ។ ខ្ញុំឮអ្នកទាំងនោះនិយាយថាពួកបូព៌ាក្បត់ អង្គការឲ្យរៀបចំរទេះគោក្របីត្រៀមស្បៀងអាហារសម្រាប់រត់ចូលព្រៃតស៊ូទៀត ។ ជាឱកាសល្អ ខ្ញុំរត់ទៅរកម្ដាយខ្ញុំនៅឯភូមិ ។

ក្នុងអំឡុងពេលខ្មែរក្រហមគ្រប់គ្រងអំណាច គ្រួសារខ្ញុំបានបាត់បង់ឪពុក បង១ជាទីបង្អែក និងក្មួយជាទីស្រឡាញ់ចំនួន ១០នាក់ ។ ប្រជាពលរដ្ឋខ្មែរត្រូវសម្លាប់រង្គាលតាមរយៈបង្អត់អាហារ បង្ខំឲ្យធ្វើការធ្ងន់បាក់កម្លាំងរហូតឈឺស្លាប់ ។ ជាងនេះទៅទៀតកម្មាភិបាលកងឈ្លបភូមិឃុំមានសិទ្ធិបណ្ដើរមនុស្សយកទៅសម្លាប់ចោលដូចសត្វធាតុ ។ ដោយឡែកនៅភូមិភាគនិរតីដឹកនាំដោយ តាម៉ុក អង្គការនៅតំបន់៣៣ (ខេត្តកំពង់ស្ពឺ) ប្រមូលប្រជាជន១៧មេសាយកទៅធ្វើទារុណកម្មយ៉ាងសាហាវព្រៃផ្សៃបំផុតដូចជា÷

- ◆ វះពោះមនុស្សទាំងរស់យកប្រមាត់
- ◆ ចងដើងព្យួរយោលឲ្យសន្ធប់ ជះទឹករហូតស្លាប់
- ◆ ក្មេងៗត្រូវចាប់យកទៅដុតទាំងរស់ ។

តើអំពើប្រល័យពូជសាសន៍និងបទឧក្រិដ្ឋទាំងនេះអ្នកណាជាអ្នកទទួលខុសត្រូវ បើមេដឹកនាំនៃរបបខ្មែរក្រហមដូចលោកខៀវ សំផន និងមេដឹកនាំមួយចំនួនទៀតឆ្លើយថាមិនដឹងនោះ? នេះមិនខុសពីចោរដែលចាប់បានហើយឆ្លើយថាមិនមែនចោរទេ ។

ចុងបញ្ចប់ដើម្បីឲ្យព្រលឹងអ្នកស្លាប់នៅក្រោមរបបព្រៃផ្សៃបិទភ្នែកជិតជងនោះ ខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាលអង្គការអន្តរជាតិនិងសហគមន៍អន្តរជាតិជួយបង្កើតតុលាការដើម្បីកាត់ទោសមេស្ដាបនិកនៃរបបវាលពិឃាដឲ្យស័ក្តិសមនឹងកំហុសដែលអ្នកទាំងនោះប្រព្រឹត្ត ។ ខ្ញុំសង្ឃឹមថាក្រោមកិច្ចប្រឹងប្រែងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា វិញ្ញាណក្ខន្ធជនរងគ្រោះនិងប្រជាពលរដ្ឋកម្ពុជាដែលនៅរស់នឹងមិនខកចិត្តឡើយ ។ **ហ៊ូ ឌួន**

## សេចក្តីប្រកាសរកប្អូនប្រុសឈ្មោះស៊ូផាន

នាងខ្ញុំឈ្មោះ សែម ផល អាយុ៥៩ឆ្នាំ រស់នៅភូមិថ្នល់ ឃុំដំបែរ ស្រុកដំបែរ ខេត្តកំពង់ចាម មានឪពុកឈ្មោះ ស៊ូ សែម និងម្ដាយឈ្មោះ ជាម មាស ។ សព្វថ្ងៃនេះនាងខ្ញុំរស់នៅជាមួយបងប្អូន៤នាក់ ១) សែម យឿ ២) សែម សឿន ៣) សែម ផល ៤) សែម ស៊ុំ ។

នាងខ្ញុំសូមស្វែងរកប្អូនប្រុសឈ្មោះ ស៊ូ ផាន ។ នៅមុនឆ្នាំ ១៩៧៥ ផាន ជាយុវជនមន្ទីរតំបន់២១ ក្រោយឆ្នាំ១៩៧៥ មាននាទីជាមេពួកនៅរោងចក្រកែវ ។ កាលពីឆ្នាំ១៩៩៩ ខ្ញុំបានទទួលដំណឹងថា ផាន បានទូរស័ព្ទទៅទីរួមខេត្តកំពង់ចាម ដើម្បីស្វែងរកបងប្អូន ហើយប្រាប់ឲ្យទាក់ទងតាមមនុស្សម្នាក់នៅច្បារអំពៅ ។ នាងខ្ញុំព្យាយាមទាក់ទងដែរ ប៉ុន្តែមិនអាចទាក់ទងបានដោយសារតែគ្មានអាសយដ្ឋានច្បាស់លាស់ ។

ប្រសិនបើបងប្អូនណាបានស្គាល់ឈ្មោះខាងលើឬសាមីខ្លួនបានឮ សូមទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ទូរសារលេខ ០២៣ ២១០ ៣៥៨ ឬប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ។

សូមអរគុណ ។

## សេចក្តីប្រកាសរកកូនប្រុសឈ្មោះទុយ ហៅផល


ញ៉ាញ់ គូ

នាងខ្ញុំឈ្មោះ ញ៉ាញ់ គូ អាយុ៧៧ឆ្នាំ សព្វថ្ងៃរស់នៅភូមិទំលាប់ ឃុំចាន់សែនលើ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ សូមស្វែងរកកូនប្រុសឈ្មោះ ទុន ហៅ ផល ដែលបានបាត់ខ្លួនក្រោយពេលរំដោះឆ្នាំ១៩៧៩ ។ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាត់តាំងឲ្យ ផល ទៅធ្វើការក្នុងកងកុមារនៅភូមិឧកស្រាត ។ នៅឆ្នាំ១៩៧៦ អង្គការបញ្ជាឲ្យ ផល ទៅឃ្វាលគោនៅឧដុង្គ ក្រោយមក ក៏ត្រូវបងស្រីដែលធ្វើការនៅរោងចក្រភួយ នៅភ្នំពេញយកទៅធ្វើការនៅមន្ទីរពេទ្យ១៧មេសា ។ ក្រោយពេលបែកឆ្នាំ១៩៧៩ភ្លាម ផល បានត្រឡប់មកផ្ទះវិញ ប៉ុន្តែស្នាក់នៅបានតែ៤-៥ថ្ងៃ ក៏បន្តដំណើរទៅតាមកងទ័ពខ្មែរក្រហម ហើយបាត់ខ្លួនតាំងពីពេលនោះមក ។

ប្រសិនបើសាមីខ្លួនបានឮ ឬបងប្អូនណាបានស្គាល់ឈ្មោះខាងលើ សូមទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ០២៣ ២១១ ៨៧៥ ឬតាមប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកកូនប្រុសឈ្មោះ ទូន ឆាន ហៅ ឃឿន

នាងខ្ញុំឈ្មោះ សាន ឃិន អាយុ៧០ឆ្នាំ រស់នៅភូមិរកា ឃុំរកាជន្លឹង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល សូមស្វែងរកកូនប្រុសច្បង ឈ្មោះ ទូន ឆាន ហៅ ឃឿន ដែលបានចូលបដិវត្តន៍កាលពីឆ្នាំ១៩៧៣ ហើយបាត់ខ្លួនរហូតបច្ចុប្បន្ន ។

មុនពេលចូលបដិវត្តន៍ ឆាន បួសជាសង្ឃនៅវត្តស្វាយពោធិ នៅក្នុងស្រុកកំណើត ។ បន្ទាប់មក ឆាន ធ្វើដំណើរទៅរៀនបន្តនៅវត្តត្នោតបុស្សីស្រុកនៅខេត្តកំពង់ចាម ។ បីឆ្នាំក្រោយ ពេលដែល ឆាន អាយុ២៥ឆ្នាំនៅឆ្នាំ១៩៧៣ ឆាន ក៏សឹកពីបួស ហើយចូលបម្រើបដិវត្តន៍ដោយមិនប្រាប់ម្តាយឪពុកឲ្យដឹងឡើយ ។

នៅឆ្នាំ១៩៧៩ ស្រី នៅក្នុងភូមិជាមួយគ្នា បានប្រាប់ខ្ញុំថា គាត់បានជួប ឆាន នៅខេត្តកំពង់ឆ្នាំង ហើយបានបបួល ឆាន ត្រឡប់មកផ្ទះវិញ ប៉ុន្តែ ឆាន ប្រកែក ។ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ គ្រួសារខ្ញុំបានទទួលសំបុត្រមួយពី ឆាន ស្វែងរកក្រុមគ្រួសារនៅភូមិកំណើត ប៉ុន្តែពេលនោះយើងទាំងអស់គ្នាមិនបានយកចិត្តទុកដាក់នឹងសំបុត្រនោះប៉ុន្មានទេ ព្រោះរវល់តែខ្វាយខ្វល់នឹងឪពុករបស់ ឆាន ដែលមានជំងឺជាទម្ងន់ ។ ក្រោយពេលធ្វើបុណ្យសពឪពុករបស់ ឆាន រួចមកសំបុត្រនោះក៏បាត់រហូត ហើយខ្ញុំក៏មិនបានទទួលដំណឹងអ្វីពី ឆាន ទៀតដែរ ។

បើកូនបានឃើញសេចក្តីប្រកាសនេះ ឬបងប្អូនណាបានដឹងដំណឹងអំពី ទូន ឆាន សូមមេត្តាទាក់ទងនាងខ្ញុំនៅភូមិឃុំខាងលើ ឬទាក់ទងតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ទូរសារ ០២៣ ២១០ ៣៥៨ ឬតាមរយៈប្រអប់សំបុត្រ ១១១០ ភ្នំពេញ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកកូន

យើងខ្ញុំដូចដែលមានឈ្មោះខាងក្រោម រស់នៅភូមិអន្ទង់តាសេកក្រោម ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល សូមស្វែងរកកូនៗដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហមហើយបាត់ខ្លួនរហូតមកដល់បច្ចុប្បន្ន ។

◆ ឈ្មោះ ប្រាក់ ហុង ភេទស្រី អាយុ៧៤ឆ្នាំ សូមស្វែងរកកូនប្រុស៣នាក់ ៖

១) ឈ្មោះ កែវ បាន ពេលចូលបដិវត្តន៍អាយុជាង២០ឆ្នាំ

២) ឈ្មោះ កែវ ម៉ាន ពេលចូលបដិវត្តន៍អាយុជាង២០ឆ្នាំ

៣) ឈ្មោះ កែវ យ៉ត

ទាំងបីនាក់នេះចូលបដិវត្តន៍អំឡុងឆ្នាំ១៩៧៣ តាមការបង្ខំរបស់ប្រធានភូមិឈ្មោះ ហម ។

◆ ឈ្មោះ ឡាច ហុង ភេទស្រី អាយុ៧៣ឆ្នាំ សូមស្វែងរកកូនប្រុសឈ្មោះ ប៉ុល ឆាង ចូលបដិវត្តន៍អំឡុងឆ្នាំ១៩៧៣ តាមការបង្ខំរបស់ប្រធានភូមិឈ្មោះ ហម ។

◆ ឈ្មោះ ព្រំ សាត ភេទប្រុស អាយុ៨០ឆ្នាំ សូមស្វែងរកកូនប្រុសឈ្មោះ ព្រំ ស ពេលចូលបដិវត្តន៍អាយុ១៨ឆ្នាំ ។

◆ ឈ្មោះ ហួន ប៉ែត ភេទស្រី អាយុ៦៥ឆ្នាំ សូមស្វែងរកកូនប្រុសឈ្មោះ ហួន គឹមឡេង ពេលចូលបដិវត្តន៍នៅឆ្នាំ១៩៧៥ មានអាយុ១២ឆ្នាំ ។ ខ្ញុំបានឮថា ហួន គឹមឡេង គឺជានីរសារ ។

◆ ឈ្មោះ យឹម យួន ភេទប្រុស អាយុ៦៣ឆ្នាំ សូមស្វែងរកកូនប្រុសឈ្មោះ យឹម ផាត ពេលចូលបដិវត្តន៍នៅឆ្នាំ១៩៧៥ មានអាយុ១៣ឆ្នាំ ។ ពេលដែល ផាត ចេញពីផ្ទះដំបូងបានធ្វើដំណើរទៅកោះខ្សាច់ទន្លា ហើយធ្វើជាកងទ័ពនៅក្នុងកងដឹកជញ្ជូនស្បៀង ។

ប្រសិនបើសាមីខ្លួនបានឮឬបងប្អូនណាបានដឹងដំណឹង សូមមេត្តាទាក់ទងយើងខ្ញុំនៅភូមិស្រុកខាងលើ ឬផ្តល់ព័ត៌មានមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬតាមទូរស័ព្ទលេខ (៨៥៥) ០២៣ ២១១ ៨៧៥ ។

សូមអរគុណ ។



ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា

ទស្សនាវដ្ដីចំនួន១០០០ច្បាប់ជារៀងរាល់លេខនីងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ ក្នុងមួយច្បាប់តម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្ដីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្ដីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@online.com.kh. Thank you.

**A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 62, February 2005.**
**Funded by Germany, Norway, Sweden, and USA.**